# រឿងព្រះចៅអសោក

លោកអាចារ្យ តិម អាន

ចាប់បកប្រែចេញពីភាសាចាក់ដំសែស

មកជាភាសាខ្មែរ



ភ្នំពេញ ព.ស. ២៥០០

ការផ្សាយរបស់ ពុទ្ធសាសនបណ្ឌិត្យ

ចម្លងសាជាថ្មី ព.ស. ២៥៤៦

# បុព្វកថា

ដោយយល់ឃើញថាសៀវភៅ រឿងព្រះបាទអសោក ដែលបកប្រែដោយលោកអាចារ្យគិម-អាន ដែលបោះពុម្ពក្នុងពុទ្ធសករាជ២៥០០ ជាសៀវភៅចំណាស់មួយ ដែលមានអត្ថន័យល្អគួរជាទីជ្រះថ្លា ហើយនិងមានបំណងទុកស្នាដៃនេះសម្រាប់ដល់កូនចៅជំនាន់ក្រោយដើម្បីបានសិក្សាស្វែងយល់ផង ទើបនាងខ្ញុំ ដែលមានការជួយជ្រោមជ្រែងគាំទ្រពីមាតាបិតាជាទីគោរពចម្លងសាជាថ្មី និងកែតម្រូវនូវអក្ខរាវិរុទ្ធមួយចំនួន ដោយពឹងផ្អែកលើវចនានុក្រមខ្មែរ-សម្តេចព្រះសង្ឃរាជ ជួន ណាត។

អំពើជាកុសលដែលបានពីការព្យាយាមក្នុងកិច្ចការជាធម្មទាននេះ នាងខ្ញុំសូមលើកជូនអ្នកមានគុណ និង ឧទ្ទិសជូនម្ចាស់អត្ថបទ គឺ លោកអាចារ្យគិម-អាន និងញាតិទាំងឡាយក្នុងសង្សារវដ្ត ម្យ៉ាងទៀត សូមជាចំណែកបុណ្យបានដល់អ្នកអានគ្រប់រូប ។

ឈូក ក្រហម

# សេចក្ដីផ្ដើម

*រឿងព្រះបាទអសោករាជនេះ ជាសេចក្ដីរៀបរៀង និងប្រែចេញមកពីភាសាបារាំងសែស របស់អាចារ្យ* ***តិម អាន*** *ដែលអនិច្ចកម្មទៅកាលពីថ្ងៃ ២៦ ដេសមប្រ៍ ១៩៣៧ ដូចមានពិស្ដារក្នុង សៀវភៅ «សាសនកិច្ចានុក្រមលេខ២ ឆ្នាំ ១៩៣៨» នោះស្រាប់។*

*រឿងព្រះបាទអសោកនេះ អ្នកអាចារ្យ* ***តិម អាន*** *បានរៀបរៀងប្រែ កាលដែលខ្លួននៅបួសនៅឡើយ ប្រហែលក្នុងរវាងឆ្នាំ១៩៣៥ ជាឆ្នាំដែលខ្លួនបានចូលមកធ្វើការជាក្រុមជំនុំប្រែព្រះត្រៃបិដក ក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យ។ លុះរៀបរៀងប្រែបានចប់ហើយ បានយកសំណៅទៅប្រគេនឲ្យក្រសួងពុទ្ធសាសនបណ្ឌិត្យ ដើម្បីឲ្យចាត់ការបោះពុម្ពផ្សាយតទៅ។*

*លោកគ្រូអាចារ្យ* ***តិម អាន*** *ធ្វើការជាក្រុមជំនុំព្រះត្រៃបិដកបាន១ឆ្នាំ ក៏លាចាកសិក្ខាបទ ដោយមានកើតរោគរបេងរីងរៃតមក រោគនេះកាន់តែបណ្ដាលខ្លាំងឡើងៗ ក៏លាចេញពីមុខក្រសួងនេះ ភៀសខ្លួនទៅនៅឯលំនៅដើមរបស់ខ្លួន ហើយដល់*

នូវអនិច្ចកម្មក្នុងឆ្នាំ ១៩៣៧ នៅភូមិវត្តព្រះទ្វារ ឃុំពគ្រ ខែត្រកំពង់ឆ្នាំង។

ឥឡូវនេះ ពុទ្ធសាសនបណ្ឌិត្យ បានយករឿងនោះចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំ១៩៤២-១៩៤៣ តាមបំណាំងរបស់លោកនិពន្ធនោះ។ ដល់មកឆ្នាំនេះ យើងបានពិនិត្យទៅឃើញថា រឿងព្រះបាទអសោកនេះ ជារឿងទាក់ទងក្នុងផ្លូវព្រះពុទ្ធសាសនា យើងក៏បានដកស្រង់ពី ទស្សនាវដ្ដីកម្ពុជសុរិយាទាំងនោះឥតមានកែប្រែអ្វីទេ មកបោះពុម្ពជាសៀវភៅមួយដោយឡែក ដើម្បីផ្សាយដល់កុលបុត្រអ្នកសិក្សាទាំងឡាយ។

ក្រសួងពុទ្ធសាសនបណ្ឌិត្យ សូមអរគុណ ដល់អ្នកអាចារ្យ **គឹម អាន** ដែលបានព្យាយាមប្រែរឿងព្រះបាទអសោកនេះ ហើយប្រគល់ឲ្យជាសម្បត្តិរបស់ក្រសួងពុទ្ធសាសនបណ្ឌិត្យៗ សូមឧទ្ទិសជូនកុសល ដែលជាផលនៃការបោះពុម្ពផ្សាយរឿងនេះ ចំពោះវិញ្ញាណក្ខន្ធរបស់អ្នកអាចារ្យ **គឹម អាន** សូមឲ្យបានទទួលឥដ្ឋមនុញ្ញផលតាមគាប់ចិត្តចុះ។

# អារម្ភកថា

រឿងព្រះបាទអសោកនេះ អ្នកប្រាជ្ញទាំងឡាយបាន តែងពីត្រឹម គតិយសង្កាយនាដរាបមក មានស្ទើរតែគ្រប់គម្ពីរ ដែលសំដែង អំពីព្រះពុទ្ធសាសនា ក្នុងភាសាបាលី ភាសា សំស្រ្កឹត និងភាសាឯទៀតៗជាច្រើន ហើយជារឿងមានឡាក់ ឋាន ដោយមានសិលាចារឹកជាគ្រឿងសំគាល់ច្រើនបំផុត ដ៏ ដេរដាសក្នុងមជ្ឈិមប្រទេស នៅមានរហូតមកដល់សព្វថ្ងៃ នេះ។ ហេតុនោះបានជាពួកអ្នកប្រាជ្ញទូទៅទាំងលោក ក្នុង ប្រទេសធំៗ មានទ្វីបអឺរ៉ុបជាដើម ច្រើនតែចេះរឿងដំណាល ព្រះបាទអសោកនេះគ្រប់ៗគ្នា អ្នកខ្លះបានឃើញតាមគម្ពីរ បាលី ឬសំស្រ្កឹត អ្នកខ្លះបានព្យាយាម ស្វះស្វែង ទៅដល់ សិលាចារឹកត្រង់ទីសំវេជនីយដ្ឋាននោះៗ ហើយថតផ្ដិតយក មកសរសេរជារឿងទុក ក្នុងសៀវភៅទាំងឡាយជាច្រើន ដើម្បី ជាប្រយោជន៍ ដល់អ្នកអានមើល សូម្បីគម្ពីរបឋមសម្ពោធិ ជាភាសាខ្មែររបស់យើងនេះ ដែលធ្លាប់មានយូរណាស់មក ហើយ ក៏មានសេចក្ដីដំណាលដល់រឿងអសោកនោះខ្លះ នៅ ត្រង់ខ្សែមារពន្ធដែលលោក អ្នកអានមើលធ្លាប់បានឃើញ

ជាញឹកញយណាស់មកហើយ ប៉ុន្តែមានសេចក្តីមិនហូរហែ ដល់ចប់សព្វគ្រប់ៗ

ព្រោះហេតុដូច្នោះ បានជាខ្ញុំប្រែរឿងព្រះបាទអសោក នេះ អំពីសៀវភៅជាភាសាបារាំងសែសឈ្មោះ ឡាឡេស៊ង់ដឺ ឡម្ប៉េរើរ អសោក (La Légende de l’empereur Açoka, par J Przyluski) មកជាភាសាខ្មែរយើង ព្រមទាំងបានផ្ទៀងផ្ទាត់ ធៀបគ្នាតាមគម្ពីរបាលី និងសំស្រ្កឹតថែមទៀត ដើម្បីនឹងឲ្យ បានត្រឹមត្រូវហើយជាប្រយោជន៍ ដល់លោកអ្នកមានប្រាថ្នា ចង់ដឹងរឿងនេះឲ្យបានច្បាស់លាស់ ព្រោះព្រះបាទអសោក អង្គនោះ ទ្រង់មានមហាករុណាដ៏ធំ ដល់លោកទាំងមូល ទ្រង់ បានធ្វើតតិយសង្គាយនា ហើយផ្សាយព្រះពុទ្ធសាសនាដោយ កម្លាំងព្យាយាមរបស់ព្រះអង្គ ឲ្យតាំងនៅគ្រប់ប្រទេស រហូត ដល់សុវណ្ណភូមិ (គឺប្រទេសឥណ្ឌូចិនយើងនេះ) ចំណែកខាង ដែនកម្ពុជាយើងសោត បើនឹងសង្កេតមើលទៅ គង់ឃើញថា កាលជាន់ដើម ពួកអ្នកស្រុកកាន់សាសនាព្រាហ្មណ៍ តមក កាន់ពុទ្ធសាសនាប៉ែកខាងមហាយាន លាយឡំគ្នាដោយមាន គ្រឿងសំគាល់នៅក្រុងនគរធំ ដែលគេសាងឡើងជាន់ដំបូង

នោះ គេធ្វើសិលាចារឹក ជារូបពោធិសត្វខ្លះ ជាព្រះសិវព្រហ្ម និងទេវរូបឯទៀតៗខ្លះ នៅគ្រប់កន្លែងជាគ្រឿងសំគាល់ថា គេសាងឡើងដើម្បីបូជាដល់សាសនាទាំងពីរនោះពិតៗ ដល់មកខាងក្រោយ គេកាន់របៀបតាមហីនយានវិញ នេះហើយសំដែងឲ្យឃើញថា ពុទ្ធសាសនាក្នុងប្រទេសយើងនេះ ក៏មានសាសនាជាប់តមកអំពីការឧបត្ថម្ភរបស់ ព្រះបាទអសោកមហារាជនេះដែរ ព្រោះ ព្រះពុទ្ធសាសនាផ្សាយចូលមកប្រទេសឥណ្ឌូចិន (ឥណ្ឌូស៊ីននេះ) ដំបូង ចូលមកប្រទេសភូមា និងមន ដោយព្រះថេរៈពីរអង្គ គឺព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរ ដែលជាពួកព្រះថេរៈទាំងមួយពាន់ ជាអ្នកធ្វើសង្គាយនាគ្រាទី៣ ក្នុងក្រុងបាតលិបុត្រ កាលពីពុទ្ធសករាជ ៣០១ នៅក្នុងសេចក្ដីឧបត្ថម្ភរបស់ព្រះបាទអសោកអង្គនោះតែ ប្រទេសឥណ្ឌូចិនជាន់នោះ ព្រះពុទ្ធសាសនា មិនបានចម្រើនរុងរឿងប៉ុន្មានទេ ព្រោះពួកមនុស្សជាន់នោះនៅជឿសាសនាព្រាហ្មណ៍ តាមទម្លាប់ដើមរបស់ខ្លួនច្រើនណាស់នៅឡើយ លុះដល់ ព្រះមហិន្ទត្ថេរ ជារាជឱរស និងនាងសង្ឃមិត្តាថេរី ជារាជធីតា នៃព្រះបាទអសោកអង្គនោះ ដែល

បានទទួលភារៈ មកប្រតិស្ឋានព្រះពុទ្ធសាសនានៅលង្កាទ្វីប (Ceylon) ក៏ពួកស្ដេច និងមហាជននៅកោះលង្កានោះ ចុះចូលជាច្រើន ហើយ បាននាំគ្នាប្រួត ជួយផ្សាយព្រះពុទ្ធសាសនាថែមទៀត ទើបព្រះពុទ្ធសាសនា នៅប្រទេសឥណ្ឌូចិនយើងនេះ រុងរឿងឡើងពេញបន្ទុក តាំងតែពីត្រឹមនោះមក មិនតែប៉ុណ្ណោះ ព្រះបាទអសោកអង្គនោះ បានសាង ព្រះស្តូប ៨៤.០០០ ទុកជាទីបូជនីយស្ថាន ព្រោះហេតុនោះ ពួកអ្នកប្រាជ្ញក្នុងទ្វីបអឺរ៉ុបសព្វថ្ងៃនេះ បើគេ ចង់ដឹងរឿងព្រះពុទ្ធសាសនាឲ្យច្បាស់លាស់ ដែលជាសាសនាមានតឹកតាងនៅមានពិតនោះ គេច្រើនមើលសៀវភៅ ដំណាលពីអសោកចុល្ល ចក្រពត្តិ ដែលអ្នកប្រាជ្ញជាន់មុន បានចម្លងមកពី ស្រុកឥណ្ឌូ ឬពីស្រុកចិន ជួនកាល មានទាំងផ្ដិតយកអក្សរថ្ម របស់ព្រះបាទអសោក នៅទីសំវេជនីយដ្ឋានគ្រប់កន្លែង មកជាគ្រឿងសំគាល់ថែមទៀត ប៉ុន្តែ អ្នកប្រាជ្ញទាំងឡាយ ដែលបានតែងគម្ពីរដីកា ឬសៀវភៅ ឡើងនោះ សឹងមានរបៀបពាក្យបានសរសេរទៅតាមសេចក្ដីយល់ផ្សេងៗគ្នាខ្លះ ដូចយ៉ាង រឿងព្រះបាទអសោក ជារបស់ប៉ែកខាងទក្ខិណនិកាយ ដែល

យើងធ្លាប់បានដឹងតាមគម្ពីរមហាវង្ស ដែលពួកព្រះថេរៈនៅលង្កាទ្វីប បានចារឹកមកជាភាសាបាលីនោះ មានដំណើរសេចក្ដីប្លែកគ្នាខ្លះដោយអន្ទើៗ អំពី រឿងព្រះបាទអសោក ដែលពួកខាងឧត្តរនិកាយបានចារឹកទុកមកជាភាសាសំស្ក្រឹតនោះ តែបើទុកជាយ៉ាងនោះក៏ដោយ សូមលោកអ្នកអានមើលកុំគប្បីសង្ស័យ នឹងដំណើរសេចក្ដីប្លែកគ្នានោះ ត្រូវកំណត់យក តែសំណុំរឿងព្រះបាទអសោក មកជាប្រមាណ បើនៅតែមិនទាន់ចូលចិត្តស៊ប់ ក្នុងរឿងនេះទេ ត្រូវសង្កេតឲ្យហ្មត់ចត់ ធៀបមើលតាមសិលាចារឹក របស់ព្រះបាទអសោក ដែលខ្ញុំបានដាក់មក ក្នុងទំព័រតៗទៅខាងមុខ គង់តែចូលចិត្តរឿងនេះច្បាស់លាស់ល្អឡើងមិនខាន។

ក្នុងសៀវភៅនេះ ខ្ញុំមិនចង់ឲ្យឃ្លាតឆ្ងាយពីប្រយោគជាភាសាបារាំងច្បាប់ដើមសោះ បានជានៅត្រង់កន្លែងខ្លះមានពាក្យផ្ទួយគ្នាលំបាកស្ដាប់ ព្រោះភាសាបារាំង និងភាសាខ្មែរយើង មានតម្លៃពាក្យមិនស្មើភាគគ្នាលំបាកនឹងរិះរកពាក្យដាក់ឲ្យត្រូវចំគ្នាផង ហើយខ្លួនខ្ញុំសោត ក៏បានរៀនសូត្រភាសាបារាំងនោះតិចតួចពេក មិនសមនឹងហ៊ានធ្វើការធំ

យ៉ាងនេះ ប៉ុន្តែ ដោយសេចក្ដីប្រាថ្នា ចង់ឲ្យពួកពុទ្ធសាសនិកជន ជ្រាបរឿងនេះណាស់ បានជាខ្ញុំ ខំព្យាយាម រហូតដល់កើតជាសៀវភៅនេះឡើង តែ ក្នុងសៀវភៅបារាំង ច្បាប់ដើមនោះ មានរឿងរ៉ាវឯទៀតៗចម្រុះជាច្រើន ដែលខ្ញុំមិនបានប្រែដាក់មក ខ្ញុំប្រែដកយកចំពោះតែរឿងអសោកមួយប៉ុណ្ណោះ។

ក្នុងសៀវភៅនេះ ចែកចេញជាពីរចំណែក ខាងដើមហៅថា (បកិណ្ណកនិទាន) គឺនិទានពោយពាយ ដែលជាប់ទាក់ទងដល់រឿងព្រះបាទអសោកនោះដែរ ប៉ុន្តែមិនមានសេចក្ដីហូរហែដោយសព្វគ្រប់ គ្រាន់តែដកយករឿងដែលខុសគ្នា មកជាគ្រឿងសំគាល់ ហើយវិនិច្ឆ័យសេចក្ដីនោះៗខ្លះ ខាងចុងហៅថា «រឿងព្រះបាទអសោក» គឺជាផ្ទៃរឿង នៃស្ដេចអង្គនោះ មានតាំងអំពីការកសាងដំបូងឡើង រហូតដល់បានជាស្ដេចចុល្លចក្រ ហើយនិងស្ដេចជាតំណខាងក្រោយព្រះបាទអសោកនោះមកខ្លះ ខ្ញុំរួបរួម ទាំងពីរចំណែក ឲ្យឈ្មោះសៀវភៅនេះថា: «រឿងព្រះបាទអសោក» នៅតាមច្បាប់ដើមដដែល ប៉ុន្តែ នៅមិនទាន់ទុកចិត្ត ក្រែងមិនត្រឹមត្រូវ ខ្ញុំបានយកសៀវភៅនេះ ទៅប្រគេនព្រះមហា **ទ.ហួត** ក្រុមជំនុំប្រែ

ព្រះត្រៃបិដក ក្នុងពុទ្ធសាសនបណ្ឌិត្យ នៅព្រះរាជបណ្ណាល័យ សូមឲ្យលោក ជួយពិនិត្យ សម្រួលពាក្យខ្មែរ ជាមួយនឹងខ្ញុំថែមទៀត ដើម្បីជម្រះមន្ទិល គឺសេចក្ដីឃ្លៀងឃ្លាត អំពីច្បាប់ដើម។

លោកអ្នកអានមើល «រឿងព្រះបាទអសោក» នេះ គង់នឹងបានប្រទះសេចក្ដីខ្លះ ដែលខុសគតិរបស់ព្រះពុទ្ធសាសនា ដូចរឿងយក្សចូលបួសជាដើម ដែលខ្ញុំរក្សាទុកតាមច្បាប់ដើម តែបើតាមរឿងនេះ គួរនឹងសន្និដ្ឋានថា យក្សមិនមែនជាអ្វី គឺមនុស្សជំពូកមួយ ដែលមានឈ្មោះយ៉ាងនោះ ឬជានាមសម្រាប់ហៅ អ្នកដែលគួរគេគោរព ព្រោះពាក្យថា យក្ខ ឬយក្សនេះ មកពីរូបធាតុថា «បូជា» ហេតុនេះ បានជាហៅបានរហូតដល់ពួកមនុស្ស ទេវតា អ្នកតាជាដើម។

ម្យ៉ាងទៀត ជាធម្មតារបស់អ្នកតែងសៀវភៅ ដែលជាប់ទាក់ទងដល់វិជ្ជាការ ឬប្រវត្តិព្រះពុទ្ធសាសនា តែងតែឧទ្ទិសសៀវភៅដែលខ្លួនតែង បូជាដល់បុព្វការី បុគ្គល ឬជូនដល់ញាតិមិត្រដែលខ្លួនស្រឡាញ់រាប់អានជាទីបំផុត ដែលមានជីវិតរស់នៅ ឬសូម្បីធ្វើមរណកាល កន្លងហួសទៅហើយ

*ក៏បាន ទើបខ្ញុំប្រគេនសៀវភៅនេះ ជាសក្ការបូជា ចំពោះព្រះតេជព្រះគុណ ព្រះឧត្តមមុនី **(អ៊ុំ ស៊ូរ)** ដែលលោកមានឧបការៈដល់ខ្ញុំជាអនេកប្រការ សមគួរដែលខ្ញុំ នឹងលើកបូជាដល់លោក មុនបុគ្គលដទៃៗ។*

**អាចារ្យ តិម អាន**

# រឿងព្រះចាងអសោក

## បកិណ្ណកនិទាន

(ក្រុងបាតលិបុត្រ និងមោរិយវង្ស)

*ព្រះរាជវង្ស ដែលព្រះបាទចន្ទ្រគុប្ត បានតាំងឡើងជាដំបូងនោះ មាននាមថា មោរិយវង្ស បានគ្រប់គ្រងក្រុងបាតលិបុត្រក្នុងដែនមគធៈ បានចំនួន ៨៥ឆ្នាំ គឺតាំងពីពុទ្ធសករាជ១២៨ ដល់ពុទ្ធសករាជ២១២ ។ ស្តេចទី២ ទ្រង់ព្រះនាមព្រះបាទវិន្ទុសារៈដែលជាឱរសរបស់ព្រះបាទចន្ទ្រគុប្ត ព្រះអង្គបានសោយរាជ្យក្នុងដែនមគធៈបាន ១៩ឆ្នាំ គឺតាំងពីពុទ្ធ-សករាជ ២៥២ ដល់ពុទ្ធសករាជ ២៧០ ព្រះបាទវិន្ទុសារៈអង្គនេះ បានវាយយកខែត្រដែនតូចៗជាច្រើន រហូតដល់ដែនមទ្រាស* (Madras) *ឲ្យតាំងនៅក្រោមអំណាចព្រះអង្គ ក្នុងគ្រានេះ ឥណ្ឌា និងក្រិក បានជាប់ទាក់ទងរកគ្នាទៅវិញទៅមកកាន់តែចម្រើនមាំមួនឡើង រហូតដល់មកស្តេចសោយរាជ្យជាន់ក្រោយៗ ក្នុងក្រុងម៉ាសេដ្វាន ក៏ទ្រង់នៅតែបញ្ជូនទូតមក*

ក្រុងបាតលិបុត្រ។

ព្រះបាទពិន្ទុសារៈ មានរាជឱរសច្រើនព្រះអង្គ តែទ្រង់ឃើញថា អសោកមានសេចក្ដីអង់អាចតាំងតែពីនៅជាកុមារតូចមក ទើបព្រះបិតាតាំងដំណែងការឲ្យជាឧបរាជ ដំបូងទ្រង់ឲ្យទៅគ្រប់គ្រងក្រុងតក្កសិលា តែខាងក្រោយមក ទ្រង់ឲ្យទៅគ្រប់គ្រងស្រុកមាលវៈ។ គ្រាកាល ព្រះបាទពិន្ទុសារៈអស់ព្រះជន្ម អសោករាជឱរស ក៏បានជាស្ដេចសោយរាជ្យស្នងព្រះអង្គឡើងក្នុងពុទ្ធសករាជ២៧៤ គឺបួនឆ្នាំខាងក្រោយព្រះបាទពិន្ទុសារៈអស់ព្រះជន្ម បានជាយឺតយូរដូច្នេះ ន័យខ្លះថា ព្រោះកើតចម្បាំងដណ្ដើមរាជសម្បត្តិនឹងព្រះអនុជា ឬព្រះជេដ្ឋា តាមគម្ពីរមហាវង្សសំដែងថា ព្រះបាទអសោកបានជ័យជំនះ ទ្រង់ធ្វើគុតព្រះជេដ្ឋា និងព្រះអនុជាអស់ ឲ្យទុកតែព្រះអនុជព្រះនាមតិស្សមួយអង្គ ដែលរួមព្រះមាតាជាមួយ តែតាមប្រវត្តិសាស្ត្រសម័យនេះ ដែលរាវរកឃើញនោះត្រឡប់ជាប្រាកដថា ព្រះបាទអសោក បានទំនុកបំរុងព្រះជេដ្ឋា និងព្រះអនុជាយ៉ាងល្អបំផុត មិនបានប្រទូស្តរ៉ាយគ្នា

ឡើយ។ ព្រះបាទអសោក មានលក្ខណៈដ៏រឹងប៉ឹងពូកែ ប្រកាន់ការងារតាមច្បាប់ដាច់ខាត តែមិនមែនជាក្សត្រិយ៍កាចអាក្រក់ ប្រកបដោយមោហចរិត ដូចយ៉ាងធ្លាប់ចូលចិត្តមកក្នុងជាន់ដើមនោះទេ។ សេចក្ដីពិតថា ព្រះបាទអសោក បានធ្វើសង្គ្រាមជាច្រើនដង តាមធម្មតារបស់ក្សត្រិយ៍គ្រប់ព្រះអង្គ ដែលត្រូវតែផ្សាយអំណាច តេជានុភាព របស់ព្រះអង្គចេញទៅ ព្រះអង្គជាស្ដេចមានបុណ្យធំបំផុត ក្រៃលែងជាងស្ដេចឯទៀតដែលមានក្នុងប្រវត្តិការណ៍របស់លោក។រាជអាណាចក្ររបស់ព្រះបាទអសោកនោះ ផ្សាយចេញទៅគ្រប់ប្រទេសក្នុងឥណ្ឌាទាំងមូល មិនតែដែនរបស់ពួកអរិយកៈប៉ុណ្ណោះទេ ព្រះអង្គយកបានចុះមកខាងក្រោម រហូតដល់ទល់នឹងទន្លេគោធាវរីទៀតផង។

ព្រះបាទអសោក ទ្រង់បង្កើតច្បាប់សម្រាប់អាណាចក្ររបស់ព្រះអង្គ ជាអាជ្ញាដាច់ខាត តែជាន់ដំបូងទ្រង់ច្រើនតែសម្រេចកិច្ចពិឃាតផ្ទាល់នឹងព្រះហស្តព្រះអង្គ លុះគ្រាខាងក្រោយមក ទើបអនុញ្ញាតឲ្យធ្វើគុកសម្រាប់ផ្ទាញ់ផ្ទាលពួក

មនុស្សទុច្ចរិត ហើយទ្រង់ចាត់ពេជ្ឈឃាតម្នាក់ឈ្មោះគិរិកៈ ឲ្យជាអ្នកទទួលភារៈនោះ។

កាលដែលអ្នកប្រាជ្ញចិនឈ្មោះ ហ្វា ហៀន ចូលមកក្នុងឥណ្ឌាពី ព.ស. ៩៤២ ត្រឡប់ទៅស្រុកចិនវិញ ព.ស. ៩៥៦ ដល់មកខាងក្រោយ មានចិនម្នាក់ឈ្មោះ ហួន ត្សង់ អ្នកប្រាជ្ញទាំងពីរនាក់នេះ ជាអ្នកស្វែងរកការពិតរបស់ព្រះពុទ្ធសាសនា បានទៅឃើញក្រុងបាតលិបុត្រ ដែលជាក្រុងបាក់បែកគ្រាំគ្រាទៅហើយ ពេលនោះ ថាមានអ្នកស្រុកបង្ហាញ «នរករបស់ព្រះបាទអសោក» គឺជាគុកដែលស្ដេចអង្គនោះធ្វើក្នុងគ្រាខាងក្រោយបានរាជសម្បត្តិ តាមរឿងរ៉ាវនេះថាៈ គុកនោះគេធ្វើសម្រាប់ផ្ចាញ់ផ្ចាល ពួកមនុស្ស ដែលប្រព្រឹត្ត អំពើទុច្ចរិត។ តាមដំណាលរបស់ហ្វា ហៀន និយាយថាៈ ស្ដេចអសោកបានយាងទៅដល់ទីបំផុតនៃកណ្ដាប់ចក្រវាឡ ទ្រង់បានទស្សនាការ ស្ថានព្រះយមរាជ ហើយមានព្រះរាជហឫទ័យ ប្រាថ្នានឹងសាងស្ថាននរកនៅទីជិតក្រុងរបស់ព្រះអង្គ ឲ្យបានដូចជានរករបស់ព្រះយមរាជនោះ។ ក្នុង

អសោកការទានថា: គុកនោះសាងឡើងដោយពេជ្ឈឃាត របស់ព្រះបាទអសោកឈ្មោះគិរិក: ទូលសូមឲ្យសាងសម្រាប់ ពិឃាតមនុស្ស ខាងក្រោយមក ពេជ្ឈឃាតនោះបានចូលទៅ ស្តាប់ភិក្ខុកំពុងស្វាធ្យាយ ពាលបណ្ឌិតសូត្រ ដែលសម្តែង អំពីស្ថាននរកក្នុងវត្តកុក្កុដារាម ទើបទូលសូមអនុញ្ញាតឲ្យធ្វើ នរកនោះមាំមួនឡើងទៀត។

ក្នុងរឿងរ៉ាវ ព្រះបាទអសោក មានដំណាលថា: នរក ដែលទ្រង់អនុញ្ញាតឲ្យគិរិក:ធ្វើនោះ មានកំពែងតែមួយជាន់ ឥតមានជញ្ជាំងខណ្ឌ ដាក់ពួកមនុស្សទោសជាច្រើន នៅ ច្របូកច្របល់គ្នាក្នុងទីនោះ។

ក្នុងទេវទូតសូត្រមជ្ឈិមនិកាយ មានសេចក្តីប្លែកគ្នាថា: «នរក (របស់ព្រះយមរាជ) នោះ ចែកជាច្រើនពួកច្រើនជាន់ នៅកណ្តាលហៅថា មហានគរ មហានគរនោះមានបួនជ្រុង បែងចែកជាទ្វារគ្រប់ជ្រុងទាំងបួន មានកំពែងដែកព័ទ្ធជុំវិញ ផែនដីមហានគរនោះសុទ្ធសឹងតែដែក មានភ្លើងឆេះក្តៅក្ងី ប្រាលឆ្អៅជានិច្ច ផ្សព្វផ្សាយកំដៅទៅចំនួនមួយយោជន៍។

ទ្វារទាំងបួនរបស់មហានគរនោះ ត្រង់ទៅចំនរក ទាំង៤ជាបន្ទាប់គ្នាគឺៈ គូថនរក កក្កុឡនរក សិម្ពលិវន និងអសិបត្តវន មានទន្លេឈ្មោះខារោទកា ជាព្រំប្រទល់។ ពាលបណ្ឌិតសូត្រសំស្ក្រឹត ថាៈ មានពួកសត្វទៅកើតក្នុងនរក ពួកនិរយបាលចាប់បាន ហើយផ្តេកសត្វនោះសន្ធឹង លើផែនដីដែក ដែលភ្លើងកំពុងឆេះសន្ធោសន្ធៅ មានសុទ្ធតែអណ្តាតភ្លើងទ្រោលឡើងតែម្យ៉ាង...។

អសោការទានថាៈ «ក្នុងនរកមានតែសេចក្តីទុក្ខ និងការឈឺចាប់ ដោយភ្លើងឆេះឆួលឆាបខ្លួន ពពួកសត្វតិរច្ឆាន សឹងតែមានសេចក្តីស្ញប់ស្ញែង ខ្លាចការប្រទូស្តដល់គ្នា នឹងគ្នាទៅវិញទៅមកគ្រប់ដង្ហើមចេញចូល ពួកប្រេតសឹងតែក្តៅក្រហាយដោយសេចក្តី ស្រេកឃ្លាន ពួកមនុស្ស សឹងតែមានសេចក្តីព្រួយថប់ ក្នុងការចិញ្ចឹមជីវិត ពួកទេវតាសឹងតែមានសេចក្តីភ័យខ្លាច នឹងការច្យុតិ ធ្លាក់ចុះមក ហើយនឹងការអស់បុណ្យ ហេតុជាវិបាកកម្មទាំង ៥ប្រការនុ៎ះឯងហើយ ដែលជាគ្រឿងចាត់ចែងសត្វក្នុងភពទាំង៣» ។

សង្កិច្ចជាតក ថា: «នរកមាន ៨រណ្តៅ គឺ: សញ្ជីវ កាឡសុត្ត សង្ឃាត រោរុវៈមាន ២រណ្តៅ មហាវិចី តាបន បតាបន។ តាបននរក ជារណ្តៅមួយដែលភ្លើងឆេះជានិច្ច បតាបននរក ជារណ្តៅដែលភ្លើងឆេះក្រៃលែង» ។

ព្រះបាទអសោក មិនគ្រាន់តែផ្សាយអាណាចក្រ ត្រួតទៅលើអាណាខេត្រ ដែលជាកិត្តិយសរបស់ព្រះអង្គប៉ុណ្ណោះទេ ព្រមទាំងបានផ្សាយព្រះពុទ្ធសាសនា ដោយសេចក្តីជ្រះថ្លាដែលជាកិត្តិគុណដល់ទ្វីបអាស៊ីទាំងមូលថែមទៀតផង។ ក្នុងសៀវភៅបារាំង ដែលប្រែមកពីសំស្ក្រឹតថា: ព្រះបាទអសោកបានជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ដោយឫទ្ធិរបស់សមុទ្រភិក្ខុ តែក្នុងមហាវង្សថា: ព្រះបាទអសោក កាលដែលព្រះអង្គបានរាជាភិសេកជាស្តេចគ្រងក្រុងបាតលិបុត្រហើយ ព្រះអង្គមានឫទ្ធានុភាពផ្សាយទៅលើ១យោជន៍ ទៅក្រោម១យោជន៍ មានពួកទេវតា នាគ យក្ស មនុស្ស បក្សី សត្វចតុប្បាទ និងសត្វទ្វេបាទ ចូលគាល់បម្រើព្រះអង្គជានិច្ច ទ្រង់បានសោយរាជ្យជាស្តេចចក្រពត្តិ សម្បូណ៌ដោយសេចក្តី

សុខ ដោយរាជបរិស័ទទាំងអស់នោះទំនុកបំរុង មិនឲ្យត្អូង ព្រះហឫទ័យ[១]។

ថ្ងៃមួយ ព្រះបាទអសោកប្រថាប់នៅទៀបសីហបញ្ជរ ទ្រង់ទស្សនាការនិគ្រោធសាមណេរ ជាព្រះអរហន្ត ដែលជាព្រះយោគាវចរ សង្រួមឥន្ទ្រិយដ៏ស្រគត់ស្រគំ និមន្តរម្យទមទៅក្នុងព្រះលាន មានអាការកិរិយាគួរឲ្យជ្រះថ្លាពន់ពេក ក៏ព្រះអង្គ មានទឹកព្រះហឫទ័យរីករាយ ដោយសមាធិគុណរបស់និគ្រោធសាមណេរនោះ។ មានសេចក្ដី ដំណាលក្នុងគម្ពីរនោះថា: និគ្រោធសាមណេរនោះជាឱរសរបស់សុមនរាជកុមារ ជាបុត្រនៃព្រះបាទវិន្ទុសារៈ លោកអង្គនោះត្រូវជាក្មួយរបស់ព្រះបាទអសោកនោះ។ លុះព្រះអង្គ ទតឃើញដូច្នោះហើយ ក៏មានសេចក្ដីជ្រះថ្លាពន់ពេក ដោយកុសលដែលបានធ្វើមក អំពីអតីតជាតិ ជួយដាស់តឿន ព្រះរាជហឫទ័យ ព្រោះ កាលបុព្វជាតិមុន ក្សត្រិយ៍ ទាំង៣ព្រះអង្គ គឺ ព្រះបាទអសោកមួយ ព្រះបាទទេវានម្បិយតិស្សមួយ

[១] មើលសេចក្ដីពិស្ដារក្នុងមហាវង្ស

និគ្រោធសាមណេរមួយ ទាំង៣នេះ ត្រូវជាបងប្អូន នឹងគ្នា ជាពាណិជទឹកឃ្មុំ នៅក្នុងក្រុង ពារាណសី គ្រានោះមាន ព្រះបច្ចេកពុទ្ធមួយអង្គ គង់លើភ្នំ គន្ធមាទន៍ កើតវណ្ណរោគ (រោគស្គមលឿង) ព្រះបច្ចេកពុទ្ធឯទៀតត្រាច់ស្វែងរកទឹកឃ្មុំ ទៅដល់ក្រុង ពារាណសី ក៏បានជួបនឹងកុម្ភទាសីម្នាក់ ហើយ សួរថា: «នែនាង ស្រុកនេះអ្នកណាមានទឹកឃ្មុំ»។

នាងកុម្ភទាសី បានលើកដៃចង្អុលបង្ហាញ ផ្ទះពាណិជ នោះ ហើយអង្គុយគិតថា «បើព្រះបច្ចេកពុទ្ធអង្គនុ៎ះ បានទឹក ឃ្មុំអំពីសំណាក់ មធុពាណិជហើយ អាត្មាអញនេះក៏ជួយ ត្រេកអរនឹងកុសលរបស់គេនោះណាស់ តែបើលោកមិនបាន ទេ អាត្មាអញនឹងយកក្រមាបង់កមួយនេះទៅចំណាយយក ប្រាក់ មកទិញទឹកឃ្មុំ ថ្វាយព្រះបច្ចេកពុទ្ធអង្គនោះ ទាល់តែ បាន»។ ឯព្រះបច្ចេកពុទ្ធ ទៅរកទឹកឃ្មុំពាណិជ ទទួលពេល នោះ ពាណិជជាប្អូននៅផ្ទះតែម្នាក់ឯង លុះឃើញដូច្នោះ ក៏ មានសេចក្តីជ្រះថ្លា ស្ទុះទៅយកទឹកឃ្មុំមកប្រគេនព្រះបច្ចេក-ពុទ្ធ ហូរហៀរហួសកណ្តាប់មាត់បាត្រ ហើយតាំងសេចក្តី

ប្រាថ្នាថា «ដោយអំណាចកុសល នៃបុញ្ញ មុញ្ចន បរាបរ ចេតនារបស់ខ្ញុំដ៏បរិសុទ្ធស្អាតក្នុងវត្ថុទាននេះ សូមឲ្យខ្ញុំបាន ជាស្តេចឯករាជ្យ ជាធំលើសកលជម្ពូទ្វីប សូមឲ្យរាជអាណា-ចក្ររបស់ខ្ញុំផ្សាយទៅលើផែនដី ១យោជន៍ ទៅក្រោមផែនដី ១យោជន៍ កុំឲ្យអ្នកណាមួយ មានសម្បត្តិសម្បូណ៌ ស្មើនឹង សម្បត្តិរបស់ខ្ញុំព្រះអង្គឡើយ» ។ ព្រះបច្ចេកពុទ្ធ បានធ្វើ អនុមោទនាហើយ និមន្តត្រឡប់មកជួបនឹងនាងកុម្ភទាសីវិញ នាងសួរថា «បពិត្រព្រះអង្គដ៏ចម្រើន ព្រះករុណាបានទឹកឃ្មុំ សម្រេចដូចសេចក្តីប្រាថ្នាហើយឬ?»។ ព្រះបច្ចេកពុទ្ធត្រាស់ តបថា «ម្នាលនាង ទឹកឃ្មុំនោះអាត្មាបានហើយ» នាងកុម្ភ ទាសីទូលសួរទៀតថា «កាលនាយពាណិជថ្វាយទឹកឃ្មុំនោះ គេប្រាថ្នាទៅអនាគតដូចម្តេចខ្លះ?»

ព្រះបច្ចេកពុទ្ធ រៀបរាប់ប្រាប់សេចក្តីប្រាថ្នាសព្វគ្រប់ នាងបានដឹងដូច្នោះ ទើបនិមន្តឲ្យព្រះបច្ចេកពុទ្ធរង់ចាំសិន ឯ ខ្លួននាងត្រឡប់មីម្នាទៅផ្ទះ យកក្រមាចាស់មកផ្លាស់ យក ក្រមាថ្មីអំពីខ្លួន ទៅលាងទឹកឲ្យស្អាត ហើយយកមកថ្វាយ

ដល់ព្រះបច្ចេកពុទ្ធអង្គនោះ ទើបតាំងប្រណិធានថា «ដោយអំណាចកុសល ដែលខ្ញុំម្ចាស់ បានថ្វាយសំពត់សាដកនេះ អំណឹះទៅអនាគត កាលបើនាយពាណិជទឹកឃ្មុំបានជាស្តេចចុល្លចក្រពត្រាធិរាជ ជាធំក្នុងសកលជម្ពូទ្វីបពេលណា សូមឲ្យខ្ញុំម្ចាស់ បានជាអគ្គមហេសីនៃស្តេចអង្គនោះក្នុងពេលនោះ សូមឲ្យខ្ញុំម្ចាស់ មានរូបឆោមដ៏ល្អ គួរគេពិតពិល រមិលមើល ហើយមានយសសក្តិ និងសម្បត្តិ ជាសិរីសួស្តី ជាទីពេញចិត្តនៃជនទាំងពួងក្នុងលោក»។ ព្រះបច្ចេកពុទ្ធបានធ្វើអនុមោទនារួចហើយ លោកហោះទៅកាន់អាកាសរហូតដល់ភ្នំគន្ធមាទន៍នោះ។ ចំណែកបងទាំង២នាក់របស់ពាណិជ ត្រឡប់មកផ្ទះវិញ ក៏បានត្រេកអរនឹងកុសលដែលប្អូនធ្វើហើយនោះឯង។

លុះពាណិជ ទាំង៣ ធ្វើកាលកិរិយាទៅ បានសោយសម្បត្តិមនុស្ស និងសម្បត្តិសួគ៌ ជាច្រើនជាតិ ដល់មកក្នុងសាសនានៃព្រះពុទ្ធជាម្ចាស់យើងនេះ ខាងក្រោយបរិនិព្វានប្រមាណ ២០០ឆ្នាំសេស ក៏ពាណិជប្អូន ដែលបានថ្វាយទឹកឃ្មុំផ្ទាល់នឹងដៃខ្លួន បានមកជា ស្តេចអសោក នាងកុម្ភទាសី

ដែលចង្អុលផ្លូវ បង្ហាញរានលក់ទឹកឃ្មុំ និងបានថ្វាយសំពត់សាដកនោះ បានជា អគ្គមហេសី ព្រះនាមនាង អសន្ធិមិត្តា ពាណិជជាបងច្បង បានជានិគ្រោធសាមណេរ ពាណិជជាកណ្តាល បានជាព្រះបាទទេវានម្បិយតិស្ស។

កាលព្រះបាទអសោក បានទស្សនាការឃើញនិគ្រោធសាមណេរ កំពុងនិមន្តបិណ្ឌបាត ដូច្នោះ ទើបចាត់រាជអាមាត្យឲ្យទៅនិមន្តសាមណេរនោះមក ស្តេចយាងចូលទៅជិតសាមណេរ ដែលមានឥន្ទ្រិយ និងឥរិយាបថដ៏ស្ងប់ស្ងៀម ដូច្នោះ ក៏មានព្រះរាជឱង្ការត្រាស់ថា «លោកម្ចាស់ចូរគង់លើអាសនៈដ៏សមគួរចុះ»។ ពេលនោះ និគ្រោធសាមណេរងាកមើលក្នុងទិសផ្សេងៗ មិនឃើញមានភិក្ខុដទៃ នៅក្នុងទីនោះ លោកក៏ចូលទៅជិតបល្ល័ង្ករាជ្យ ព្រះបាទអសោកជ្រាបដូច្នោះ ទើបទ្រង់ព្រះតម្រិះថា «សាមណេរនេះ នឹងជាម្ចាស់នៃព្រះរាជដំណាក់ របស់អាត្មា ក្នុងថ្ងៃនេះ»។ សាមណេរបាន ហុចបាត្រដល់ព្រះហស្តព្រះបាទអសោកហើយ ទើបឡើងគង់លើបល្ល័ង្ករាជ្យនៅក្រោមស្វេតច្ឆ័ត្រ ព្រះរាជាទ្រង់ទតឃើញ

ដូច្នោះ ក៏មានព្រះរាជហឫទ័យជ្រះថ្លា ទ្រង់សរសើរនូវការសង្រួមឥន្ទ្រិយជាដើម ហើយទើបព្រះរាជទានភោជនាហារដ៏ត្រកាល ដែលគេតាក់តែងដើម្បីព្រះអង្គ ប្រគេនដល់និគ្រោធសាមណេរ និមន្តឲ្យធ្វើភត្តកិច្ចរួចស្រេចហើយ ទើបត្រាស់សួរនូវពុទ្ធវចនៈ នឹងនិគ្រោធសាមណេរ ៗ បានសម្ដែងធម៌ទេសនាក្នុងធម្មបទអប្បមាទវគ្គថ្វាយព្រះរាជាថា:

**អប្បមាទោ អមតំ បទំ   បមាទោ មច្ចុនោ បទំ**
**អប្បមត្តា ន មិយ្យន្តិ   យេ បមត្តា យថា មតាតិ។**

សេចក្ដីមិនប្រហែស ជាផ្លូវមិនស្លាប់ សេចក្ដីប្រហែសជាផ្លូវស្លាប់ ពួកអ្នកមិនប្រហែសឈ្មោះថាមិនស្លាប់ ពួកអ្នកប្រហែសទុកដូចជាស្លាប់។

ព្រះបាទអសោក បានទ្រង់ព្រះសណ្ដាប់ នូវគាថាមួយប្រកបដោយ បាទ៤នេះ ព្រះអង្គ កើតសេចក្ដីជ្រះថ្លាក្នុងពុទ្ធសាសនា ទើបបរិច្ចាគនិច្ចភត្ត ដល់និគ្រោធសាមណេរ ៨ សម្រាប់។ សាមណេរថ្វាយព្រះពរថា «អាត្មាភាពបានទទួលព្រះរាជទានដោយត្រូវធម៌ហើយ អាត្មាភាពនឹងបូជាវត្ថុនេះ

ដល់ព្រះឧបជ្ឈាយ៍ ដែលលោកប្រដៅអាត្មាភាពឲ្យដឹងគុណ ទោស ខុសត្រូវ» ព្រះបាទអសោកបានប្រគេន៨សម្រាប់ទៀត និគ្រោធសាមណេរថ្វាយព្រះពរថា «អាត្មាភាពនឹងបូជាដល់ អាចារ្យដែលលោកលើកយកនូវធម៌ជាប្រយោជន៍ មកប្រដៅ អាត្មាភាព»។ ព្រះរាជាប្រគេន៨សម្រាប់ទៀត សាមណេរក៏ យកទៅបូជា ដល់ព្រះសង្ឃអស់ទៅ ព្រះមហាក្សត្រិយ៍ ប្រគេន ៨សម្រាប់ ទៀត ក្នុងគ្រាជាគំរប់៤នេះ សាមណេរជា បណ្ឌិតមានប្រាជ្ញាមិនបានធ្វើសទ្ធាទាយកឲ្យធ្លាក់ចុះ ទើប លោកទទួលយកដោយខ្លួនឯង។ ដល់ថ្ងៃ ទី២ ព្រឹកឡើង និគ្រោធសាមណេរ បាននាំភិក្ខុសង្ឃ ៣២រូប ចូលទៅកាន់ រាជស្ថាន ព្រះបាទអសោក បានប្រគេនចង្ហាន់ផ្ទាល់ដោយ ព្រះហស្តព្រះអង្គ ហើយនិមន្តព្រះសង្ឃ ឲ្យធ្វើភត្តកិច្ចក្នុង រាជដំណាក់នោះ ដល់ពេលខាងក្រោយភត្តកិច្ច និគ្រោធ សាមណេរ បានសម្តែងធម៌ទេសនា ញុំាងមហាក្សត្រិយ៍ ព្រមទាំងសេនាបតី និងរាជបរិសទ្យទាំងពួង ឲ្យតាំងនៅក្នុង

ព្រះត្រៃសរណគមន៍និងសីល៥ សីល៨ក្នុងព្រះពុទ្ធសាសនា ចាប់ដើមតាំងតែអំពីថ្ងៃនោះមក។

លំដាប់តពីនោះមក ព្រះបាទអសោក បានត្រាស់សួរព្រះសង្ឃថា «ព្រះបរិយត្តិធម៌ ដែលព្រះបរមគ្រូទ្រង់ត្រាស់ទេសនានោះមានប៉ុន្មាន?» ព្រះមោគ្គលីបុត្តតិស្សត្ថេរ ថ្វាយព្រះពរថា «បើរាប់ដោយអង្គ មាន៩ បើរាប់ដោយ ធម្មក្ខន្ធមាន៨៤.០០០»។ លុះព្រះរាជា ទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ព្រះអង្គកំណត់ថានឹងបូជា ព្រះធម្មក្ខន្ធ ដោយវិហារឲ្យគ្រប់ ៨៤.០០០ ទ្រង់ត្រាស់បង្គាប់ ឲ្យបរិច្ចាគព្រះរាជទ្រព្យ ៩៦កោដិ ត្រាស់បញ្ញត្តទៅលើក្សត្រិយ៍ទាំង ៨៤.០០០ ឯព្រះអង្គ ក៏ទ្រង់ប្រារព្ធ សាងអសោការាមឡើង ក្នុងពេលនោះរហូតដល់ ៣ឆ្នាំ ទើបសម្រេចនូវនវកម្មនោះ ហើយព្រះអង្គចេញព្រះរាជប្រកាស ប្រាប់ដល់ស្ដេចគ្រប់ប្រទេសឲ្យឆ្លងវិហារទាំង ៨៤.០០០ នោះ ក្នុងថ្ងៃមួយព្រមគ្នា ប្រកាសឲ្យអ្នកនគរទាំងអស់ សមាទាននូវ អដ្ឋង្គឧបោសថសីលក្នុងពេលនោះគ្រប់ៗគ្នា។

ព្រះបាទអសោកមានវត្ថុ២ប្រការ ដែលមានឫទ្ធានុភាព យ៉ាងវិសេសគឺព្រះខាន់កែវ១ឈ្មោះបរន្តបៈអាចទៅកាត់ក្បាល សត្រូវបានចម្ងាយ ១០០យោជន៍ យកមកថ្វាយព្រះអង្គដូច ព្រះបំណង មានច្រវាក់មាស១ខ្សែ អាចទៅចាប់ចងក្រៀក មនុស្ស ឬវត្ថុទាំងឡាយនាំយកមកបានដូចព្រះរាជប្រាថ្នា។

ថ្ងៃមួយ ព្រះបាទអសោក ទ្រង់ព្រះសណ្តាប់ថា កាឡ នាគរាជ មានអាយុ ១កល្ប ជាអ្នកបានទាន់ ឃើញព្រះពុទ្ធ ទាំង៤ព្រះអង្គ ដែលទ្រង់ចូលកាន់ព្រះនិព្វានទៅហើយ ទើប ស្តេចប្រើច្រវាក់មាស ឲ្យទៅនាំយក កាឡនាគរាជ នោះមក ព្រះអង្គ បានអញ្ជើញ កាឡនាគរាជ ឲ្យឡើងលើរតនបល្ល័ង្ក បូជាដោយគ្រឿងសុគន្ធជាតិ និងផ្កានានា ហើយស្តេចត្រាស់ បង្គាប់ឲ្យកាឡនាគរាជនិម្មិតខ្លួនធ្វើជារូបព្រះពុទ្ធម្ចាស់ ស្តេច នាគ ក៏បានធ្វើតាម ព្រះរាជបំណង បាននិម្មិតខ្លួន ធ្វើជា ព្រះពុទ្ធឡើង មានរូបភាពដូចជាព្រះពុទ្ធសុទ្ធសាធ ជាទីនាំ មកនូវសេចក្តីជ្រះថ្លាពន់ពេក ព្រះបាទអសោក បានទត មើលព្រះពុទ្ធនិម្មិតនោះ ដោយបីតិ រីករាយ ផ្សព្វផ្សាយ សព្វ

សព៌ាង្គកាយ ឲ្យកើតមានសេចក្ដីជ្រះថ្លារឹងរឹតតែចម្រើនខ្លាំង ឡើង ព្រះអង្គទតសំឡឹងឆ្ពោះទៅព្រះពុទ្ធនោះ មិនប៉ប្រិច នេត្រា ហាក់ដូចជា នឹងរកដកព្រះនេត្រាពីព្រះអង្គ ទៅជាប់ នឹងព្រះពុទ្ធនិម្មិតនោះ ដោយទ្រង់ អត់ព្រះក្រយាស្ងោយ រហូតដល់៧ថ្ងៃ កិច្ចនោះឈ្មោះថា អក្ខិបូជា (បូជាភ្នែក)។

ព្រះបាទអសោក បានបំបួសព្រះមហិន្ទរាជឱរសជាភិក្ខុ និងនាងសង្ឃមិត្តារាជធីតា ជាភិក្ខុនី ក្នុងព្រះពុទ្ធសាសនា។

ប្រវត្តិសាស្ត្រសាកលរបស់ ហ្វង់វិចិត្រវ៉ាទកាថា ដែន មគធៈនោះ ជាទីដែលព្រះពុទ្ធសាសនា បានប្រតិស្ឋានជា ដំបូង ហើយនាំគ្នាកាន់កាប់តៗរៀងមក តែកាលចន្ទ្រគុប្តចូល មកគ្រប់គ្រងផែនដីនោះ ហើយសាសនាព្រាហ្មណ៍ ក៏មាន អំណាចរុងរឿងឡើងក្នុងអាណាចក្រ មគធៈ ព្រោះហេតុតែ មួយយ៉ាង គឺចន្ទ្រគុប្ត មានអាចារ្យជាព្រាហ្មណ៍ ហើយការ ដែលចន្ទ្រគុប្ត អាចតាំងខ្លួនជាស្ដេចផែនដីបាន ក៏ដោយវិធី ប្រៀនប្រដៅរបស់ព្រាហ្មណ៍ជាអាចារ្យទាំងនោះ។

មួយយ៉ាងទៀត ក្នុងពុទ្ធកាលក្តី ខាងក្រោយពុទ្ធកាលយូរមកក្តី ក៏ពួកព្រាហ្មណ៍តែងមាននាទីជាបុរោហិត (ជាទីប្រឹក្សារាជការផែនដី) ហើយគេតែងប្រកាន់ថា ព្រាហ្មណ៍ជាបុគ្គលជំពូកមួយ ដែលជាអ្នកចេះដឹងក្នុងរដ្ឋសាស្ត្រ (រដ្ឋប្រសាសន៍ ឬនឹងហៅឲ្យងាយៗ ថា វិជ្ជាគ្រប់គ្រង ឬវិជ្ជាការពារនគរ)។ ព្រះបាទវិន្ទុសារៈ ជាព្រះបិតារបស់ព្រះបាទអសោក ក៏គង់ជ្រះថ្លា ក្នុងសាសនាព្រាហ្មណ៍ដែរ ដោយការធ្លាប់បានអញ្ជើញពួកព្រាហ្មណ៍ មកលៀងអាហារ ក្នុងមួយលើកៗមួយម៉ឺនប្រាំមួយពាន់នាក់។ ឯព្រះបាទអសោកសោតកាលព្រះអង្គ នៅជាកុមារនៅឡើយ ក៏ទ្រង់ បានទទួលការសិក្សាក្នុងស្នាដៃរបស់ពួកព្រាហ្មណ៍ដែរ តែដល់ពុទ្ធសករាជ ២៧៩ ទើបបានទ្រង់ប្រកាសព្រះអង្គថាជាពុទ្ធមាមកៈ ដោយសេចក្តីណែនាំ នៃមន្ត្រីរបស់ព្រះអង្គម្នាក់ឈ្មោះ រាជគុប្តៈ។ ព្រះមហាក្សត្រិយ៍ទ្រង់កាន់ព្រះពុទ្ធសាសនានោះ ព្រោះទ្រង់ជ្រាបថា ព្រះអង្គបានធ្វើសង្គ្រាមជាកម្មដ៏អាក្រក់ច្រើនលើសលុបពេក និងទ្រង់ជ្រាបច្បាស់ថា គ្រាកាលដែលព្រះអង្គវាយ

ដណ្ដើមយកបានដែនកលិង្គៈ ទ្រង់បានធ្វើដោយអំណាច បំផ្លាញជីវិតមនុស្សច្រើនជាអនេក។

កាលពុទ្ធសករាជ ២៩៤ ស្ដេចបានទៅនមស្សការនូវទីប្រសូតរបស់ព្រះពុទ្ធជាម្ចាស់ លុះដល់ ពុទ្ធសករាជ ៣០៣ បានទ្រង់ឧបសម្បទាជាភិក្ខុក្នុងព្រះពុទ្ធសាសនា។

កាលសង្គ្រាម ដែលព្រះបាទអសោក ធ្វើក្នុងខេត្តកលិង្គៈនោះ ជាសង្គ្រាមធំបំផុត ដែលជាហេតុ នាំឲ្យផ្លាស់ព្រះរាជហឫទ័យរបស់ព្រះអង្គ ចាកភាពជាអ្នកធ្វើចម្បាំង មកជាអ្នកប្រព្រឹត្តធម៌វិញ សិលាចារឹក ដែលបញ្ចុះពាក្យប្រកាសរបស់ព្រះបាទអសោកនោះឯង សំដែងឲ្យឃើញថា ព្រះអង្គទ្រង់ស្តុតព្រះហឫទ័យយ៉ាងណាៗ មានសេចក្ដីប្រែដូចតទៅនេះ៖

«ព្រះករុណាជាម្ចាស់ជីវិត ជាអ្នកសក្តិសិទ្ធិបានជ័យជំនះដល់ខេត្តកលិង្គៈ កាលទ្រង់បានរាជសម្បត្តិហើយ៨ឆ្នាំ។ ទ្រង់បានចាប់មនុស្សមកជាឈ្លើយ ១៥០.០០០ និងបានសម្លាប់អស់១០០.០០០»។

«កាលដែលបានរួមខេត្ត កលិង្គៈ ចូលមកហើយ ទើប

ព្រះករុណា ជាម្ចាស់ជីវិត ជាអ្នកសក្តិសិទ្ធិ បានតាំងខ្លួនជាអ្នកគ្រប់គ្រង រក្សាព្រះធម៌ ទ្រង់ស្រឡាញ់ក្នុងធម៌ និងទ្រង់ស្រឡាញ់ការប្រៀនប្រដៅព្រះធម៌ ហើយរឿងនេះឯងដែលធ្វើឲ្យព្រះករុណា ជាម្ចាស់ជីវិត ជាអ្នកសក្តិសិទ្ធិ ទ្រង់តូចព្រះហឫទ័យ ក្នុងការដែលទៅវាយដណ្ដើមយកក្រុងកលិង្គៈ ព្រោះការវាយក្រុងនោះ ត្រូវតែប្រទូស្តរ៉ាយ ពិឃាតមនុស្ស ឬចាប់យកជាឈ្លើយ ជារឿងដែលព្រះករុណាជាម្ចាស់ជីវិត ទ្រង់មានព្រះទ័យទោមនស្សជាយ៉ាងក្រៃលែង» ។

តាំងអំពីបានទ្រង់ប្រកាស ព្រះអង្គជាពុទ្ធមាមកៈហើយ ក៏លោកទាំងមូលបានដឹងច្បាស់ថា ព្រះអង្គជាពុទ្ធសាសនូបត្ថម្ភកៈពិតប្រាកដ ទ្រង់បានសាងព្រះស្តូប ៨៤.០០០[១] ឡើងក្នុងក្រុងរាជគ្រឹះ ហើយតាំងអំពីនោះមក ក្រុងរាជគ្រឹះផ្លាស់នាមថា «វិហារ» ដោយទីនោះ ជាទីតាំង នៃព្រះស្តូប

(១) មានសៀវភៅបារាំងប្រាប់ចំនួនខុសៗគ្នាច្រើន ខ្លះថា៨០.០០០ ខ្លះថា៦៤.០០០ ខ្លះ៨.៤០០ ការដែលពិតនោះ បើនឹកដល់អាណាចក្រនិងសេចក្ដីជ្រះថ្លា ចាស់ថ្លាក្រៃលែង របស់ព្រះបាទអសោក ហើយការកសាងព្រះស្តូប៨៤.០០០អង្គនោះ ជារបស់ដែលគួរជឿ មិនជាការលើសវិស័យដែលទ្រង់កសាងបាន។

ដល់មកសម័យនេះហៅថា «ប៊ីហារ» ។

ក្នុងរជ្ជសម័យរបស់ព្រះបាទអសោកនេះ ពួកព្រាហ្មណ៍អាប់រស្មីចុះទៅ ពួកព្រាហ្មណ៍ ដែលធ្លាប់បានទទួលប្រាក់ទំនុកបំរុងរបស់រដ្ឋបាលពីមុនមកនោះ ក៏ត្រូវកាត់ចេញអស់ផ្លាស់យកប្រាក់នោះ ទៅទំនុកបំរុងព្រះសង្ឃវិញ។ តែទុកជាព្រះបាទអសោក យកព្រះរាជហឫទ័យទុកដាក់ ក្នុងការប្រកាស ព្រះពុទ្ធសាសនាដូច្នេះហើយក៏ដោយ ក្នុងព្រះរាជអាណាចក្ររបស់ព្រះអង្គ ក៏គង់នៅមានសាសនាដទៃៗទៀតជាច្រើន។ ព្រះបាទអសោក ទ្រង់ទំនុកបំរុងព្រះពុទ្ធសាសនាតែទ្រង់មិនប្រទូស្តរ៉ាយ សាសនាដទៃទេ សូម្បីទ្រង់ដកសាសនាព្រាហ្មណ៍ដែលធ្លាប់ជាសាសនាសម្រាប់អាណាចក្រចេញហើយ ក៏គង់នៅប្រើព្រាហ្មណ៍ធ្វើពិធីផ្សេងៗនៅឡើយរឿងទាំងនេះ ក៏ព្រោះថាជាកិច្ចខានសោះមិនបាន ដោយពួកដែលជឿសាសនាព្រាហ្មណ៍ក្នុងវេលានោះ មិនមែនតិចជាងពួកពុទ្ធសាសនិកជនទេ ម្យ៉ាងទៀត តាំងអំពីបុរាណកាលយូរមកហើយក្តី ក្នុងសម័យនេះក្តី ចិត្តរបស់ជនជាតិឥណ្ឌា

នៅជាប់តែនឹងសាសនា បើព្រះបាទអសោក បដិសេធចោល សាសនាព្រាហ្មណ៍ចេញហើយ ក៏ប្រាកដជានឹងកើតការក្បត់ កាប់សម្លាប់គ្នារីករាលយ៉ាងធំ បើទុកជាទ្រង់ លះបង់ចោល សោះមិនបានដូច្នេះ ក៏គង់ទ្រង់មិនទំនុកបំរុងព្រាហ្មណ៍ជា ការធំដុំប៉ុន្មានឡើយ។

មិនមែនតែសាសនាព្រាហ្មណ៍ប៉ុណ្ណោះទេ សូម្បីសាសនា ដទៃៗ ដែលមានគណាចារ្យតាំងការប្រៀនប្រដៅនៅឡើយ ព្រះបាទអសោកក៏មិនបានលុបលាងចោលដែរ គ្រាន់តែទ្រង់ សំដែងព្រះរាជប្រាថ្នាឲ្យម្ចាស់នៃសាសនាទាំងនុ៎ះៗ ជួយទំនុកបំរុង សីលធម៌របស់ប្រជាជនប៉ុណ្ណោះ សេចក្តីប្រាថ្នានេះ ទ្រង់បាន ចារឹក នៅលើផែនសិលា ហើយនាំទៅប្រតិស្ឋាន ទុកក្នុងទី ផ្សេងៗសិលាចារឹកនោះតាំងនៅរហូតដល់សម័យនេះ មាន ផែនថ្ម ១ផ្ទាំង ដែលសំដែងឲ្យឃើញ ចរិយាវត្ត ដ៏ល្អរបស់ ព្រះបាទអសោក ដូចសេចក្តីប្រែតទៅនេះ៖

«ប្រជារាស្ត្រគ្រប់គ្នា សុទ្ធតែជាបុត្ររបស់ខ្ញុំ ៗ ត្រូវការ អោយបុត្រក្នុងទ្រូងរបស់ខ្ញុំ មានសេចក្តីសុខ សួស្តីក្នុងលោក

នេះយ៉ាងណា ខ្ញុំក៏មានប្រាថ្នា អោយពួកប្រជាជន មានសេចក្តីសុខសួស្តីយ៉ាងនោះ។ ខ្ញុំឲ្យដាំដើមជ្រៃនៅប្រឹបខាងផ្លូវដើរ ដើម្បីឲ្យជាម្លប់ដល់មនុស្សនិងសត្វ។ ខ្ញុំបានឲ្យដាំសួនស្វាយ ជីកស្រះ និងសាងសាលា ឲ្យជាទីសំណាក់អាស្រ័យនៃមនុស្សនិងសត្វ។ ខ្ញុំបានតាំងអ្នកមើលការខាងផ្លូវសាសនាសម្រាប់ធ្វើការកុសល គ្រប់ប្រភេទ និងប្រតិបត្តិ នាទីរបស់សាសនា គ្រប់និកាយ។ ខ្ញុំយកចិត្តទុកដាក់ចំពោះព្រះសង្ឃរបស់ព្រះពុទ្ធសាសនា សូម្បីពួកព្រាហ្មណ៍ដែលជាសាសនារបស់ពួកសូមទាន ហើយនិងម្ចាស់លទ្ធិដទៃៗ ខ្ញុំក៏យកចិត្តទុកដាក់ផង »។

កាលក្នុងពុទ្ធសករាជ ៣០១ ព្រះបាទអសោកបានចាត់ឲ្យមានសង្គាយនា[១] ជាគ្រាទី៣ ក្នុងក្រុងបាតលិបុត្រដែលជាក្រុងរបស់ព្រះអង្គគង់នៅ។ ក្នុងកាលសង្គាយនា ជាន់នេះមានភិក្ខុ មកប្រជុំ ១.០០០អង្គ ហើយក្នុងគ្រានេះឯង ដែល

---

[១] មើលសេចក្តីសង្ខេប តែងាយយល់ក្នុងសៀវភៅ Les Religions ˝Du monde˝ par G.Clément

បានបញ្ជូនពួកព្រះថេរៈ ជាអ្នកអង់អាចទៅប្រកាសព្រះពុទ្ធសាសនា ក្នុងមួយទិសមួយរូប គ្រប់ផ្លូវ គឺព្រះមហារក្ខិតត្ថេរទៅប្រកាសដល់ពួកក្រិកខាងខេត្ត បាក់ត្រីយ៉ាន (Bactriane) ព្រះមទ្ធិយន្តិកៈ (មជ្ឈន្តិក?) ទៅប្រកាសខាងកស្មីរៈ និងដែនគន្ធារៈ ព្រះមហាជិម្មៈ(?) និងសហទេវៈ ទៅប្រកាសក្នុងអាណាចក្រតូចៗ ផ្សេងៗ ខាងភ្នំ ហិមាល័យ ព្រះមហា ធម្មៈទៅប្រកាសខាងខេត្ត មហារាស្ត្រ ព្រះមហា ទេវៈ ទៅប្រកាសខាង ម៉ៃសរ ព្រះសោណៈ និងព្រះឧត្តរៈ ទៅប្រកាសខាងប្រទេសភូមាមន ព្រះឱរស និងព្រះធីតា របស់ព្រះបាទអសោក បានទទួលនាទី ទៅប្រកាសខាងកោះលង្កា។

ក្នុងខេត្តដែល ព្រះបាទអសោក បញ្ជូនព្រះថេរទៅប្រកាសព្រះពុទ្ធសាសនានេះ មានទីខ្លះជាដែនដែលមិនបាននៅក្នុងអំណាច របស់ព្រះអង្គ តែអាស្រ័យ ហេតុដែលព្រះអង្គ មានអំណាចជាធំក្រៃលែង នៅក្នុងឥណ្ឌា ទើបមិនមានអ្នកណា ហ៊ានឃាត់ឃាំងឡើយ ហើយកាលនោះ ព្រះពុទ្ធសាសនាជាសាសនាដែលដោះទុក្ខរបស់មនុស្សបានពិតៗ

ដូច្នេះ អ្នកប្រទេសទាំងឡាយ ក៏ជ្រះថ្លាជាច្រើន ម្យ៉ាងទៀត បណ្ដាលោកអ្នក ដែលប្រកាស ព្រះពុទ្ធសាសនានេះ ក៏បាន ធ្វើប្រយោជន៍ដ៏សំខាន់ឲ្យដល់អ្នកប្រទេសទូទៅ ដូចក្នុងដែន ដិក្កាន់ (Dek-kan) ដែលវេលានោះ នៅជាមនុស្សព្រៃនៅឡើយ ក៏បានទទួលសេចក្ដីចម្រើន រុងរឿងឡើង ដោយពុទ្ធានុភាព តែដែលសំខាន់បំផុតក៏គឺកោះលង្កា និងខាងកស្មីរៈ។

ព្រះមហិន្ទត្ថេរ និងព្រះនាងសង្ឃមិត្តាថេរី ជាឱរស និង ធីតា របស់ព្រះបាទអសោក បានមកដល់ កោះលង្កា ហើយ ធ្វើឲ្យស្ដេចក្នុងលង្កាទ្វីប ដែលទ្រង់ព្រះនាមថា ព្រះបាទ ទេវានម្បិយតិស្ស ជ្រះថ្លាក្នុងពុទ្ធោវាទ ហើយសាសនារបស់ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ក៏បានប្រតិស្ឋាន ក្នុងលង្កាទ្វីប ក្នុង កាលពុទ្ធសករាជ ៣១៣ កាលដែលព្រះមហិន្ទត្ថេរ និងព្រះ នាងសង្ឃមិត្តាថេរី ស្ដេចទៅលង្កាទ្វីបនោះ ទ្រង់បាននាំយក មែកពោធិ៍ អំពីពោធិព្រឹក្ស ដែលព្រះសម្មាសម្ពុទ្ធ ត្រាស់នោះ ទៅដាំក្នុងកោះលង្កា ហើយដើមពោធិ៍នោះ ចម្រើនធំឡើង នៅដល់មកសព្វថ្ងៃនេះ ជាឈើ ដែលរស់នៅ បានយូរបំផុត

ក្នុងលោក មានអាយុជាង ២.០០០ឆ្នាំ មកហើយ។ កាលព្រះពុទ្ធសាសនាប្រតិស្ឋានមាំក្នុងកោះលង្កា ពួកជនអ្នកលង្កាក៏ខ្វល់ខ្វាយប្រឹងប្រែងក្នុងការតែងគម្ពីរ និងប្រកាសព្រះពុទ្ធសាសនាទៅកាន់ប្រទេសភូមា-ជ្វា និងឥណ្ឌូស៊ីនទាំងអស់ទូទៅ ហើយតមកក្នុងសម័យកណ្ដាល កាលព្រះពុទ្ធសាសនាបានខ្ចាត់ ធ្លាក់ចេញចាក ឥណ្ឌា ដោយការបៀតបៀនរបស់សាសនាហិណ្ឌូ និងមហាម៉ាត់ (ឥស្លាម) ហើយកោះលង្កាក៏ត្រឡប់ប្រែជាប្រធានរបស់ព្រះពុទ្ធសាសនា។

ចំណែកប៉ែកខាងជើង គឺខាងកស្មីរៈ និងគន្ធារៈនោះ ព្រះសាវកជាអ្នកប្រកាសព្រះពុទ្ធសាសនា បានធ្វើប្រយោជន៍ជាច្រើនជាងប៉ែកខាងឯទៀត ព្រោះថាព្រះមជ្ឈិយន្តិកៈ អ្នកនាំព្រះពុទ្ធសាសនា ទៅប្រកាសក្នុងដែននោះ បាននាំភិក្ខុ ៥០០រូប ទៅជាមួយផង ហើយពួកលោកទាំងអស់នេះបានធ្វើសេចក្ដីចម្រើន មិនតែផ្លូវចរិយា និងសីលធម៌របស់ប្រជាជនប៉ុណ្ណោះទេ លោកក៏បានទាំងណែនាំ ជួយក្នុងការសាងទីក្រុង ធ្វើផ្លូវទឹក ទំនុកបម្រុង ក្នុងការដាំដំណាំ ឲ្យបាន

សេចក្ដីចម្រើន ក្នុងផ្លូវរកចិញ្ចឹមជីវិត របស់មនុស្សទៀតផង ក្នុងបទដែលពោលតទៅ នឹងឃើញបានថា ខាងកស្មីរៈ និង គន្ធារៈនេះឯង ដែលជាអ្នកប្រកាស សាសនា ចេញទៅកាន់ ប្រទេសចិន ដែលបង្កើតជានិកាយ មហាយានឡើង។ សូម្បី ព្រះបាទអសោកបានទំនុកបម្រុងព្រះពុទ្ធសាសនាឲ្យរុងរឿង ពេញបន្ទុកយ៉ាងនេះហើយ ក៏គង់មិនទាន់ ពេញព្រះរាជ ហឫទ័យ ព្រះអង្គនៅឡើយ បានជាព្រះអង្គ ព្យាយាមធ្វើឲ្យ ព្រះពុទ្ធសាសនាផ្សាយចេញទៅ ដល់ប្រទេសក្រិក តាំងអំពី រជ្ជសម័យ ព្រះបាទអាឡិក្សន្ទ្រមហារាជ និងផ្សាយទៅដល់ អ៊ឺរ៉ុប និងអាហ្វ្រិកថែមទៀត។ មានសិលាចារឹកចុះព្រះនាម ស្ដេច ក្នុងប្រទេសផ្សេងៗ ដែលជាអ្នក ជួយក្នុងការប្រកាស សាសនា តែព្រះនាម របស់ស្ដេចទាំងអស់នោះ ព្រះបាទ អសោកយកមកសរសេរជាភាសាបាលីទាំងអស់ ដូចអន្តិយកៈ (ព្រះបាទអែន្តិឱគោសទី២) ជាស្ដេចក្រុងសីរី (Syrie) តុរុមាយៈ (ព្រះបាទប៉តោលេមេ) ជាស្ដេចដែនដីអេហ្ស៊ីប្ត៍ (Egypte) អន្តិកេនៈ (ព្រះបាទអន្តិកោន) ជាស្ដេចដែនដីម៉ាសេដ្វាន

(Macédoine) អសិកសន្ទរោ (ព្រះបាទអាឡិក្សន្ទ្រ) ជាស្តេចក្រុងអេប៉ិរ(Epire) មក:(ព្រះបាទមាគ័ស)ស្តេចគ្រងនគរតូចៗមួយកន្លែង ជាខាងកើតប្រទេស អេហ្ស៊ីប ដោយហេតុនេះទើបត្រូវរាប់ថា ព្រះបាទអសោក បានប្រកាសព្រះពុទ្ធសាសនា មិនមានពុទ្ធសាសនិកជនឯណា ឲ្យបានត្រឹមស្មើនឹងព្រះអង្គនោះឡើយ ហើយក្នុងគ្រានេះ យើងក៏ចូលចិត្តបានថា ហេតុអ្វីគោលសំខាន់ ក្នុងគ្រិស្តសាសនា ទើបប្រហែលគ្នា នឹងព្រះពុទ្ធសាសនា ដ៏ច្រើនម្ល៉េះ ប្រសិនបើព្រះបាទអសោក មិនអស់ព្រះជន្មដោយរហ័ស ឬថាកាលអស់ព្រះជន្មហើយ មានអ្នកប្រព្រឹត្តតាមព្រះរាជលំអានតមកដោយសេចក្តីជ្រះថ្លា ដ៏ហ្មត់ចត់ មានអំណាចរាជសក្តិយ៉ាងព្រះបាទអសោកផង ហើយក៏មិនបាច់សង្ស័យឡើយ អ៊ឺរ៉ុបទាំងទ្វីប ក៏នឹងកាន់ ព្រះពុទ្ធសាសនាមិនខាន កាលបើអ៊ឺរ៉ុបទាំងទ្វីប កាន់ព្រះពុទ្ធសាសនាហើយ ព្រះពុទ្ធសាសនា ក៏នឹងត្រឡប់ ជាទីរាប់អានរបស់លោកទាំងអស់ទួទៅ ទ្រង់ទ្រាយរបស់លោក ហើយនិងបែបផែនការងារ ប្រព្រឹត្តទៅនៃខេត្ត

ដែន ក៏នឹងខុសប្លែកចាកហេតុកេទក្នុងវេលានេះជាច្រើន។

សិលាចារឹករបស់ព្រះបាទអសោក ដែលប្រតិស្ឋាននៅទីប្រសូតរបស់ព្រះពុទ្ធជាម្ចាស់ ដូចបានប្រែមកជាអក្សរខ្មែរ និងភាសាខ្មែរដូចតទៅនេះ៖

១- ទេវាន បិយេន បិយទសិន លាជិន វីសតិវសាភិសិតេន

២- អតន អាគាច មហីយិតេ ហិទ ពុធេ ជាតេ សក្យមុនីតិ

៣- សិលាវិគឌភីចា កាលាបិត លិលាថំភេច ឧសបាបិតេ

៤- ហិទ ភគវំ ជាតេតិ លំមិនិគាមេ ឧពលិតេ កដេ

៥- អឋភាគិទយច

ពាក្យប្រែ

១- ព្រះរាជា បិយទស្សី ជាទីស្រឡាញ់របស់ទេវតា រាជាភិសេកហើយបាន២០ឆ្នាំ[១]។

២- ស្តេចមកបូជាដោយព្រះអង្គឯង ទ្រង់ជ្រាបច្បាស់ថា ព្រះសក្យមុនីពុទ្ធទ្រង់ប្រសូតហើយក្នុងទីនេះ។

---

[១] ព្រះនាមពេញរបស់ព្រះបាទអសោកថា: « អសោកបិយទសី»។

៣- ទើបប្រោសឲ្យចារឹកសិលាទុក?[១] និងប្រោសឲ្យតាំងសសរថ្ម។

៤- សម្តែងប្រាប់ថា ព្រះដ៏មានព្រះភាគ ទ្រង់ប្រសូតហើយក្នុងទីនេះ និងប្រោសឲ្យបន្ថយសួយលួង ក្នុងតំបន់ស្រុកលុម្ពិនី។

៥- ចុះ៨ភាគ (?)។

[១] ដែលមានគ្រឿងសម្គាល់ដូច្នេះឲ្យដឹងថា: អ្នកប្រែមិនសូវច្បាស់។

# អសន្ធិមិត្តាអគ្គមហេសី

## គម្ពីរមហាវង្ស

ព្រះបាទ អសោកមហារាជ ទ្រង់មានអគ្គមហេសីមួយអង្គ ព្រះនាមនាងអសន្ធិមិត្តា[១] (មានអវយវៈឥតស្នាមតំណ) ព្រះនាងមានរូបឆោមដ៏ល្អ ជាឆ្នើមក្នុងលោក គួរអ្នកផង ក្រលេកមើល ដោយសេចក្ដីពេញចិត្ត ព្រះនាង មានបសាទសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា តែងនិមន្តព្រះភិក្ខុសង្ឃទាំង ៦០.០០០អង្គ មកប្រគេនចង្ហាន់ជាមួយនឹងព្រះបាទអសោកជាព្រះរាជស្វាមី។

ថ្ងៃមួយ ព្រះនាងប្រថាប់នៅលើ (កៅអីមាស ដាំត្បូង) កំពុងសោយអំពៅ ដែលពួកទេព្ដានាំយកពី ហិមវន្តប្រទេសមកថ្វាយ ពេលនោះព្រះបាទអសោកស្ដេចយាងចូលទៅក្នុងទីនោះ ទ្រង់ទតឃើញព្រះនាងអសន្ធិមិត្តាកំពុងសោយអំពៅ ទើបចំអន់ព្រះនាងក្រសាលព្រះរាជហឫទ័យថាៈ «ហៃនាង

---

[១] តាមសៀវភៅពុទ្ធសាសនារបស់លោកល្វី ហ្វីណូត៍ ដែលលោកជុំម៉ៅ ប្រែជាខ្មែរថា ព្រះនាងអសន្ធិមិត្តាមានបុត្រមួយព្រះអង្គព្រះនាមកុនាល តែក្នុងគម្ពីរមហាវង្សមិនឃើញមាននិយាយ។

មានរូបឆោម និងភ័ក្ត្រាដ៏ល្អស្រស់ប្រិមប្រិយ នាងបរិភោគនូវទឹកអំពៅដ៏ផ្អែម ត្រជាក់ ដូចជារសនៃទឹកឃ្មុំនេះ សប្បាយរីករាយចិត្តណាស់ទៅឬ?។»

ព្រះរាជទេវី បានស្តាប់ព្រះឱង្ការត្រាស់សរសើរចំអកដូច្នោះ ក៏តូចព្រះហឫទ័យ ក្រាបទូលថា «បពិត្រ ព្រះសម្មតិទេពដ៏ប្រសើរ អំពៅនេះ កើតក្នុងហិមវន្តប្រទេស ទេព្តានាំយកមកថ្វាយនេះ ព្រោះតែបុញ្ញានុភាពនៃខ្ញុំម្ចាស់ មិនមែនព្រោះបុណ្យសម្ភារនៃព្រះអង្គទេ»។

ព្រះមហាក្សត្រ ត្រាស់តបថា «នែនាងមានភ័ក្ត្រដ៏ចម្រើនឥស្សរិយសម្បត្តិ ក្នុងសកលជម្ពូទ្វីបនេះជារបស់យើង នាងថាសម្បត្តិទាំងពួង កើតព្រោះបុណ្យ របស់នាងទៅវិញ នាងឯង វាយឫកស្មើ លើកដម្កើងខ្លួន ឲ្យខ្ពស់ដល់ ភពមហាព្រហ្ម បន្ទោកបុណ្យរបស់យើងទំលាក់ឲ្យទាបដល់អវិចីមហានរកទៅឬ? នាងឯងថាសម្បត្តិកើតព្រោះបុណ្យខ្លួននាងឯងៗមានបុណ្យពិតណាស់ហើយ បើដូច្នោះ ព្រឹកនេះយើងនឹងលាងព្រះសង្ឃ ៦០.០០០អង្គ ចូរនាងឯងរកសំពត់ឲ្យបាន

៦០.០០០ផាប់ និងប្រគេនដល់ព្រះភិក្ខុសង្ឃក្នុងថ្ងៃព្រឹកនេះ បើនាងឯងរកបានទាន់ក្នុងពេលធ្វើទាននេះ ទើបឃើញជាក់ច្បាស់ថា នាងមានបុណ្យប្រាកដមែន តែបើរកមិនបានទេ យើងនឹងត្រូវធ្វើតាមរាជអាជ្ញាដល់នាងឯងក្នុងថ្ងៃព្រឹកនេះ»។

កាលនាងទេវី បានស្តាប់ព្រះរាជឱង្ការ ដាក់រាជអាជ្ញាដល់នាង ក៏ភិតភ័យ មានព្រះភ័ក្ត្រស្លឹតស្លាំង ដោយរំពឹងថា «ព្រះមហាក្សត្រិយ៍ ទ្រង់ព្រះក្រោធដល់អាត្មា»។ ហើយព្រះនាងសោយសោក ហាក់ដូចជាត្រូវថ្នាំពិស ពុលក្តៅក្តួល ជាប់នៅនឹងដួងហឫទ័យ ភ័យជានិច្ចគ្រប់ដង្ហើមចេញចូល ព្រះនាងរំពឹងថា «ឱអាត្មាអញនេះ នឹងទៅរកសំពត់ក្នុងទីឯណាឲ្យបាន ដល់ទៅ ៦០.០០០ផាប់ដូច្នេះហ្ន៎!»។ ព្រះនាងចូលទៅក្នុងក្រឡាព្រះបន្ទំ យំទួញ បម្រះនន្ទៀលទៅមកៗ លើទីសិរីសេយ្យា មិនបាននិន្ទ្រាលក់ អស់មួយរាត្រី ដោយថប់បារម្មណ៍ថា មុខជានឹងត្រូវស្លាប់ព្រឹកនេះ ហេតុតែតេជៈកុសលដែលនាងបានកសាងមកអំពីអតីតជាតិក៏ក្តៅដល់ចតុលោក

បាល ទាំង៤[១] គ្រានោះស្ដេចវេស្សវណមហារាជបានជ្រាបថា ព្រះនាងអសន្និមិត្តា អគ្គមហេសីមានទុក្ខព្រួយដូច្នោះ ក៏ស្ដេចចូលទៅកាន់សំណាក់ព្រះនាង ហើយត្រាស់ថា «បពិត្រព្រះរាជទេវី ព្រះនាងកុំសោយសោក ថប់បារម្ភឡើយ សំពត់សាដករបស់ព្រះនាង កាលថ្វាយដល់ព្រះបច្ចេកពុទ្ធអំពីជាតិមុននោះ ចូរព្រះនាងពិចារណារំពឹងដល់ផលសំពត់សាដករបស់ព្រះនាងនោះចុះ នឹងឲ្យផលប្រាកដដល់ព្រះនាងគ្រានេះ» លុះទ្រង់ដាស់តឿន ព្រះស្មារតី ព្រះអគ្គមហេសីដូច្នេះហើយ ក៏និម្មិតដោយឫទ្ធិ នាំយកប្រអប់មួយមានជាយសំពត់សាដកចេញមកប្រាកដខាងក្រៅ ប្រគល់ឲ្យព្រះនាងអសន្និមិត្តារាជទេវី ហើយត្រាស់បង្គាប់ថា «បពិត្រព្រះរាជទេវី បើព្រះនាង ប្រាថ្នានឹងចង់យកសំពត់សាដកប៉ុន្មានៗ ក្ដី ចូរចាប់ទាញជាយសំពត់ដែលចេញមកប្រាកដខាងក្រៅនេះចុះ នឹងកើតសំពត់សាដក យ៉ាងល្អវិសេសដូចចិត្ត មានតម្លៃនឹងកាត់

---

[១] ចតុលោកបាល ទេវតារក្សាលោកមាន៤អង្គគឺៈ កុវេរៈ(ឬវេស្សវណក៏ហៅ) ធតរដ្ឋ វិរូបក្ខ និងវិរុឡ្ហកៗ ទេវតាទាំង៤អង្គនេះជាអ្នកដឹងថា សត្វធ្វើល្អធ្វើអាក្រក់គ្រប់យ៉ាងៗ

ថ្ងៃមិនបាន ប្រមាណមិនកើត» ។ លុះព្រះបាទ វេស្សវណ មហារាជត្រាស់បង្គាប់ព្រះនាងសព្វគ្រប់ហើយ ក៏ស្ដេចចេញ ចាកទីនោះទៅ លុះដល់ព្រឹកព្រលឹមស្រាងឡើង ព្រះបាទ អសោកស្ដេចអង្គាសព្រះភិក្ខុសង្ឃដោយភោជនាហារដ៏ឧត្ដម បូជាដោយសុគន្ធបុប្ផាស្រេចហើយ ក៏ធ្មៀងព្រះនេត្រាទត មើលព្រះអគ្គមហេសីត្រាស់ថា «ចូរនាងយកសំពត់ប្រាំមួយ ហ្មឺនផាប់តាមដោយកំឡាំងបុណ្យរបស់ខ្លួនមក នឹងប្រគេន ដល់ព្រះសង្ឃប្រាំមួយហ្មឺនរូបនេះ»។ ព្រះរាជទេវី ក៏នាំយក ប្រអប់ទិព្វមក ទាញហូតយកសំពត់ ម្ដងមួយគូ ៗ ជាសំពត់ កាត់ថ្ងៃមិនបាន ហាក់ដូចជា សំពត់ទិព្វ ដែលកើតក្នុងដើម កល្បព្រឹក្ស ថ្វាយដល់ព្រះមហាក្សត្រិយ៍ ហើយក្នុងសំពត់ មួយផាប់ ៗ នោះល្មមបានចីវរមួយត្រៃ ៗ ព្រះមហាក្សត្រិយ៍ ទ្រង់ប្រទានដល់ព្រះសង្ឃថេរ ហើយទើបថ្វាយទួទៅគ្រប់ ព្រះសង្ឃទាំងប្រាំមួយហ្មឺនរូបដែលគង់នៅក្នុងទីនោះ ព្រះ សង្ឃទាំងអស់អនុមោទនា ហើយថ្វាយព្រះពរលាព្រះមហា ក្សត្រិយ៍ចេញទៅកាន់អាវាស។

ឯព្រះបាទអសោក ទ្រង់សព្វព្រះរាជហឫទ័យសប្បាយរីករាយ ស្មើចនឹងបុណ្យកុសល នៃព្រះនាងទេវី ត្រាស់ស្រស់ស្រាយ ដោយសេចក្ដីសោមនស្ស ទើបស្ដេច ទ្រង់ឈរក្នុងកណ្ដាលប្រជុំពួកស្រីស្នំដ៏រុងរឿង ដូចជាព្រះឥន្ទ្រ នៅក្នុងកណ្ដាលពួកស្រីទេពអប្សរ ក្នុងស្ថានសួគ៌ ហើយត្រាស់ ថា «នៃនាង! ខ្ញុំនបងនេះមានសេចក្ដីជ្រះថ្លា ក្នុងកុសលរបស់នាងពន់ពេក យើងដឹងច្បាស់ហើយថា កុសលនាងបានធ្វើទុកមកអំពីជាតិមុនពិត ទើបបានមកជួបប្រសព្វនឹងយើងៗធ្វើអាការកិរិយា ដល់នាងទាំងនេះ ដើម្បី នឹងល្បងកុសលរបស់នាងមើល នាងកុំតូចចិត្តឡើយ ចូរអត់ទោសចុះ ឥស្សរិយសម្បត្តិទាំងពួងនេះ យើងប្រគល់ឲ្យដល់នាងហើយ ចូរនាងជាធំចម្បង ជាងពួកស្រីស្នំទាំងមួយហ្មឺនប្រាំមួយពាន់នេះ ចាប់ដើមតាំងតែពីថ្ងៃនេះទៅ» ។

កាលព្រះបាទអសោក ប្រោសប្រទាន ឥស្សរិយយសដល់ព្រះនាង អសន្ធិមិត្តាអគ្គមហេសី ដូច្នេះ ក៏ស្រីស្នំទាំងឡាយ ដែលគាល់បំរើស្និទ្ធស្នេហានឹងព្រះបាទអសោក មាន

សេចក្ដីឫស្យា ពោលពាក្យនិន្ទាដល់ស្ដេច ព្រះមហាក្សត្រិយ៍ទ្រង់ជ្រាបហេតុនោះ ទើបត្រាស់បង្គាប់ឲ្យពួកអ្នកពិសេស ធ្វើនំឲ្យបាន មួយម៉ឺនប្រាំមួយពាន់ ហើយក្នុងនំមួយនោះ ទ្រង់បង្កប់ ព្រះទម្រង់ដ៏មានតម្លៃ កាត់ថ្លៃមិនបាន មួយវង់ ទើបត្រាស់ឲ្យហៅពួកស្រីទាំងនោះ ឲ្យចូលមកគាល់ព្រមគ្នា ព្រះអង្គត្រាស់ឲ្យស្រីស្នំទាំងឡាយ កាន់យកនំមួយម្នាក់ៗ ដើម្បីនឹងផ្សងមើលបុណ្យ ពួកស្រីទាំងនោះ តែឲ្យនាងអសន្ធិមិត្តាយកក្រោយគេបំផុត ហេតុតែបុណ្យនាង ក៏បានត្រូវជួបទៅលើនំ ដែលមានព្រះទម្រង់នោះ ទើបព្រះមហាក្សត្រិយ៍ ត្រាស់ឲ្យស្រីទាំងនោះបកនំឲ្យព្រមគ្នាក្នុងទីចំពោះព្រះភក្ត្រព្រះអង្គ ក៏ពួកស្រីឯទៀតបកមើលនំរបស់ខ្លួនៗទៅមិនឃើញមានវត្ថុអ្វី ក្នុងនំនោះ ឯនាងអសន្ធិមិត្តា បកនំទៅឃើញព្រះទម្រង់មួយវង់ កាត់ថ្លៃមិនបាន ប្រាកដច្បាស់ដល់ពួកនាងស្នំទាំង១ម៉ឺនប្រាំមួយពាន់នោះៗ ទើបព្រះបរមក្សត្រិយ៍មានព្រះរាជឱង្ការ ត្រាស់ថា: «ម្នាលនាងទាំងឡាយនាងរាល់គ្នាបានរើសយកនំមុននាងអសន្ធិមិត្តាៗ យកក្រោយ

ហេតុដូចម្តេច ក៏បានព្រះទម្រង់ទៅនាងអសន្ធិមិត្តា? ព្រោះដូច្នោះ ពួកនាងមិនគួរនឹងនិន្ទា ដល់នាងអសន្ធិមិត្តា ជាអ្នកមានបុញ្ញនិធិធ្វើទុកមកហើយក្នុងកាលមុននោះទេ ដែលជាស្រីអាចនឹងទទួលគ្រប់គ្រងឥស្សរិយសម្បត្តិបាន»។ ចាប់ដើមតាំងតែពីត្រឹមនោះមក ស្រីស្នំទាំងឡាយ ក៏នាំគ្នាស្ងៀមស្ងាត់វាចា មិនហ៊ានឫស្យាព្រះនាងអសន្ធិមិត្តាទៀតឡើយ កាលព្រះនាងអសន្ធិមិត្តានឹងសំដែងកុសលអំពីមុនឲ្យប្រាកដនោះ ព្រះនាងកាន់ប្រអប់ទិព្វ ដោយព្រះហស្តខាងឆ្វេង ចាប់យកសំពត់ទិព្វ ដោយព្រះហស្តខាងស្តាំ ហូតយកបានចំនួនមួយពាន់ផាប់ ថ្វាយដល់ព្រះមហាក្សត្រិយ៍ ហើយព្រះនាងបរិច្ចាគសំពត់ប្រាំរយៗ ដល់ព្រះរាជវង្សានុវង្ស ដល់ពួកស្រីស្នំ ដល់ពួក សេវកាមាត្យ ព្រមទាំង ចតុរង្គសេនា ទូទៅទាំងនគរ ព្រះបាទអសោករាជបពិត្រ បានជ្រាបហេតុអស្ចារ្យចម្លែកដូច្នោះ ទើបព្រះអង្គ ត្រាស់សួរព្រះនាង ថា: «ឱ! អសន្ធិមិត្តា នាងបានប្រអប់ទិព្វនេះមកអំពីទីឯណា ក៏អស្ចារ្យ

ចម្ងៃកម្ង៉ៃ ទាញយកសំពត់ទាំងសែន ក៏មិនចេះអស់សោះ?»។

ព្រះនាងអសន្ធិមិត្តាក្រាបបង្គំទូលតបថា: «បពិត្រមហារាជ កុសល ដែលខ្ញុំម្ចាស់បានសន្សំទុកហើយអំពីអតីតជាតិ ទើបដល់មកជាតិជាបច្ចុប្បន្ននេះបានជាកុវេរមហារាជ ដែលជាអ្នករក្សាលោក ទ្រង់ជ្រាបថា ខ្ញុំកំពុងមានទុក្ខព្រួយ គ្រាកាល ព្រះមហាបពិត្រ ដាក់ព្រះរាជអាជ្ញា ឲ្យរកសំពត់ប្រាំមួយម៉ឺន មកប្រគេនដល់ព្រះសង្ឃនោះ ក៏កុវេរមហារាជបានប្រាប់ខ្ញុំម្ចាស់ឲ្យរលឹកដល់កុសល ដែលបានថ្វាយសំពត់សាដកដល់ព្រះបច្ចេកពុទ្ធ អំពីបុព្វជាតិនោះ ហើយប្រទានប្រអប់ទិព្វនេះ ដល់ខ្ញុំម្ចាស់ ដែលជាប្រអប់ ឲ្យនូវសេចក្តីប្រាថ្នាដល់ខ្ញុំម្ចាស់ បានគ្រប់យ៉ាង ការឲ្យទានសំពត់សាដកមួយដល់ព្រះបច្ចេកពុទ្ធនោះ បានផលមកវិញយ៉ាងនេះឯង»។

# រឿងឲ្យធានដី

ខ្ញុំសូមទីពឹង នឹងព្រះភគវ័ត ព្រះអង្គ ជាអសេក្ខបុគ្គល ទ្រង់គង់ប្រថាប់នៅនាព្រៃឫស្សីកលន្ទក: ទៀបក្រុងរាជគ្រឹះ។

សម័យមួយ ជាពេលគួរព្រះភគវ័តទ្រង់ឃ្លុំចីវរ ហើយកាន់បាត្រ មានពួកភិក្ខុខាងមុខខាងក្រោយចោមរោមជុំវិញ ស្តេចយាងចូលសំដៅទៅក្រុងរាជគ្រឹះ ត្រាច់បិណ្ឌបាតតាមច្រកល្ហកក្នុងក្រុងនោះ។

មានសេចក្តីដំណាល ថា: «ព្រះអង្គ ជាបុគ្គលមិនរំភើបញាប់ញ័រ ហាក់ដូចជាភ្នំមាសមួយ ការយាងយាសរបស់ព្រះអង្គគួរឲ្យជ្រះថ្លា ហាក់ដូចជា ការយាងយាស នៃរាជកុញ្ជរ ទ្រង់មានព្រះភក្ត្រមូលក្រឡង់ ហាក់ដូចដួងព្រះចន្ទ្រាដ៏ពេញវង់[១] ទ្រង់មានភិក្ខុចោមរោមជាពួកៗ ទ្រង់យាងចូលទៅក្នុងព្រះមហានគររាជគ្រឹះ ឥរិយាបថព្រះអង្គក៏សមរម្យជាទីបំផុត»។

ព្រោះដូច្នោះ ព្រះអង្គ ទ្រង់ពុទ្ធដំណើរទៅដល់ទីក្រុង

---

[១] តាមអដ្ឋកថាប៉ែកខាងបាលីដែលអធិប្បាយពីមហាបុរិសលក្ខណ:ថា ព្រះពុទ្ធមានព្រះភក្ត្រដូចវង់ព្រះចន្ទ្រក្នុងថ្ងៃ១២កើត (គឺមិនពេញជាមូលសុទ្ធនោះទេ)។

នោះហើយ គ្រាន់តែដាន់ព្រះបាទទៅត្រង់មាត់ទ្វារនគរ ក៏កក្រើកប្រថពី ៦ដង ក្នុងពេលនោះៗ

មានសេចក្តីដំណាល ថា: កាលព្រះមហាមុនី ដាន់ព្រះបាទទៅត្រង់មាត់ទ្វារ ក៏ប្រថពី ដែលប្រដាប់ទៅដោយ មហាសមុទ្រព្រមទាំងភ្នំ និងទីក្រុង សព្វអន្ទើទាំងអស់ ក៏ប៉ោងខ្ពស់ឡើង ហើយទ្រោមចុះទៅវិញខ្លួនឯងៗ កាលដែល ព្រះអង្គយាងចូលទៅក្នុងក្រុង ដោយទំនងយ៉ាងនោះ ពួកជនប្រុសស្រីទើបកើតមានសទ្ធាជ្រះថ្លាដ៏បរិសុទ្ធរាល់ៗគ្នា ក្នុងក្រុងទាំងមូល ក៏ផ្អើលជ្រួលសូរគឹកកងរំពងទ្រហឹងអឺងអាប់ ហាក់ដូចជារលកនៃមហាសមុទ្រ គ្រាកាលដែលខ្យល់បក់ផ្ទប់មកជនទាំងនោះ នាំគ្នាបន្លឺសំឡេងដ៏ពីរោះរងំមុខគួរឲ្យស្រណោះហាក់ដូចជាមិនមានអ្វីក្នុងលោក ឲ្យលើសលប់ជាងទៅទៀតឡើយៗ ពេលដែលព្រះពុទ្ធជាម្ចាស់កំពុងយាងចូលទៅក្នុងក្រុងនោះ ទីទួល និងភ្នំតូចៗ ទាំងឡាយ ក៏រាបស្មើទៅឯងមិនឲ្យមានខ្សាច់ និងដុំគ្រួសដ៏រដិបរដុបសោះឡើយ បន្ទានិងគំនរសម្រាមទាំងឡាយ ក៏បាត់បង់អស់រលីងគេងពីលើផ្ទៃនៃ

ប្រថពី ពួកមនុស្សខ្វាក់ ក៏បានមើលឃើញឡើង ពួកថ្លង់ ក៏បានស្តាប់ឮឡើង ពួកគ ក៏បាននិយាយកើតឡើង ពួកខ្វិកគម ក៏បានដើរត្រង់ខ្លួនឡើង ពួកឆ្កួត ក៏ត្រឡប់បានស្មារតីឡើង ពួកអ្នកខ្សត់ទុគ៌ត ក៏មានសម្បត្តិទ្រព្យ បរិបូណ៌ឡើង ពួកអ្នកឈឺ ក៏ជាសះស្បើយ បាត់រោគទៅ ភ្លេងតូរ្យតន្ត្រីទាំងអស់ ក៏រោទិ៍ឮសូរស័ព្ទស៊ានទ្រហឹងអឹងកង ដោយឥតគេវាយគ្រឿងប្រដាប់ ដ៏មានតម្លៃក៏រណ្តំគ្នាឮសូរស័ព្ទស៊ានគ្រប់បែបគ្រប់យ៉ាង ព្រះរស្មីដែលចេញពីព្រះសម្មាសម្ពុទ្ធ ភ្លឺផ្សាយទៅគ្រប លើលោកសន្និវាសទាំងមូលដ៏ប្រសើរ លើសក្រៃលែងជាងព្រះអាទិត្យទាំងមួយសែន រស្មីនោះបំភ្លឺគ្រប់វត្ថុទាំងខាងក្នុងទាំងខាងក្រៅ ឲ្យមានពន្លឺ ហាក់ដូចជា ពណ៌នៃមាសវិស័យ ព្រះរស្មី ដែលផ្សាយពីព្រះសម្មាសម្ពុទ្ធ គ្របទៅលើពន្លឺព្រះអាទិត្យនិងព្រះចន្ទ្រ ហើយបំភ្លឺចាំងបាណកសត្វទាំងឡាយឲ្យមានសម្ផស្សដ៏ត្រជាក់ ធ្វើឲ្យបាណកសត្វទាំងឡាយនោះ មានបីតិសោមនស្សសប្បាយរីករាយជាទីបំផុតគ្រប់ៗគ្នាហាក់ដូចគេលាបស្រឡាប ដោយលំអិតចួងចន្ទន៍ក្រឹស្នាដល់

អ្នកមានជំងឺគ្រុនឲ្យបាត់ក្តៅក្រហល់ក្រហាយទៅបាន។

គ្រានោះឯង ព្រះភគវ័តមានព្រះអានន្ទជាបច្ឆាសមណៈ ព្រះអង្គយាងតាមផ្លូវ បានជួបនឹងកុមារ២នាក់ ម្នាក់ឈ្មោះជ័យ[១] ជាកូននៃមហាត្រកូល ម្នាក់ទៀតឈ្មោះវិជ័យ[២] ជាកូន នៃត្រកូលសុភាពរាបសា។ កុមារទាំងពីរនាក់នោះកំពុងតែប្របាច់ដីលេងជាមួយគ្នា វាសូនដីធ្វើជា ទីក្រុងមួយក្នុងក្រុងនោះ ធ្វើឲ្យមានដេរដាសទៅដោយទីគេហស្ថាន និងកោដ្ឋាគារទាំងឡាយ វាសូនដីនោះ ធ្វើជាគ្រាប់ស្រូវ ដាក់ពេញៗ កោដ្ឋាគារទាំងនោះ។ លុះកុមារទាំងពីរនាក់នោះ បានឃើញព្រះសម្មាសម្ពុទ្ធ ប្រដាប់ដោយ ទ្វត្តឹសមហាបុរិសលក្ខណៈ មានរស្មីពណ៌មាស ផ្សាយចេញព្រោងព្រាយ ភ្លឺពណ្ណរាយឆ្មៀលឆ្ងាត់ទៅទាំងក្នុងក្រុងទាំងក្រៅក្រុង ចាំងមកត្រូវវត្ថុទាំងឡាយ ក៏ក្លាយទៅជា ពណ៌លឿងដូចជាមាសទាំងអស់ មិនមានពណ៌អ្វីឲ្យភ្លឺលុបលាងបាន លុះឃើញ

---

[១] ជ័យកុមារដែលបានមកជាស្តេចអសោកចក្រពត្តិ។

[២] វិជ័យកុមារដែលបានមកជាសេនាបតីឯកឈ្មោះរាធគុប្តៈ។

ដូច្នោះហើយ ទើបមានចិត្តជ្រះថ្លា ក៏ជ័យកុមារចាប់យកដីដែលខ្លួនសន្មតថា គ្រាប់ស្រូវនៅក្នុងកោដ្ឋាគារនោះមួយក្តាប់ថ្វាយទៅព្រះភគវ័ត ដោយសេចក្តីគោរព។ វិជ័យកុមារ ជាសំឡាញ់បានលើកដៃឡើងប្រណម្យ ជួយអនុមោទនាដោយសេចក្តីពេញចិត្ត។ ក្នុងលំដាប់នោះ ជ័យកុមារបានសូត្រសរសើរគាថា: «លោកអ្នក ដែលពេញទៅដោយ មេត្តាចិត្តត្រាស់ដឹងខ្លួនឯង ដោយឥតសាស្តាណាប្រដៅ មានព្រះរស្មីមូលភ្លឺចិញ្ចែងជាពណ៌មាសឆ្អៀលឆ្អាត់ផ្សព្វផ្សាយ ព្រះសរីរៈព្រះអង្គ មានទឹកព្រះភក្ត្រដ៏ប្រកបដោយខន្តីនិងសោរច្ច គួរដល់សេចក្តីគោរព និងសេចក្តីជ្រះថ្លា ខ្ញុំសូមថ្វាយដីដល់ព្រះតថាគត ខ្ញុំសូមឱនសិរសាគោរព ចំពោះព្រះភក្ត្រ នៃព្រះភគវ័ត ចំពោះព្រះភក្ត្រលោកអ្នកដែលមានវដ្តសង្សារកំចាត់បង់ហើយ»។

គ្រាជ័យកុមារថ្វាយទានដីនោះ បានតាំងសេចក្តីប្រាថ្នាថា: «អំណឹះតទៅអនាគត ខ្ញុំសូមឲ្យលោកសន្និវាសទាំងមូល

តាំងនៅ ក្រោមស្វេតច្ឆត្ររាជ្យរបស់ខ្ញុំ[១] លុះសូត្រនូវគាថានេះហើយ ទើបថ្វាយនូវគ្រឿងបូជានោះទៅ មានសេចក្ដីដំណាលថាៈ

ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបថាៈ កុមារនោះ បានតាំងតម្កល់សេចក្ដីប្រាថ្នា ត្រឹមត្រូវក្នុងចិត្តល្អហើយ ពីព្រោះបានធ្វើទាន មកលើបុញ្ញក្ខេត្តដ៏ឧត្ដម នឹងមិនខានបានទទួលផលដ៏ប្រសើរនោះទេ។

ព្រះភគវ័ត ព្រះអង្គ ពេញទៅដោយមេត្តាចិត្ត លុះទ្រង់បានទទួលដីមួយក្ដាប់នោះហើយ មុនពេលដែលនឹងត្រឡប់មកវិញ ទ្រង់បានធ្វើអនុមោទនា ដល់កុមារនេះឯង ជាដើមហេតុដែលបណ្ដាលឲ្យកុមារនោះបានជាស្ដេច។

ពេលនោះ ព្រះភគវ័តព្រះអង្គទ្រង់ញញឹម។ ព្រះអានន្ទលុតជង្គង់លើកកំបង់អញ្ជលីប្រណម្យក្រាបទូលសួរថាៈ «បពិត្រព្រះភគវ័ត មិនមែនជាឥតហេតុឥតផលទេ ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់ញញឹម មានហេតុការអ្វីបានជា

[១] ឯកច្ឆត្រា ឬថវី ដាក់ផែនដីនៅក្រោមស្វេតច្ឆត្ររាជតែ១។

ព្រះអង្គសំដែងសេចក្តីញញឹមឲ្យប្រាកដឡើង?»។

គ្រានោះ ព្រះអានន្ទសូត្រនូវគាថានេះថាៈ

«លោក-អ្នក ដែលលះផុតស្រឡះ ចាកសេចក្តីសោកស្តាយ និងសេចក្តីរន្ធត់ដោយលោកធម៌ ហើយជាឯកអគ្គបុគ្គលក្នុងលោក មិនមែនឥតហេតុទេ ដែលទ្រង់នឹងបញ្ចេញព្រះទន្ត មានពណ៌ដ៏ដូចជាស័ង្ខ និងដូចជាក្រអៅឈូក។ បពិត្រព្រះអង្គ! ទ្រង់មានព្រះសូរសៀងហាក់ដូចជាផ្គរ កំពុងលាន់ឮចេញមកចាកពលាហក ព្រះអង្គមានព្រះនេត្រ ហាក់ដូចជាភ្នែក គោឧសភរាជ ខ្ញុំព្រះអង្គ សូមក្រាបបង្គំ ទូលសួរផលបុណ្យ នៃទានដីមួយក្តាប់នេះ ហើយនិងការដែលទ្រង់ធ្វើសេចក្តីញញឹមឲ្យប្រាកដនេះ»។

ព្រះសម្មាសម្ពុទ្ធ ទ្រង់មានព្រះបន្ទូលនឹងព្រះអានន្ទថាៈ «ឱ អានន្ទយ៉ាងហ្នឹងហើយ! យ៉ាងហ្នឹងហើយ មិនមែនឥតហេតុឥតផលទេ ការដែលព្រះពុទ្ធទាំងឡាយ ទ្រង់ញញឹមនេះ អ្នកបានឃើញកុមារពីរនាក់អម្បាញ់មិញនេះឬទេ?»។ ព្រះអានន្ទទូលតបថាៈ បពិត្រព្រះភគវ័ត! ខ្ញុំព្រះអង្គឃើញ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា: «មួយរយ[១]ឆ្នាំ អំពីតថាគតបរិនិព្វានទៅ កុមារនេះ នឹងបានជាស្ដេច មានបុញ្ញានុភាពអាចញ៉ាំងចក្រឲ្យប្រព្រឹត្តទៅ (ស្ដេចចក្រពត្តិ) ជាម្ចាស់លើទ្វីបមួយ ក្នុងទ្វីបទាំង៤[២] ជាស្ដេចទ្រង់សច្ចធម៌ ព្រះនាមព្រះអង្គថា អសោកក្នុងក្រុងកុសុមបុរៈ (បាតលិបុត្រ) ស្ដេចអង្គនោះ នឹងបានបែងចែក ព្រះសារីរិកធាតុ បានសាងព្រះស្តូប ៨៤.០០០ សុទ្ធសឹងតែវត្ថុមានតម្លៃ ដើម្បីជាប្រយោជន៍និងសេចក្ដីចម្រើន ដល់សត្វលោក»។

ពេលនោះព្រះភគវ័ត ទ្រង់ត្រាស់គាថានេះថា:

«ក្នុងកាលជាខាងក្រោយនៃនិព្វានតថាគតទៅ នឹងកើតស្ដេចអសោកឡើង កេរ្តិ៍ឈ្មោះរបស់ស្ដេចនោះ នឹងល្បីឮទូទ័រទៅក្នុងទីឆ្ងាយ ស្ដេចនោះនឹងបានរៀបតាក់តែងអដ្ឋិធាតុរបស់តថាគត ហើយបានចែកចាយ ពេញទួទៅទាំងជម្ពូទ្វីប មានពួកមនុស្ស ព្រមទាំងទេវតា កាន់យកគ្រឿងសក្ការៈ មកបូជា

---

[១] សៀវភៅពុទ្ធសាសនារបស់លោក ល្វី-ហ្វីណូត៍ថា ស្ដេចអសោកបានសោយរាជខាងក្រោយព្រះពុទ្ធបរិនិព្វាន២៦៦ឆ្នាំ។

[២] ទីវ្យាវទាន, ចតុភាគ៍ចក្រវត្តិន។

សារីរិកធាតុនោះ។ ការឲ្យដីបន្តិចនេះនឹងបានផលមកវិញដ៏ឧត្តមយ៉ាងនេះ»។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់គាថានេះហើយ ព្រះអង្គប្រទានដីមួយក្តាប់នោះ ទៅព្រះអានន្ទ ដើម្បីនឹងបាន បាចព្រាចទៅត្រង់ទីដែលព្រះតថាគតស្តេចយាងទៅ[១] គ្រានោះព្រះអង្គទ្រង់ត្រាស់ព្រះពុទ្ធដីការនេះថា «ឱអានន្ទ[២] ...»។

ក្នុងអតីតកាល ព្រះបាទពិម្ពិសារ បានសោយរាជ្យសម្បត្តិក្នុងក្រុងរាជគ្រឹះ ព្រះអង្គមានព្រះរាជឱរសដែលជាប់ជាតំណព្រះវង្សមក ទ្រង់ព្រះនាមអជាតសត្រូវ។

ព្រះបាទអជាតសត្រូវ មានរាជឱរស ទ្រង់ព្រះនាមឧទានភក្រ។

ព្រះបាទឧទានភក្រមានរាជឱរស ទ្រង់ព្រះនាមមុណ្ឌ។

ព្រះបាទមុណ្ឌមានរាជឱរស ទ្រង់ព្រះនាមកាកណ្ណី។

---

[១] ក្នុងអាយុវង់-កឹង អានន្ទលាយអាចម៍គោនឹងដីខ្សាច់មួយក្តាប់ដែលជ័យកុមារឲ្យនោះ ហើយបោះទៅត្រង់ផ្លូវច្រងនៃព្រះសម្មាសម្ពុទ្ធ។

[២] មានសេចក្តីពិស្តារទៅទៀត តែសៀវភៅច្បាប់ដើមមិនបាននិយាយ គ្រាន់តែចុចច្រើនជាគ្រឿងសំគាល់ថានៅមានតទៅទៀត។

ព្រះបាទកាកណ្ណវីមានរាជឱរស ទ្រង់ព្រះនាមសផល។

ព្រះបាទសផលមានរាជឱរស ទ្រង់ព្រះនាមតុលកុចី។

ព្រះបាទតុលកុចី មានរាជឱរស ទ្រង់ព្រះនាម សហមណ្ឌល។

ព្រះបាទសហមណ្ឌល មានរាជឱរស ទ្រង់ព្រះនាមប្រសេនជិត។

ព្រះបាទប្រសេនជិតមានរាជឱរស ទ្រង់ព្រះនាមនន្ទ[១]។

ព្រះបាទនន្ទមានរាជឱរស ទ្រង់ព្រះនាមវិន្ទុសារៈ។

ព្រះបាទវិន្ទុសារៈគ្រង់ក្រុងបាតលិបុត្រ ព្រះអង្គមានរាជឱរស ព្រះនាមសុសីមៈ[២] ត្រូវជា១២តំណ។

គ្រានោះ ក្នុងក្រុងចម្បាល មានព្រាហ្មណ៍ម្នាក់មានកូនស្រីមួយ ដែលបរិបូណ៌ដោយរូបសម្បត្តិដ៏ល្អសម នាងជាស្រី

---

[១] អាយុវង់-កឹង ស្តេចដែលតាំងក្រុងបាតលិបុត្រជាដំបូង ទ្រង់ព្រះនាមព្រះបាទចន្ទ្រគុប្តៈ ព្រះអង្គមានឱរសព្រះនាមវិន្ទុសារៈ ព្រះនាមថាចន្ទ្រគុប្តៈនេះ មិនមានក្នុងទិព្វាវទាន និងអាយុវង់-ជួនទេ ប៉ុន្តែពួកអ្នកប្រាជ្ញក្នុងទ្វីបអ៊ឺរ៉ុប ច្រើនដឹងថាចន្ទ្រគុប្តៈតាមអាយុវង់-កឹង។

[២] រាជសម្បត្តិមិនបានសុសីមៈនេះទេ គឺបានទៅអសោកជារាជឱរសដែរ តែក្នុងមហាវង្សហៅថាសុមនរាជកុមារ។

កែវ ហោរាចារ្យបានទាយដួងជាតារបស់នាងកាលពីថ្ងៃដែល នាងកើតមកថា «នាងកុមារិកានេះ នឹងបានជា អគ្គមហេសី នៃស្តេចអង្គមួយ ជាប្រាកដ នឹងបានជាទី សព្វព្រះរាជ ហឫទ័យ នៃព្រះរាជាអង្គនោះ ហើយនិងមានឱរសដែលល្បី កេរ្តិ៍ឈ្មោះពីព្រះអង្គ មួយព្រះអង្គ នឹងបានជាស្តេចចក្រពត្តិ គ្រប់គ្រងប្រថពីមណ្ឌល ជាម្ចាស់លើទ្វីបមួយ ក្នុងទ្វីបទាំង៤ មួយព្រះអង្គទៀត កាលបើចេញបួស ក្នុងព្រះពុទ្ធសាសនា ហើយ នឹងបានសម្រេចព្រះអរហត្តផល»។

ចំណែកព្រាហ្មណ៍ កាលបើបានស្តាប់ពាក្យទំនាយ ដូច្នោះ ក៏មានចិត្ត ពេញទៅដោយសេចក្តីត្រេកអរក្រៃពេក ទើបនាំធីតាចេញពីគេហស្ថានទៅកាន់ក្រុងបាតលិបុត្រ លុះ ដល់ព្រះនគរនោះហើយ ទើបតាក់តែងស្អិតស្អាងធីតានោះ ដោយគ្រឿងប្រដាប់ ដ៏ល្អប្លែកៗ ហើយនាំទៅថ្វាយដល់ ព្រះបាទពិន្ទុសារៈ ដើម្បីជាបាទបរិចារិកា ក្រាបទូលថា «សូម ព្រះរាជតេជៈ សូមព្រះអង្គទ្រង់ទតព្រះនេត្រចំពោះនាងដ៏ល្អ ព្រម»។ ព្រះបាទពិន្ទុសារៈក៏ទ្រង់ទទួលនាងទុកជារាជបរិពារ

ខាងក្នុង តែពួកនាងស្នំគំនាល់ ក្នុងព្រះបរមរាជវាំង ជាស្រី ប្រកបដោយសេចក្ដីឫស្យា វានាំគ្នាត្រិះរិះថា «នាងនេះមាន រូបល្អចំណាប់ កាលបើក្រឡេកមើលទៅ មុខគួរជាទីស្នេហា គ្រប់ៗគ្នា នាងជាមហាសិរីរបស់នគរ បើព្រះមហាក្សត្រិយ៍ ទ្រង់ទទួលទុកជាព្រះស្នំហើយ សមព្រះអង្គ នឹងសព្វព្រះរាជ ហឫទ័យចំពោះតែនាងជាប្រាកដ និងមិនទ្រង់ប្រោសប្រាណ ដល់ពួកយើងឡើយជាដាច់ខាត បើដូច្នេះយើងត្រូវបង្រៀន វិជ្ជាដ៏ថោកទាបដល់នាង ដើម្បីកុំឲ្យស្ដេច សព្វព្រះរាជ ហឫទ័យ» ទើបគេបង្រៀនវិជ្ជាខ្មាន់ព្រះកេសដល់នាង នាង ទើបមាននាទី ជាអ្នកតែងព្រះកេសា និងព្រះមស្សុ នៃព្រះ រាជា តាំងអំពីដើមមករហូតដល់មានសេចក្ដីស្ទាត់ជំនាញក្នុង សិល្បៈនោះ។ ថ្ងៃមួយ ពេលដែលព្រះរាជា កំពុងផ្ទំ គេប្រើ នាង ឲ្យចូលទៅ កោរព្រះមស្សុ ថ្វាយព្រះអង្គ លុះស្ដេចតើន ឡើង ចាកព្រះបន្ទំ ទ្រង់មានព្រះបន្ទូលថា «ចូរនាងកោរព្រះ មស្សុឲ្យអញ» នាងក្រាបបង្គំទូលថា «ពរម្ចាស់ ខ្ញុំម្ចាស់កោរ រួចស្រេចហើយ»។ ពេលនោះ ព្រះរាជាទ្រង់ទតទៅឯកញ្ចក់

ឃើញមែនដូច្នោះ ទើបទ្រង់ព្រះប្រណីនាងបានត្រាស់សួរថា «នាងត្រូវការចង់បានអ្វីខ្លះ?»។

នាងទូលស្នងវិញថា «សូមតេជៈ! ព្រះករុណាជាម្ចាស់ជីវិតលើត្បូង សូមទ្រង់ ប្រោសមេត្តា តាំងខ្ញុំម្ចាស់ ក្នុងទីជាមហេសីនៃព្រះអង្គ»។ ព្រះបាទវិន្ទុសារៈទ្រង់ប្រកែកថា «យើងជាក្សត្រិយ៍បានមុទ្ធាភិសេកហើយ នាងឯងជាស្រីជាតិថោកទាប នឹងឲ្យយើងតាំងនាងជាមហេសីដូចម្ដេចបាន?»។

នាងកុមារិកាទូលស្នងថា «ពរម្ចាស់ ខ្ញុំម្ចាស់មិនមែនជាធីតា មានជាតិដ៏ថោកទាបទេ ខ្ញុំម្ចាស់ជាធីតានៃព្រាហ្មណ៍ៗនោះបាននាំខ្ញុំម្ចាស់មកថ្វាយព្រះអង្គ ដើម្បីជាព្រះមហេសី។ តែពួកស្រីជាគំនាល់មានសេចក្ដីប្រចណ្ឌប្ញស្យា បានបង្ហាត់វិជ្ជាដ៏ថោកទាបនេះដល់ខ្ញុំម្ចាស់ បានជាខ្ញុំម្ចាស់តាំងនៅក្នុងដំណែងនេះរបស់ព្រះអង្គ»។

ព្រះរាជា ទ្រង់មានព្រះបន្ទូល ថា «ចាប់ដើមតាំងតែពីត្រឹមថ្ងៃនេះទៅ នាងកុំធ្វើកិច្ចនេះទៀតឡើយ»។

កាលគ្រានោះ ព្រះមហាក្សត្រិយ៍ ទ្រង់តម្កល់នាងទុកជា

មហេសីឯក ទ្រង់មានព្រះរាជហឫទ័យស្នេហាប្រោសប្រាណចំពោះនាង តមកព្រះនាងក៏ទ្រង់គភ៌ កាលគ្រប់កំណត់ហើយ ក៏ប្រសូតព្រះឱរសមួយអង្គ ព្រះរាជាបានធ្វើពិធីសម្ភោទរ្យនិងថ្វាយព្រះនាមព្រះឱរសដោយមហកម្មដ៏ធំ ពេលនោះទ្រង់ត្រាស់សួរព្រះនាងថា«នាងថ្វាយព្រះនាមព្រះឱរសដូចម្ដេច?» ព្រះនាងក្រាបទូលថា «កាលដែលប្រសូតនោះខ្ញុំម្ចាស់ មិនបានឈឺចាប់សោះ ព្រោះហេតុនេះ សូមថ្វាយព្រះនាមឱរសថាអសោក (ឥតសោក)»។ គ្រាខាងក្រោយតពីនោះមក ព្រះនាងបានប្រសូត ព្រះឱរស ទីពីរទៀត ព្រោះព្រះនាងមិនបានលំបាកអ្វី ក្នុងការប្រសូតសោះ ទើបថ្វាយព្រះនាមថា វីតសោក (ប្រាសចាកសេចក្ដីសោក[១])»។

ព្រះសរីរាវយវៈរបស់អសោករាជកុមារ មានសម្ផស្សរឹងគ្រោតគ្រាត ព្រោះដូច្នោះ ទើបមិនបានជាទីប្រោសប្រាណរបស់ព្រះបិតាឡើយ ព្រះបាទពិន្ទុសារៈ មានព្រះអគ្គមហេសី

---

[១] មហាវង្សថា: ព្រះមាតាអសោករាជឱរស ព្រះនាមនាងសិរីធម្មា ៗមានបុត្រពីរព្រះអង្គគឺអសោកមួយ តិស្សមួយ។

និងព្រះឱរសឯទៀតជាច្រើនអង្គ ថ្ងៃមួយ ទ្រង់មានព្រះរាជហឫទ័យនឹកក្នុកចង់ជ្រាបទំនាយដួងជាតាព្រះរាជកុមារទាំងអស់អង្គ ទើបត្រាស់ឲ្យហៅរាជបុរោហិតឈ្មោះបិលិង្គវត្សមក ហើយត្រាស់ថា: «ចូរអ្នកពិចារណា មើលដួងជាតាកំណើតរាជឱរសរបស់ខ្ញុំទាំងអស់នេះ តើឱរសណា នឹងបានជាស្តេច?»។ រាជបុរោហិតក្រាបបង្គំទូលថា: «បពិត្រព្រះសម្មតិទេព! សូមព្រះអង្គ នាំព្រះរាជកុមារទាំងអស់ ទៅកាន់រាជសុវណ្ណឧទ្យានឯណោះ ខ្ញុំព្រះអង្គនឹងពិចារណាមើលនូវព្រះរាជកុមារទាំងអស់នោះ ក្នុងទីនោះ»។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះរាជានុញ្ញាត ឲ្យនាំព្រះរាជកុមារ ទៅកាន់សួននោះហើយ ខណៈនោះព្រះរាជជននីបានត្រាស់នឹងអសោកកុមារថា «ម្នាលកូន ព្រះរាជាកំពុងទ្រង់ពិនិត្យ មើលទំនាយព្រះរាជឱរសទាំងឡាយរបស់ព្រះអង្គ នៅក្នុងសុវណ្ណឧទ្យាន ព្រះអង្គស្តេចយាងទៅមុនហើយ ចូរបាឯងទៅនឹងគេទៅកូន» អសោករាជកុមារតបថា «ស្តេចមិនទ្រង់ប្រោសប្រាណខ្ញុំទេ ព្រះអង្គនឹងមិនទតមកត្រង់ខ្ញុំឡើយ នឹងទៅក្នុងទីនោះ

តើមានប្រយោជន៍អ្វី?»។ ព្រះមាតាត្រាស់ថា«បើទុកជាយ៉ាង ណា ក៏ត្រូវតែឯងទៅ»។ អសោករាជកុមារទូលថា «បើដូច្នោះ ខ្ញុំទៅហើយ ព្រះមាតាឲ្យគេយកអាហារទៅឲ្យខ្ញុំផង»។

គ្រានោះ អសោករាជកុមារ បានលាព្រះមាតា ហើយ ស្ដេចចេញចាកព្រះនគរបាតលិបុត្រ ទតឃើញរាធគុប្តកុមារ ជាបុត្រ នៃសេនាបតីទី១ នៅកណ្ដាលផ្លូវ រាធគុប្តកុមារទូល សួរថា «ព្រះអង្គម្ចាស់ស្ដេចយាងទៅណាហ្នឹង?» អសោករាជ កុមារតបថា «ព្រះរាជបិតាទ្រង់ប្រជុំព្រះរាជឱរសទាំងឡាយ នៅទីសុវណ្ណឧទ្យាន ឥឡូវនេះ ខ្ញុំក៏ទៅក្នុងទីនោះដែរ»។ កាលនោះ រាធគុប្តកុមារជិះលើកុញ្ជរចាស់ជរាមួយ ក៏ក្រាប ទូលអសោករាជកុមារ ថា «ពេលនេះ ខ្ញុំព្រះអង្គ ក៏ទៅក្នុង ទីនោះដែរ សូមព្រះអង្គម្ចាស់ ទ្រង់គង់លើកុញ្ជរនេះ ជាមួយ នឹងខ្ញុំទៅ» ព្រោះដូច្នោះ អសោករាជកុមារ ទ្រង់ឡើងគង់លើ ដំរី ជាមួយនឹងរាធគុប្តកុមារ ស្ដេចយាងទៅកាន់ព្រះរាជ ឧទ្យាននោះ លុះដល់ហើយក៏ចុះចាកកុញ្ជរ យាត្រាទៅ ដោយព្រះបាទា ចូលទៅប្រថាប់លើផែនពសុធា នាទីជិតរាជ

កុមារទាំងឡាយ។ ក៏ពួករាជកុមារទាំងនោះ នាំគ្នាសោយអាហារដ៏ឧត្តម ប្រសើរប្លែកៗគ្រប់យ៉ាង ឯអសោកកុមារនោះសោយបាយបាយាស លាយដោយទឹកដោះគោ ដាក់ក្នុងភាជនៈដី ហើយនឹងទឹកសុទ្ធជាធម្មតា។ គ្រានោះ ព្រះរាជាមានព្រះបន្ទូល នឹងបុរោហិតថា «លោកអាចារ្យ ខ្ញុំសូមឲ្យលោកពិចារណាមើល ពិនិត្យពិច័យ ព្រះរាជកុមារ ឲ្យជាក់ច្បាស់ថា អ្នកណាអាចនឹងបានជាស្តេចគ្រប់គ្រងរាជអាណាចក្រក្នុងកាលជាអំណឹះឥតអំពីខ្ញុំទៅ?»។

រាជបុរោហិត ទើបពិចារណា មើលលក្ខណៈ ព្រះរាជកុមារទាំងឡាយ រំពឹងតែក្នុងចិត្តថា «ប្រាកដជាអសោកកុមារនេះឯង នឹងបានជាព្រះរាជា ប្រសិនបើអញ ក្រាបទូលថា អសោកកុមារ នឹងបានជាស្តេច ព្រះអង្គមិនសព្វព្រះរាជហឫទ័យ ចំពោះកុមារនោះសោះឡើយ ក៏នឹងអន្តរាយ ដល់ជីវិតរបស់អាត្មាអញមិនខាន» លុះរិះគិតដូច្នោះហើយ បុរោហិត ទើបក្រាបទូលព្រះរាជាថា «សូមតេជៈ ខ្ញុំព្រះអង្គនឹងទាយ ដោយមិនចំពោះព្រះនាម ព្រះកុមារ អង្គណាមួយ

ឡើយ» ខ្ញុំទាយទៅតាមឫកពាថា «ជោគជួងជាតារាជកុមារឯណា ដែលប្រើប្រាស់វត្ថុដ៏ឧត្តម ប្រសើរជាងគេបំផុត រាជកុមារនោះនឹងបានជាស្ដេច»។

ព្រះរាជកុមារ គ្រប់ព្រះអង្គ គិតស្មានតែក្នុងចិត្តរបស់ខ្លួនៗ មួយអង្គគិតថា អញមានពាហនៈប្រសើរ អញនឹងបានជាស្ដេច មួយអង្គគិតថា អញអង្គុយលើអាសនៈ ដ៏ប្រសើរ អញ នឹងបានជាស្ដេច មួយអង្គគិតថា អញបរិភោគអាហារដ៏ប្រសើរ អញនឹងបានជាស្ដេច មួយអង្គគិតថា អញប្រើប្រាស់ភាជនៈ ដ៏ប្រសើរ អញ នឹងបានជាស្ដេច មួយអង្គទៀត គិតថា អញ ផឹកទឹកដ៏ប្រសើរ អញ នឹងបានជាស្ដេច។ ឯអសោករាជកុមារ ត្រិះរិះក្នុងចិត្តថា «អញនឹងត្រូវបានជាស្ដេច ព្រោះកុញ្ជរជាពាហនៈដ៏ប្រសើរបំផុត ពសុធាជាអាសនៈដ៏ប្រសើរបំផុត បាយាស ជាអាហារដ៏ប្រសើរបំផុត ភាជនៈដីជាវត្ថុដ៏ប្រសើរបំផុត ទឹកដោះគោ ជាព្រះស្ងោយដ៏ប្រសើរបំផុត ទឹកសុទ្ធ ជាបានៈ ដ៏ប្រសើរបំផុត ខ្លួនអញនឹងឯង នឹងបានជាស្ដេច ព្រោះត្រូវសមគ្រប់វត្ថុទាំងអស់នេះ» រាជបុរោហិតក្រាបទូលទំនាយ

នេះស្រេចហើយ ព្រះរាជាក៏បញ្ជូនរាជកុមារទាំងអស់អង្គឲ្យស្តេចត្រឡប់មកព្រះនគរវិញ។

រាជបុរោហិត បានចូលទៅគាល់ព្រះមាតារបស់អសោករាជកុមារ ហើយទូលព្រះនាង ថា «ប្រាកដជាអសោកកុមារនឹងបានជាស្តេច»។ ព្រះមាតាអសោករាជកុមារត្រាស់ថា «ចូរអ្នកបិទរឿងនេះឲ្យជិត កុំនិយាយប្រាប់អ្នកណាមួយសោះឡើយ បើមិនថ្ងៃណា គង់ថ្ងៃណាមួយ ព្រះករុណាជាម្ចាស់ជីវិត នឹងត្រាស់ហៅអ្នក ទៅសួរដំណឹងនេះទៀតមិនខានហើយអ្នក នឹងត្រូវអន្តរធានដល់ជីវិត ព្រោះដូច្នោះ ត្រូវអ្នកចេញចាក រដ្ឋសីមាមណ្ឌលនេះ ទៅលាក់ខ្លួន ពួនអាត្មា នៅឲ្យឆ្ងាយ ផុតអាណាខេត្ត របស់ព្រះអង្គ ដើម្បីនឹងរក្សាជីវិតរបស់អ្នក បើបានឮដំណឹងថា អសោករាជកុមារ បានរាជសម្បត្តិហើយ សូមអ្នកត្រឡប់មកវិញក្នុងពេលនោះចុះ»។

គ្រាខាងក្រោយមក នគរតក្កសិលា កើតបះបោរ ក្បត់កាប់សំលាប់គ្នា ជាចលាចលវឹកវរ ព្រះបាទវិន្ទុសារៈទើបទ្រង់ចាត់ឲ្យអសោករាជកុមារ ទៅបង្ក្រាបរៀបចំទីនោះ ទ្រង់

ត្រាស់ថា «ម្នាលកូន ឯងចូរទៅរៀបចំនគរតក្កសិលា» តែព្រះរាជាទ្រង់ព្រះរាជទាន ចំពោះតែកងទ័ព ព្រមដោយចតុរង្គិនីសេនា មិនបានព្រះរាជទានគ្រឿងសស្ត្រាវុធ និងរថសង្គ្រាមឡើយ។

ខណៈដែលអសោករាជកុមារ បានទទួលព្រះរាជឱង្ការហើយ លើករេហ៍ពលចេញចាកនគរបាតលិបុត្រ គ្រានោះពួកពល ដែលជាប់តាមព្រះអង្គទៅ បានទូលអង្វរ ឃាត់ថា «ពួកយើង មិនមានសស្ត្រាវុធទេ យើងនឹងធ្វើចម្បាំង តយុទ្ធនឹងពួកខ្មាំងដូចម្ដេចបាន?»។

អសោករាជឱរស មានព្រះបន្ទូលថា «ប្រសិនបើបុញ្ញានុភាព ដែលបណ្ដាលឲ្យយើងខ្ញុំ បានរាជសម្បត្តិមែន ខ្ញុំសូមឲ្យគ្រឿងសស្ត្រាវុធ ដែលយើងត្រូវការនោះ កើតមានឡើងឯងៗ ក្នុងកាលឥឡូវនេះ»។ ត្រាស់មិនទាន់ផុតពីព្រះឱស្ឋ ក៏ពួកភូមិទេវតា ជ្រែកមហាប្រថពី ស្ទុះស្ទាចេញមក នាំយកគ្រឿងសស្ត្រាវុធរាល់ដៃមកថ្វាយ។

គ្រានោះ ព្រះរាជឱរស ព្រមដោយចតុរង្គសេនា ស្ដេច

យាត្រាចូលក្រុងតក្កសិលា ជាឱឡារិកគួរស្ញែង ពួកអ្នកនគរនោះ កាលបានឮដំណឹងថា អសោករាជកុមារយាងមកដល់ក៏នាំគ្នា រម្ងាប់អធិករណ៍នោះទៅឯង ត្រឡប់ជានាំគ្នារៀបចំតាក់តែងកំពែងបុរី ស្អិតស្អាងថ្នល់ ប្រដាប់ទៅដោយគូ និងស្នាមភ្លោះ ដ៏ស្អាតល្អ ហើយនាំគ្នាយកភាជនៈ ដ៏ពេញទៅដោយគ្រឿងបណ្ណាការ និងក្អួងផ្កា ចេញមកទទួលព្រះរាជកុមារ ដើម្បីសំដែងសេចក្ដីចុះចូលនឹងព្រះអង្គ កាលទៅដល់ក្នុងទី ចំពោះព្រះភក្ត្រ ចំនួនចម្ងាយ កន្វះយោជន៍ ក៏នាំគ្នាស្រែកបន្លឺសំឡេងដ៏ស្រទន់ពីរោះក្រាបទូលថា«ពួកខ្ញុំព្រះអង្គនឹងបានគិតជាសត្រូវខ្មាំងតតាំងនឹងស្ដេចក៏ទេ ពួកខ្ញុំព្រះអង្គនឹងគិត តតាំងជាខ្មាំង នឹងព្រះរាជឱរស ក៏ទេដែរ តែពួកខ្ញុំព្រះអង្គ បះបោរ តទល់នឹងអាមាត្យកំណាចឯណោះ» ថាហើយ ក៏នាំគ្នាហែហម ចោមរោម អសោករាជកុមារ ថ្វាយគ្រឿងបណ្ណាការដោយសេចក្ដីគោរព ហើយស្ដេចយាង ចូលទៅកាន់ក្រុង តក្កសិលា ជាសុខសួស្ដី ដោយព្រះកិត្តិយសយ៉ាងធំអស្ចារ្យ។ អ្នកនគរទាំងនោះ លុះចុះចូលជារបៀប

រៀបរយ សាន្តត្រាណស្រួលបួលហើយ ទ្រង់ក៏ត្រឡប់ទៅក្នុងនគរព្រះអង្គវិញ។

ព្រះបាទវិន្ទុសារៈ បានបញ្ជូនអសោករាជកុមារ ឲ្យទៅបង្ក្រាបនគរខសៈម្តងទៀត ពួកអ្នកនគរនោះ ក៏បាក់បបខ្ចបខ្ចាចព្រះចេស្តា ចុះចូលដោយអាការដូចគ្នានឹងរឿងមុន ហើយទ្រង់ត្រឡប់ទៅក្នុងនគរព្រះអង្គវិញ។ មានអ្នកចំបាប់ខ្លាំងពូកែពីរនាក់ ចូលមកសុំនៅអាស្រ័យបម្រើអសោករាជកុមារ ទ្រង់ប្រទានមុខការ ឲ្យត្រួតត្រារក្សាអាណាខេត្តរបស់ព្រះអង្គដាច់ដោយឡែក។

ពេលនោះឯង ទេវតានិងភូមិទេវតាទាំងឡាយ ដែលជាអ្នកគ្រប់គ្រងព្រះរាជធានីនោះ បានប្រកាសសេចក្តីឲ្យឮប្រាកដដូច្នេះថា «ចូរអ្នករាល់គ្នាកុំបះបោរឡើយ ព្រោះអសោករាជកុមារ នឹងបានជាស្តេចចក្រពត្តិ ជាម្ចាស់នៃទ្វីបមួយក្នុងទ្វីបទាំង៤ មិនមានមនុស្សណាអាចហ៊ានតតាំងនឹងព្រះចេស្តាបាន ព្រះអង្គនឹងពង្រីកអាណាខេត្តឲ្យដល់ទីបំផុតនៃផ្ទៃប្រថពី ទៅទល់នឹងច្រាំងមហាសមុទ្រទាំង៤ ឲ្យតាំងនៅ

ក្រោមអំណាចព្រះអង្គ»។

ថ្ងៃមួយ ព្រះរាមនៃអសោករាជកុមារ ព្រះនាមសុសីមៈ ស្តេចត្រឡប់មក (អំពីការប្រពាតឧទ្យាន) ចូលទៅកាន់ក្រុង បាតលិបុត្រ ។ មានអគ្គមហាសេនាបតីម្នាក់ ឈ្មោះ ខល្វាតកៈ[១] កំពុងដើរ ចេញទៅអំពីក្រុង ទៅជួបនឹង សុសីមរាជកុមារ នៅកណ្តាលផ្លូវ សុសីមរាជកុមារ ឃើញ ក្បាលទំពែករលីង យ៉ាងដូច្នោះ ទ្រង់តាំងព្រះរាជហឫទ័យ នឹងសើចកំសាន្ត លេងសប្បាយ ក៏ទះក្បាលអគ្គមហាសេនា បតីនោះ នឹងព្រះហស្ត សេនាបតីនោះឃើញដូច្នោះហើយក៏ គិតថាៈ «ថ្ងៃនេះ ព្រះអង្គម្ចាស់មិនទាន់បានរាជាភិសេកនៅ ឡើយ ហ៊ានទះក្បាលយើងទៅហើយ ក៏កាលបើបានរាជា ភិសេកហើយ សមជាស្តេចនឹងកាត់ក្បាលយើង ដោយព្រះ ខ័នមិនខាន»។ ចាប់ដើមតាំងតែពីត្រឹមនោះមក ក៏អគ្គមហា សេនាបតីនោះ នាំរឿងកំហុសអាក្រក់របស់សុសីមរាជកុមារ មកនិយាយបរិហារ ប្រាប់ពួកសេនាបតីទាំង ៥០០នាក់ ថា

---

[១] ខល្វាតកៈនេះ មានក្បាលទំពែករលីង។

«សុសីមរាជកុមារ មិនសមគួរជាស្តេចសោយរាជ្យទេ ហោរាចារ្យបានទាយថា អសោករាជកុមារ នឹងបានជាស្តេចចក្រពត្តិ ជាធម្មិករាជ ព្រះអង្គគ្រប់គ្រង លើទ្វីបមួយក្នុងទ្វីបទាំង៤ ពួកយើងទាំងអស់គ្នា ត្រូវលើកព្រះអង្គនោះឲ្យបានរាជបល្ល័ង្ក»។

ខណៈនោះ ពួកអ្នកស្រុកក្នុងនគរតក្កសិលា កើតក្បត់បះបោរឡើងទៀត ដោយតាំងនៅក្រោមបង្គាប់ សេនាបតីកាចអាក្រក់ ក៏ព្រះរាជាចាត់បញ្ជូន សុសីមរាជកុមារ ឲ្យទៅបង្ក្រាបសត្រូវទៀត ក្នុងនគរនោះ តែមិនអាចនឹងរម្ងាប់ ឲ្យរៀបរយទៅបាន។ ព្រះបាទវិន្ទុសារៈ ទ្រង់ជ្រាបដូច្នោះ ក៏ព្រួយព្រះរាជហឫទ័យខ្លាំង ទៅជាប្រឈួន ទ្រង់ត្រាស់បង្គាប់ដល់ពួកសេនាបតី ឲ្យប្រគល់ រាជសម្បត្តិរបស់ព្រះអង្គ ទៅសុសីមរាជឱរស ហើយ ឲ្យអសោករាជកុមារ ទៅរម្ងាប់ពួកខ្មាំងនៅនគរតក្កសិលានោះទៀត តែពួកសេនាបតីទាំងនោះមានសេចក្តីពេញចិត្តនឹងអសោករាជកុមារ ក៏ប្រើកលឧបាយយកល័ខលឿង មកលាបស្រឡាបដងខ្លួនអសោករាជកុមារ ហើយលាយល័ខលឿងទុំ ដាក់ក្នុងភាជនៈ ដើម្បីសំដែងឲ្យ

ឃើញប្រាកដគ្រប់គ្នា ទើបទៅក្រាបទូល បំភាន់ព្រះរាជា ថា «អសោករាជឱរស ប្រឈួនជាទម្ងន់ណាស់ ក្អួតឈាមចេញមកពីព្រះឱស្ឋស្រស់ៗ មិនសមនឹងទ្រង់ចាត់ឲ្យទៅទទួលការនោះទេ»។

ពេលនោះ ព្រះបាទវិន្ទុសារៈ ប្រឈួន រឹងរឹតតែចម្រើនខ្លាំងឡើង មានព្រះកាយពល ថយណាស់ហើយ ព្រះអង្គយល់ច្បាស់ថា មិនទ្រង់គង់ព្រះជន្ម នៅបានតទៅទៀតទេ ក៏ពួកសេនាបតីឃើញដូច្នោះ នាំគ្នាតាក់តែងអសោករាជកុមារដោយគ្រឿងរាជ ឥស្សរិយយសគ្រប់ប្រការ ហើយនាំស្ដេចទៅគាល់ព្រះរាជាក្រាបទូលថាៈ «យើងខ្ញុំសូមឲ្យព្រះអង្គតាំងអសោករាជកុមារឲ្យទ្រង់គ្រងរាជបល្ល័ង្ក បណ្ដោះអាសន្នមុនសិន កាលបើព្រះសុសីមកុមារនឹងត្រឡប់មកអំពីក្រុងតក្កសិលាហើយ យើងខ្ញុំនឹងប្រគល់រាជសម្បត្តិថ្វាយជាក្រោយ»។

អសោករាជឱរសទើបផ្សងថា «បើរាជបល្ល័ង្កនឹងបានជារបស់ខ្ញុំដោយពិតមែនហើយ សូមឲ្យទេវតាបំពាក់មកុដរាជ្យលើក្បាលខ្ញុំចុះ»។ ពួកទេវតា បានឮពាក្យនោះ ក៏ឆ្លើយតប

មកព្រះអង្គវិញ ហើយទើបយកមកុដរាជ្យ បំពាក់ព្រះសិរ ថ្វាយ ក្នុងខណៈនោះ។ កាលឃើញ សេចក្ដីអស្ចារ្យរបស់ អសោករាជកុមារ ដូច្នោះ ព្រះរាជា ក៏ទ្រង់ព្រះក្រោធ ពិរោធ ខ្លាំង បណ្ដាលឲ្យព្រះលោហិតស្រស់ៗ ពុះពោរហូរចេញមក ចាកព្រះឱស្ឋព្រះអង្គ ហើយស្ដេច ទ្រង់សោយទីវង្គត ក្នុង ពេលនោះទៅ[១]។

លុះព្រះបាទអសោកបានរាជសម្បត្តិហើយ បានតាំង រាធគុប្តៈឲ្យធ្វើជាអគ្គមហាសេនាបតីទីមួយរបស់ព្រះអង្គ[២]។

ពួកយក្ស បាននាំគ្រឿងពលិកា រាជាភិសេក ប្រកាស ឡើងទៅលើប្រថពីបានមួយយោជន៍ ចំណែកនាគក៏ប្រកាស ចុះទៅខាងក្រោមប្រថពីបាន ១យោជន៍ដូចគ្នា ហេតុការណ៍ ទាំងនេះ បណ្ដាលឲ្យឮគ្រប់តំបន់ថា «ថ្ងៃនេះ រាជ្យនៃ

---

(១) សៀវភៅពុទ្ធសាសនារបស់លោកល្វី-ហ្វីណូត៍ ដែលលោកម៉ៅប្រែជាខ្មែរថា កាល ក្នុងរាជ្យព្រះបាទវិន្ទុសារៈជាបិតានោះ អសោកនៅជាឧបរាជ នៅស្រុកអវន្តី តាំងព្រះរាជ ដំណាក់នៅឧជ្ជយិនី អសោកបានយកធីតាសេដ្ឋីមួយនៅស្រុកវិទិសា សព្វថ្ងៃនេះហៅ ភិស្សនាមជាព្រះជាយា ហើយបានព្រះរាជបុត្រមួយឈ្មោះមហេន្ទ្រ និងព្រះធីតាមួយ ឈ្មោះសង្ឃមិត្រាដែលទៅមុខទៅនឹងបានជាសាស្ដាចារ្យនៅក្នុងស្រុកសីឡង់ (កោះលង្កា)។

(២) មហាវង្សបានតាំងព្រះតិស្សរាជកុមារដែលរួមឧទរជាមួយព្រះអង្គឲ្យជាព្រះឧបរាជ។

ព្រះបាទពិន្ទុសារៈ អស់ហើយ ព្រះបាទអសោក ស្ដេចឡើងប្រថាប់លើបល្ល័ង្ករាជ្យហើយ»។

ព្រះសុសីមរាជឱរស កាលទ្រង់សណ្ដាប់ថា ព្រះបិតាទិវង្គតហើយ អសោករាជកុមារបានមុទ្ធាភិសេកហើយដូច្នោះ ក៏ពិរោធខ្លាំង ស្ដេចត្រឡប់ចូលទៅកាន់នគរ បាតលិបុត្រ ដោយប្រញាប់ប្រញាល់។ ព្រះបាទអសោកជ្រាបថា សុសីមៈត្រឡប់មក ក៏ចាត់ឲ្យអ្នករក្សាព្រះអង្គដាក់អ្នកចំបាប់ម្នាក់ ឲ្យឈរចាំនៅទ្វារទី១ ម្នាក់ទៀតឲ្យឈរចាំនៅទ្វារទី២ ម្នាក់ទៀតឲ្យឈរចាំនៅទ្វារទី៣ ជាមួយនឹងរាជគុប្តសេនាបតី ចំណែកទ្វារខាងកើត ព្រះអង្គឯងស្ដេចគង់ចាំនៅទីនោះ នៅត្រង់ទីមុខទ្វារទិសខាងកើតនោះ ស្ដេចបានឲ្យធ្វើរូបដំរីសអំពីយន្តមួយ ឲ្យធ្វើរូបចម្លាក់ស្ដេចអសោកជិះលើខ្នងនោះ ទីជុំវិញដំរីនោះ បានឲ្យជីកគូធំៗ ក្នុងទិសទាំង៤ ខាងក្នុងដាក់ពេញទៅដោយរងើកភ្លើង ហើយពីខាងក្រៅ គ្របបិទបាំងដោយស្មៅ និងសម្រាមជិតជិតល្អរហូតទាល់តែភ្នែកមនុស្សធម្មតាមើលមិនយល់។

សុសីមរាជឱរស យាងសំដៅទៅទ្វារទីបី ក៏រាធគុប្ត សេនាបតីក្រាបទូលថា «ឥឡូវនេះ ព្រះបាទអសោកកំពុងទ្រង់គង់នៅទិសខាងកើត សូមព្រះអង្គយាងទៅតាមទ្វារទិសនោះចុះ ប្រសិនបើព្រះអង្គយាងទៅបានដូចសេចក្ដីប្រាថ្នា ខ្ញុំព្រះអង្គ សូមជ្រកកោណ ក្រោមម្លប់ព្រះបារមីផង ប្រសិនបើព្រះអង្គមិនអាចនឹងបង្ក្រាបព្រះបាទអសោកបានទេ ព្រះអង្គនឹងមិនអាចយាងចូលតាមទ្វារនេះបានទេ»។

លុះព្រះសុសីមរាជកុមារទ្រង់ជ្រាបដូច្នោះ ក៏ស្ដេចយាងទៅកាន់ទ្វារ ទិសខាងកើត ទតឃើញដំរី និងរូបចម្លាក់នោះហើយ ក៏ខំប្រឹងរុករាន ទន្ទ្រានចូលទៅ ដើម្បីនឹងឡើងលើដំរី ហើយចាប់រូបចម្លាក់ព្រះបាទអសោកនោះ ក៏ធ្លាក់ចុះក្នុងរណ្ដៅគូដែលពេញទៅដោយរងើកភ្លើង ទ្រង់ក៏អស់ព្រះជន្មក្នុងទីនោះទៅ។

កាលបើសុសីមកុមារអស់ព្រះជន្មហើយ យក្សជាបរិវាររបស់ព្រះអង្គ ឈ្មោះកទ្រាយុធ ព្រមដោយពួកពលជាច្រើនពាន់ បានចូលបួស ក្នុងព្រះពុទ្ធសាសនា ហើយបានសម្រេច

មគ្គផលព្រះអរហត្តគ្រប់ៗព្រះអង្គទៅ។

ខាងក្រោយ អំពីព្រះបាទអសោកស្តេចទ្រង់រាជ្យ ពួកសេនាបតីក៏កើតសេចក្តីមើលងាយដល់ព្រះអង្គ ទើបទ្រង់រិះរកហេតុឧបាយកល ដោយការស្ងាត់ ដើម្បីនឹងផ្ចាញ់ផ្ចាលអស់ពួកអ្នកទាំងនោះ។ ពេលនោះ ទ្រង់ត្រាស់បង្គាប់ឲ្យពួកសេនាបតី កាប់ដើមឈើមានផ្លែ និងឈើមានផ្កាទាំងឡាយយកមកស្រះព័ទ្ធ ធ្វើជារបងនៃឈើមានបន្លា ជាការផ្ទុយគ្នាយ៉ាងនេះ។

ពួកសេនាបតី ទូលទទឹងទាស់ព្រះឱង្ការថា «តាំងតែពីដើមរហូតមកដល់ពេលនេះហើយ យើងដែលឮតែគេថា ស្រះព័ទ្ធសួនឈើមានផ្លែផ្កាដោយឈើមានបន្លា មិនដែលឮថាអ្នកណាស្រះព័ទ្ធឈើមានបន្លាដោយឈើមានផ្លែផ្កានោះសោះ»។

ពួកសេនាបតីទទឹងទាស់ មិនគោរពតាមព្រះរាជឱង្ការរហូតដល់៣លើក។

គ្រានោះឯង ព្រះបាទអសោក ទ្រង់ព្រះពិរោធដ៏លើសលុប ក៏ចាប់ព្រះខ័នឡើង ប្រហារជីវិតពួកសេនាបតីទាំង

៥០០នាក់នោះទៅៗ លំដាប់តមក ក្នុងរដូវផ្កាឈើ ដល់វេលាព្រឹក្សាជាតិបញ្ចេញផ្កា រីកស្គុះស្គាយគ្រប់ដើម ក៏ព្រះបាទអសោក មាននាងព្រះស្នំចោមរោមជាបរិវារ ស្តេចយាងយាត្រាទៅក្រសាលក្នុងរាជឧទ្យាន នៅក្នុងឧទ្យាននោះ មានដើមឈើមួយដើមឈ្មោះអសោក កំពុងតែផ្កាមានក្លិនកេសរក្រអូបឈ្ងុយឈ្ងប់ ទើបព្រះបាទអសោក ទ្រង់សព្វព្រះរាជហឫទ័យនឹងដើមឈើនោះ ព្រោះឈើនោះ មានឈ្មោះត្រូវនឹងនាមព្រះអង្គៗ បានពោលមកហើយថា ព្រះសរីរវយវៈរបស់ព្រះបាទអសោក មានសម្បុររឹងគ្រោតគ្រាត ហេតុនោះបានជាមិនពេញចិត្តនៃពួកស្រីព្រះស្នំ ដែលជាអ្នកត្រូវការដោយសម្បុរ លុះព្រះរាជាកំពុងផ្ទំលក់ នៅទីព្រះពន្លាក្នុងឧទ្យាននោះ ក៏ពួកស្រីព្រះស្នំដែលគាល់នៅខាងក្នុងនាំគ្នាត្រាច់ ដើរលេងសប្បាយ តាមអំពើចិត្ត ទៅក្នុងឧទ្យាន បានឃើញដើមអសោកនោះ ក៏បេះបោចផ្កា កាប់ទាំងមែកឈើនោះផង កាលព្រះរាជា ទ្រង់តើនឡើង ចាកព្រះបន្ទំ ទតឃើញដូច្នោះ ទើបត្រាស់សួរថា «អ្នកណាធ្វើបំផ្លាញដើមឈើ

នោះអស់?» រាជបរិពារក្រាបទូលថា «សូមទ្រង់ព្រះមេត្តាប្រោស ពួកស្រីព្រះស្នំ»។ កាលព្រះរាជា ទ្រង់ព្រះសណ្ដាប់ដូច្នេះហើយ ទើបទ្រង់ព្រះពិរោធខ្លាំង ត្រាស់ឲ្យចាប់ពួកស្រីព្រះស្នំ របស់ព្រះអង្គទាំង ៥០០ យកទៅតម្រៀបជុំវិញដើមឈើនោះ ហើយដុតភ្លើងទាំងរស់ស្លាប់ទាំងអស់គ្នាទៅ។ ពួកអ្នកនគរទាំងអស់ បានឃើញព្រះអង្គមានព្រះហឫទ័យខ្លាំងដូច្នោះ ទើបនាំគ្នាហៅព្រះអង្គថា «ចណ្ឌាសោក (អសោកកាច)»។

ខណៈនោះ រាធគុប្តៈ ជាសេនាបតីទី១ ទើបទូលតឿនព្រះរាជាថា «សូមព្រះរាជតេជៈ មិនជាការសមគួរ ដល់ព្រះអង្គ ជាស្ដេច ដែលធ្វើកម្មដូច្នោះ ដោយផ្ទាល់នឹងព្រះហស្តព្រះអង្គទេ ព្រះអង្គគួរតាំងបុរសឲ្យមាននាទីជាអ្នកពិឃាតមនុស្ស ដែលព្រះអង្គបានដាក់ព្រះរាជអាជ្ញា ហើយត្រូវពេជ្ឈឃាតនោះ ធ្វើតាមការពិភាក្សារបស់ព្រះអង្គ»។

ព្រះបាទអសោកក៏យល់ព្រមតាមពាក្យសូមនោះ ទើបមានព្រះឱង្ការ ចាត់ឲ្យបុរសម្នាក់ មានចិត្តក្លាហាន ដែល

ល្មមតាំងឲ្យធ្វើជាពេជ្ឈឃាតបាន។

គ្រានោះ មានជាងជម្បាញម្នាក់ តាំងផ្ទះនៅក្នុងបច្ចន្តគ្រាមជិតជើងភ្នំ ជាងជម្បាញនោះ មានកូនប្រុសមួយឈ្មោះ គិរិកៈ[១] មនុស្សនេះកាចជាទីបំផុត វាតែងធ្វើទុក្ខបុកម្នេញដេរពោលម្តាយឪពុកវាជានិច្ច វាកាន់លប់នៅដៃ វាដោតជង់ វាលាបថ្នាំពុលនៅលើស្នៅ និងស្ទឹកឈើទាំងឡាយពួកសត្វដើរទៅប៉ះពាល់ថ្នាំនោះ ពុលស្លាប់វិនាសជាអនេក។ ពួកអ្នកស្រុកទាំងអស់ គេប្រកាសប្រាប់គ្នាថា បុរសនោះកាចណាស់ ហើយក្នុងស្រុកទាំងមូល គេតែងហៅគិរិកៈនោះថា «ចណ្ឌគិរិកៈ[២])»។

រាជបុរសបានទៅជួបនឹងគិរិកៈ ហើយនិយាយថា «អ្នកឯងហ៊ានធ្វើជាពេជ្ឈឃាត របស់ស្តេចអសោក ឬទេ?»។ គិរិកៈ ឆ្លើយតបថា: «ប្រសិនបើឲ្យខ្ញុំធ្វើទោសផ្ចាញ់ផ្ចាលមនុស្សខូចកាច ក្នុងទ្វីបមួយទាំងមូល ក៏ខ្ញុំធ្វើបានដែរ មិនជា

---

[១] គិរិកៈជាឈ្មោះរបស់មនុស្សអ្នកនៅភ្នំ។

[២] មហាវង្សៈ មិនមាននិយាយដល់រឿងរ៉ាវគិរិកៈនេះទេ។

ការសំខាន់អ្វី នឹងធ្វើជាពេជ្ឈឃាត ទទួលការ សម្រាប់ស្តេចអសោកមួយប៉ុណ្ណោះ»។ រាជបុរស បានស្តាប់ពាក្យនោះហើយ ទើបត្រឡប់ទៅក្រាបទូល ព្រះមហាក្សត្រិយ៍ ព្រះអង្គទ្រង់ ឲ្យទៅនាំគិរិកៈនោះមក។ រាជបុរស ត្រឡប់ទៅដល់គិរិកៈវិញ និយាយប្រាប់ថា «មកគិរិកៈ ព្រះរាជាត្រាស់ឲ្យហៅអ្នកទៅ»។

ចណ្ឌគិរិកៈ ដឹងដូច្នោះហើយ ក៏ម្នីម្នាទៅសូមអនុញ្ញាតអំពីមាតាបិតា តែមាតាបិតា មិនព្រមបើកឲ្យ បានព្យាយាមហាមប្រាម ឃាត់មិនឲ្យធ្វើ ក្នុងដំណែងនេះ ក៏ចណ្ឌគិរិកៈសម្លាប់មាតាបិតាទាំងពីរនោះទៅ ទើបស្ទុះ ចុះពីលើផ្ទះមកខណៈនោះរាជបុរសសួរថាៈ «ហេតុដូចម្តេច បានជាយឺតយូរម្ល៉េះ?» ចណ្ឌគិរិកៈតបថាៈ «ម៉ែឪខ្ញុំគាត់មិនព្រមអនុញ្ញាតឲ្យខ្ញុំមកសោះ តែខ្ញុំសម្លាប់គាត់ទាំងពីរនាក់នោះទៅហើយហេតុនេះបានជាខ្ញុំយឺតយូរបន្តិច»។

ចណ្ឌគិរិកៈ និយាយរឿងរ៉ាវគ្រប់ប្រការឲ្យស្តាប់ហើយទើបចូលទៅគាល់ស្តេច លុះដល់ហើយក្រាបបង្គំទូលថាៈ

«សូមព្រះអង្គ សាងគុកមួយ ទុកជាមន្ទីរយុត្តិធម៌ ចាត់ជារបៀបល្អយ៉ាងសំខាន់ ឲ្យមានរូបរាងខាងក្រៅគួរជាទីសប្បាយរីករាយ នៃចិត្តអ្នកផងទាំងពួង កាលបើសាង មន្ទីរនោះរួចហើយ សូមឲ្យឈ្មោះថា: «គុកជាទីសុខសម្រាន្ត[១])»។

គ្រានោះ ចណ្ឌគិរិក: ទូលសូមពរព្រះរាជា ថា: «សូមតេជ:ព្រះអង្គ ចូរព្រះរាជទានពរមួយដល់ខ្ញុំព្រះអង្គ គឺបើអ្នកណាមួយក៏ដោយ តែចូលមកក្នុងមន្ទីរនេះ សូមទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គថា មិនត្រូវឲ្យអ្នកនោះ ចេញទៅវិញជាដាច់ខាត»។ ព្រះបាទអសោក ក៏ទ្រង់ប្រោសប្រទានពរឲ្យតាមសេចក្ដីសូមដូច្នោះ។

ខាងក្រោយពីនោះមក ចណ្ឌគិរិក: បានចូលទៅក្នុងវត្តកុក្កុដារាម ក្នុងវត្តនោះ មានភិក្ខុមួយរូបកំពុងស្វាធ្យាយពាលបណ្ឌិតសូត្រថា: «ពួកសត្វដែលចូលចិត្តនឹងទឹកពុះនៅក្នុងខ្ទះ ត្រូវគេបុកវានោះកំទេចដោយអង្រែ។ ពួកសត្វដែលចូលចិត្តគេបុកក្នុងត្បាល់ ត្រូវគេចំអិនវាក្នុងខ្ទះ។ ពួកសត្វដែល

---

[១] Prison-Agreable

នៅក្នុងនរក លេបដុំដែកធំមូល ហើយនាយនិរយបាលបង្អក ទឹកទង់ដែងក្តៅ ទៅក្នុងមាត់[១]។ កាលបើបានព្រះសេចក្តី នៃព្រះសូត្រនោះហើយ ចណ្ឌគិរិកៈទើបត្រិះរិះថាៈ «គុកអញ ត្រូវឲ្យមានវិធីបែបនេះចុះ»។

គ្រានោះមានគហបតីម្នាក់ព្រមទាំងភរិយា ទៅស្វែងរកវត្ថុដ៏មានតម្លៃ ដើម្បីចិញ្ចឹមជីវិតនៅទីសមុទ្រ ខណៈកំពុងត្រាច់ទៅ ក៏ភរិយាមានគភ៌ ហើយបានប្រសូតកូនប្រុសមួយនៅទីសមុទ្រនោះ ទើបឲ្យឈ្មោះបុត្រនោះថាៈ «សមុទ្រកុមារ»។ គ្រាកាលកន្លងមក១២ឆ្នាំ គហបតីនោះ ក៏នាំភរិយាចេញពីសមុទ្រត្រឡប់មកស្រុកកំណើតវិញ តែត្រូវពួកចោរសមុទ្រទាំង៥០០ ប្លន់ដណ្តើមយកទ្រព្យសម្បត្តិ ហើយវា

[១] ពាលបណ្ឌិតសូត្រសំស្ក្រឹត សេចក្តីប្រហែលគ្នានឹងទេវទូតសូត្របាលី ក្នុងគម្ពីរមជ្ឈិមនិកាយ។ ទេវទូតសូត្របាលីថា...ពួកនិរយបាលសួរថាៈ «ឯងប្រាថ្នាអ្វី» សត្វនរកតបថាៈ«ព្រះគុណអើយខ្ញុំឃ្លានណាស់»។ ពួកនិរយបាលយកដែកស្រួចដ៏ក្តៅកំពុងឆេះប្រាលផ្តៅភ្លឺរន្ទាលមកទល់មាត់សត្វនរកនោះ ហើយញាត់ដុំទង់ដែងដែលភ្លើងកំពុងឆេះសន្ធោសន្ធៅទៅក្នុងមាត់...។ ពួកនិរយបាលសួរទៀត សត្វនរកតបថាៈ«ព្រះគុណអើយស្រេកណាស់»។ ពួកនិរយបាលយកដែកស្រួចដ៏ក្តៅកំពុងឆេះប្រាលផ្តៅភ្លឺរន្ទាលមកទល់មាត់សត្វនរកនោះ ហើយបង្អកទឹកទង់ដែងដែលភ្លើងកំពុងឆេះសន្ធោសន្ធៅទៅក្នុងមាត់។

សម្លាប់គហបតីនោះទៅ។ គ្រានោះ សមុទ្រកុមារនៅកំព្រាតែម្នាក់ឯងអនាថា ទើបចូលទៅបួស ក្នុងព្រះពុទ្ធសាសនា។ លោកត្រាច់ស្វែងរកអាហារបិណ្ឌបាត គ្រប់ស្រុកតូចស្រុកធំ និគមជនបទរៀងៗទៅ រហូតដល់មកក្រុងបាតលិបុត្រ លុះឃុំចីវរជាបរិមណ្ឌលតាមសមណភេទហើយ ក៏ចូលទៅក្នុងក្រុងដើម្បីបិណ្ឌបាត លោកនិមន្តរៀងៗទៅ ស្រាប់តែចូលទៅក្នុងគុក ជាទីសុខសម្រាន្តនោះ ដោយមិនដឹងខ្លួនថាជាមន្ទីរអ្វី លុះឃើញដូច្នោះហើយ ទើបពោលពាក្យនេះថា: «ឱហ្ន៎! មន្ទីរនេះ ពីខាងក្រៅមុខគួរជាទីពេញចិត្តពេក តែខាងក្នុងហាក់ដូចជាស្ថាននរកសុទ្ធសាធសោះ»។ លុះភិក្ខុនោះនឹងត្រឡប់មកវិញ នាយចណ្ឌគិរិក:ឃាត់មិនឲ្យចេញ ហើយប្រាប់ភិក្ខុនោះថា: «ឥឡូវនេះ លោកត្រូវនៅក្នុងទីនេះ គឺត្រូវពិឃាតជីវិតបង់ លោកមិនត្រូវគេចចេញទៅណាទេ» ពាក្យពោលតែប៉ុណ្ណោះ ក៏ភិក្ខុនោះស្រែកទ្រហោយំ សោយសោកបរិទេវនាការឥតស្រាក ចណ្ឌគិរិក:ឃើញដូច្នោះ ទើបសួរថា: «ព្រោះហេតុអ្វីបានជាលោកស្រែកយំបែបដូចជាទារកដូច្នេះ»។

ភិក្ខុនោះតបថាៈ «អាត្មាមិនមែនយំសោកព្រោះខ្លាចសេចក្តីស្លាប់ដូច្នេះទេ គឺយំដោយស្តាយ ដោយការវិនាសបង់នូវសមណធម៌ដែលអាត្មាត្រូវបាន ព្រោះថាអាត្មាទើបនឹងបួសហើយថ្មីៗ មិនទាន់បានសម្រេចមគ្គផលអ្វីនៅឡើយសោះ។ ការបានអត្តភាពមកជាមនុស្ស ជាការបានដោយកម្រ ធម៌របស់ព្រះពុទ្ធ ជាសភាពក្របានជួបប្រសព្វ ព្រោះអាត្មា នឹកដល់រឿងនោះហើយ បានជាអាត្មាយំស្តាយ»។ ចណ្ឌគិរិកៈប្រាប់ថាៈ «តាំងពីយូរមកហើយ ព្រះរាជាជាម្ចាស់ជីវិតបានព្រះរាជទានពរឲ្យខ្ញុំថា បើមានមនុស្សចូលមក មិនត្រូវឲ្យចេញវិញទេ ត្រូវឲ្យប្រហារជីវិតក្នុងកំពែងនេះឯង»។

ភិក្ខុនោះនិយាយអង្វរថាៈ «អាត្មាភាព សូមឲ្យអ្នកអាណិត ទុកជីវិតអាត្មាបាន ៧ថ្ងៃសិន ខាងក្រោយពី៧ថ្ងៃនោះទៅ បើអ្នកចង់សម្លាប់អាត្មាភាពក៏សម្លាប់ចុះ»។ ចណ្ឌគិរិកៈក៏ព្រមអនុញ្ញាតឲ្យតាមសេចក្តីអង្វរ។

គ្រានោះ ព្រះបាទអសោកបានទតឃើញនាងស្នំ កំពុងចរចាដោយកាមរាគៈ ជាមួយនឹងព្រះអង្គម្ចាស់កំឡោះមួយ

ព្រះអង្គ ដែលជាសាហាយ លុះទ្រង់ ទស្សនាការដូច្នោះ ហើយ ក៏ទ្រង់ព្រះពិរោធ ទើបត្រាស់បង្គាប់ឲ្យនាំទាំងពីរនាក់ នោះ ចូលទៅក្នុងគុកជាទីសុខសម្រាន្ត តែមួយរំពេចនោះ ក៏ ចណ្ឌាគិរិកៈ បុកប្រំកំទេចគូពានរាំងទាំង២នាក់នោះ សំពង ក្បាលនឹងអង្រែដែក លៀនភ្នែក ក្រឡោតក្រលួងចេញមក ខាងក្រៅ។ ដោយការឃើញកម្មគួរស្ញែងយ៉ាងនេះ ភិក្ខុនោះ ទើបថ្លែងឧទានថាៈ «អា! ព្រះវាចារបស់ព្រះបរមគ្រូជាម្ចាស់ ព្រះអង្គ ពេញទៅដោយសេចក្ដីករុណា ទ្រង់ត្រាស់ដោយ បញ្ញាពិចារណាឃើញពិតថាៈ រូបរាងមិនមែនជារបស់រឹងប៉ឹង មាំមួនទេ មានសភាពដូចជាពពុះទឹក»។ រូបរាងនេះបែក ធ្លាយទៅដោយឆាប់រហ័ស ឥតមានបន្ទូរបន្ថយសោះឡើយ ឥឡូវនេះ រូបឆោមដ៏ល្អនោះ ទៅណាទៅហើយ? ទឹកមុខ ស្រស់ប្រិមប្រិយ និងឆវីវណ្ណទាំងអស់នោះក៏វិនាស សូន្យទៅ អស់ហើយ។ «ឱអនិច្ចា! ក្នុងរូបនិមិត្តនេះឯងហើយ ដែល ជាទីពេញចិត្តនៃពួកជនល្ងង់អប្បឥតប្រាជ្ញា ដែលមានគំនិត យល់ឃ្លាង ខុសគ្នានឹងធម៌របស់ព្រះសម្មាសម្ពុទ្ធ អាត្មាអញ

បានឃើញច្បាស់មែន ពិតតាមធម៌របស់ព្រះអង្គនោះហើយ នៅក្នុងផ្ទះ នៃនាយពេជ្ឈឃាតនេះ អាត្មាអញ នឹងមិនលិចលង់ចុះទៅក្នុងឱឃៈ គឺកាមគុណទៀតឡើយ»។

ក្នុងមួយរាត្រីទាំងមូលនោះ ភិក្ខុនោះ ពិចារណាឃើញត្រង់ តាមបរមពុទ្ធោវាទដូចខាងលើនេះ លោកបានទំលាយបង់នូវចំណង (សំយោជនៈ) ទាំងអស់ហើយ បានសម្រេចសោតាបត្តិផល ហេតុដូច្នោះ លោកខំព្យាយាមជាលំដាប់នៃមគ្គតទៅ ទើបបានសម្រេចដល់អរហត្តផល។

លុះអរុណរះឡើង ដល់ពេលគ្រប់៧ថ្ងៃកន្លងទៅហើយ ចណ្ឌគិរិកៈទើបនិយាយប្រាប់ភិក្ខុនោះថាៈ «កន្លង៧រាត្រីទៅហើយ ថ្ងៃនេះជាថ្ងៃទី៨ លោកនឹងត្រូវទទួលកម្មវេរានោះហើយ»

ភិក្ខុនោះ តបថាៈ «រាត្រីរបស់អាត្មាកន្លងផុតទៅហើយ ដួងព្រះអាទិត្យរបស់អាត្មា រះឡើងហើយ ពេលជាមង្គលមកដល់ហើយ អ្នកនឹងសម្លាប់អាត្មាក៏ធ្វើតាមប្រាថ្នាចុះ»។

ចណ្ឌគិរិកៈ ឃើញហេតុប្លែកអំពីថ្ងៃមុនដូច្នោះ ទើបសួរថាៈ «សំដីលោកនិយាយថា រាត្រីរបស់អាត្មាកន្លងផុតទៅ

ហើយ ដួងព្រះអាទិត្យរបស់អាត្មា រះឡើងហើយ ពេលជាមង្គលមកដល់ហើយ ចូរលោកអធិប្បាយពាក្យទាំងអស់នេះឲ្យសព្វគ្រប់មកមើល»។

ភិក្ខុនោះតបថា: «អាត្មាភាព ស្ថិតនៅក្នុងរាត្រី គឺអវិជ្ជាដែលរុំបិទជិត មិនឲ្យមើលពន្លឺអ្វីឃើញសោះ អកុសលទាំងឡាយ នាំចិត្តឲ្យក្រាញរួញរា ដែលជាចំណងដ៏មាំ គឺសំយោជនកិលេសនេះ ក៏អាត្មាភាពបានទំលាយបង់ជ្រះស្រឡះហើយ មិនបានត្រឡប់មករកអាត្មាវិញទេ ទាំងអស់នុ៎ះបានសេចក្តីថា: រាត្រីរបស់អាត្មា កន្លងផុតទៅហើយ ចិត្តរបស់អាត្មាផូរផង់ហើយដោយប្រាជ្ញា បានមើលឃើញច្បាស់នូវលោកទាំងបី ទាំងអស់នុ៎ះ បានសេចក្តីថា: ដួងព្រះអាទិត្យរបស់អាត្មារះឡើងហើយ។ កិច្ចដែលព្រះសម្មាសម្ពុទ្ធធ្វើហើយជាកិច្ចដែលអាត្មា បានបំពេញសព្វគ្រប់ហើយដែរ ទាំងអស់នុ៎ះបានសេចក្តីថា: ពេលជាមង្គលមកដល់ហើយ រាងកាយនេះ ក៏រស់នៅ មកយូរអង្វែងណាស់ដែរហើយ បើអ្នកចង់សម្លាប់អាត្មាក៏តាមតែចិត្តអ្នកចុះ»។

ចណ្ឌាគិរិកៈ ជាអ្នកប្រាសចាកសេចក្ដីករុណា មានចិត្ត រឹងរូសដូចថ្មសិលា បណ្ដាលទោសៈ ក្នុងអាត្មារឹងរឹតតែខ្លាំង ឡើង ឥតមានកោតក្រែងផលកម្មទៅអនាគត ក៏លើកខ្ទះធំ ដាក់លើជើងក្រានភ្លើង ក្នុងខ្ទះធំនោះមានទឹកដ៏ពេញលាយ ទៅដោយខ្លាញ់លោហិត ខួរក្នុងឆ្អឹង លាមក(អាចម៍) ទឹកមូត្រ និងកំទេចកំញមទាំងឡាយ ក៏ចាប់ភិក្ខុនោះ ឥតមានមេត្តា បោះទៅក្នុងខ្ទះធំនោះ ស្រែកប្រាប់មនុស្ស អ្នកដុតភ្លើងឲ្យ ប្រឹងខ្មីឃ្មាតយ៉ាងសម្បើម ពីខាងក្រោម ធ្វើយ៉ាងនោះហើយ ឱសនិងសម្រាមក៏ឆេះសន្ធោសន្ធៅឡើង តែមិនមានចំហាយ ក្ដៅដល់ភិក្ខុនោះសោះ សូម្បីតែបន្តិចបន្តួចក៏គ្មានផង នាយ ពេជ្ឈឃាត ឃើញដូច្នោះ ក៏ខឹង ឃោរឃៅនឹងអ្នកដុតភ្លើង ស្ទុះទៅវាយមួយដំបង ហើយដុតភ្លើងដោយដៃខ្លួនឯង ភ្លើង ក៏ឆេះ សន្ធោឡើងក្រៃលែងជាងមុន តែមិនមានកំដៅសោះ នាយពេជ្ឈឃាត រឹតតែខឹងខ្លាំងក៏បោចរោចគ្រឿងទព្វសម្ភារ មន្ទីរនោះ យកមកដុតលាយនឹងសំពត់ជាច្រើនផ្នត់ ភ្លើងក៏ ឆេះលើសលុបខ្ទះធំនោះ ប៉ុន្តែទឹកនៅតែត្រជាក់ដដែលដូច

មុន ក៏នាយពេជ្ឈឃាតនឹកស្ងើចនឹងហេតុអស្ចារ្យចំឡែកនោះ ក្រឡេកមើលទៅក្នុងខ្ទះឃើញភិក្ខុនោះ អង្គុយសមាធិលើផ្កាឈូកធំ មានត្របក មួយពាន់ស្រទាប់ ខណៈនោះ នាយចណ្ឌាគិរិកៈ មានសេចក្តីស្ញប់ស្ញែងចិត្តពន់ពេក ក៏រត់ទៅក្រាបទូលដល់ព្រះរាជាឲ្យទ្រង់យាងមកទតហេតុអស្ចារ្យនោះផង។

ព្រះរាជា ស្តេចយាងមកព្រមដោយបរិពារជាច្រើនពាន់ ទ្រង់ទំលាយកំពែងគុកជាទីសុខសម្រាន្តនោះ ដើម្បីពួកអ្នកនគរទាំងអស់ រាប់ដោយកោដិ នាំគ្នាចូល ទៅមើលភិក្ខុនោះបានដោយងាយ។ ពេលនោះភិក្ខុនោះបានជ្រាបថាៈ ឥឡូវនេះ ដល់ពេលដែលលោក គួរនឹងទូន្មានព្រះមហាក្សត្រិយ៍ឲ្យទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនាហើយ ទើបលោកសំដែងឥទ្ធិបាដិហារ្យផ្សេងៗច្រើនបែបយ៉ាង មានចីវរដ៏បរិសុទ្ធស្អាតចេញ ចាកខ្ទះដែលពេញទៅដោយ អបោធាតុ នាកណ្តាលប្រជុំជនដ៏ច្រើន ឲ្យបានឃើញគ្រប់ៗគ្នា លោកហោះទៅកាន់អាកាសវេហាស៍ ហើយ សំដែងបាដិហារ្យគ្រប់យ៉ាង ធ្វើឲ្យមានចំណែក ពាក់កណ្តាលដងខ្លួន របស់លោកខាងលើ

បង្កើតឡើងជាទឹកហូរ ចេញមកឥតស្រាក ចំណែកពាក់កណ្ដាលដងខ្លួនរបស់លោកខាងក្រោម បង្កើតឡើងជាភ្លើងឆេះភ្លឺច្រាលរន្ទាលពណ្ណរាយ ហាក់ដូចជាភ្នំមួយដ៏ធំ មានរស្មីភ្លឺឆ្អៀលឆ្វាត់រុងរឿងនៅនាកណ្ដាលអាកាសនោះ។

កាលទ្រង់ ទតឃើញភិក្ខុនោះ ហោះទៅក្នុងវេហាសប្រទេស ជាហេតុចំឡែក អស្ចារ្យគួរស្ញែងដូច្នោះ ព្រះរាជាក៏ទ្រង់ទតឆ្ពោះទៅខាងលើ លើកព្រះហស្តឡើងប្រណម្យដោយក្រពុំនៃអញ្ជលីជាទីគោរព ហើយទ្រង់មានព្រះបន្ទូលថាៈ «ភិក្ខុនេះ ដូចគ្នានឹងយើងសព្វគ្រប់អន្លើ មានរូបរាងកាយជាមនុស្សសាមញ្ញ តែឫទ្ធានុភាពនិងសេចក្ដីបរិសុទ្ធរបស់លោកចំឡែក អស្ចារ្យលើសលុបជាងមនុស្សធម្មតា លោកហោះឡើងលើអាកាសវេហាស៍ ហើយសំដែងឲ្យឃើញឫទ្ធិដ៏សម្បើមអស្ចារ្យ ហួសវិស័យនៃសត្វលោក។ ឥឡូវនេះ ខ្ញុំមិនទាន់ស្គាល់លោកម្ចាស់ទេ ប៉ុន្តែខ្ញុំសូមជ្រកកោន នៅក្នុងឱវាទដ៏វិសេសរបស់លោក ធ្វើដូចម្ដេចហ្ន៎? នឹងបានដឹងធម៌ដែលលោកម្ចាស់សំដែងដល់ខ្ញុំនោះ បើបានដឹងហើយ ខ្ញុំនឹងបាន

ប្រព្រឹត្តតាមដោយកម្លាំងនិងប្រាជ្ញារបស់ខ្ញុំ[១]»។

ខណៈនោះ ភិក្ខុបានដឹងច្បាស់ថាៈ ព្រះបាទអសោកជាមហាទានបតី១ ដែលនឹងអាច បានចែកចាយព្រះសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធ ដើម្បីជាប្រយោជន៍ដល់ទេវតានិងមនុស្សទាំងឡាយ ព្រោះដូច្នោះ ភិក្ខុនោះទើបថ្វាយវិសជ្ជនាដល់ព្រះបាទអសោកថាៈ «ព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានត្រាស់ថាៈ តថាគតមានករុណាដ៏ធំ ជាអ្នកកាត់បង់នូវបំណង គឺសំយោជនៈបាន។ អ្នកដែលប្រព្រឹត្តតាមធម៌ដ៏សមគួរដល់ធម៌ ឈ្មោះថា ជាឱរសនៃព្រះពុទ្ធត្រៃភព អ្នកនោះនឹងបានសម្រេចនូវអមតមហានិព្វាន។ ព្រះសម្មាសម្ពុទ្ធនោះព្រះអង្គឈ្នះដោយខ្លួនឯង ហើយញុំាងអ្នកដទៃឲ្យឈ្នះផងព្រះអង្គបានដល់ទីក្សេម ហើយញុំាងអ្នកដទៃឲ្យដល់ទីក្សេមផង ព្រះអង្គបានដល់នូវទីរំលត់ទុក្ខ ហើយញុំាងអ្នកដទៃឲ្យបានដល់ទីរំលត់ទុក្ខផង។ បពិត្រមហារាជ សូមទ្រង់ជ្រាបថាៈ ព្រះសម្មាសម្ពុទ្ធបានព្យាករទុកហើយ ដោយច្បាស់

---

[១] មហាវង្សៈ ព្រះបាទអសោកទ្រង់ជ្រះថ្លាជាដំបូង នឹងនិគ្រោធសាមណេរ។

លាស់ទៅក្នុងអនាគតថា ខាងក្រោយអំពីបរិនិព្វានរបស់តថាគតទៅមួយរយឆ្នាំ ទ្រង់នឹងបានសោយរាជ្យក្នុងក្រុងបាតលិបុត្រ មានព្រះនាមថា អសោក ទ្រង់នឹងជាស្តេចចក្រពត្តិ ជាធម្មិករាជ គ្រប់គ្រងទ្វីបមួយ ក្នុងទ្វីបទាំង៤ និងជាស្តេចប្រកបដោយសច្ចធម៌ បានចែកចាយ ព្រះសារីរិកធាតុព្រមទាំងបានសាងព្រះស្តូប ៨៤.០០០ សុទ្ធសឹងដ៏មានតម្លៃឱមហាបពិត្រ ឥឡូវនេះ ត្រឡប់ជាមានផលផ្ទុយគ្នាទៅវិញព្រះអង្គបានសាងគុកធំនេះ ដែលដូចជាស្ថាននរកសុទ្ធសាធទ្រង់បានបំផ្លាញជីវិតរាប់ចំនួនដោយពាន់មនុស្ស។ បពិត្រមហារាជ ឥឡូវនេះ សូមទ្រង់ព្រះរាជទានអភ័យឲ្យដល់សត្វលោកទាំងអស់ សូមទ្រង់ប្រព្រឹត្តបំពេញសេចក្តីប្រាថ្នា របស់ព្រះសម្មាសម្ពុទ្ធ សូមទ្រង់ព្រះរាជទានអភ័យដល់មនុស្ស និងទេវតាទាំងឡាយ សូមព្រះអង្គ ធ្វើមេត្តា ករុណាចិត្ត ឲ្យកើតឡើង ហើយសូមចែកចាយ ព្រះសារីរិកធាតុ និងជួយផ្សាយធម៌ពិតធម៌មែន ឲ្យចំរើនរុងរឿងធំទូលាយឡើង»។

ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ មានព្រះ

ហឫទ័យ យាងចុះកាន់ធម៌ របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គប្រកបដោយប្រសាទសទ្ធាជ្រះថ្លា ទ្រង់ប្រណម្យអញ្ជលីឡើងគោរពចំពោះព្រះឱរសរបស់ព្រះទសពល ទើបទ្រង់មានព្រះបន្ទូលថា: «អំពើរបស់ខ្ញុំពីមុនមក ជាកម្មដ៏អាក្រក់បំផុត សូមឲ្យលោកម្ចាស់ ទទួលអត់ទោស នៃបាបកម្មរបស់ខ្ញុំនោះ ពេលនេះ ខ្ញុំសូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក ខ្ញុំសូមដល់នូវព្រះធម៌ ជាជយមង្គល ដែលព្រះតថាគត ត្រាស់សំដែងហើយ ជាទីពឹងទីរលឹកហើយ[១] ចាប់ដើមតាំងតែពីត្រឹមថ្ងៃនេះទៅ ខ្ញុំនឹងផ្ដើមបំពេញតែការកុសល ខ្ញុំនឹងសាងព្រះស្តូបឲ្យបានដេរដាស នៅលើផ្ទៃនៃប្រថពីនេះ ដើម្បីជា បូជនីយដ្ឋាន ជាទីរលឹកដល់ព្រះអង្គ»។

គ្រានោះ ភិក្ខុនោះបានឃើញព្រះរាជាស្ដេចមានសទ្ធាបរិបូណ៌ហើយ ក៏ចេញចាកមន្ទីរនៃនាយពេជ្ឈឃាត ទៅតាមផ្លូវអាកាស ព្រះមហាក្សត្រិយ៍ក៏ស្ដេចចេញមកព្រមផង តែចណ្ឌគិរិក: ទូលឃាត់ព្រះអង្គថា: «កាលពីមុនព្រះអង្គបាន

---

[១] បាត់សង្ឃសរណៈមួយមិនឃើញក្នុងច្បាប់ដើម។

ព្រះរាជទានពរ ដល់ខ្ញុំព្រះអង្គថា បើអ្នកណាមួយ ចូលមកក្នុងគុកជាទីសុខសម្រាន្តនេះហើយ នឹងចេញទៅវិញពុំបានជាដាច់ខាត»។

ព្រះរាជាត្រាស់តបថា:«ឯងប្រាថ្នានឹងសម្លាប់យើងផងឬ?»

នាយពេជ្ឈឃាតទូលតបថា: «ព្រះករុណាវិសេស ទូលព្រះបង្គំជាខ្ញុំប្រាថ្នានឹងសម្លាប់ព្រះអង្គផង»។

ព្រះមហាក្សត្រិយ៍ត្រាស់សួរថា: «យើងទាំងពីរនាក់នេះ អ្នកណាចូលមកក្នុងទីនេះមុនគេ»។

នាយពេជ្ឈឃាត ក្រាបទូលថា: «គឺខ្ញុំព្រះអង្គនឹងឯង ដែលជាអ្នកចូលមកមុនគេ»។

ព្រះរាជា ត្រាស់ថា: «អើបើឯងចូលមកមុន ត្រូវតែអញសម្លាប់ឯងមុន»។

ខណៈនោះ ព្រះមហាក្សត្រិយ៍ទើបត្រាស់ឲ្យហៅរាជបរិពារមក ឲ្យចាប់ចណ្ឌគិរិកៈនាំយកទៅកាន់ទីពិឃាត ចណ្ឌគិរិកៈ ត្រូវនាយពេជ្ឈឃាតឯទៀតវាយ ផ្ចាញ់ផ្ចាលជាដំណំ ហើយទើបគរឧសបង្កាត់ភ្លើងដុតចណ្ឌគិរិកៈទាំងរស់ ឲ្យឆេះ

ជាធូលីក្នុងទីនោះទៅ។ ព្រះរាជាទ្រង់ត្រាស់ឲ្យទំលាយគុកជាទីសុខសម្រាន្តនោះ ហើយចាប់ដើម តាំងតែពីត្រឹមនោះមកទ្រង់ប្រទានអភ័យដល់សត្វលោកទាំងអស់។

គ្រានោះ ព្រះបាទអសោក ព្រមដោយចតុរង្គិនីសេនាស្ដេចយាងចូលទៅក្នុងក្រុងរាជគ្រឹះ ព្រះអង្គចាត់ឲ្យបើកព្រះស្តូបដែលព្រះបាទអជាតសត្តុរាជបានសាងទុកនោះ ទ្រង់ឲ្យគាស់កកាយ យកព្រះសារីរិកធាតុទាំងអស់នោះ ហើយព្រះអង្គឲ្យចែកចាយ ផ្សាយទៅស្ថានទីផ្សេងៗ តពីនោះមកទ្រង់ឲ្យសាងព្រះស្តូបមួយធំ នៅត្រង់កន្លែងដដែលនោះ។ ចំណែកទីឯទៀត ដែលមានបញ្ចុះព្រះសារីរិកធាតុ ទ្រង់ក៏ឲ្យគាស់កកាយយកជាលំដាប់មក នៅកន្លែងទី២ ទី៣។ល។ ទី៧ ព្រះអង្គ យកព្រះសារីរិកធាតុពីទីនោះៗទាំងអស់ដូចគ្នាតមក ស្ដេចយាងចូលទៅក្នុងស្រុក រាមគ្រាម ដែលជាទីសំណាក់អាស្រ័យ នៃស្ដេចនាគឈ្មោះសាគរៈ ដោយមានព្រះបំណងនឹងយកព្រះសារីរិកធាតុក្នុងទីនោះទៀត។

គ្រានោះ ស្ដេចនាគបានសំដែងកាយ ឲ្យឃើញប្រាកដ

ឡើង ហើយទូលអញ្ជើញ ព្រះមហាក្សត្រាធិរាជ ឲ្យស្តេច យាងចូលទៅក្នុងពិភពនាគ ហេតុដូច្នោះ ព្រះរាជាស្តេចយាង ចុះកាន់ព្រះទីនាំងនាវា ហើយចូលទៅក្នុងបុរីនៃស្តេចនាគ។

ស្តេចនាគ បានក្រាបទូលព្រះបរមក្សត្រិយ៍ថា: «សូម ព្រះរាជតេជ: ខ្ញុំព្រះអង្គ មានប្រាថ្នានឹងរក្សាទុកនូវព្រះសារី រីកធាតុនេះ សូមទ្រង់ព្រះមេត្តាប្រោស ព្រះរាជទានទុកឲ្យខ្ញុំ ព្រះអង្គ នឹងបានធ្វើសក្ការបូជាព្រះសារីរីកធាតុនេះផង សូម ព្រះអង្គស្តេចអនុគ្រោះកុំបីយករបស់ខ្ញុំព្រះអង្គទៅ»។

ព្រះរាជាទ្រង់ទតឃើញស្តេចនាគធ្វើសក្ការ: គោរពរាប់ អាន បូជាដោយគ្រឿងបូជា ចំពោះព្រះសារីរីកធាតុពីរដង មួយថ្ងៃ ឃើញថា ជាការវិសេស ថ្លៃថ្លាជាងពួកមនុស្សទៅ ទៀត ទើបទ្រង់ឲ្យទុកព្រះសារីរីកធាតុក្នុងព្រះស្តូបនោះ មិន បានយក ហើយស្តេចយាងត្រឡប់មកព្រះនគរព្រះអង្គវិញ។

លុះមកដល់ព្រះបរមរាជវាំងហើយ ទ្រង់បាន ឲ្យជាង សាងប្រអប់ ដ៏ប្រសើរ ៨៤.០០០ ប្រដាប់ដោយ មាស ប្រាក់ និងកែវពិទូរ្យ ក្នុងប្រអប់មួយៗនោះ ទ្រង់ឲ្យបញ្ចុះព្រះបរម

សារីរិកធាតុមួយគ្រាប់ៗ មិនតែប៉ុណ្ណោះសោត ទ្រង់ឲ្យសាង ក្អម ៨៤.០០០ និងគ្រប ៨៤.០០០ ដែលជារបស់មានតម្លៃ ហើយនិងសំពត់កម្ពល ៨៤.០០០ សឹងដ៏មានពណ៌ប្លែក ផ្សេងៗពីគ្នា ដើម្បីនឹងរុំវត្ថុដ៏មានតម្លៃទាំងនោះ។

ព្រះអង្គ ទ្រង់ព្រះរាជទាន ព្រះបរមសារីរិកធាតុឲ្យដល់ ពួកយក្ស ក្នុងម្នាក់ៗមួយគ្រាប់ ទ្រង់ត្រាស់ បង្គាប់ឲ្យដើរទៅ សព្វមណ្ឌល នៃជម្ពូទ្វីប ឲ្យយកទៅសាងព្រះស្តូប នៅកន្លែង គ្រប់ៗប្រទេស ដែលមានមនុស្សចំនួន មួយកោដិ កាលចាត់ ចែងដូចសំដែងមកនេះ យក្ស និងទេវតាទាំងឡាយ ក៏បាន នាំយកព្រះបរមសារីរិកធាតុទាំងអស់នោះ ដង្ហែទៅក្នុងទិស ទាំង៤ ដើម្បីនឹងសាងព្រះស្តូបទាំងនោះ។

គ្រានោះ មានយក្សម្នាក់ បានទទួល ព្រះសារីរិកធាតុ មួយគ្រាប់ ហើយនាំទៅកាន់នគរតក្កសិលា បំណងនឹងសាង ព្រះស្តូបមួយ នៅទីក្រុងនោះ តែពួកអ្នកប្រទេសនោះ បាន និយាយថា: «មនុស្សនៅក្នុងប្រទេសយើង មានចំនួន ៣៦កោដិ បើដូច្នោះ ត្រូវអ្នកឲ្យប្រអប់៣៦មកយើង»។

គ្រានោះ យក្សនិងទេវតាក៏ត្រឡប់មកក្រាបទូលសេចក្ដីនោះដល់ព្រះមហាក្សត្រិយ៍វិញ ព្រះអង្គមានព្រះតម្រិះថា: «មនុស្សទាំងឡាយ មានចំនួនច្រើនណាស់ ប្រសិនបើធ្វើតែយ៉ាងនេះ ព្រះបរមសារីរិកធាតុនឹងមិនបានផ្សាយទូទៅសព្វជម្ពូទ្វីបទាំងមូលទេ បើដូច្នោះ ត្រូវរកឧបាយនឹងបញ្ឈប់ការបែកចាយត្រឹមនេះ»។ ខណៈនោះ ព្រះរាជាទ្រង់ត្រាស់ឲ្យយក្សត្រឡប់ទៅប្រាប់ដល់មនុស្សទាំងនោះថា: «ក្នុងប្រទេសនេះ ត្រូវបន្ថយមនុស្ស ៣៥កោដិ ចេញ ឲ្យនៅតែត្រឹមមួយកោដិ ដែលនឹងត្រូវបាន ព្រះបរមសារីរិកធាតុមួយគ្រាប់ប៉ុណ្ណោះ»។

ពួកអ្នកស្រុកនៅក្នុងប្រទេសនោះ ភិតភ័យតក្កមា នាំគ្នានិយាយអង្វរថា: «ពួកយើងចង់បានប្រអប់៣៦នោះណាស់ទៅហើយ តែបើដូច្នោះ នឹងឲ្យប្រអប់តែមួយមកយើងក៏បាន សូមកុំឲ្យតែសម្លាប់ពួកយើង»។ គ្រានោះ ពួកយក្សក៏ព្រមតាមសេចក្ដីអង្វរ ហើយប្រគល់ប្រអប់ដែលដាក់ ព្រះសារីរិកធាតុនោះឲ្យមួយទៅ។

មានហេតុដូចខាងលើនេះ ព្រះរាជាទើបទ្រង់ត្រាស់ថា: «ក្នុងប្រទេសដែលមានមនុស្សច្រើនជាងពីមួយកោដិទៅ អ្នកចូរកុំឲ្យព្រះបរមសារីរិកធាតុ ឲ្យលើសទៅតាមចំនួនពួកមនុស្សនោះ ក្នុងប្រទេស ដែលមានមនុស្ស តិចជាងពី មួយកោដិទៅ អ្នកចូរកុំឲ្យព្រះបរមសារីរិកធាតុ ទៅប្រទេសនោះឡើយ»។ ទ្រង់មានព្រះបន្ទូលដូច្នេះហើយ ទើបស្តេចយាងចូលទៅវត្តកុក្កុដារាម លុះដល់ហើយ ទ្រង់យាងទៅជួបព្រះថេរៈព្រះនាមយស[១] ទ្រង់ប្រណម្យអញ្ជលីនមស្សការហើយត្រាស់ថា: «ឥឡូវនេះ ខ្ញុំមានប្រាថ្នា នឹងសាងព្រះស្តូប ៨៤.០០០ ដោយវត្ថុដ៏មានតម្លៃតម្កល់ទុកក្នុងជម្ពូទ្វីប»។

ព្រះថេរៈថ្វាយព្រះពរតបថា: «ប្រពៃហើយ! ប្រពៃហើយ! មហារាជ បើទ្រង់ប្រាថ្នានឹងសាងព្រះស្តូបទាំងអស់នោះឲ្យសម្រេចតែម្តង ក្នុងពេលមួយជាមួយគ្នា លុះដល់ពេលដែល មហាបពិត្រ កំពុងកសាងព្រះស្តូបនោះ អាត្មា

[១] មហាវង្ស ព្រះយសត្ថេរនេះ លោកជាអធិបតីក្នុងកាលធ្វើទុតិយសង្គាយនា ឯក្នុងគ្រាព្រះបាទអសោកនេះ គឺព្រះមោគ្គលីបុត្តតិស្សត្ថេរជាអធិបតីវិញ។

នឹងបាំងដួងព្រះអាទិត្យ ថ្វាយដោយបាតដៃ សូមចេញព្រះរាជានុញ្ញាតទៅក្នុងប្រទេសទាំងអស់ឲ្យបានដឹងថា ក្នុងពេលដែលអាត្មាភាព បាំងដួងព្រះអាទិត្យ ដោយបាតដៃ ត្រូវអ្នកទាំងអស់គ្នាសាងព្រះស្តូបឲ្យហើយស្រេចស្មើគ្នា»។

លំដាប់តពីនោះមក ព្រះថេរៈ បានបាំងដួងព្រះអាទិត្យដោយបាតដៃ ក៏អ្នកនគរទាំងឡាយ បានសាងព្រះស្តូបទាំងអស់នោះ ក្នុងពេលមួយជាមួយគ្នា គ្រប់ប្រទេស ក្នុងជម្ពូទ្វីបកាលសាងរួចស្រេចអស់ហើយ ពួកអ្នកនគរទាំងអស់បានថ្វាយព្រះនាមដល់ស្តេចថាៈ «អសោកធម្មិករាជ» ទ្រង់បានព្យាយាមផ្សាយសេចក្តីក្សេមក្សាន្ត ជាសុខសួស្តីទួទៅសព្វសត្វទាំងអស់ នៅលើផ្ទៃនៃភូមិប្រទេស ទ្រង់បានចារឹកព្រះស្តូបនិងព្រះវិហារទាំងឡាយ ក៏សេចក្តីល្អរបស់ព្រះអង្គរឹងរឹតតែចម្រើនធំទូលាយឡើង ព្រះនាមព្រះអង្គថាៈ «ចណ្ឌាសោក» ក៏វិនាសបាត់ទៅ ហើយក្នុងលោកទាំងមូល គេនាំគ្នាហៅព្រះអង្គថាៈ «ធម្មាសោក» ទៅវិញ។

កាលបើ ព្រះបាទអសោក សាងព្រះស្តូបរួចស្រេច

ហើយ ទ្រង់មានព្រះរាជហឫទ័យសោយបីតិ សប្បាយរីករាយពន់ពេក ព្រះអង្គ មានពួកសេវកាមាត្យជាច្រើនពាន់ចោមរោម ជាបរិពារ ស្ដេចយាត្រាទៅកាន់វត្តកុក្កុដារាម ទ្រង់ទៅថ្វាយបង្គំព្រះមហាថេរ ហើយត្រាស់សួរថា: «ក្នុងជម្ពូទ្វីបនេះ មានមហាជនជាច្រើន ក្រែងមានអ្នកណាមួយបានពុទ្ធទំនាយជាមួយនឹងខ្ញុំដែរឬទេ?»។

គ្រានោះ ព្រះយសត្ថេរថ្វាយព្រះពរព្រះមហាក្សត្រិយ៍ថា: «មនុស្សឯទៀតក៏បានពុទ្ធព្យាករជាមួយនឹងមហាបពិត្រដែរ»។ ក្នុងអតីតកាល ពេលដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រថាប់ នៅក្នុងរាជធានីឧទ្ទិយាននោះ ព្រះអង្គបានផ្ចាញ់នូវស្ដេចនាគ ឲ្យចុះចាញ់ព្រះអង្គ។ គ្រាកាលដែលទ្រង់ប្រថាប់នៅក្នុងរាជធានី កស្មីរៈនោះ ព្រះអង្គ បានញុំាងព្រាហ្មណ៍មហាសាល ឲ្យចុះចូលព្រះអង្គ។ គ្រាកាលដែលទ្រង់ប្រថាប់នៅក្នុងរាជធានី គន្ធារៈនោះ ព្រះអង្គបានញុំាង មនុស្សចណ្ឌាលឲ្យចុះចូលព្រះអង្គ។ គ្រាកាល ដែលទ្រង់ប្រថាប់នៅក្នុងរាជធានី គន្ធារៈដដែលនោះ ព្រះអង្គ បានផ្ចាញ់គោ

ឧសកភរាជ និងនាគរាជឲ្យចុះចាញ់ព្រះអង្គ លុះព្រះអង្គបាន ធ្វើសម្រេចកិច្ចដូចសំដែងមកហើយនោះ ទើបទ្រង់យាងទៅ កាន់រាជធានីមថុរាទៀត ទ្រង់មានព្រះពុទ្ធដីកានឹងព្រះអានន្ទ ថា: «ក្នុងមួយរយឆ្នាំទៀត រាជធានីមថុរានឹងមានគហបតី ម្នាក់ឈ្មោះគុប្ត: មានកូនប្រុសមួយឈ្មោះឧបគុប្ត: ៗនេះ បើ ទុកជាមិនមានទ្វត្តឹសមហាបុរិសលក្ខណ:ទេ ក៏គង់អាចធ្វើឲ្យ មនុស្សទាំងឡាយជ្រះថ្លា ចុះចូលដូចជាព្រះពុទ្ធមួយព្រះអង្គ ដែរ។ ឧបគុប្ត:នោះ មិនបាច់ចូលឈានសមាបត្តិ ក៏គង់អាច កំណត់ដឹងចិត្តគំនិតនៃសត្វលោកបានចំនួន មួយយោជន៍ លោកនោះ នឹងបានជាប្រធាននៃអ្នកទ្រទ្រង់ធម្មវិន័យទាំង អស់ ដោយការរៀបចំ ឲ្យបានត្រឹមត្រូវ ចំរើនល្អឡើងគ្រប់ យ៉ាង ខ្លួនលោកនោះ នឹងត្រូវទទួលកិច្ច ដែលជានាទីនៃព្រះ ពុទ្ធជាម្ចាស់បាន»។

ព្រះសម្មាសម្ពុទ្ធ ត្រាស់នឹងព្រះអានន្ទថែមទៀត ថា: «ឥឡូវនេះ អ្នកឃើញព្រៃនេះ កំពុងតែមានពណ៌ខៀវស្រស់ ខ្ចីឬទេ?» ព្រះអានន្ទក្រាបទូលតបថា «ខ្ញុំព្រះអង្គឃើញហើយ»។

ព្រះពុទ្ធកគវន្ត ទ្រង់មានព្រះបន្ទូលផ្ទួនទៀតថា «មានភ្នំមួយឈ្មោះឧរុមណ្ឌ និងមានទីអាស្រមជាស្ថានតាំងនៅក្នុងអារណ្យប្រទេសឈ្មោះ នដកដិកា បរិបូណ៌ដោយផ្ទះ និងមន្ទីរធំៗ ដែលជាប្រធាននៃទីកន្លែងឯទៀតទាំងអស់ ជាស្រុកដែលគេអាចធ្វើឈានសមាបត្តិឲ្យកើតបាន»។ ទំនាយនោះ និងទំនាយមហារាជទាំងពីរនេះហើយដែលព្រះពុទ្ធទ្រង់ទាយមក។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់ថេរៈវាចានេះហើយ ទើបត្រាស់នឹងព្រះថេរៈ ថាៈ «ព្រះមហាថេរ ដ៏បរិសុទ្ធអង្គនោះបានឧប្បត្តិឡើងក្នុងលោកហើយឬ?

ព្រះយសត្ថេរ ថ្វាយព្រះពរ តបថាៈ «លោកឧប្បត្តិហើយ លោកបានទាំងបំបាត់បង់នូវកង់តណ្ហា ជាគ្រឿងចងក្នុងភពទាំងឡាយ ហើយបានសម្រេច ព្រះអរហត្ត ហើយមានពួកព្រះអរហន្ត ១៨.០០០ ចោមរោមជាបរិវារ នៅលើភ្នំឧរុមណ្ឌ ក្នុងអារណ្យប្រទេសឈ្មោះ នដកដិកា(នោះ)។ ព្រះថេរៈអង្គនោះបានសម្រេចព្រះអរហត្តផល ព្រមទាំងបដិសម្ភិទាញាណ ដ៏បរិសុទ្ធផុតគ្រឿងសៅហ្មង លោកជាទីពេញចិត្ត

នៃពួកបណ្ឌិត ពួកអរហន្តនិងសត្វលោកទាំងអស់ លោកបានបើកទ្វារនៃព្រះធម៌ ដោយការទេសនារបស់លោក។ ពួកទេវតា (នាគ) យក្សមនុស្ស (និងពួកសត្វតិរច្ឆាន) ទាំងអស់សឹងតែបានចូលទៅក្នុងបុរីកែវ គឺអមតមហានិព្វាន ដោយសារតែគុណ គឺឱវាទរបស់លោក»។

ព្រះរាជា ទ្រង់ត្រាស់ទៅនឹងពួកសេនាបតីថា: «ចូរអ្នកទាំងឡាយ ប្រុងប្រៀបឲ្យប្រញាប់ត្រៀមទុកនូវពលរថ ព្រមដោយពល ថ្មើរជើង និងពលសេះ ពលដំរីផង យើងមានប្រាថ្នា នឹងឡើងទៅលើភ្នំ ឧរុមណ្ឌឥឡូវនេះ ដើម្បីនឹងបានឃើញ ព្រះថេរៈទាំងឡាយជាច្រើនពាន់ ដែលលោកបានសម្រេច ព្រះអមតមហានិព្វានហើយ ព្រមទាំងបានឃើញព្រះថេរៈ ឧបគុប្តៈ ដែលលោក បានផ្តាច់បង់នូវកិលេសវដ្តអស់ហើយនោះផង»។

ពួកសេនាបតីក្រាបទូល តបព្រះមហាក្សត្រិយ៍ ថា: «បពិត្រមហារាជ នគរនោះចង្អៀតពេក ចំណែកពួកពលយើងច្រើនណាស់ណាន់តាន់តាប់ គួរតែព្រះអង្គបញ្ជូនរាជ

ទូតម្នាក់ ឲ្យទៅនិមន្តព្រះឧបគុប្តៈនោះមក លោកក៏គង់តែនឹងនិមន្តមកមិនខាន»។

ព្រះរាជាត្រាស់ថាៈ «ត្រូវយើងទៅជួបនឹងលោក ព្រោះហេតុអ្វី? ព្រោះថា យើងមិនទាន់បានញាណដែលដូចជាពេជ្រ[១] (វជិរៈ) នៅឡើយ យើងមិនគួរបន្ទោកមនុស្សដែលមានភាពដូចជា ព្រះពុទ្ធនោះទេ»។ គ្រានោះ ព្រះអង្គទ្រង់បញ្ជូនរាជទូតទៅទូលព្រះថេរៈឧបគុប្តៈថាៈ «បពិត្រព្រះថេរៈពេលនេះខ្ញុំមានប្រាថ្នាចង់ទៅជួបនឹងលោកម្ចាស់ ចង់សាកសួរប្រស្នានឹងលោកម្ចាស់ផង»។

លុះរាជទូត ក្រាបទូលព្រះថេរៈ ដូច្នោះហើយ ក៏ព្រះថេរៈត្រិះរិះថាៈ «បើប្រសិនជាអាត្មាអញ បណ្ដោយឲ្យស្ដេចយាងមកក្នុងនគរនេះ ទីដីក៏ចង្អៀតពេក ហើយពួកមហាជនក៏ក្រីក្រលំបាកណាស់ផង គួរតែអាត្មាអញចូលទៅឯព្រះរាជដំណាក់វិញទើបស្រួល»។ ព្រះថេរៈចាត់ការប្រមូលទូកចង

[១] ក្នុងអាយុវង-កឹង: ប្រាជ្ញាព្រះឧបគុប្តៈមុតដូចជាពេជ្រ។ ក្នុងទិវ្យាវទានៈ ខ្លួនព្រះឧបគុប្តៈជាវិការៈនៃពេជ្រ។

គាបជាក្បូនដ៏ធំទូលាយ ចំនួន ១២យោជន៍ លោកឡើងជិះលើទូកឃ្នាបនោះ ព្រមទាំងព្រះអរហន្ត ១៨.០០០ ក៏និមន្តចូលទៅកាន់ក្រុងបាតលិបុត្រ ដោយព្រះកិត្តិយសដ៏រុងរឿង គ្រានោះ មានរាជបុរសម្នាក់ ចូលទៅក្រាបទូល ព្រះមហាក្សត្រិយ៍ថា: «ព្រះថេរៈឧបគុប្តៈនិមន្តមកដល់ហើយ ដើម្បីសេចក្តីចម្រើន និងជាប្រយោជន៍ដល់ព្រះរាជា លោកម្ចាស់អង្គនោះ មានបរិពារជាច្រើន ខ្លួនលោកជាចង្កូត នៃនាវាដ៏ធំរបស់លោកនោះ[១]។

កាលទ្រង់ ព្រះសណ្តាប់ ដំណឹងនោះហើយ ព្រះបាទអសោកមានព្រះរាជហឫទ័យសោមនស្សរីករាយ ទ្រង់ដោះព្រះសង្វារ អំពីព្រះសូរង ដែលជារបស់មានតម្លៃ មួយសែនតម្លឹងមាស ព្រះរាជទានជាថ្លៃរង្វាន់ដល់អ្នកថ្វាយដំណឹងនោះ។

ស្តេចទ្រង់ត្រាស់ បង្គាប់ឲ្យរាជបុរស ទូងគេរីប្រកាសដំណឹងថា: «អ្នកណា ដែលមានប្រាថ្នា ចង់បានសម្បត្តិដ៏ធំ

---

[១] ក្នុងទិវ្យាវទាន: ព្រះថេរៈនោះលោកជាចង្កូតនៃសាសនា។ ក្នុងអាយុ វង-កឹង: «ធម៌របស់ព្រះពុទ្ធដូចជានាវា។ ឱព្រះរាជា! ដោយធម៌ជាកុសលនឹងហើយ ដែលគេអាចឆ្លងបាននូវឱឃៈ គឺភពទាំងបី ហើយដល់នូវត្រើយគឺព្រះនិព្វាន»។

ក្នុងលោកនេះ ដែលចង់បានទៅកើតជាទេវតា និងអ្នកដែលប្រាថ្នា នូវអមតមហានិព្វាន ព្រមទាំងអ្នកចង់ឃើញ ព្រះតថាគត អ្នកទាំងឡាយនោះ ចូរមកជាមួយគ្នា ដើម្បីនឹងទៅធ្វើសក្ការបូជា ដល់ព្រះថេរៈ ឧបគុប្តៈ» ហើយទ្រង់សូត្រនូវគាថាតទៅនេះថាៈ «ពួកសត្វលោក ដែលប្រាថ្នា ចង់ឃើញព្រះថេរៈ លោកជាកំពូលនៃសត្វទ្វេបាទ លោកប្រកបដោយសេចក្តីករុណាដ៏ធំទូលាយ លោកជាអ្នកអង់អាច លោកជាអ្នកត្រាស់ដឹងខ្លួនឯង ដោយឥតគ្រូ ឱវាទរបស់លោកក៏ជាប្រទីបពន្លឺក្នុងត្រៃភព ដូចជាព្រះសម្មាសម្ពុទ្ធដែរ ក៏ពួកសត្វទាំងនោះ ចូរមកជួបជុំ រួបរួមគ្នាទាំងអស់ក្នុងទីនេះ ហើយយើងទៅជួបនឹងព្រះថេរៈអង្គនោះទាំងអស់គ្នា»។

កាលព្រះបាទអសោក បានសូត្រគាថា ប្រកាសដូច្នេះហើយ ទ្រង់ចាត់ការឲ្យរៀបចំ តាក់តែងទីក្រុង និងឲ្យលាងសំអាតគ្រប់ផ្លូវទាំងអស់ ហើយព្រះអង្គ មានពួកសេវកាមាត្យនិងពួកអ្នកនគរតាមហែហមចោមរោមស្តេចទៅ ព្រមដោយភ្លេងតូរ្យតន្ត្រី និងគ្រឿងក្រអូប មានគន្ធពិដោរ ឈ្ងុយឈ្ងប់

គ្រប់យ៉ាង ស្ដេចយាងចេញ ចាកក្រុងបាតលិបុត្រ ទៅតាមលំដាប់មាគ៌ា ទៅដល់ទីចំនួន កន្ទះយោជន៍។ ព្រះអង្គទតឃើញព្រះថេរៈ មានព្រះអរហន្ត ១៨.០០០អង្គ ចោមរោមហែ ជាជួរទាំងខាងស្ដាំ ទាំងខាងឆ្វេង ហាក់ដូចជា ដួងអឌ្ឍចន្ទ្រ (ព្រះចន្ទ្រមួយចំហៀង)។ ពេលនោះ ព្រះរាជា ចុះចាកព្រះទីនាំងដំរី ស្ដេចយាងដោយព្រះបាទ ទៅកាន់ប្រាំងទន្លេ ព្រះអង្គ ទ្រង់ឈានព្រះបាទម្ខាងទៅលើនាវា ព្រះបាទម្ខាងស្ថិតនៅលើផែនដី ទ្រង់ទទួលព្រះមហាថេរ ថ្នាក់ថ្នមដោយព្រះហស្ត នាំឡើងមកលើគោក ហើយក្រាបថ្វាយបង្គំដោយគោរព ប្រកបដោយ អង្គ៥ មានព្រះកាយ ផ្ទាល់នឹងផែនដី ព្រះអង្គ ជប់ព្រះបាទ ព្រះថេរៈ[១] ហើយទតសំឡឹង មើលដោយគោរព ចំពោះព្រះភក្ត្រ នៃព្រះមហាថេរ លើកព្រះហស្តឡើងប្រណម្យត្រាស់ថា: «ឥឡូវនេះ ខ្ញុំបានបង្ក្រាបសឹកសត្រូវអស់ហើយ ខ្ញុំបានធ្វើជម្ពូទ្វីប ដែលប្រដាប់ដោយទីក្រុងភ្នំ មហាសមុទ្រ គោគសម្ប័ទ និងមនុស្សទូទៅក្នុងលោកទាំង

---

[១] ក្នុងទិវ្យាវទាន និងអាយុ វង-កឹង លិខ្នូនូវព្រះបាទទាំងគូដោយព្រះជីវ្ហា។

មូល ឲ្យនៅក្រោមអំណាចខ្ញុំហើយ ។ ឱមហាថេរ! មិនមាន ពេលឯណា ដែលសប្បាយ រីករាយកន្លងហួសទៅហើយទាំង ប៉ុន្មាន ឲ្យមានសទ្ធាក្លាហានរីករាយចិត្ត ដូចជាឃើញលោក ម្ចាស់ច្បាស់នឹងចក្ខុ ក្នុងកាលឥឡូវនេះឡើយ ព្រោះហេតុអ្វី! បពិត្រព្រះមហាថេរ ព្រោះថា ឃើញលោកម្ចាស់ ក្នុងពេល នេះ ដូចជាឃើញព្រះសម្មាសម្ពុទ្ធដែរ»។

ដោយព្រះសទ្ធា រឹងរឹតតែចាស់ក្លាឡើង ហើយសេចក្តី គោរព ចំពោះព្រះរតនត្រ័យ ក៏កាន់តែចម្រើនឡើង ព្រះអង្គ ទើបទ្រង់ បន្លឺនូវគាថាតទៅនេះថា: «ឱព្រះថេរ:! ទុកជាព្រះ ពុទ្ធ ព្រះអង្គនោះ ចូលបរិនិព្វាន ហួសទៅហើយ គង់បាន លោកម្ចាស់ ដែលមានព្រះជន្មនៅជាជំនួសស្នងព្រះអង្គ។ ឱ ព្រះថេរ:! ព្រះពុទ្ធ ជាអាទិត្យវង្ស ទ្រង់អស្តង្គតទៅ លោក ម្ចាស់ បានទទួលរស្មីនោះ ធ្វើឲ្យភ្ជីពណ្ណរាយ រុងរឿងឡើង ឥឡូវនេះ ខ្ញុំសូមឲ្យលោកម្ចាស់ ឲ្យទានឱវាទ ដល់ខ្ញុំ ៗនឹង ប្រព្រឹត្តតាមឱវាទនោះ»។

គ្រានោះ ព្រះថេរ:ស្ទាបអង្អែលព្រះសិរព្រះមហាក្សត្រា

ធិរាជដោយព្រះហស្តខាងស្តាំ ហើយថ្វាយព្រះពរតបដោយគាថានេះថា: សូមព្រះអង្គកុំប្រមាទ សូមទ្រង់ តាំងព្រះរាជហឫទ័យភ័យ ខ្លាច (សេចក្តីទុក្ខ ក្នុងវដ្តសង្សារ) សូមទ្រង់ប្រយ័ត្ន កុំបន្ធូរបន្ថយ! ភាពជាស្តេច ព្រមទាំងព្រះរាជទ្រព្យជារបស់មិនយាយនឹងគ្រប់គ្រងទេ គ្រប់ៗគ្នាត្រូវតែទីពឹងព្រះនិព្វាន។ លោកនេះ មិនមែនតាំងនៅទៀងទាត់ទេ ព្រះរតនត្រ័យក៏ជាវត្ថុមិនងាយនឹងបានជួបប្រសព្វទេ បើបានជួបប្រសព្វហើយ សូមទ្រង់គោរពប្រតិបត្តិជានិច្ចកុំខាន។

«បពិត្រមហារាជ សម្តេចព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រទាននាទី ឲ្យព្រះអង្គ រក្សាព្រះធម្មវិន័យ ជាមួយនឹងអាត្មាភាព យើងគួរធ្វើសេចក្តីព្យាយាមជាមួយគ្នា ដើម្បីថែរក្សាគ្រប់គ្រងទុកឲ្យហ្មត់ចត់ នូវទ្រព្យជាមត៌កដែលព្រះអង្គប្រទានឲ្យ»។

ព្រះរាជា បានត្រាស់នូវគាថានេះទៀតថា: «ការដែលព្រះពុទ្ធដាក់ភារៈឲ្យខ្ញុំនោះ ខ្ញុំបានប្រតិបត្តិតាម ស្រេចហើយខ្ញុំបានប្រដាប់ តាក់តែងប្រថពីមណ្ឌល ដោយព្រះស្តូប និងព្រះវិហារដ៏វិចិត្រ ដូចជាអារណ្យប្រទេស ដ៏ដេរដាសទៅ

ដោយភ្នំទាំងឡាយ ខ្ញុំប្រកបដោយសទ្ធាចិត្ត បានតាក់តែងព្រះស្តូបទាំងនោះដោយទង់ជាយ ទង់ជ្រុង និងស្វេតច្ឆ័ត្រដ៏មានតម្លៃ ហើយខ្ញុំបានរំលេចក្បាច់ វិចិត្រដោយរតនវត្ថុដ៏ច្រើនប្រការ។ ដើម្បីនឹងធ្វើប្រដាប់ឲ្យបរិសុទ្ធល្អរុងរឿងថ្លៃថ្លាបំផុត រហូតពេញទាំងផែនប្រថពី ខ្ញុំបានបញ្ចុះព្រះសារីរិកធាតុក្នុងជម្ពូទ្វីបជាចំនួនច្រើន។ ខ្លួនខ្ញុំ ភរិយា បុត្រនិងធីតា កោដ្ឋាគារ(ឃ្លាំង) ព្រះរាជវាំងនិងព្រះរាជដំណាក់ ប្រជាជនជាចំណុះខ្ញុំ ព្រមទាំងផ្ទៃនៃផែនដីទាំងមូល ខ្ញុំសូមវេរប្រគេននូវវត្ថុទាំងអស់នោះ ដោយគោរពចំពោះទៅព្រះពុទ្ធព្រះធម៌ និងភិក្ខុសង្ឃ»។ ព្រះថេរៈថ្វាយព្រះពរសរសើរថាៈ ប្រពៃហើយ! ប្រពៃហើយ! មហារាជ! ទ្រង់ធ្វើដូច្នោះគួរហើយ។ បើនឹងប្រៀបផ្ទឹមគ្នាដោយរាងកាយ ដោយជីវិត ឬដោយទ្រព្យសម្បត្តិនោះ[១] ព្រះធម៌ថ្លៃជាសភាពរឹងប៉ឹងមាំមួនបំផុត ហេតុ

---

[១] តាមសៀវភៅលោកប្អូកនូហ្វដែលប្រែមកពីអាយុ វង់-កឹង បុគ្គលដែលទូន្មានរាងកាយរបស់ខ្លួនក្នុងសេចក្តីចម្រើនដ៏ល្អ និងប្រើវត្ថុជាគ្រឿងទំនុកបំរុងដល់ការចិញ្ចឹមជីវិតដ៏សមគួរ បុគ្គលនោះនឹងមិនសោយសោកក្នុងពេលជាទីស្លាប់ដោយគតិដ៏អាក្រក់ ហើយនឹងទៅកាន់ទេវលោកដែលជាទីប្រាថ្នា(របស់ខ្លួន)។

នេះបានជាគេលះបង់ឥតស្តាយ (របស់ទាំងនោះ) ហើយគេបានទៅកើតក្នុងទេវលោក។

ព្រះថេរៈ ថ្វាយព្រះពរយ៉ាងនេះហើយ ក៏ព្រះរាជាទ្រង់និមន្តព្រះថេរៈ ឲ្យចូលទៅក្នុងព្រះបរមរាជវាំង ទ្រង់ចាត់ឲ្យរៀបចំរ (គ្រែស្នែង) ហើយលើកព្រះថេរៈ ដោយកម្លាំងព្រះពាហារបស់ព្រះអង្គ ឲ្យគង់លើ រនោះ កាយព្រះថេរៈ មានសម្ផស្សដ៏ទន់ត្រជាក់ដូចជាសំឡី ព្រះរាជាប្រណម្យអញ្ជលីហើយត្រាស់នឹងព្រះថេរៈថា «កាយរបស់ព្រះថេរៈទន់ដូចជាសំឡី ឯខ្ញុំដែលមានកុសលតិចតួច ស្គួចស្តើង កាយរបស់ខ្ញុំគគ្រាតគគ្រើមមានសម្ផស្សដ៏រឹង»។

ព្រះថេរៈ ថ្វាយព្រះពរថាៈ «កាលពីអតីត អាត្មាភាពបានធ្វើគ្រឿងសក្ការបូជា តែវត្ថុដែលបរិសុទ្ធស្អាតរកអ្វីប្រៀបមិនបានជានិច្ច អាត្មាភាពមិនបានចាត់ចែងជុំជី ដើម្បីធ្វើគ្រឿងសក្ការបូជាឡើយ»។

ព្រះមហាក្សត្រិយ៍ ត្រាស់តបថាៈ «កាលពីអតីត ខ្លួនខ្ញុំជាទារក ជាមនុស្សស្លូតត្រង់តែល្ងង់ខ្លៅ ខ្ញុំបានជួបនឹងព្រះ

ពុទ្ធកគរ័ត ដែលជាបុញ្ញក្ខេត្តឥតខេត្តដទៃឲ្យត្រឹមស្មើ ហើយខ្ញុំបានថ្វាយដុំដីដល់ព្រះអង្គ ព្រោះវិបាកនៃកម្មរបស់ខ្ញុំនោះទើបបានមកជាយ៉ាងនេះឯង»។

ព្រះថេរៈ ប្រាថ្នានឹងបំបាត់វិប្បដិសារី របស់ព្រះរាជាទើបសំដែងទឹកព្រះភក្ត្ររាក់ទាក់ ស្រស់ស្រាយ ហើយថ្វាយព្រះពរថា: «លោកដែលជាបុញ្ញក្ខេត្តឥតខេត្តដទៃឲ្យត្រឹមស្មើ សូម្បីថ្វាយតែដុំដី ក៏អាចធ្វើផលឲ្យសម្រេចបានថ្កើងរុងរឿងថ្ងៃថ្លាយ៉ាងនេះ»។

ព្រះរាជា កាលបានទ្រង់ព្រះសណ្ដាប់នូវថេរវាចានោះហើយ ព្រះអង្គមានព្រះរាជហឫទ័យសប្បាយរីករាយ ដោយមិនធ្លាប់បានជួបប្រទះពាក្យនេះឡើយ ទើបទ្រង់អនុញ្ញាតឲ្យដល់ពួកសេនាបតីថា: «ព្រោះតែខ្លួនខ្ញុំបានធ្វើទានដោយដុំដីទើបខ្ញុំបានជាស្តេចចក្រពត្តិ បើដូច្នោះ ត្រូវតែយើងនាំគ្នាមានចិត្តព្យាយាម ធ្វើសក្ការបូជាដល់ព្រះរតនត្រ័យ»។

ព្រះមហាក្សត្រិយ៍ ត្រាស់នឹងព្រះថេរៈថា «ក្នុងកន្លែងដែលជាទីគោចរនៃព្រះពុទ្ធ ទីស្ថានដែលព្រះអង្គបានយាងទៅ

ហើយនិងទ្រង់អាស្រ័យនៅទាំងប៉ុន្មាន ខ្ញុំប្រាថ្នាចង់សាងព្រះស្តូបបូជាត្រង់ទីស្ថាននោះៗ ឲ្យបានសព្វអន្លើ ព្រោះហេតុអ្វី? ព្រោះថា សម្រាប់ពួកសត្វណា អ្នកមានសទ្ធាជ្រះថ្លាគោរពនមស្សការតទៅក្នុងអនាគត»។

ព្រះថេរៈ ថ្វាយព្រះពរសរសើរកុសលនោះថាៈ «ប្រពៃហើយ! ប្រពៃហើយ! មហារាជ! ពេលនេះត្រូវអាត្មាភាពទៅបង្ហាញទីស្ថានទាំងនោះថ្វាយព្រះអង្គ»។

ព្រះបាទអសោកបានទ្រង់នាំគ្រឿងសក្ការបូជា គឺសុគន្ធបុប្ផា ភួងមាលា គ្រឿងក្រអូប និងគ្រឿងលាបជាច្រើនយ៉ាងប្រគេនដល់ព្រះឧបគុប្តថេរ ទ្រង់ប្រជុំចតុរង្គិនីសេនាសព្វគ្រប់ហើយ ស្តេចយាងហែហម ព្រះឧបគុប្តថេរ ចូលកាន់សួនលុម្ពិនី ព្រះថេរៈ បានលើកព្រះហស្ត ចង្អុលបង្ហាញព្រះមហាក្សត្រិយ៍ថា «ត្រង់ទីនេះហើយព្រះអង្គ ជាស្ថានដែលព្រះពុទ្ធប្រសូតចាកព្រះឧទរព្រះមាតា»។ ព្រះស្តូបនេះ គេបានសាងមុនដំបូងបំផុត គឺត្រង់ទីនេះហើយ ដែលព្រះពុទ្ធជាឯកអគ្គបុគ្គល បានទ្រង់ព្រះដំណើរ ៧ជំហាន ក្នុងថ្ងៃ ដែលប្រសូត

នោះ ព្រះអង្គ ទ្រង់ទស្សនាការ គ្រប់ចំណែក នៃទិសទាំង ៤ ហើយលើកព្រះហស្តឡើង បន្ទឹឧទានវាចាថា: «នេះភពខាង ក្រោយបំផុតរបស់យើងហើយ»។

លុះទ្រង់ ព្រះសណ្តាប់ពាក្យនោះហើយ ព្រះមហាក្សត្រាធិរាជ ស្តេចធ្វើក្រពុំ នៃអញ្ជលី ប្រណម្យឡើង ប្រកបដោយ បញ្ចង្គប្រតិស្ឋាន ក្រាបផ្គាល់ចុះ លើផែនដីដោយសេចក្តីគោរព លើកព្រះហស្តឡើងប្រណម្យ ស្តេចទ្រង់ព្រះពិលាបហើយត្រាស់ព្រះគាថានេះថា: «បុគ្គលឯណាអ្នកបានឃើញព្រះមុនីភគវ័ត ឬពុំនោះសោត អ្នកបានឃើញព្រះពុទ្ធកាលដែលព្រះអង្គ ស្តេចមកកាន់លោកនេះ និងអ្នកដែលបានស្តាប់ព្រះសូរសៀង ដ៏ពីរោះរបស់ព្រះអង្គ ពួកបុគ្គលនោះ រមែងបានបុណ្យដ៏ឧត្តម ហើយបាន ផលប្រយោជន៍ជាទីក្សេមក្សាន្តចិត្ត។ ខ្លួនខ្ញុំជាមនុស្សឥតវាសនាដ៏ខ្លង់ខ្លស់ ខ្ញុំមិនបានឃើញព្រះភគវ័ត ខ្ញុំមិនបានឃើញគ្រាកាលព្រះអង្គប្រសូត ទាំងមិនបានស្តាប់ព្រះសូរសៀងដ៏ពីរោះរបស់ព្រះអង្គ»។

គ្រានោះ ព្រះឧបគុប្តថេរចង្អុលបង្ហាញព្រះបរមក្សត្រិយ៍

ត្រង់ស្ថានទី ដែលព្រះនាងមាយាទេវី ឈោងចាប់មែកឈើ ហើយប្រសូតព្រះពោធិសត្វមក ព្រះថេរៈលើកព្រះហស្ត ឡើង ប្រកាសបួងសួងរុក្ខទេវតា លោកអ្នកដែលបានឃើញ ព្រះពុទ្ធ ឥឡូវនេះត្រូវអ្នកសំដែងកាយរបស់អ្នក ឲ្យប្រាកដ ឡើងបង្ហាញព្រះមហាក្សត្រិយ៍ ដើម្បីឲ្យស្ដេចបានឃើញខ្លួន អ្នក ឲ្យព្រះអង្គទ្រង់មានព្រះរាជសទ្ធាចាស់ក្លាក្រៃលែងឡើង»។

គ្រានោះ រុក្ខទេវតា សំដែងកាយចេញមក ព្រះថេរៈ ឧបគុប្តៈ ថ្វាយព្រះពរស្ដេច ថាៈ «រុក្ខទេវតានេះ បានឃើញ ព្រះពុទ្ធគ្រាកាលព្រះអង្គប្រសូតចាកព្រះឧទរព្រះមាតា»។

គ្រានោះ ព្រះរាជា ទ្រង់ប្រណម្យព្រះហស្ត យាង ប្រទក្សិណរុក្ខទេវតា ហើយត្រាស់គាថានេះថាៈ «អ្នកបាន ឃើញព្រះអគ្គបុរស ប្រកបដោយសុភលក្ខណ៍ដ៏ស្រស់ បញ្ចង់ ក្នុងពេលដែលទ្រង់ប្រសូតចាកព្រះឧទរ ព្រះអង្គមាន ព្រះកាយប្រកបដោយអាការៈ និងអនុព្យញ្ជនៈ អ្នកបាន ឃើញព្រះនេត្រដ៏វែងទូលាយ ដូចជាត្របកនៃផ្កាឧត្បលដែរ ឬ? អ្នកបានឮព្រះវាចា ដ៏ទន់ពីរោះរបស់វីរបុរស ដូចជា

សំឡេងនៃគោឧសភរាជនោះដែរឬ»។

គ្រានោះ រុក្ខទេព្តា កាលដែលនឹងទូលតបមកវិញ បានពោលនូវគាថានេះថា: «ខ្ញុំបានឃើញព្រះអគ្គបុរស ព្រះអង្គ មានសម្បុរភ្លឺស្រស់ ដូចជាពណ៌នៃមាសឆ្អិន ព្រះអង្គប្រសើរបំផុតជាងសត្វទ្វេបាទទាំងឡាយ ទ្រង់បានលើកព្រះបាទឈានទៅ៧ជំហាន ខ្ញុំបានទាំងស្តាប់ព្រះសូរសៀងរបស់ព្រះភគវ័ត (នោះផង)«។

ព្រះមហាក្សត្រិយ៍ ត្រាស់សួរតទៅទៀតថា: «កាលដែលព្រះអគ្គបុរសទ្រង់ប្រសូត ព្រះអង្គប្រកបដោយសុភលក្ខណ៍ដូចម្តេចខ្លះ?»។

រុក្ខទេព្តាតបថា: «ព្រះអង្គមានព្រះសូរសៀងមិនអាចនឹងអធិប្បាយប្រាប់ឲ្យច្បាស់លាស់កើតឡើយ ពាក្យពេចន៍ទាំងនោះ មិនអាចនឹងសំដែងពន្យល់គ្នាបានទេ តែឥឡូវនេះខ្ញុំព្រះអង្គនឹងទូលដោយសេចក្តីបំព្រួញ»។ គ្រានោះ រុក្ខទេព្តាពោលគាថានេះ ថា: «ព្រះកាយរបស់ព្រះអង្គ ភ្លឺស្រស់បញ្ចង់ រុងរឿង ពណ្ណរាយ ដោយរស្មី នៃពណ៌មាស មុខគួរ

អស្ចារ្យ ពួកមនុស្ស និងទេវតា បានសោយបីតិ សប្បាយរីករាយ ដោយបានឃើញច្បាស់នឹងភ្នែក ឯផ្ទៃនៃប្រថពី ព្រមទាំងបព៌តទាំងឡាយ ក៏កក្រើករំភើបញាប់ញ័រ រហូតចុះមកដល់ឆ្នេរនៃមហាសមុទ្រ ហាក់ដូចជានាវា ត្រូវរលកបោកមកគ្រាំគ្រេងទៅកណ្ដាលសមុទ្រ»។

ព្រះរាជា បានបូជាទ្រព្យមួយសែនតម្លឹងមាស ទ្រង់ចាត់ឲ្យសាងព្រះស្តូបមួយ នៅត្រង់កន្លែងនោះ ហើយទើបស្តេចយាងចេញទៅទៀត។

ព្រះថេរៈបាននាំស្តេចតអំពីទីនោះ ទៅកាន់ក្រុងកបិលពស្តុ ក្នុងទីនេះ លោកបានលើកព្រះហស្តខាងស្តាំឡើងថ្វាយព្រះពរថាៈ «ត្រង់ស្ថានទីនេះហើយព្រះអង្គ ដែលគេថ្វាយព្រះបរមពោធិសត្វ ដល់ព្រះបាទសុទ្ធោទនៈ» ហើយនាំទៅបង្ហាញមន្ទីរ ដែលគេសម្រាប់ធ្វើសក្ការបូជា ដល់ទេវតាជារបស់នៃសក្យ ត្រង់គ្រាគេនាំព្រះបរមពោធិសត្វចូលទៅដើម្បីគោរពដល់ទេវរូបទាំងនោះ តែទេវរូបទាំងនោះ ដែលគេធ្វើអំពីឈើនិងដីឥដ្ឋក៏ត្រឡប់ជារំកិលចុះមក ធ្វើគោរព

នមស្សការលុតជង្គង់ ប្រណម្យចុះក្នុងទីចំពោះព្រះភក្ត្រព្រះពោធិសត្វវិញ។ ព្រះបាទសុទ្ធោទនៈ ជ្រាបហេតុដូច្នោះ ទើបថ្វាយព្រះនាមថា: «ទេវតាក្នុងពួកនៃទេវតា(១)»។ តពីនោះមក ព្រះថេរៈ បានបង្ហាញស្ថានទី ដែលគេ បានប្រជុំពួកព្រាហ្មណ៍មហាសាល ដើម្បីនឹងទាយលក្ខណៈព្រះពោធិសត្វ ហើយបានបង្ហាញ ស្ថានទីដែលអសិតតាបស(២) ពិចារណាមើលលក្ខណៈព្រះពោធិសត្វ ហើយឃើញថានឹងបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គជាប្រាកដ។ លំដាប់ពីនោះមក ព្រះថេរៈ បានបង្ហាញព្រះរាជា ត្រង់ស្ថានទី ដែលព្រះនាង បជាបតិ ចិញ្ចឹមរក្សា ព្រះពោធិសត្វ ហើយបង្ហាញស្ថានទី ដែលព្រះពោធិសត្វ បានសរសេរអក្សរ ក្នុងទី ដែលព្រះពោធិសត្វហាត់ ឡើងគង់យានដំរី ស្ថានទី ដែលព្រះពោធិសត្វ ហាត់ឡើងគង់យានសេះ ស្ថានទី ដែលព្រះពោធិសត្វ ហាត់ឡើងគង់ព្រះរាជរថ ស្ថានទី ដែលព្រះពោធិសត្វ ហាត់បាញ់ធ្នូ

---

(១) ទិវ្យាវទានៈ ទេវាតិទេវៈ អាយុ-វង់-កឹង: ទេវតាក្រៃលែងជាងទេវតាទាំងឡាយ។

(២) បឋមសម្ពោធិ, កាលទេវិលតាបស។ អសិតៈ ប្រែថាមិនស, កាឡៈ ប្រែថាខ្មៅ ជាឈ្មោះល្មមជំនួសគ្នាបាន។

ស្ថានទី ដែលព្រះពោធិសត្វ សំណាក់អាស្រ័យ ស្ថានទីដែល ព្រះពោធិសត្វទ្រង់ប្រថាប់ ជាទី ស្រស់ស្រាយជាមួយនឹងពួក ស្រីទាំង៦ម៉ឺន ស្ថានទី ដែលព្រះពោធិសត្វ ទ្រង់រំពឹង (ដល់ លោក) ដោយទ្រង់បានឃើញ មនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងជាតិកំណើត ហើយទ្រង់យាង (ជាមួយនឹង ព្រះបិតា) ទៅកាន់អារណ្យប្រទេស។

តពីនោះមក ព្រះថេរៈបាននាំស្តេចទៅកាន់ដើមជម្ពូព្រឹក្ស ហើយលើកព្រះហស្តឡើងចង្អុលបង្ហាញថា: គឺត្រង់ស្ថានទី នេះហើយមហារាជ ដែលព្រះពោធិសត្វ ទ្រង់ប្រថាប់នៅ ក្រោមម្លប់ឈើ ដោយវិធីរំពឹងគិត ពិចារណាព្រះអង្គ ដើម្បី រំលៀកខ្លួនចេញចាកកាមតណ្ហា ចាកពុតកំណាច និងអំពើ ដ៏លាមក ព្រះអង្គ បានយល់ជាក់ស្តែង (ថាជាទោស) ទើប ទ្រង់តាំងនៅក្នុង សមាធិ (អានាបាណស្សតិកម្មដ្ឋាន) ហាក់ ដូចជា មិនមែនកុមារតូច ស្តេចចូលកាន់ បឋមជ្ឈាន ទ្រង់ សោយ នូវវិមុត្តិសុខ ជាទីសប្បាយ ក្នុងឈាននោះ។ ខណៈ នោះ ម្លប់នៃឈើឯទៀត ក៏វិលទៅតាម មណ្ឌលព្រះអាទិត្យ

តែម្ចប់ជម្ពូព្រឹក្សនោះ មិនបានលះបង់ចោល ព្រះពោធិសត្វទៅឡើយៗ គ្រានោះ ព្រះបាទសុទ្ធោទនៈ បានទតឃើញដូច្នោះហើយ ទើបក្រាបថ្វាយបង្គំផ្ទាល់នឹងផែនដី ដោយបញ្ចង្គប្រតិស្ឋានចំពោះព្រះពោធិសត្វ។

លំដាប់ពីនោះទៅ ព្រះថេរៈបានបង្ហាញទ្វារក្រុង ហើយថ្វាយព្រះពរថា៖ «គឺតាមស្ថានទីនេះហើយព្រះអង្គ ដែលព្រះពោធិសត្វ មានទេវតាទាំងមួយសែនជាបរិវារ ស្តេចយាត្រាចេញចាកក្រុង កបិលពស្តុ» ព្រះថេរៈ បានបង្ហាញស្ថានទីដែលព្រះពោធិសត្វប្រទានសេះកណ្ឋកៈ និងគ្រឿងរាជាភរណដល់នាយឆន្នកៈ (ឆន្នអាមាត្យ) ហើយទ្រង់ត្រាស់ឲ្យត្រឡប់វិលកាន់បុរីវិញ។ តពីនោះមក ព្រះថេរៈ បានបង្ហាញស្ថានទី ដែលព្រះពោធិសត្វ ស្តេចយាងចូល ទៅក្នុងព្រៃតែមួយព្រះអង្គ។ តពីនោះមក ព្រះថេរៈ បានបង្ហាញស្ថានទីដែលព្រះពោធិសត្វ ទ្រង់កាត់ព្រះកេសាព្រះអង្គ ដោយកាំបិត ដែលធ្លាក់មកអំពីអាកាស ហើយនិងកន្ទែងដែល

សក្រទេវេន្ទ្រ[១] បានទទួលព្រះកេសា ដោយសេចក្ដីគោរព។ តពីនោះមក ព្រះថេរៈបានបង្ហាញស្ថានទី ដែលព្រះពោធិសត្វទ្រង់ប្ដូរព្រះភូសាដ៏មានតម្លៃ នឹងសំពត់កាសាយៈ អំពីព្រានម្នាក់[២]។ តពីនោះមក ព្រះថេរៈ បានបង្ហាញស្ថានទី ដែលព្រះបាទ ពិម្ពិសារៈ បានទូលអញ្ជើញពោធិសត្វ ដោយទ្រង់ថ្វាយនគរពាក់កណ្ដាល។ តពីនោះមក ព្រះថេរៈ បានបង្ហាញស្ថានទី ដែលព្រះពោធិសត្វ ស្ដេចយាងទៅជួបនឹងអាឡារកាលាម (អាឡារតាបសកាលាមគោត្រ) និងឧទ្រកពាម (ឧទកតាបសរាមបុត្រ) តពីនោះមក ព្រះថេរៈ បានបង្ហាញស្ថានទីដែលព្រះពោធិសត្វ ទ្រង់បំពេញទុក្ករកិរិយាយ៉ាងតឹងក្រៃលែងអស់វេលា៦ឆ្នាំ ហើយទើបព្រះថេរៈពោលព្រះគាថានេះថា: «ក្នុងវេលា៦ឆ្នាំ ព្រះពោធិសត្វ ទ្រង់បំពេញទុក្ករកិរិយាយ៉ាងតឹងក្រៃលែង ស្ដេចផ្ទំតែលើផេះនិងលើបន្លា ទើបទ្រង់ជ្រាបច្បាស់ ក្នុងព្រះចិន្ដាថា: សេចក្ដីប្រព្រឹត្តដ៏តឹងនេះ

---

[១] សក្រទេវេន្ទ្រ ជាឈ្មោះរបស់ព្រះឥន្ទ្រ។

[២] សៀវភៅព្រះពុទ្ធសាសនារបស់លោក ល្វី-ហ្វីណូត៍ដែលលោកជុំម៉ៅប្រែជាខ្មែរ យដិកាមហាព្រហ្មបានយកចីវរនិងគ្រឿងបរិក្ខារសម្រាប់សមណមកថ្វាយ។

មិនសមគួរ មិនមែនជាផ្លូវ ដ៏ត្រូវពិតទេ ហើយទ្រង់លះបង់ចោលអំពើនោះទៅ ទើបប្រព្រឹត្តនូវធម៌ដ៏ពិតឡើង»។ ព្រះថេរៈបានបង្ហាញតទៅទៀតថា: «ស្ថានទីនេះហើយមហារាជ ដែលព្រះពោធិសត្វទ្រង់ទទួលបាយាសលាយដោយទឹកដោះគោ[១] មានឱជារស មួយរយយ៉ាង អំពីនាងនន្ទពណ៌ និងនាងនន្ទា[២]»។ តពីនោះមក ព្រះថេរៈ បានបង្ហាញស្ថានទី ដែលព្រះពោធិសត្វ ស្ដេចយាងឆ្ពោះទៅកាន់ពោធិព្រឹក្ស។

ព្រះរាជា ទ្រង់ប្រោសឲ្យសាងព្រះស្តូបមួយៗ ក្នុងស្ថានទីដែលព្រះថេរៈបង្ហាញហើយទាំងអស់នោះ។

ម្យ៉ាងទៀត ព្រះថេរៈ បានបង្ហាញស្ថានទី ដែលកាលនាគរាជ[៣]បានពោលពាក្យសរសើរព្រះពោធិសត្វ លុះទ្រង់ព្រះសណ្ដាប់ដូច្នោះ ទើបព្រះបរមក្សត្រាធិរាជថ្វាយបង្គំ ព្រះ

---

[១] ទិវ្យាវទាន: ថ្វាយទឹកឃ្មុំនិងទឹកដោះគោ ដែលបានចំរើនកើនឡើងឯងជាជង្វាយ ១០ភាគ។ អាយុ-វង់-កឺង: បានទទួលបាយាសលាយដោយទឹកដោះគោដែលចម្រាញ់ ១៦ដង។

[២] បឋមសម្ពោធិ: នាងសុជាតានិងនាងប៉ុណ្ណា។

[៣] ទិវ្យាវទាន: កាលិកានាគរាជ។

បាទព្រះថេរៈ ហើយលើកព្រះហស្តប្រណម្យឡើងត្រាស់ថា: «ឥឡូវនេះ ខ្ញុំមានប្រាថ្នា ចង់សួរកាលនាគរាជនោះ ដែលជាអ្នកបានឃើញ ព្រះសម្មាសម្ពុទ្ធ តើឃើញព្រះអង្គ ស្តេចទ្រង់ពុទ្ធដំណើរទៅក្នុងមាគ៌ាណាខ្លះ?»។

គ្រានោះ ព្រះថេរៈហៅកាលនាគរាជថា: «ចូរអ្នកមកឲ្យឆាប់! ចូរអ្នកមកឲ្យឆាប់! ព្រះរាជាចង់សួរអ្នកអំពីកាលដែលអ្នកបានឃើញ ព្រះសម្មាសម្ពុទ្ធ តើឃើញព្រះអង្គ ស្តេចទ្រង់ពុទ្ធដំណើរក្នុងមាគ៌ាណាខ្លះ[១]»។

ក្នុងខណៈនោះ កាលនាគរាជ ក៏ប្រាកដឡើង ចូលមកជិតព្រះថេរៈ លើកដៃប្រណម្យ ទូលថា: «ឱព្រះថេរៈម្ចាស់ ! ព្រះករុណាមានត្រូវការអ្វី?»។

ព្រះថេរៈ ថ្វាយព្រះពរព្រះមហាក្សត្រិយ៍ ថា: « អ្នកនេះឯងហើយជាកាលនាគរាជ ដែលបានសូត្រគាថាសរសើរព្រះសម្មាសម្ពុទ្ធនោះ»។

គ្រានោះ ព្រះរាជាប្រណម្យព្រះហស្តឡើង ត្រាស់នូវ

---

[១] មហាវង្សៈ ស្តេចប្រើប្រវាក់មាសដោយឫទ្ធិ ឲ្យទៅចងនាំកាលនាគរាជមកថ្វាយព្រះអង្គ។

គាថានេះថា: « អ្នកបានឃើញព្រះភគវ័ត ព្រះអង្គឥតបុគ្គលប្រៀបស្មើ ព្រះអង្គ មានឆវីវណ្ណភ្លឺផ្លេកត្រចះ ហាក់ដូចជាពណ៌ នៃមាសឆ្អិន ព្រះអង្គ មានវង្វង់ព្រះភក្ត្រដូចជាដួងព្រះចន្ទ្រដ៏ពេញវង់ ចូរអ្នកសំដែង ប្រាប់ខ្ញុំអំពីគុណសម្បត្តិរបស់ព្រះអង្គគ្រាកាលដែលទ្រង់យាងឆ្ពោះទៅកាន់ពោធិព្រឹក្សនោះ»

នាគរាជទូលតបថា: ដើម្បីនឹងនិយាយសរសើរសេចក្តីរុងរឿងរបស់ព្រះមហាមុនីនោះ មិនមានពាក្យដែលនឹងពោលសរសើរឲ្យត្រឹមស្មើបានទេ ឥឡូវនេះ ខ្ញុំនឹងថ្លែងដោយសង្ខេប ហើយនាគរាជពោលនូវគាថានេះថា: «កាលដែលព្រះពុទ្ធដាក់ព្រះបាទផ្ទប់នឹងផែនប្រថពី ក៏ភ្នំនិងទន្លេទាំងឡាយ ដែលតាំងនៅលើផែនដីទាំងមូល ប៉ោង ខ្ពស់ឡើង ហើយមហាប្រថពីក៏ញាប់ញ័រ ៦ដង ព្រះរស្មីផ្សាយអំពីកាយព្រះតថាគតគ្របទៅលើពន្លឺព្រះចន្ទ្រ និងព្រះអាទិត្យ ហើយភ្លឺរុងរឿង ឆ្លៀលឆ្វាត់ ចាំងទៅក្នុងទិស ទាំង១០ ដើម្បីជាប្រយោជន៍ដល់សត្វលោកទាំងពួង»។

ខាងក្រោយការសន្ទនានោះ ព្រះមហាក្សត្រាធិរាជ បាន

ប្រោសឲ្យសាងព្រះស្តូបមួយឡើង ក្នុងស្ថានទីនោះ ហើយស្តេចយាងហួសទៅទៀត។

ក្នុងលំដាប់នោះ ព្រះថេរៈនិមន្តឆ្ពោះទៅកាន់ពោធិព្រឹក្សលុះដល់ហើយ លើកព្រះហស្ត ចង្អុលបង្ហាញព្រះរាជា ថាៈ «គឺត្រង់ស្ថានទីនេះឯងហើយ ដែលព្រះពោធិសត្វ ទ្រង់មានព្រះមហាករុណា ដ៏ធំដល់លោក ទ្រង់បានឈ្នះនូវមារ និងពលនៃមារ ហើយបានអនុត្តរសម្ពោធិញ្ញាណ» ព្រះរាជាទ្រង់ប្រោសឲ្យសាងព្រះស្តូបមួយនៅត្រង់ស្ថានទីនោះ ហើយទ្រង់ព្រះរាជទានទ្រព្យ មួយសែនដំឡឹងមាស។ ព្រះថេរៈ បានបង្ហាញថាៈ «គឺត្រង់ស្ថានទីនេះហើយ ដែលចាតុម្មហារាជបានថ្វាយបាត្រ៤ ដល់ព្រះពុទ្ធ ព្រះតថាគតទទួលបាត្រនោះហើយ ទ្រង់ទះរូបបាត្រទាំងនោះ ដោយព្រះហស្ត[១] ហើយអធិដ្ឋានធ្វើជាបាត្រមួយ»។

តពីនោះមក ព្រះថេរៈ បានបង្ហាញស្ថានទី ដែល

---

[១] សៀវភៅព្រះពុទ្ធសាសនារបស់លោក ល្វី-ហ្វីណូត៍ ដែលលោកជុំម៉ៅប្រែជាខ្មែរថា ព្រះសម្មាសម្ពុទ្ធតម្រួតបាត្រទាំង៤ធ្វើជាបាត្រ១ដោយឫទ្ធានុភាពរបស់ព្រះអង្គ។

ពាណិជទាំង៥០០[១] បានថ្វាយភោជនាហារ (ដល់ព្រះពុទ្ធ) ហើយបង្ហាញស្ថានទី ដែលព្រះពោធិសត្វ[២] ស្តេចចូលទៅកាន់សំណាក់ស្ត្រី នៅបេណារ៉េស (ពារាណសី)។

តពីនោះមក ព្រះថេរៈបានបង្ហាញស្ថានទីដែលព្រាហ្មណ៍ម្នាក់ពោលសរសើរព្រះពុទ្ធ។ ព្រះរាជា បានប្រោសឲ្យសាងព្រះស្តូប នៅទីគ្រប់កន្លែងដែលព្រះថេរៈ បានបង្ហាញហើយនោះៗ លំដាប់ពីនោះមក ព្រះថេរៈ បាននាំព្រះរាជាទៅក្នុងព្រៃឫសីបតនៈ ហើយលើកព្រះហស្តខាងស្តាំឡើង ចង្អុលបង្ហាញព្រះមហាក្សត្រិយ៍ ថាៈ «ត្រង់ទីនេះហើយ មហារាជ ដែលព្រះតថាគត ព្រះអង្គបានញុំាងធម្មចក្រ ដ៏បវរឲ្យប្រព្រឹត្តទៅ»។

ព្រះរាជា បានប្រោសឲ្យសាងព្រះស្តូបមួយ ហើយព្រះរាជទានទ្រព្យមួយសែនតម្លឹងមាស។ ព្រះថេរៈបានបង្ហាញតទៅទៀត នូវស្ថានទីដែលព្រះតថាគត ព្រះអង្គញុំាងជដិល

---

[១] សៀវភៅព្រះពុទ្ធសាសនារបស់លោក ល្វី-ហ្វីណូត៍ថា ពាណិជពីរនាក់បានយកនំធ្វើពីអង្ករ១ ពីទឹកឃ្មុំ១ទៅថ្វាយព្រះអង្គ។

[២] គួរថាព្រះពុទ្ធ តែច្បាប់ដើមជាព្រះពោធិសត្វដូច្នេះ។

ទាំងមួយពាន់ ឲ្យកាន់យកភេទជា ភិក្ខុ ហើយបានបង្ហាញស្ថានទីដែលព្រះបាទពិម្ពិសារៈ ទ្រង់ព្រះសណ្តាប់នូវព្រះធម៌ទេសនា ហើយទ្រង់បានឃើញច្បាស់នូវសច្ចធម៌ ស្ថានទីដែលស្តេចនៃទេវតាទាំង ៨៤.០០០ បានញុាំងកិលេស គឺសេចក្តីសៅហ្មងឲ្យឃ្លាតចេញពីខន្ធសន្តាន បានបរិសុទ្ធល្អព្រមទាំងបាន ធម្មចក្ខុគ្រប់ៗគ្នា ស្ថានទី ដែលពួកព្រាហ្មណ៍និងពួកគហបតីជាច្រើនពាន់បានសម្រេចនូវសោតាបត្តិផល។

ព្រះថេរៈ បានបង្ហាញតមកទៀត នូវស្ថានទីដែលសក្រទេវេន្ទ្រ (ព្រះឥន្ទ្រ) មានសេចក្តីជ្រះថ្លា ស្ថានទីដែលព្រះតថាគត ទ្រង់សំដែងយមកប្បាដិហារ្យជាអស្ចារ្យ ហើយនិងស្ថានទី ដែលព្រះតថាគត ស្តេចយាងចុះមកអំពីខាងក្រោយដែលស្តេចទៅចាំវស្សានៅក្នុងស្ថានតាវត្តិង្ស ដើម្បីនឹងសំដែងធម៌ប្រោសព្រះពុទ្ធមាតា។

ព្រះរាជា បានទ្រង់ប្រោសឲ្យសាងព្រះស្តូប ដ៏មានតម្លៃក្នុងស្ថានទីដែលព្រះថេរៈបានបង្ហាញហើយនោះៗ។

តពីនោះមក ព្រះថេរៈ បាននាំព្រះបរមក្សត្រិយ៍ ទៅ

ក្រុងកុសិនគរ (កុសិនារា) ហើយលើកព្រះហស្តឡើងចង្អុលបង្ហាញថា: «គឺត្រង់ស្ថានទីនេះហើយ ដែលព្រះតថាគតស្តេចចូលកាន់និព្វាន ក្នុងកាលជាខាងក្រោយ ដែលទ្រង់បំពេញពុទ្ធកិច្ចបរិបូណ៌ហើយ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ព្រះអង្គទ្រោបចុះទៅលើផែនដី ស្តេចទ្រង់ព្រះពិលាបរហូតដល់បាត់ស្មារតី សូន្យសញ្ញីភាព ពួករាជបរិវារ បានយកទឹកមកប្រស់ព្រំ ស្រប់ព្រះភក្ត្រហើយ ទើបស្តេចត្រឡប់បាន ព្រះស្មារតីតើនឡើង បានទ្រង់ព្រះរាជទានទ្រព្យ មួយសែនតម្លឹងមាសនិងប្រាក់ ឲ្យសាងព្រះស្តូបមួយ នៅត្រង់ស្ថានទីនោះ។

លំដាប់នោះ ព្រះរាជាប្រណម្យព្រះហស្តថ្វាយបង្គំដោយគោរពចំពោះព្រះបាទព្រះថេរៈ ហើយត្រាស់ទៀតថា: «ឥឡូវនេះ ខ្ញុំមានប្រាថ្នានឹងនមស្សការព្រះស្តូប នៃពួកមហាសាវ័ករបស់ព្រះពុទ្ធជាម្ចាស់(ទៀត)»។

ព្រះថេរៈថ្វាយព្រះពរសរសើរថា: «សាធុ! សាធុ! ឱព្រះរាជា! ព្រះអង្គមានព្រះរាជហឫទ័យប្រកបដោយប្រសាទ

សទ្ធាក៏ក្លា និងសេចក្ដីគោរពដ៏វិសេស»។

ខណៈនោះ ព្រះថេរៈ បាននាំព្រះមហាក្សត្រិយ៍ទៅក្នុងសួនជេតវ័ន ហើយលើកព្រះហស្ដឡើង ថ្វាយព្រះពរថាៈ «បពិត្រមហារាជ នេះហើយព្រះស្តូបរបស់ព្រះសារីបុត្រ សូមព្រះអង្គទ្រង់ព្រះរាជទានគ្រឿងសក្ការបូជា»។

ព្រះរាជាត្រាស់សួរថាៈ «គុណវិសេសរបស់លោកម្ចាស់អង្គនោះដូចម្ដេចទៅ?»

ព្រះថេរៈថ្វាយព្រះពរតបថាៈ «លោកជាសាវ័កទី១ ជាធម្មសេនាបតីរបស់ព្រះភគវ័ត លោកជាអ្នកស្ទាត់ជំនាញក្នុងការញុំាំងធម្មចក្រដ៏បវរឲ្យប្រព្រឹត្តទៅ»។

«ព្រះតថាគត ទ្រង់លើកដម្កើងលោកជាចំបង លើសជាងពួកសាវ័កអ្នកមានប្រាជ្ញា។ ប្រាជ្ញានៃសត្វលោកទាំងអស់ វៀរលែងតែប្រាជ្ញាព្រះតថាគតមួយចេញ ក៏មិនមានប្រាជ្ញាអ្នកណាមួយ ស្មើនឹងប្រាជ្ញារបស់ព្រះសារីបុត្រត្រឹមតែមួយចំណិត ដែលបែងជា ១៦ដង ហើយ។ គេអាចនិយាយបានតែដោយសង្ខេបយ៉ាងនេះ អ្នកណាឡើយ នឹងអាច

សំដែងអំពីឃ្លាំងប្រាជ្ញារបស់លោកឲ្យសព្វគ្រប់បាន»។

កាលដែលព្រះថេរៈថ្វាយព្រះពរដូច្នោះហើយ ព្រះរាជាមានសេចក្ដីជ្រះថ្លាពន់ពេក ទ្រង់ព្រះរាជទានទ្រព្យមួយសែនតម្លឹងមាស ដល់ព្រះស្តូបនោះ។ កាលព្រះអង្គថ្វាយបង្គំព្រះសារីបុត្រ ទ្រង់ត្រាស់នូវគាថានេះថា: «លោកជាអ្នកបានកំចាត់បង់នូវចំណងនៃភព ល្បីល្បាញកេរ្តិ៍ឈ្មោះរបស់លោកសាយសព្វ ទូទៅទាំងលោក បណ្ដាអ្នកដែលមានប្រាជ្ញាទាំងឡាយ មានតែលោកជាចម្បងលើសជាងគេទាំងអស់»។

តពីនោះមក ព្រះថេរៈ បានបង្ហាញព្រះស្តូប នៃព្រះម៉ៅទ្គល្យាយនៈ (មោគ្គល្លាន) ដល់ព្រះមហាក្សត្រិយ៍ ថ្វាយព្រះពរឲ្យស្ដេចព្រះរាជទានគ្រឿងសក្ការបូជា។

ព្រះរាជាត្រាស់សួរទៀតថា: «គុណវិសេសរបស់លោកអង្គនោះដូចម្ដេចទៅ?»។

ព្រះថេរៈ ថ្វាយព្រះពរថា: «លោកជាចម្បងលើសពួកអ្នកដែលមានឫទ្ធិបាទ (ឥទ្ធិបាទ) លោកអាចឈានតែជើងខាងស្ដាំរបស់លោកទៅដល់បូរី នៃសក្រទេវេន្ទ្រ (ព្រះឥន្ទ្រ)

បាន»។ ម្យ៉ាងទៀត លោកអាចផ្ចាញ់នាគរាជឈ្មោះនន្ទ និង ឧបនន្ទ ឲ្យចុះចាញ់បាន។ អានុភាព សំដែងគុណវិសេស របស់លោក បានតែដោយសង្ខេបថា គេធ្វងដល់ត្រើយខាង នាយនៃមហាសមុទ្រ សង្សារសាគរបាន ដោយសារវាចាជា គុណធម៌របស់លោកអង្គនោះ»។

ព្រះរាជា បានព្រះរាជទានទ្រព្យ មួយសែនតម្លឹងមាស ដល់ព្រះស្តូបនោះ ព្រះរាជទានហើយ ទើបប្រណម្យព្រះ ហស្តឡើង ត្រាស់គាថានេះគ្រានោះថាៈ «ខ្ញុំសូមនមស្សការ ព្រះម៉ោគ្គល្លាយនៈ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ លោក ជាចម្បង លើសជាងពួកអ្នក ដែលបានឫទ្ធិបាទទាំងឡាយ លោកបានកំចាត់បង់នូវជាតិ ជរា សេចក្តីសោក និងសេចក្តី ទុក្ខព្រួយ»។

លំដាប់ពីនោះមក ព្រះថេរៈ បានបង្ហាញព្រះស្តូប ព្រះ កស្សប ដល់ព្រះមហាក្សត្រិយ៍ លើកព្រះហស្តឡើងថ្វាយ ព្រះពរថាៈ «ស្ថានទីនេះហើយជាព្រះស្តូបនៃព្រះមហាកស្សប សូមទ្រង់ព្រះរាជទានគ្រឿងសក្ការបូជាត្រង់ស្ថានទីនេះផង»។

ព្រះរាជាត្រាស់សួរថាៈ «គុណវិសេសរបស់លោកអង្គនោះដូចម្ដេចទៅ?»។

ព្រះថេរៈ ថ្វាយព្រះពរតបថាៈ «លោកជាអ្នកប្រាថ្នាតិច ចូលចិត្តតែរបស់តិច លោកជាចម្បងលើសជាងពួកអ្នកដែលប្រព្រឹត្តធុតង្គវត្ត។ ព្រះតថាគត បានប្រទាន ទីសេនាសនៈសម្រាប់ព្រះអង្គឲ្យលោកគង់។ ព្រះពុទ្ធជាម្ចាស់ទ្រង់ដោះចីវររបស់ព្រះអង្គ ប្រទានដល់ ព្រះមហាកស្សប។ ព្រះថេរៈអង្គនោះ តែងមានព្រះហឫទ័យមេត្តាដល់អ្នកខ្សត់ទុគ៌ត និងអ្នកមានទុក្ខព្រួយ លោកជាអ្នកគ្រប់គ្រង រក្សានូវធម៌វិន័យរបស់ព្រះពុទ្ធជាម្ចាស់ ដែលអាត្មាភាពសំដែងឥឡូវនេះ គឺនិយាយដោយសង្ខេប អ្នកណាឡើយ នឹងអាចសំដែងអំពីគុណវិសេស នៃការប្រព្រឹត្តតឹងរបស់លោកឲ្យសព្វគ្រប់បាន?»។

ព្រះរាជា ទ្រង់ប្រោសព្រះរាជទានទ្រព្យមួយសែនតម្លឹងមាស ដល់ព្រះស្តូបនៃព្រះមហាកស្សបនោះ ក្រាបបូជាហើយ ក៏ប្រណម្យព្រះហស្តឡើងត្រាស់គាថានេះថាៈ «លោកជាអ្នកគង់នៅក្នុងគុហានៃភ្នំ ជាអ្នកបានបន្សាត់បង់នូវការ

វិវាទ មិនបានប្រព្រឹត្ត ទៅតាមអំណាច នៃទោសៈទាំងពួង លោកបានចម្រើនធ្យាន (ឈាន) និងសមាបត្តិជាប្រក្រតី លោកជាអ្នកប្រាថ្នាតិច ចូលចិត្តតែរបស់តិច គុណវិសេសរបស់លោកឥតគូនឹងប្រៀបផ្ទឹម ឥឡូវនេះ ខ្ញុំសូមនមស្សការចំពោះលោកម្ចាស់អង្គនោះ ដោយការបន្ទន់ព្រះសិរ ខ្ញុំសូមថ្វាយបង្គំចំពោះលោកម្ចាស់អង្គនោះដោយអស់អំពីចិត្ត»។

តពីនោះមក ព្រះថេរៈ បានបង្ហាញព្រះស្ដូប ព្រះវក្កុលត្ថេរពាកុល ដល់ព្រះមហាក្សត្រិយ៍ ថ្វាយព្រះពរឲ្យស្ដេចព្រះរាជទាន គ្រឿងសក្ការបូជា ។

ព្រះរាជាត្រាស់សួរថា: «គុណវិសេសរបស់លោកម្ចាស់អង្គនោះដូចម្ដេចទៅ?»។

ព្រះថេរៈថ្វាយព្រះពរតបថា: «ព្រះតថាគត បានលើកលោកជាចម្បងលើសជាងពួកអ្នក ដែលមានសេចក្ដីអត់ទ្រាំនឹងរោគ ហើយនឹងពួកអ្នកដែលប្រាថ្នាតិច លោកមិនដែលសំដែងគាថា១ ប្រកបដោយបាទ៤ ដល់មនុស្សណាមួយសោះឡើយ»។

គ្រានោះ ព្រះរាជាទ្រង់ប្រោសព្រះរាជទានមាសមួយពែ ដាក់ទៅលើព្រះស្តូប នៃព្រះថេរៈអង្គនោះ ពួកអាមាត្យក្រាប ទូលសួរថា: «ព្រះស្តូបព្រះអរហត្តជាទីគោរពស្មើៗគ្នា ព្រោះ ហេតុអ្វីបានជាទ្រង់ ព្រះរាជទានគ្រឿងបូជាតែត្រឹមមាសមួយ ពែប៉ុណ្ណោះ?»។

ព្រះរាជា ត្រាស់តបថា: «ព្រោះលោករួច (ចាកទុក្ខ) បាន តែខ្លួនលោកម្នាក់ឯង មិនបានធ្វើមនុស្សឯទៀតឲ្យរួចចាកទុក្ខ ផង ព្រោះហេតុនោះ បានជាយើងបូជាតែត្រឹមមាសមួយ ពែប៉ុណ្ណោះ»។

រុក្ខទេវតា ដែលរក្សាព្រះស្តូប បានបង្វែរមាស មួយពែ នោះថ្វាយមកព្រះរាជាវិញ ទើបពួកអាមាត្យ ក្រាបទូលទៀត ថា: «លោកជាអ្នកមានសេចក្តីប្រាថ្នាតិចដោយពិត បានជា លោកមិនទទួលយកមាសមួយពែនោះឡើយ?»

គ្រានោះ ព្រះថេរៈបានបង្ហាញព្រះស្តូប ព្រះអានន្ទត្ថេរ ដល់ព្រះមហាក្សត្រិយ៍ ថ្វាយព្រះពរ ឲ្យស្តេចព្រះរាជទាន គ្រឿងសក្ការបូជា។ ព្រះរាជាត្រាស់សួរថា: «គុណវិសេស

របស់លោកម្ចាស់អង្គនោះដូចម្ដេចទៅ?»។

ព្រះថេរៈថ្វាយព្រះពរថា: «ព្រះតថាគតបានលើកព្រះអានន្ទនោះជាចម្បង លើសជាងពួកអ្នក ដែលជាពហុស្សូតលោកបានចាំជាក់ច្បាស់ នូវធម៌របស់ព្រះពុទ្ធជាម្ចាស់។ កម្លាំងគំនិតប្រាជ្ញា និងការឈ្លាសវាងវៃរបស់លោក ដ៏ធំទូលាយ ប្រៀបដូចជាមហាសមុទ្រ វាចារបស់លោកផ្អែមល្ហែមពីរោះក្បោះក្បាយ មនុស្ស និងទេវតាទាំងឡាយ តែងធ្វើសេចក្ដីគោរពចំពោះលោកអង្គនោះ លោកអាចកំណត់ដឹងនូវពុទ្ធអធ្យាស្រ័យបាន លោកបរិបូណ៌ដោយសេចក្ដីល្អ និងពេញទៅដោយគុណសម្បត្តិគ្រប់យ៉ាង លោកជាឃ្លាំងមួយដែលពេញណែនចង្អៀតទៅដោយព្រះធម៌»។

ព្រះរាជា កាលទ្រង់ព្រះសណ្ដាប់ពាក្យនេះហើយ មានព្រះរាជហឫទ័យពេញទៅដោយបីតិនិងប្រាមោទ្យ ទ្រង់ព្រះរាជទានទ្រព្យមួយកោដិតម្លឹងមាសដល់ព្រះស្តូបនោះ។

ពួកអាមាត្យក្រាបទូល សួរថា: «ព្រោះហេតុអ្វីបានជាទ្រង់ ព្រះរាជទានគ្រឿងបូជា ត្រង់ស្ថានទីនេះ ច្រើនលើស

ជាងស្តានទីទាំងពួង?»។

ព្រះរាជាត្រាស់តបថា: «ព្រោះព្រះថេរៈអង្គនេះ លោកជាពហូសូត្រក្នុងធម៌វិន័យ លោកបានផ្សាយព្រះធម៌ ឲ្យជាប្រទីបដ៏ភ្លឺរុងរឿង រហូតដល់មកថ្ងៃនេះ ឥតមានបាត់បង់យ៉ាងនេះឯង ស្នាមជើងគោ មិនអាចនឹងទទួលយកទឹកមហាសមុទ្របានទេ នោះក៏ពិតមែនហើយ តែសមុទ្រគឺប្រាជ្ញារបស់ព្រះពុទ្ធជាម្ចាស់ ព្រះអានន្ទអាចទទួលបាន ព្រោះដូច្នោះទើបយើងបូជាស្តានទីនេះច្រើនលើសជាងស្តានទីទាំងពួង»។

កាលដែលព្រះរាជា បានបូជាព្រះស្តូប នៃពួកមហាសាវ័ករួចហើយ ទ្រង់សប្បាយរីករាយ ក្នុងព្រះរាជហឫទ័យពន់ពេក ស្តេចក្រាបថ្វាយបង្គំទៀបព្រះបាទ ព្រះថេរៈ ហើយលើកព្រះហស្ត ប្រណម្យឡើងដោយគោរព ត្រាស់គាថានេះថា: «ខ្ញុំបានសម្រេចអត្តភាពជាមនុស្ស បានបរិច្ចាគនូវទានទាំងសែនៗ ឥឡូវនេះ ខ្ញុំបានធ្វើកិច្ចរបស់ខ្ញុំនោះរួចស្រេចហើយ មិនមែនជាការឥតអំពើទេ ដែលខ្ញុំបានទទួលអត្តភាពនេះ។ ខ្ញុំបានជួបនឹងបុញ្ញក្ខេត្ត ដ៏ប្រសើរ ខ្ញុំបានធ្វើឲ្យជាក់

ច្បាស់ ដល់ផលសំរាប់អត្តភាពជាមនុស្ស។ ដោយសារទ្រព្យសម្បត្តិ ដែលជារបស់ប្រកបដោយទោស ហើយពុករលួយទៅៗ ផាយៗ ខ្ញុំបានបំពេញកុសលឲ្យបានសម្រេចផលដ៏មាំមួន ដល់ព្រះធម៌ជាម្ចាស់។ ព្រះស្តូបទាំងឡាយ ដែលខ្ញុំបានកសាងទុកជាគ្រឿងលំអនៃជម្ពូទ្វីប ដ៏ដេរដាសដូចជាពពកមានពណ៌ស ដែលជាគ្រឿងលំអនៃអាកាសវេហាស៍។ ខ្ញុំបានជួបប្រសព្វនឹងព្រះធម៌របស់ព្រះពុទ្ធដែលជាសភាវៈដ៏បរិសុទ្ធផុតគ្រឿងសៅហ្មង»។

កាលទ្រង់ ត្រាស់នូវគាថានេះចប់ហើយ ព្រះរាជាទ្រង់ថ្វាយបង្គំលា ថយចេញចាកទីនោះទៅ។ ទុកជាព្រះបាទអសោក បានព្រះរាជទានទ្រព្យ ១សែនតម្លឹងមាស ដល់ព្រះស្តូបមួយៗគ្រប់កន្លែង (ក្នុងព្រះស្តូបទាំង៤) គឺព្រះស្តូបនៅទីប្រសូតព្រះពុទ្ធជាម្ចាស់ ព្រះស្តូបនៅទីដើម ពោធិព្រឹក្សព្រះស្តូបនៅទីញ៉ាំងធម្មចក្រដ៏បវរឲ្យប្រព្រឹត្តទៅ និងព្រះស្តូបនៅទីនិព្វាន ក៏ព្រះអង្គគង់មានព្រះរាជសទ្ធាដ៏វិសេសបំផុតចំពោះតែត្រង់ ព្រះស្តូបនៅពោធិព្រឹក្សនោះ ព្រោះហេតុអ្វី?

ព្រោះថាទីនោះ ព្រះសម្មាសម្ពុទ្ធ បានទ្រង់ត្រាស់សម្មាសម្ពោធិញ្ញាណ បានជាព្រះរាជា ទ្រង់ព្រះរាជទាន គ្រឿងប្រដាប់ រតនវត្ថុដ៏មានតម្លៃជាច្រើនប្រការ ដល់ព្រះស្តូបនៅពោធិព្រឹក្សនោះ។

ព្រះអគ្គមហេសី ទី១ របស់ព្រះមហាក្សត្រិយ៍ ទ្រង់មានព្រះនាម ព្រះនាង តិស្សរក្សិតា[១] កាលឃើញព្រះរាជសទ្ធារបស់ព្រះបាទអសោកដូច្នោះ ទើបព្រះនាងត្រិះរិះដូច្នេះថា: «រតនវត្ថុដ៏មានតម្លៃ ដែលព្រះអង្គមានទាំងប៉ុន្មាន ទ្រង់ព្រះរាជទាន ដល់ពោធិព្រឹក្សទាំងអស់ហើយ» ខណៈនោះ ព្រះនាងមានព្រះសវនីយ៍ហៅមនុស្សចណ្ឌាល ឈ្មោះមាតង្គ: មកគាល់ ហើយត្រាស់ថា: «អ្នកអាចនឹងទំលាយ ដើមពោធិព្រឹក្សដោយវេទមន្តបានឬទេ?។

មាតង្គបុរសតបថា: ប្រសិនបើព្រះនាងប្រទានរង្វាន់ជាមាសដល់ខ្ញុំ ខ្លួនខ្ញុំនោះនឹងអាចបំផ្លាញបាន។

---

[១] មហាវង្ស: នាងអសន្ធិមិត្តារាជមហេសីទិវង្គតទៅបាន៤ឆ្នាំ ទើបព្រះបាទអសោកតាំងនាងតិស្សរាជទេវីជាអគ្គមហេសីឯកឡើង តែនាងនេះមិនមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា។

គ្រានោះ ព្រះនាងសន្មតថា នឹងប្រទានរង្វាន់ជាមាស ដល់មនុស្សចណ្ឌាលនោះ ក៏មាតង្គបុរស លាក់អាថ៌កំបាំង នោះ ទុកដោយលោភចិត្តនៃខ្លួន វាបានដើរសំដៅទៅដើម ពោធិព្រឹក្សហើយវាយកខ្សែចងព័ទ្ធសីមាជុំវិញដើមពោធិព្រឹក្ស នោះ វាបំណងនឹងសម្លាប់ដោយវេទមន្តរបស់វា ក្នុងមួយ រំពេចនោះដើមឈើក៏ស្វិតស្រពោនរញមចុះសន្សឹមៗទៅ។

ពួករាជបុរសអ្នករក្សានូវដើមឈើនោះ ឃើញដូច្នោះ ក៏ មកក្រាបទូល ដល់ព្រះមហាក្សត្រិយ៍ ថា: «ឥឡូវនេះ ដើម ពោធិព្រឹក្ស កំពុងតែស្វិតស្រពោនទៅឯងៗ»។ ខណៈនោះ ពួករាជបុរស ពោលនូវគាថានេះ ថា: «នៅត្រង់ស្ថានទី ដែល ព្រះតថាគត បានត្រាស់ដឹងនូវវិជ្ជាក្នុងលោក ទ្រង់ប្រព្រឹត្ត ទៅតាមផ្លូវនៃពោធិញ្ញាណ ឥឡូវនេះ ដើមឈើនោះឯងកាន់ តែថយកម្លាំងណាស់ ទៅហើយ កាន់តែស្វិតស្រពោនចុះ សន្សឹមៗទៅហើយ។

ព្រះរាជាកាលទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ទ្រង់ក៏អស់ព្រះស្មារតី ដួលចុះទៅលើផ្ទៃនៃប្រថពី លុះទ្រង់

បានទទួលទឹកប្រស់ព្រំស្រប់ព្រះកន្ត្រាយូរបន្តិចមក ទើបត្រឡប់បានព្រះស្មារតីឡើង ហើយទ្រង់ព្រះពិលាបរៀបរាប់ថា: «កាលខ្ញុំឃើញពោធិព្រឹក្ស ក៏ហាក់ដូចជាបានឃើញព្រះសម្មាសម្ពុទ្ធជាម្ចាស់ដែរ ប្រសិនបើដើមពោធិព្រឹក្សនោះស្ងិតស្រពោនទៅហើយ ខ្លួនខ្ញុំនឹងស្លាប់ទៅជាមួយផងជាប្រាកដ»

ព្រះនាងតិស្សរក្ខិតា ក្រាបទូលលួងលោមព្រះរាជាថា: «បើទុកជាដើមពោធិព្រឹក្សក្ស័យជីវិតទៅ ខ្ញុំម្ចាស់ឯងនឹងអាចបម្រើមហារាជ ឲ្យព្រះអង្គទ្រង់ព្រះសម្រាន្តព្រះរាជហឫទ័យតរៀងទៅ»។

ព្រះរាជាត្រាស់ថា: «មានតែដើមពោធិព្រឹក្សនោះ អាចធ្វើសេចក្តីសុខដល់ខ្លួនអញ ឯជាតិស្ត្រីភាពណានឹងធ្វើបាន! គឺត្រង់ទីនោះឯងហើយដែលព្រះសម្ពុទ្ធជាម្ចាស់ ព្រះអង្គបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ»។

ព្រះរាជាគ្រាន់តែមានព្រះឱង្ការតែប៉ុណ្ណោះ ក៏ព្រះនាងតិស្សរក្ខិតា រំជួលក្តួលក្តៅក្នុងចិត្ត កើតវិប្បដិសារីឡើង ទើបនិយាយនឹងបុរសឈ្មោះមាតង្គៈថា: «ឥឡូវនេះ អ្នកអាចធ្វើ

ដើមពោធិព្រឹក្សឲ្យរស់ឡើងវិញបានឬទេ?»។

មាតង្គបុរសក្រាបទូលតបព្រះនាងថា: «ប្រសិនបើឈើនោះមិនទាន់ស្ងួតក្រៀមនៅឡើយ ហើយនៅមានជីវិតសូម្បីតែបន្តិចបន្តួច ក៏ខ្ញុំនឹងអាចធ្វើឲ្យបានដូចដើមឡើងវិញ»។

ខណៈនោះ មាតង្គបុរស ស្រាយខ្សែអំបោះដែលចងព័ទ្ធសីមាបណ្ដើរ សូត្រពាយមន្តដោះបណ្ដើរ ដោយសេចក្ដីព្យាយាមពេញបន្ទុក ខំស្រោចពោធិព្រឹក្សនោះ ដោយទឹកដោះគោមួយពាន់ក្អម តពីនោះមកមួយស្របក់ ដើមឈើនោះក៏រស់ឡើងវិញជាប្រក្រតីដូចដើម។

ពួករាជបុរសអ្នករក្សា បានឃើញឈើនោះលូតលាស់ស្រស់សន្ទឹកឡើងវិញ ក៏មកក្រាបទូលដល់ព្រះរាជាថា: «បពិត្រមហារាជ ពោធិព្រឹក្សរស់ឡើងវិញហើយ មិនបានប្លែកអំពីកាលជាន់មុននោះទេ»។

លុះព្រះរាជាទ្រង់ព្រះសណ្ដាប់នូវពាក្យតែប៉ុណ្ណោះក៏មានព្រះបីតិសោមនស្ស ស្ដេចយាងទៅជិតដើមពោធិព្រឹក្សព្រះអង្គទតត្រង់ទៅដើមឈើនោះ ទ្រង់ត្រាស់ថា: «រាជកិច្ចឯ

ណា ដែលស្តេចពិម្ពិសារ និងពួកស្តេចឯទៀតមិនទាន់បានធ្វើឲ្យសម្រេចនៅឡើយ រាជកិច្ចនេះ ខ្ញុំនឹងធ្វើឥឡូវនេះឲ្យបានចំណែកពីរយ៉ាង។ ចំណែក២យ៉ាងគឺអ្វីខ្លះ? គឺចំណែក១ ខ្ញុំនឹងធ្វើឲ្យមានមហាកម្មសម្ភោទ្យធ្វង ព្រមទាំងឲ្យធ្វើក្អមមួយពាន់ដោយវត្ថុដ៏មានតម្លៃដាក់ពេញទៅដោយសុគន្ធជាតិ សម្រាប់ស្រោចដើមពោធិព្រឹក្ស ចំណែក១ទៀត ខ្ញុំនឹងលៀងព្រះអរិយសង្ឃជាច្រើន ឲ្យអស់កាលនៃរដូវភ្លៀង[១] ៤ខែ។

គ្រានោះ ព្រះរាជាត្រាស់ឲ្យធ្វើក្អមដ៏ប្រសើរចំនួនមួយពាន់ជាវិការវាន់មាស ប្រាក់ និងកែវពៃទូរ្យ ទ្រង់ឲ្យបំពេញដោយសុគន្ធវារី ហើយឲ្យស្រោចដើមពោធិព្រឹក្សនោះ ព្រះអង្គឲ្យធ្វើប្រដាប់ស្អិតស្អាងដើមឈើនោះ ដោយកម្រងផ្កាដោយលំអិតសុគន្ធជាតិ និងគ្រឿងលាបលនទាំងឡាយដ៏ច្រើន។ ព្រះរាជាស្រង់ព្រះវារីហើយ ទ្រង់ព្រះភស្ត្រថ្មីដ៏បរិសុទ្ធស្អាតល្អ ព្រះអង្គសមាទាននូវអដ្ឋង្គឧបោសថ ស្តេចឡើងទៅលើខឿនពោធិព្រឹក្ស

[១] ក្នុងអាយុ-វង-កឹង បញ្ចូវស់ ប្រែថា:«ប្រជុំសង្ឃជាច្រើនមកធ្វើកុសលអស់៥ឆ្នាំ» តែបើពិនិត្យមើលតាមកំណើតដើមរបស់ពាក្យបញ្ចូវស់ គួរនឹងប្រែថា: «អស់កាលនៃរដូវភ្លៀង៥ខែ» ហៅថាធ្វើបញ្ចូវស់។

នោះ ពិចារណាមើលគ្រប់ទិសទាំង៤ហើយត្រាស់បួងសួងថាៈ «ឱព្រះអរិយសង្ឃទាំងឡាយដ៏ច្រើន លោកជាសាវ័កនៃព្រះសម្ពុទ្ធម្ចាស់ លោកប្រតិបត្តិដើម្បីចំរើននូវការយល់ត្រូវ លោកជាអ្នកផ្តាច់បង់នូវចំណងនៃតណ្ហា បានដោយឫសនៃកុសលរបស់លោក ដែលកើតព្រមដោយសមាធិ លោកជាអ្នកមានគុណធម៌ គួរពួកមនុស្ស ពួកទេវតា និងពួកអសុរគោរព ខ្ញុំសូមឲ្យពួកលោកទាំងអស់នោះ និមន្តមកជួបនឹងខ្ញុំ ដោយមេត្តាចិត្តរបស់លោកដល់ខ្ញុំ សូមឲ្យព្រះករុណាទាំងអស់នោះ ព្រមទទួលនូវនិមន្តរបស់ខ្ញុំ»។

ពួកលោកទាំងអស់ ដែលជាអ្នកសោយនូវបីតិក្នុងឈ្យាន (ឈាន) និងសមាបត្តិ មានប្រាជ្ញាចក្ខុកើតឡើងព្រមហើយ ជាអង្គនៃអរិយសង្ឃ ដែលបានសម្រេចនូវព្រះអមតមហានិព្វាន លោកជាកុលបុត្រដ៏ពិតឥតបុគ្គលប្រៀបផ្ទឹម ជាអ្នកបានទទួលរក្សាទុកនូវព្រះធម៌ជាមត៌ករបស់ព្រះសុគត សូមឲ្យព្រះករុណាទាំងអស់អង្គនោះ ព្រមទទួលនូវការនិមន្តរបស់ខ្ញុំដោយមេត្តាចិត្ត»។

«ពួកលោកដែលគង់នៅក្នុងដែនកស្មិរៈ ជាអ្នករួចផុតចាកភ័យអន្តរាយទាំងយប់ទាំងថ្ងៃ ព្រមទាំងលោកជាអ្នកប្រព្រឹត្តនៅក្នុងព្រៃមហាវ័ន និងព្រៃរេវតៈ សូមនិមន្តមកផងដោយមេត្តាចិត្តរបស់លោក សូមឲ្យព្រះករុណាទាំងអស់នោះព្រមទទួលនូវការនិមន្តរបស់ខ្ញុំ»។

«ពួកលោកដែលគង់នៅស្ថានទីមិនរាបស្មើ ទៀបមាត់ស្រះដ៏ធំឈ្មោះអនវតប្ត និងពួកលោកដែលគង់នៅនាមាត់ទន្លេ នាជ្រោះជ្រលងភ្នំ និងនាគុហាឈ្មោះសេរីសកៈ ព្រមទាំងពួកលោកដែលគង់នៅនាភ្នំគន្ធមាទនៈ សូមនិមន្តមកដោយមេត្តាចិត្តរបស់លោក សូមឲ្យព្រះករុណាទាំងអស់នោះ ព្រមទទួលនូវការនិមន្តរបស់ខ្ញុំ»។

កាលព្រះរាជា បានអធិដ្ឋានការនិមន្តយ៉ាងនេះហើយ ពួកព្រះថេរៈទាំងនេះ ក៏និមន្តមកអំពីទិសទាំង៤ចំនួនបីសែនអង្គ។ ១សែនអង្គជាព្រះអរហន្ត ២សែនអង្គជាព្រះសោតាបន្ន ព្រះសក្ខទាគាមិន(សកទាគាមី)និងព្រះអនាគាមិន(អនាគាមី) មានទាំងពួកមនុស្សជាសាមញ្ញបុថុជ្ជន និងពួកជនអ្នកមាន

ចិត្តដ៏បរិសុទ្ធ ក៏មកអង្គុយប្រជុំគ្នា នៅសល់តែកន្លែងមួយ សម្រាប់ព្រះមហាថេរ ជាកន្លែងទំនេរ មិនមានអ្នកណាមួយ ហ៊ានចូលទៅអង្គុយឡើយ។

ព្រះរាជា ត្រាស់សួរព្រះយសត្ថេរថា: «ព្រោះហេតុអ្វីបាន ជាទុកទីសេនាសនៈនេះឲ្យនៅទំនេរ?»

ព្រះថេរៈថ្វាយព្រះពរតបថា: «នឹងមានព្រះមហាថេរ១ អង្គទៀត ត្រូវលោកអង្គនោះគង់នៅត្រង់ទីសេនាសនៈនេះ»។

ព្រះរាជា ត្រាស់សួរទៀតថា: «ព្រះមហាថេរៈ មួយអង្គ នោះ ធំជាងលោកម្ចាស់ឬ?» ព្រះថេរៈ ថ្វាយព្រះពរតបថា: «ក្នុងកាលមុន ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រកាសថា: «ភិក្ខុដែលជា ចម្បងលើសជាងពួកអ្នកដែលបន្លឺសីហនាទ(នោះ) ឈ្មោះ បិណ្ឌោលភារទ្វាជៈ ព្រះថេរអង្គនោះ លោកចាស់ជាងអាត្មា ភាព»។

កាលព្រះរាជា ទ្រង់ព្រះសណ្ដាប់ពាក្យនេះហើយ ក៏ព្រឺ រោមព្រឺស្បែកខ្លាកឡើង ដូចជាឈើកទម្ពៈ (ក្ទម្ព) ដែលកំពុង មានផ្ការីកស្គុះស្គាយ ទ្រង់មានព្រះបន្ទូលទៀត ថា: « លោក

ដែលបានទាន់ បានឃើញព្រះតថាគតមានច្រើនអង្គឬ?»។

ព្រះថេរៈថ្វាយព្រះពរតបថា: «មានតែព្រះអរហន្តព្រះនាមបិណ្ឌោលមួយព្រះអង្គនោះ ដែលបានទាន់ បានឃើញព្រះពុទ្ធ កាលដែលព្រះអង្គទ្រង់ព្រះជន្ម នៅក្នុងលោកនេះ»។

ព្រះរាជាត្រាស់សួរថា: «ខ្ញុំនឹងឃើញព្រះអរហន្តនោះផងបានឬទេ?»

ព្រះថេរៈថ្វាយព្រះពរតបថា: «ព្រះអង្គគង់នឹងបានឃើញ លោកអង្គនោះ នឹងនិមន្តមកជួបមហារាជ ក្នុងកាលឥឡូវនេះ»។

ព្រះរាជាត្រាស់ដោយពេញព្រះរាជហឫទ័យថា: «ខ្លួនខ្ញុំនឹងបានសម្រេចប្រយោជន៍ដ៏ធំទូលាយហើយ ប្រសិនបើខ្ញុំបានឃើញព្រះថេរៈបិណ្ឌោល ជាបឋមក្នុងកាលឥឡូវនេះ ព្រោះហេតុតែមេត្តាចិត្តរបស់លោកដល់ខ្ញុំ»។ ខណៈនោះ ព្រះរាជាប្រណម្យព្រះហស្តរង់ចាំ ប្រឹងទតសម្លឹងឆ្ពោះទៅឯអាកាសវេហាស៍ លុះព្រះអង្គទស្សនាការព្រះថេរៈបិណ្ឌោល ដែលគួរនាដូចជាអង្គនៃអឡ្ឋចន្ទ្រ ហើយប្រហែលគ្នានឹងរាជ

ហង្ស មានព្រះអរហន្តជាច្រើនពាន់អង្គចោមរោមជាបរិវារ លោកនិមន្តចុះមកក្នុងទីនោះ ចូលទៅគង់លើសេនាសនៈជាខាងមុខព្រះយសត្ថេរ ក៏ពួកព្រះថេរៈទាំងបីសែនដែលគង់នៅត្រៀបត្រា ក្រោកឡើងព្រមគ្នាទាំងអស់ ធ្វើសេចក្ដីគោរពចំពោះព្រះមហាថេរអង្គនោះ។ ព្រះមហាក្សត្រិយ៍បានទ្រង់ទស្សនាការ ព្រះបិណ្ឌោលត្ថេរ លោកមានព្រះកេសដ៏សក្រោង មានចិញ្ចើមដ៏ក្រាស់ មានព្រះកាយដ៏ប្រដាប់ដោយសុកលក្ខណៈ និងអនុព្យញ្ជនៈទាំងឡាយ ជារបស់នៃព្រះប្រត្យេពុទ្ធ (បច្ចេកពុទ្ធ) ក៏ព្រះរាជាលុតព្រះជានុចុះផ្ទាល់នឹងផែនដី លើកកំបង់អញ្ជលីថ្វាយបង្គំប្រកបដោយអង្គប្រាំ ទ្រង់ឱនជប់ព្រះបាទព្រះថេរហើយងើបឡើង ព្រះអង្គបញ្ឈរព្រះជានុ ហើយត្រាស់នូវគាថានេះថា: «ឱព្រះថេរៈ! ទុកជាព្រះតថាគតព្រះអង្គនោះ ចូលព្រះនិព្វានហួសទៅហើយ គង់បានលោកម្ចាស់ ដែលមានព្រះជន្មនៅ ជាជំនួសស្នងព្រះអង្គ។ ដោយសេចក្ដីមេត្តាចិត្ត របស់លោកម្ចាស់ដល់ខ្ញុំ សូមលោកម្ចាស់ឲ្យទាននូវឱវាទ ដើម្បីខ្ញុំនឹងបានដាស់តឿនគំនិត

មារយាទខ្ញុំទៅតាមឱវាទនោះ[១]»។

កាលទ្រង់សូត្រគាថានេះចប់ហើយ ព្រះរាជាស្តេចសួរព្រះថេរៈថា «លោកម្ចាស់បានទាន់បានឃើញព្រះតថាគតមែនឬ?»

ព្រះថេរៈថ្វាយព្រះពរតបថា: «បពិត្រមហារាជ អាត្មាភាពបានឃើញព្រះតថាគតព្រះអង្គនោះ មានព្រះឆវីវណ្ណដ៏ពណ្ណរាយដូចជាដុំនៃមាសឆ្អិន ព្រះភក្ត្រព្រះអង្គដូចជាព្រះចន្ទ្រដ៏ពេញវង់ ព្រះកាយព្រះអង្គប្រដាប់ដោយលក្ខណៈទាំង៣២ ព្រះសូរសៀងព្រះអង្គ ធូន់ជ្រៅមុតហើយពីរោះអស្ចារ្យ (ហាក់ដូចជាសំឡេង) នៃព្រហ្ម ព្រះមហាករុណាព្រះអង្គមានគុហាជាទីសេនាសនៈ»។

ព្រះរាជាត្រាស់សួរទៀតថា: «លោកម្ចាស់បានឃើញព្រះមហាមុនីនៅត្រង់ទីណាខ្លះ?»។

ព្រះថេរៈថ្វាយព្រះពរតបថា: «កាលដែលព្រះសម្ពុទ្ធជាម្ចាស់ ព្រះអង្គអាស្រ័យនៅជាមួយនឹងពួកព្រះអរហន្តទាំង

---

[១] កាលព្រះបាទអសោកជួបនឹងព្រះថេរឧបគុប្តនោះ ក៏សូត្រគាថានេះដែរ។

៥០០អង្គ ក្នុងទីសម្រាប់នៅសំចតក្នុងគិម្ហរដូវ ជិតក្រុងរាជគ្រឹះនោះ អាត្មាភាពក៏នៅក្នុងទីនោះដែរ អាត្មាភាពបានទាំងចិញ្ចឹមជីវិតដោយលាភៈ និងសក្ការៈនៃបុញ្ញក្ខេត្តនោះផង»។

«កាលព្រះអង្គគង់នៅក្នុងនគរសាវត្ថី ព្រះអង្គបានសំដែងយមកប្បាដិហារ្យដ៏ធំសម្បើមអស្ចារ្យ ដើម្បីផ្ចាញ់ផ្ចាលពួកតិរ្ថិយ ទ្រង់និម្មិតជាព្រះពុទ្ធទាំងឡាយដ៏ថ្កើងរុងរឿង មុខគួរអស្ចារ្យពេក ហើយព្រះអង្គប្រែងដោយឫទ្ធិ ឲ្យបានឃើញជាក់ច្បាស់នឹងភ្នែកគ្រប់ៗគ្នា ព្រះរស្មីភ្លឺផ្ទេកផ្ទៀលធ្វាត់ឡើងទៅអាកាស ចាំងរហូតដល់ទៅស្ថានព្រហ្មឈ្មោះអកនិដ្ឋ ពេលនេះ អាត្មាភាពក៏នៅក្នុងទីនោះដែរ»។

«ក្នុងកាលជាខាងក្រោយ នៃការសម្តែងធម៌ប្រោសព្រះពុទ្ធមាតានៅស្ថានតាវត្តិង្ស ព្រះពុទ្ធស្តេចយាងចុះមក មានពួកទេវតាហែហាមអមព្រះអង្គ អាត្មាភាពក៏នៅក្នុងទីនោះដែរ»។

«កាលព្រះអង្គ ស្តេចយាងដល់មាត់ទ្វារនគរ សង្កស្ស អាត្មាភាពក៏នៅក្នុងទីនោះដែរ»។

«កាលនាងភិក្ខុនីឈ្មោះ ឧប្បលវណ្ណា សំដែងបាដិហារ្យ

និម្មិតធ្វើជាស្ដេចចក្រពត្តិ មានព្រះរាជបុត្រាមួយពាន់គត់មកថ្វាយបង្គំទៀបព្រះពុទ្ធនោះ អាត្មាភាពក៏នៅក្នុងទីនោះដែរ»

«កាលដែលនាងសុមាគធាក្នុងក្រុងបូណ៌វចនៈ បាននិមន្តព្រះសម្មាសម្ពុទ្ធទៅ ក៏ពួកព្រះអរហន្តទាំង ៥០០អង្គបានសំដែងឫទ្ធិបាដិហារ្យគ្រប់ៗអង្គ រហូតទៅដល់ក្រុងបូណ៌វចនៈ ពេលនោះ ខ្លួនអាត្មាភាពឯង បានទាំងសំដែងឫទ្ធិបាដិហារ្យអង្គុយនៅក្នុងរតនគុហា នាក្នុំរតនបព៌ត ហើយអាត្មាភាពក៏បានចូលទៅក្នុងក្រុងបូណ៌វចនៈនោះ[១] ដែរ»។

កាលដែលព្រះពុទ្ធចូលទៅក្នុងក្រុងរាជគ្រឹះ ព្រះអង្គកំពុងស្ដេចយាងទៅបិណ្ឌបាត គ្រានោះ មហារាជបានថ្វាយដុំដីដល់ព្រះអង្គនោះ រាជគុប្តៈបានប្រណម្យដៃជួយអនុមោទនាផង ពេលនោះ ព្រះពុទ្ធបានព្យាករឲ្យមហារាជ អាត្មាភាព

---

[១] ធម្មបទអដ្ឋកថាៈ «នាងចូឡសុភទ្ទាជាធីតានៃអនាថបិណ្ឌិកសេដ្ឋី ដែលបានស្វាមីទៅនៅឧគ្គនគរ បានរំលឹកពុទ្ធគុណ ហើយចាប់ផ្កាម្លិះ៨ក្ដាប់ អធិដ្ឋានឲ្យទៅនិមន្តព្រះសម្មាសម្ពុទ្ធមកទទួលភត្ត ព្រះអង្គបានជ្រាប ក៏និមន្តមកជាមួយនឹងព្រះអរហន្តទាំង៥០០ ដោយឥទ្ធិប្បាដិហារ្យ ជាសិរីសួស្ដីដ៏ប្រសើរអស្ចារ្យ ពួកអ្នកនគរនោះមានសេចក្ដីជ្រះថ្លា បានចាត់ចែងធ្វើមហាទានរហូតអស់៧ថ្ងៃ។

ក៏បានឃើញដែរ»។

ព្រះមហាក្សត្រាធិរាជ ត្រាស់សួរម្ដងទៀតថាៈ «ឱព្រះថេរៈ! លោកម្ចាស់គង់នៅឯណាអម្បាញ់មិញនេះ?»។

ព្រះថេរៈថ្វាយព្រះពរតបថាៈ «ថ្វាយព្រះពរមហារាជ! អាត្មាភាពនៅលើភ្នំគន្ធមាទនបព៌ត»។

ព្រះរាជាត្រាស់សួរថាៈ «មានភិក្ខុជាបរិវារលោកម្ចាស់ប៉ុន្មានអង្គ?»។

ព្រះថេរៈថ្វាយព្រះពរតបថាៈ «ភិក្ខុទាំងអស់៦០.០០០ មហារាជ! ពេលល្មមហើយ! ព្រោះហេតុអ្វី បានជាទ្រង់ត្រាស់សួរអាត្មាភាពច្រើនម្ល៉េះ? ល្មមពេលដែលនឹងព្រះរាជទានភត្ត ដល់ព្រះភិក្ខុសង្ឃហើយ លុះកាលជាខាងក្រោយភត្ត អាត្មាភាពនឹងដំណាលរឿងរ៉ាវអាត្មាភាពថ្វាយព្រះអង្គទៀត»។

ព្រះរាជាត្រាស់ថាៈ «ឱព្រះថេរៈ! ខ្ញុំប្រាថ្នានឹងប្រព្រឹត្តតាមដំបូន្មានលោកម្ចាស់ហើយ ប៉ុន្តែគំនិតរបស់ខ្ញុំ ដែលបានផ្ដួចផ្ដើមឡើងកាលជាន់ដំបូង ចំពោះត្រង់ទៅព្រះពុទ្ធជាម្ចាស់ ខ្ញុំសូមស្រោចពោធិព្រឹក្សសិន ហើយតទៅ ខ្ញុំនឹងប្រគេនភត្ត

ដល់ព្រះភិក្ខុសង្ឃ។ ព្រះបរមក្សត្រិយ៍ទ្រង់ត្រាស់ហៅសរមិត្រជាអ្នកចាត់ចែងក្នុងការបរិច្ចាគទាន ហើយមានព្រះរាជឱង្ការថា: ខ្ញុំបូជាទ្រព្យមួយសែនតម្លឹងមាសដល់ព្រះសង្ឃ ខ្ញុំនឹងស្រោចដើមពោធិព្រឹក្សដោយទឹកសុគន្ធជាតិ នឹងក្អមដ៏មានតម្លៃទាំងមួយពាន់។ អ្នកទាំងឡាយចូរវាយរគាំងប្រកាសប្រាប់ឈ្មោះខ្ញុំថា ជាទានបតីដែលជាអ្នកធ្វើទានដល់ប្រជុំសង្ឃដ៏ច្រើន អស់កាលនៃរដូវភ្លៀង៥ខែ[១]។

គ្រានោះ ព្រះកុនាលរាជឱរស ក្រោកឈរឡើងនៅទីខាងស្តាំព្រះមហាក្សត្រិយ៍ នៅស្លៀមពុំស្រដី គ្រាន់តែលើកម្រាមព្រះហស្តពីរឡើង ដែលសំគាល់ថា: «ខ្ញុំនឹងបូជាទ្វេគុណ» ហេតុនោះ ពួកជនទាំងអស់នាំគ្នាសើចគឹកកងឡើងទាំងព្រះរាជាក៏ ទ្រង់ព្រះសម្រួលដែរ ហើយព្រះអង្គត្រាស់សួររាធគុប្តសេនាបតីថា «អ្នកណាហ៊ានធ្វើអ្វីដូច្នោះ?»។

រាធគុប្តសេនាបតី ក្រាបទូលថា: «សូមទ្រង់ព្រះមេត្តា

---

[១] ក្នុងអាយុ-វង់-កឹង បញ្ចវស់ ប្រែថា:«ប្រជុំសង្ឃជាច្រើនមកធ្វើកុសលអស់៥ឆ្នាំ» តែបើពិនិត្យមើលតាមកំណើតដើមរបស់ពាក្យបញ្ចវស់ គួរនឹងប្រែថា: «អស់កាលនៃរដូវភ្លៀង៥ខែ» ហៅថាធ្វើបញ្ចវស់។

ប្រោស ក្នុងពួកមនុស្សជាច្រើនពាន់នេះ មានមនុស្សជាចំនួនច្រើន ដែលជាអ្នកចង់ធ្វើបុណ្យកុសលដោយក្រៃលែង»។

ព្រះរាជាត្រាស់បន្ថែមទៀតថា: «អញនឹងបូជាទ្រព្យបីសែនតម្លឹងមាសដល់ព្រះសង្ឃ អញនឹងស្រោចដើមពោធិព្រឹក្សដោយទឹកសុគន្ធជាតិ នឹងក្អមទាំងបីពាន់សុទ្ធសឹងមានតម្លៃ»។

ខណៈនោះ ព្រះកុនាលរាជឱរស លើកម្រាមព្រះហស្ត ៤ឡើងម្តងទៀត។

ព្រះរាជាត្រាស់សួររាជគុប្តសេនាបតីថា: «អ្នកណាហ្នឹងហ្ន៎! វាចង់តតាំងនឹងអញ?»។

រាជគុប្តសេនាបតីលុតជង្គង់ចុះ ហើយក្រាបបង្គំទូលថា: «សូមតេជៈ! នរណាឡើយ ហ៊ានតតាំងនឹងព្រះនរិន្ទ្រនេះ! មានតែព្រះកុនាលៈជារាជឱរស ហើយជាកុមារតូចដែលតែងក្រសាលលេងជាមួយនឹងព្រះរាជបិតា»។

ព្រះមហាក្សត្រាធិរាជ ទតសម្លឹង ឆ្ពោះទៅខាងស្តាំព្រះអង្គបានទស្សនាព្រះកុនាលរាជឱរស ហើយទើបត្រាស់

នឹងព្រះមហាថេរថា: «ខ្ញុំសូមឧទ្ទិសឃ្លាំងរតនវត្ថុ[១] របស់ខ្ញុំ បាទបរិចារិកាទាំងអស់របស់ខ្ញុំ ពួកមុខមន្ត្រីរបស់ខ្ញុំ ព្រមទាំងខ្លួនខ្ញុំ កូនខ្ញុំឈ្មោះកុនាលៈ និងមនុស្សដទៃទៀត បូជាវត្ថុទាំងអស់នេះទៅព្រះភិក្ខុសង្ឃ។ ខ្ញុំប្រាថ្នាចង់ឲ្យគេប្រកាសនាមរបស់ខ្ញុំ ឲ្យបានជាក់ច្បាស់ថា ជាអ្នកបរិច្ចាគទាន ដល់ប្រជុំសង្ឃដ៏ច្រើន អស់កាលនៃរដូវភ្លៀង៤ខែ»។

កាលទ្រង់បរិច្ចាគទានរួចស្រេចហើយ ក៏ពួកភិក្ខុសង្ឃអនុមោទនាថ្វាយព្រះពរ លុះព្រះអង្គទទួលត្រេកអរ និងអនុមោទនាពរនេះ ស្ដេចប្រោសឲ្យសាងកំពែង ក្នុងទិសទាំង៤នៃពោធិព្រឹក្ស ហើយស្ដេចយាងទៅលើខឿនពោធិព្រឹក្សនោះ ទ្រង់យកក្អមទាំង ៤ពាន់ដ៏មានតម្លៃ ពេញដោយសុគន្ធវារី ព្រះអង្គស្រោចដើមពោធិព្រឹក្សនោះ លុះទ្រង់ស្រោចរួចហើយ ទើបប្រគេនភត្តដល់ព្រះភិក្ខុសង្ឃ។

ព្រះយសត្ថេរថ្វាយព្រះពរថា: «ឱព្រះរាជា! ព្រះអង្គបានជួបនឹងបុញ្ញក្ខេត្តមួយដ៏ឧត្តមបំផុត សូមទ្រង់កុំព្រួយព្រះ

---

[១] ក្នុងទិវ្យាវទាននិងអាយុ-វង-គឹង ស្ដេចរក្សាឃ្លាំងរតនវត្ថុទុក។

រាជហឫទ័យថានឹងបានទទួលព្រះកិត្តិយសដទៃផ្សេងទៅទៀតឡើយ»។

ព្រះរាជា ស្ដេចអង្គាសភោជនាហារដោយផ្ទាល់ខ្លួនព្រះអង្គរហូតដល់ពួកសាមណេរតូចៗ។

គ្រាមួយមានសាមណេរពីររូប ជាមិត្រសំឡាញ់ធ្លាប់គោរពដល់គ្នានិងគ្នា សាមណេរមួយរូបចាប់ទ្រាបប្រគេនទៅសាមណេរមួយ ហើយសាមណេរនោះ ប្រគេនទ្រាបត្រឡប់មកវិញដដែល។ សាមណេរមួយរូប ប្រគេននំកឹងទៅសាមណេរមួយ ហើយសាមណេរនោះ ប្រគេននំកឹងមកវិញដដែល។ សាមណេរមួយរូប ប្រគេនដំណាប់ទៅសាមណេរមួយ ហើយសាមណេរនោះ ក៏ប្រគេនដំណាប់មកឲ្យវិញដដែល ឲ្យគ្នាទៅវិញទៅមកយ៉ាងនេះ ព្រះមហាក្សត្រាធិរាជទតឃើញ ទើបស្ដេចទ្រង់ព្រះសម្រួលដោយព្រះតម្រិះថា: «សាមណេរទាំង២នុ៎ះ លេងទៅវិញទៅមកដូចជាទារក»។ លុះទ្រង់អង្គាសភោជនាហាររហូតទៅដល់មុខព្រះថេរៈៗ ក៏បានថ្វាយព្រះពរ សួរថា: «ឱព្រះរាជា! កាលបើព្រះអង្គទតឃើញ

វត្ថុណាមួយ ផុតចក្ខុវិស័យ ទ្រង់នឹងមិនបាននឹកនិទ្ទាក្នុងព្រះរាជហឫទ័យទេឬ?»។ ព្រះរាជាត្រាស់តបថា: «ទេលោកម្ចាស់ តែពេលនេះ ខ្ញុំឃើញច្បាស់នឹងភ្នែកជាសាមណេរទាំងពីររូបនុ៎ះ កំពុងលេងដូចជាទារកតូចៗ»។

ព្រះថេរៈថ្វាយព្រះពរថា: «បពិត្រមហារាជ! កុំស្តេចនិន្ទាឡើយ សាមណេរទាំងពីររូបនុ៎ះ ជាព្រះអរហន្តបានក្រេបផឹកនូវទឹកអម្រឹតមហានិព្វានហើយ»។

ព្រះបរមក្សត្រិយ៍ ទ្រង់ព្រះសណ្តាប់ថេរវាចានោះហើយ ព្រះរាជហឫទ័យពេញទៅដោយសេចក្តីរីករាយ ទើបទ្រង់ព្រះតម្រិះថា: «អាត្មាអញនឹងប្រគេនសំពត់មានសាច់ម៉ដ្ឋដល់ព្រះសង្ឃឲ្យបានគ្រប់រូបទាំងអស់»។

ខណៈនោះសាមណេរទាំងពីររូបដឹងព្រះរាជតម្រិះដូច្នោះ ទើបប្រឹក្សាគ្នាថា: «ឥឡូវនេះ យើងគួរនឹងធ្វើឲ្យព្រះរាជាទ្រង់មានព្រះរាជសទ្ធា ព្រមទាំងសេចក្តីគោរពទ្វេគុណឡើងទៀត»។

គ្រានោះ សាមណេរទាំងពីររូបនោះ សាមណេរមួយរូបប្រុងប្រៀបស្នូក សម្រាប់ជ្រលក់ មួយរូបទៀតនាំយកនូវ

គ្រឿងជ្រលក់មកក្នុងទីនោះ។ព្រះរាជាទ្រង់ទតឃើញដូច្នោះ ទើបមានព្រះបន្ទូលនឹងសាមណេរទាំងពីរនោះថា: «លោកម្ចាស់នាំគ្នាធ្វើអ្វីហ្នឹង ញាប់ដៃម្ល៉េះ?»។

សាមណេរថ្វាយព្រះពរថា: «ព្រោះតែអាត្មាភាពទាំងពីររូបនេះ ទើបព្រះអង្គមានព្រះរាជបំណងនឹងព្រះរាជទានសំពត់មានសាច់ម៉ដ្ឋ ដល់ព្រះភិក្ខុសង្ឃទូទៅ គ្រានេះ អាត្មាភាពទាំងពីររូប ប្រុងប្រៀបគ្រឿងជ្រលក់ត្រៀមទុកឲ្យហើយ ដើម្បីនឹងជ្រលក់សំពត់ទាំងនោះ»។

គ្រាទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ព្រះរាជាស្ដេចទ្រង់ព្រះចិន្ដាថា: «សាមណេរទាំងពីររូបនេះ ដឹងនូវគំនិតរបស់អញ» ហើយស្ដេច ទ្រង់សោមនស្សរីករឹតតែខ្លាំងឡើងទៀត ទើបព្រះអង្គថ្វាយបង្គំផ្ទាល់នឹងផែនដី ដោយបញ្ចង្គប្រតិស្ឋាន គោរពចំពោះព្រះបាទសាមណេរទាំងពីររូបនោះ ស្ដេចងើបឡើងប្រណម្យព្រះហស្ដត្រាស់ថា: «ពួកញាតិមិត្រ និងពួកពលជាបរិវាររបស់ខ្ញុំ បានសេចក្ដីចំរើនផលដ៏ធំទូលាយ ដោយបានជួបនឹងបុញ្ញក្ខេត្តយ៉ាងប្រសើរបំផុតនេះ ឥឡូវនេះខ្ញុំ

នឹងបរិច្ចាគវត្ថុដែលខ្ញុំអាចនឹងបូជាបានទាំងអស់នោះ»។ ព្រះមហាក្សត្រិយ៍ត្រាស់នឹងសាមណេរទាំងពីររូបនោះថា: «ព្រោះដោយសារគុណានុភាពលោកម្ចាស់ ទើបខ្ញុំបានបូជាត្រៃចីវរដល់ព្រះភិក្ខុសង្ឃគ្រប់រូបទូទៅ»។

តពីនោះមក ព្រះបាទអសោក បានធ្វើនូវបញ្ចវស័បង្អើយព្រះអង្គបានព្រះរាជទានទ្រព្យមួយសែនតម្លឹងមាស ព្រះរាជធានីរបស់ព្រះអង្គ ពួកបាទបរិចារិកា ពួកសេនាបតី ខ្លួនរបស់ព្រះអង្គ ព្រះរាជឱរសព្រះនាមកុនាលៈ និងវត្ថុឯទៀតជាច្រើនដល់ព្រះសង្ឃ ហើយស្តេចយាងត្រឡប់ទៅរាជនិវេសន៍ព្រះអង្គវិញ។

ខាងក្រោយ ដែលព្រះបាទអសោក ទ្រង់មានព្រះរាជសទ្ធាជ្រះថ្លានឹងធ្វើសេចក្តីគោរព (ចំពោះព្រះធម៌របស់ព្រះពុទ្ធនោះមក) ទ្រង់បានសាងព្រះស្តូប ៨៤.០០០ និងធ្វើកិច្ចបញ្ចវស័នោះ ក៏ពួកអ្នកស្រុកនិងអ្នកនគរពេញទាំងសកលជម្ពូទ្វីប នាំគ្នាមានប្រសាទសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធព្រះធម៌ឡើង។

# អវទាននៃព្រះអនុជរបស់ព្រះបាទអសោក

ព្រះអនុជរបស់ព្រះបាទអសោក ព្រះនាមវីតសោក[១] ជាអ្នកមានសទ្ធាជឿក្នុងធម៌វិន័យរបស់ពួកតិរ្ថិយ គោរពរាប់អានតែពួកតិរ្ថិយនោះ តែងតែត្មះតិះដៀលព្រះធម៌ ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ព្រះអនុជចូលចិត្តជឿថា: «ពួកសមណ:ជាសាក្យបុត្តិយ៍ ដែលចេញបួសហើយបានអមតមហានិព្វាននោះ សូម្បីតែម្នាក់ក៏គ្មានផង»។

គ្រានោះ ព្រះបាទអសោក ត្រាស់នឹងវីតសោកថា: «ដូចម្ដេចបានជាអ្នកដឹងបាន យ៉ាងនោះ?»។

ព្រះអនុជក្រាបទូលថា: «ព្រោះពួកសមណ:ជាសាក្យបុត្រទាំងនោះ លោកវៀរចាកសេចក្ដីប្រតិបត្តិដ៏លំបាក ហើយស្វែងរកតែសេចក្ដីសុខសម្រាន្ត»។

---

[១] ច្បាប់ដើមដាក់តាមពាក្យចិនថា: សុគតោ អ្នកប្រែថាសុខទគ្គ? បើតាមបែបនេះរកប្រាដកមិនបាន តែដែលខ្ញុំដាក់ថាសេចក្ដីវីតសោកនោះ ដោយអាងខាងដើមថា: ព្រះមាតារបស់អសោកមានព្រះរាជបុត្រមួយទៀតឈ្មោះវីតសោក។ ក្នុងច្បាប់អាយុ-វង៉-កឹង និងទីវ្យាវទានក៏ថា វីតសោកដែរ ហេតុនោះ វីតសោកទើបត្រូវជាង បើសំឡឹងយកសេចក្ដីជាប្រមាណ ឃើញជាមិនប្លែកគ្នាទេ ព្រោះសុខទគ្គ ប្រែថាឲ្យសុខ ឯវីតសោក(គឺថាបានសុខដូចគ្នា)។

ព្រះមហាក្សត្រិយ៍ ត្រាស់នឹងវីតសោកជាព្រះអនុជថា: «ចូរអ្នកបិទទុកឲ្យជិត កុំជឿវត្ថុដែលគេមិនគួរជឿដូច្នោះឡើយ ហើយកុំត្មះតិះដៀល ដល់អ្នកមានសទ្ធាល្អឲ្យសោះ ត្រូវតែអ្នកមានសទ្ធាដ៏ជ្រៅទូលាយ ជឿក្នុងព្រះពុទ្ធ ក្នុងព្រះធម៌ និងព្រះសង្ឃឡើង»។ ក្នុងខណៈដទៃទៀត ព្រះបាទអសោក ស្ដេចកំពុងយាងប្រពាត (បរបាញ់) ជាមួយនឹងព្រះវីតសោក ជាព្រះអនុជ ទ្រង់ទស្សនាការព្រាហ្មណ៍ម្នាក់ កំពុងតែកំដៅខ្លួន ដោយគំនរភ្លើងទាំងប្រាំភ្នក់ វីតសោកជាព្រះអនុជ មានចិត្តពេញទៅដោយសទ្ធា និងសេចក្ដីគោរព ទើបចូលទៅជិត ទ្រង់ថ្វាយព្រះបង្គំជើងព្រាហ្មណ៍ ហើយត្រាស់សួរថា: «លោកប្រព្រឹត្តទុក្ករកិរិយាដ៏លំបាកនេះ ប៉ុន្មានឆ្នាំមកហើយ»។

ព្រាហ្មណ៍តបថា: «ដប់ពីរឆ្នាំហើយ»។

«លោកទម្លាប់បរិភោគអ្វីជាអាហារ?»

ព្រាហ្មណ៍តបថា: «បរិភោគតែផ្លែឈើ និងមើមឈើ លោកបិទរាំងកាយ ដោយសំលៀកបំពាក់អ្វី អាត្មាបិទបាំង

កាយ តែដោយសំលៀកបំពាក់ស្មៅ»។

«លោកយកអ្វីធ្វើជាទីដេក?»។

ព្រាហ្មណ៍តបថា: «កម្រាលស្មៅជាគ្រែដេករបស់អាត្មា»។ (ព្រះវីតសោក) សួរថា: «កិច្ចដែលលោកធ្វើទាំងនោះ មានវត្ថុអ្វីដែលលំបាកក្រៃលែងជាងទៅទៀត?»។

ព្រាហ្មណ៍តបថា: «កាលបើអាត្មាឃើញសត្វម្រឹគក្នុងរដូវ ដែលវាក្ដាញីឈ្មោលវា ក៏កើ្តើងរាគៈរឹតរួតខ្លួនអាត្មា ធ្វើឲ្យរសាប់រសល់សព្វសព៌ាង្គ ទុំះឯង ជាកិច្ចដែលលំបាកបំផុតរបស់អាត្មា»។

វីតសោក ទើបត្រាស់ថា: «ឱហ្ន៎! លោកអ្នកបិទបាំងកាយតែដោយសំលៀកបំពាក់ដ៏សៅហ្មង បរិភោគតែអាហារដ៏សៅហ្មង ហើយលោកនៅតែមានរាគតណ្ហានៅឡើយទៀត ចំណង់បើពួកសមណៈ ជាសាក្យបុត្រ ដែលបិទបាំងកាយតែដោយសំលៀកបំពាក់ដ៏ប្រសើរ បរិភោគតែអាហារមានរសឆ្ងាញ់ ដូចម្ដេចឡើយនឹងរម្ងាប់រាគតណ្ហាបាន ក៏ស្ដេចអសោកជាព្រះជេដ្ឋាអញ មិនដែលដឹងរឿងប្រព្រឹត្តតបធម៌

នេះសោះឡើយ បានជាស្ដេចចាញ់បោកពួកសមណៈ ជាសក្យបុត្រិយ៍ដល់ម្ល៉ោះ»។

ព្រះបាទអសោក ទ្រង់ព្រះសណ្ដាប់ពាក្យព្រះអនុជហើយ ទើបទ្រង់ត្រាស់នឹងពួកសេនាបតីព្រះអង្គថាៈ «យើងត្រូវប្រើឧបាយកល យ៉ាងវិសេសមួយ ដើម្បីនឹងឲ្យវីតសោក មានប្រសាទសទ្ធាជ្រះថ្លា ក្នុងព្រះធម៌របស់ព្រះសក្យមុនី ហើយនិងព្រះអមតមហានិព្វាន»។

ពួកសេនាបតី ក្រាបទូលថាៈ «បពិត្រមហារាជ យើងនឹងតាមព្រះរាជឱង្ការព្រះអង្គ»។

ព្រះមហាក្សត្រិយ៍ ទ្រង់ដោះគ្រឿងប្រដាប់ព្រះសិរ និងមកុដ ដែលជាគ្រឿងសម្គាល់នៃព្រះរាជា ហើយទើបទ្រង់ព្រះពស្ត្រសម្រាប់ស្រង់ ស្ដេចយាងចូលទៅស្រង់ទឹកក្នុងបន្ទប់ វេលានោះពួកសេនាបតីក្រាបទូលព្រះអង្គម្ចាស់វីតសោកថាៈ «កាលបើព្រះបាទអសោកទិវង្គតទៅ ព្រះអង្គនឹងជាក្សត្រិយ៍តំណាងឡើងពេលនេះ សូមព្រះអង្គទ្រង់គ្រឿងប្រដាប់ព្រះសិរ និងមកុដនេះ លមើល នឹងបានឃើញថាៈ «ព្រះអង្គល្អ

សមរម្យជាក្សត្រិយ៍យ៉ាងណាដែរឬទេ?»។

ព្រះវីតសោក ក៏ជឿតាមពាក្យពួកសេនាបតី បាន ប្រដាប់ព្រះកាយ ដោយខត្តិយាភរណៈដូច្នោះហើយ ស្តេចឡើងប្រដាប់លើបល្ល័ង្ករាជ្យ ស្រាប់តែព្រះរាជា ស្តេចចេញចាកបន្ទប់ទឹក ទ្រង់ទតឃើញវីតសោកជាព្រះអនុជ ប្រថាប់លើបល្ល័ង្ករាជ្យ ក៏ព្រះអង្គត្រាស់គម្រាមថា: «អញមិនទាន់ស្លាប់នៅឡើយ ឯងហ៊ានសោយរាជ្យទៅហើយ?» ខណៈនោះ ព្រះរាជាទ្រង់ត្រាស់ព្រះសូរសៀងដ៏ខ្លាំងៗថា: «យីអ្នកណាហ្នឹងវឹយ!» គ្រានោះ ពួកចណ្ឌាល (ពេជ្ឈឃាត) ដែម្នាងកាន់ដាវ ដែម្នាងកាន់រគាំង លេចឡើងស្រ មក នាំគ្នាចូលទៅក្រាបទូលព្រះរាជាថា: «សូមទ្រង់ព្រះមេត្តាប្រោស ព្រះអង្គមានព្រះរាជប្រាថ្នាឲ្យចាត់ការយ៉ាងណា?

ព្រះបរមក្សត្រិយ៍ ត្រាស់តបថា: «គ្រានេះ ត្រូវយើងលះបង់ចៅវីតសោកចោល យើងអនុញ្ញាត ឲ្យអ្នករាល់គ្នាវាយប្រដៅផ្ចាញ់ផ្ចាលវាឲ្យយើង»។

ពួកសេនាបតីក្រាបទូលសូមទោសថា: «ព្រះវីតសោក

ជាព្រះអនុជព្រះអង្គដ៏ពិតប្រាកដណាស់ សូមទ្រង់ព្រះមេត្តាប្រោស ទ្រង់ព្រះរាជទានទោស កុំផ្ដន្ទាកុំផ្ចាញ់ផ្ចាលឡើយ»។

ព្រះរាជា ត្រាស់ថា: «យើងអនុកូល តាមពាក្យអ្នកទាំងឡាយ យើងព្រមឲ្យវា សោយរាជ្យបាន ៧ថ្ងៃ សិនចុះ តែតទៅនឹងត្រូវពិឃាតជីវិតបង់»។

ក្នុងពេល៧ថ្ងៃនោះ គេលេងតូរ្យតន្ត្រីរាប់ដោយសែន ក្មេងពួកព្រាហ្មណ៍ ទាំងមួយសែន ក៏មកប្រជុំគ្នាចំពោះព្រះភក្ត្រ ប្រណម្យដៃពោលសរសើរគុណព្រះវីតសោក ពួកស្រីគំនាល់ទាំងមួយសែន ចោមរោមគាល់បំរើត្រៀបត្រា ឯពួកចណ្ឌាល(ពេជ្ឈឃាត)ទាំង៤មានដៃប្រឡាក់ដោយឈាមនៅស្រស់ៗ ធ្វើអាការហាក់ដូចជាចង់ពិឃាតអ្នកណាមួយ ស្រែកសូរស័ព្ទទ្រហឹងអឹងកងនៅមាត់ទ្វារទាំង៤ថា: «រាត្រីមួយបានកន្លងផុតទៅហើយ នៅតែ៦រាត្រីទៀតទេ យើងនឹងទំលាយកាយអ្នកឯង យើងនឹងផ្ដាច់បង់អវយវៈអ្នកឯង យើងនឹងពិឃាតជីវិតអ្នកឯង សេចក្ដីស្លាប់របស់អ្នកឯងជិតហើយ» ពួកវាធ្វើអាការក្នុងថ្ងៃទី១ដូច្នោះហើយ វាធ្វើរៀងៗមក រហូត

មកដល់ថ្ងៃទី៧ វាស្រែកតែសូរសំឡេងបែប១។

លុះថ្ងៃទី ៧ កន្លងផុតហើយ គេនាំព្រះចៅវីតសោកទៅគាល់ព្រះរាជា ស្ដេចទ្រង់ត្រាស់សួរព្រះអនុជថា: «ក្នុងពេល ៧ថ្ងៃនេះ ឯងសប្បាយចិត្តណាស់ទៅឬ?»។

ព្រះវីតសោកតបថា: «ក្នុងពេល ៧ថ្ងៃនេះ ចក្ខុខ្ញុំមិនបានឃើញ រូបារម្មណ៍អ្វីទេ អណ្ដាតខ្ញុំ មិនបានលិទ្ធភ្លក់រសារម្មណ៍អ្វីទេ ព្រោះអ្វី? ព្រោះថា ខ្ញុំបានឃើញពួកចណ្ឌាល (ពេជ្ឈឃាត) វាស្រែកផង លើកដាវផ្ដាឡើងផង តាំងតែពីថ្ងៃទី១ កន្លងហើយ វាថា: «ឯងសោយរាជ្យបាន១ថ្ងៃហើយ ឯងនៅតែត្រឹម៦ថ្ងៃទៀតទេ» តែបែបនេះរាល់ថ្ងៃ រហូតមកដល់ថ្ងៃទី៧ ខ្ញុំព្រះអង្គជាទុក្ខព្រួយ ស្រៀវសាច់នឹងមរណភ័យមកយាយី ខ្ញុំព្រះអង្គរំពឹងគិតថប់បារម្ភស្ញែងខ្លាច ក្នុងពេលរាត្រីទាំងអស់នោះ ខ្ញុំព្រះអង្គមិនអាចនឹងផ្ទំបានទេ បើដូច្នេះ តើសេចក្ដីសុខសម្រាន្តនឹងមានដល់ខ្លួនខ្ញុំព្រះអង្គដូចម្ដេច?»។

ព្រះមហាក្សត្រិយ៍ ត្រាស់តបថា: «គ្រាន់តែជាទុក្ខ និងមរណភ័យ ដែលនឹងបំផ្លាញជីវិតមួយប៉ុណ្ណោះ ឯងថាមិន

ដឹងរសនៃសេចក្ដីសុខក្នុងភាពជារាជាធិបតីទៅហើយចំណង់បើពួកសមណៈ ជាសក្យបុត្រ លោកតែងនឹកសញ្ជឹងជាទុក្ខព្រួយ ដល់សេចក្ដីលំបាកនានា ដែលធ្វើឲ្យកើតទុក្ខ គឺៈ ជាតិជរា ព្យាធិ និងមរណៈ សេចក្ដីលំបាកនៃពួកអ្នកដែលធ្លាក់ទៅសោយទុក្ខក្នុងនរក មានភ្លើងឆេះ ផ្សាខ្លោចផ្សេងៗគ្រប់យ៉ាង សេចក្ដីលំបាក នៃពួកសត្វតិរច្ឆាន ដែលមានសេចក្ដីតក់ស្លុតជាទម្ងន់ និងការត្រូវពួកសត្វឯទៀត ស៊ីជាអាហារ សេចក្ដីលំបាក នៃពួកប្រេត ដែលក្រហល់ក្រហាយ ដោយសេចក្ដីស្រេកឃ្លានៗ ក្នុងពួកមនុស្សនេះ អ្នកណាដែលជាអ្នកមានសេចក្ដីសុខ គង់តែមានសេចក្ដីទុក្ខលំបាកជាប់តាមមក ចាំបាច់និយាយទៅថ្វីដល់ពួកសត្វដែលមិនមានសេចក្ដីសុខនោះ សូម្បីទេវតាទាំងឡាយដែលជាអ្នកសោយតែសេចក្ដីសុខផងក៏ដោយ ក៏គង់តែមានទុក្ខព្រួយនឹងការច្យុតិទៅក្នុងអនាគតដែរៗ ក្នុងកិរិយាបូករួមនៃភពទាំង៣ សត្វដែលមានជីវិតទាំងឡាយគ្រប់ចំពូក រមែងឈឺកាយឈឺចិត្ត ហើយសេចក្ដីលំបាកទាំងអស់នោះ បង្ខំជម្រុញទៅរកសេចក្ដីស្លាប់

នឹងធ្វើទុក្ខបុកម្នេញពួកសត្វ ឲ្យបានសេចក្តីក្រហល់ក្រហាយ។ ខន្ធទាំងឡាយ៥ដូចជាពួកចណ្ឌាល (ពេជ្ឈឃាត) ដែលកាន់ដាវផ្លាឡើងនឹងប្រហារជីវិត។ អាយតនៈទាំងឡាយ៦ ដូចជាភូមិដែលគេបំផ្លាញហើយ។ អារម្មណ៍ទាំងឡាយ[១]៥ ដូចជាចោរប្លន់ដែលជាខ្មាំងសត្រូវ។ ពួកសត្វទាំងអស់ក្នុងភពទាំង៣ សុទ្ធតែត្រូវភ្លើងគឺអនិច្ចតាធម៌ឆេះបំផ្លាញនៅជានិច្ច។ វត្ថុទាំងអស់មិនទៀង ជាទុក្ខ សូន្យទៅទទេ មិនមានជារបស់ខ្លួន ព្រោះហេតុដូច្នោះបានជាគេថា: ពួកសមណៈ ជាសក្យបុត្រ មិនបាច់ប្រព្រឹត្តធ្វើកិរិយាដ៏លំបាក ហើយលោកបានដល់នូវអមតមហានិព្វាន មិនមែនឬ? ចិត្តរបស់ពួកសមណៈ មិនមែនសៅហ្មងដោយកាមរាគៈទេ កាមរាគៈនោះ ដូចជាទឹកដែលមិនស្ថិត ជាប់នៅលើត្របក នៃផ្កាឈូកឡើយ ពួកសមណៈទាំងនោះ មានចិត្តនឿយណាយ នឹងវដ្តសង្សារ ហើយទើបលោកភ្ញៀចខ្លួន ចេញចាកភពទៅបាន ចុះបើលោកប្រព្រឹត្តធ្វើយ៉ាងដូច្នោះហើយ ដូចម្តេចបានជាមិនបាន

[១] រូប សំឡេង ក្លិន រស និងសម្ផស្ស។

សម្រេចផល គឺអមតមហានិព្វាននៅឡើយ?»។

ព្រះបាទអសោក ទ្រង់ទូន្មានព្រះវីតសោកជាព្រះអនុជគ្រប់បែបយ៉ាងដូច្នេះហើយ ខណៈនោះ វីតសោកប្រណម្យព្រះហស្ត ហើយទូលព្រះរាមថា: «បពិត្រមហារាជ! ពេលនេះ ខ្ញុំសូមដល់នូវព្រះរតនត្រ័យជាទីពឹងទីរលឹក»។

គ្រានោះ ព្រះបាទអសោក កៀកព្រះសូរង់ព្រះអនុជហើយត្រាស់ថា: «យើងមានប្រាថ្នាចង់ធ្វើឯងឲ្យមានប្រសាទសទ្ធាជ្រះថ្លាក្នុងព្រះធម៌របស់ព្រះពុទ្ធ ហើយឲ្យឯងគិត នឹករលឹកព្រះធម៌នោះឡើង ព្រោះដូច្នោះ បានជាយើងធ្វើឧបាយកលនេះដោយពិតនោះ យើងមិនសម្លាប់ឯងទេ»។

គ្រានោះ ព្រះវីតសោកបានថ្វាយគ្រឿងសុគន្ធជាតិ និងផ្កាកម្រងដល់ព្រះស្តូបទាំងឡាយរបស់ព្រះពុទ្ធហើយ បានទៅស្តាប់ធម៌ទេសនា ទ្រង់បានធ្វើសក្ការបូជាដល់ពួកភិក្ខុសង្ឃហើយស្តេចយាងតម្រង់ ចូលទៅកាន់ វត្តកុក្កុដារាម លុះស្តេចយាងទៅដល់ ថ្វាយបង្គំព្រះយសត្ថេរហើយ ទើបប្រថាប់នៅក្នុងទីចំពោះព្រះភក្ត្រព្រះថេរៈ ស្តាប់ធម៌ទេសនា។

លំដាប់នោះ ព្រះថេរៈពិចារណាមើលឧបនិស្ស័យ ក្នុងភព មុនរបស់ព្រះវីតសោក ក៏ជ្រាបក្វាមរហូតដល់កុសលមូលជា បារមីរបស់ព្រះអង្គ ដែលបានសាងមកទុំហើយ ជាតិនេះជា បច្ឆិមជាតិ ត្រូវព្រះអង្គស្តេចចូលកាន់ព្រះនិព្វាន ក្នុងអត្តភាព ជាបច្ចុប្បន្ននេះឯង ព្រោះហេតុនោះ ព្រះថេរៈទើបសំដែង សរសើរការបំពេញព្រហ្មចារ្យ ដើម្បីដឹកនាំឲ្យស្តេចទ្រង់បព្វជ្ជា។

ព្រះវីតសោក លុះបានស្តាប់ធម៌ព្រះថេរៈនោះហើយ ក៏កើតបីតិ ផ្សព្វផ្សាយឡើង ព្រះអង្គ មានសេចក្តីចំណង់ នឹងសូមផ្នួសក្នុងធម៌វិន័យរបស់ព្រះពុទ្ធ ទើបស្តេចងើបឡើង ប្រណម្យអញ្ជលី ហើយត្រាស់នឹងព្រះថេរៈថា: «ឥឡូវនេះ ខ្ញុំ ប្រាថ្នា ចង់សូមបព្វជ្ជាក្នុងធម៌វិន័យរបស់ព្រះពុទ្ធ និងបាន សិក្សាក្នុងផ្លូវដ៏ប្រសើរនេះ»។

ព្រះថេរៈ តបថា: «កូនអើយ ព្រះអង្គ ចូរទូលសេចក្តី ប្រាថ្នាឲ្យព្រះរាជាទ្រង់ជ្រាបជាមុនសិន»។

គ្រានោះ ព្រះវីតសោក ក៏ស្តេចទៅទូលព្រះរាមថា: «បពិត្រមហារាជ! សូមព្រះអង្គព្រះរាជទាន ព្រះរាជានុញ្ញាត

បព្វជ្ជាដល់ខ្ញុំព្រះអង្គ កាលពីមុននេះ ខ្ញុំព្រះអង្គ ជាមនុស្សពាលឃោរឃៅ ដូចជាកុញ្ជរចុះប្រេងហើយឥតកង្វេរ (នឹងប្រដៅ) ឱព្រះរាជា! ព្រះអង្គបានតម្រង់ខ្ញុំដោយកង្វេរ ព្រះអង្គបានហ្វឹកហ្វឺនខ្ញុំឲ្យបានសុភាពរាបសាឡើង សូមព្រះមហាករុណាទិគុណ ទ្រង់ព្រះរាជទាន ព្រះរាជានុញ្ញាតបព្វជ្ជាក្នុងព្រះពុទ្ធសាសនា ក្នុងទីដែលជាប្រទីបពន្លឺភ្លឺព្រោងព្រាយឲ្យដល់ខ្ញុំព្រះអង្គ»។

ព្រះបរមក្សត្រ លុះទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ស្ដេចកៀកព្រះស្ងួនព្រះអនុជ មានអស្សុជលដ៏ពេញនេត្រា ស្ដេចទ្រង់ព្រះកន្សែងខ្សឹកខ្សួលរៀបរាប់ថា: «ឱអនុជអើយ! ចូរឯងលះចោលសេចក្ដីប្រាថ្នានេះចេញ! ព្រោះហេតុអ្វី? ព្រោះថាបព្វជិត តែងប្រព្រឹត្តចិញ្ចឹមជីវិត ជាមួយនឹងនរជាតិដ៏ថោកទាបសក្តិ តែងប្រើប្រាស់សំពត់បង្សុកូល ដែលរើសមកចាកគំនរសម្រាម ជារបស់ដែលទាស:គេបោះបង់ចោល ចំណែកអាហារសោត ក៏សូមបានតែសំណល់អាហារអំពីគេមកបរិភោគ ពេលយប់នៅតែក្រោមព្រឹក្សា មានស្មៅនិងស្លឹក

ឈើជាកម្រាល ក្នុងពេលអាពាធ ព្យាបាលជម្ងឺតែដោយឱសថអស់ជម្រើសពីគេ។ តាំងតែពីកុមារមក ឯងជាសុខុមាលជាតិ គួរជាទីពិតពិលរមិលមើល ឯងនឹងមិនអាចអត់ធនសេចក្ដីស្រេកឃ្លាន កំដៅថ្ងៃ និងខ្យល់ដ៏ត្រជាក់រងាបានឡើយ ចូរទប់ចិត្តក្នុងសេចក្ដីប្រាថ្នានេះចេញហ្មាអនុជ!»

ព្រះវីតសោក ក្រាបទូលស្នងថា: «ខ្ញុំប្រាថ្នាចង់បួសឥឡូវនេះ មិនមែនព្រោះខ្ញុំនឿយណាយ នឹងរាជសម្បត្តិទេ មិនមែនព្រោះខ្ញុំ មើលងាយសេចក្ដីសុខ ដែលគេសោយក្នុងស្ថានទេវតាទេ មិនមែនព្រោះគេធ្វើទុក្ខបុកម្នេញ ឲ្យលំបាកចិត្ត រហូតដល់ធុញទ្រាន់ នឹងព្រះរាជទ្រព្យ ហើយនិងព្រះឃ្លាំងទេ មិនមែនព្រោះខ្ញុំខ្លាចរំជួលចិត្តថ្វើម អ្នកដែលជាបច្ចាមិត្រត្រូវបំផ្លាញយើងនោះទេ គឺខ្ញុំព្រះអង្គភ័យខ្លាចសេចក្ដីលំបាកក្នុងជាតិ ជរា ព្យាធិ និងមរណៈ បានជាខ្ញុំព្រះអង្គប្រាថ្នាចង់បួស ដើម្បីនឹងបានសម្រេចនូវព្រះនិព្វានជាស្ថានទីរំលត់ទុក្ខទាំងនោះ»។

ព្រះរាជា កាលទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ

ស្តេចទ្រង់ព្រះពិលាប ស្រែកទ្រហោយំរីងរឹតតែខ្លាំងឡើង តែព្រះវិតសោក មានប្រាជ្ញានឹងល្អងលោម ព្រះរាជហឫទ័យទើបត្រាស់ថា: «ឱព្រះរាជា! ព្រះអង្គមិនគួរនឹងសោយសោកទេ សង្សារចក្ររិលទៅឥតស្រាកទេ អ្នកដែលទៅរួមជាមួយគ្នា ត្រូវតែព្រាត់ប្រាសនិរាសចាកគ្នាទៅជាធម្មតា ព្រះអង្គសោយសោក ព្រោះហេតុនេះ តើមានប្រយោជន៍អ្វី?»។

ព្រះរាជា ត្រាស់តបថា: «ឥឡូវនេះ ត្រូវតែឯងប្រព្រឹត្តបិណ្ឌបាតចារិកវត្ត ចូរឯង អង្គុយតែក្រោមព្រឹក្សាទាំងឡាយ ហើយក្នុងរាត្រី ចូរឯងប្រព្រឹត្តនៅតែលើកម្រាលស្មៅលមើលសិន»។ រឿងរ៉ាវដូចសំដែងមកហើយនេះ ទើបព្រះរាជាព្រះរាជទានបាត្រនិងច្រត់សម្រាប់បព្វជិត ហើយត្រាស់បង្គាប់ឲ្យត្រាច់បិណ្ឌបាតគ្រប់ស្រីក្នុងវាំងជាវេន តៗ គ្នា ក៏ពួកស្រីក្នុងវាំង បានដាក់បាត្រដោយអាហារយ៉ាងឧត្តម ព្រះរាជា ទ្រង់ជ្រាបដូច្នោះ ទើបត្រាស់បន្ទោសពួកស្រីទាំងនោះថា: «ហេតុអ្វីបានជានាងឲ្យអាហារដ៏ឧត្តមនោះទៅវិតសោក? ចូរនាងឲ្យតែអាហារគ្រោតគ្រាត ហើយនិងអាហារដ៏សៅហ្មងទៅ

ដើម្បីឲ្យវីតសោកទម្លាប់ខ្លួននឹងអាហារនោះ ពួកបាទបរិចា-
រិកាទាំងនោះ ប្រតិបត្តិតាមព្រះរាជឱង្ការ បានថ្វាយអាហារ
គ្រោតគ្រាត និងសៅហ្មងដល់ព្រះវីតសោក ទ្រង់បាន
ទទួលបិណ្ឌបាតនោះហើយ សោយឥតមានផ្លាស់ប្ដូរឡើយ
ព្រះបាទអសោកបានទតឃើញព្រះអនុជដូច្នោះហើយ ទើប
ទ្រង់ត្រាស់ថា: «យើងអនុញ្ញាតឲ្យឯងបួសហើយ កាលបើ
ឯងបួសរួចហើយ ត្រូវតែមកសួរយើងផងកុំខាន»។

ព្រះវីតសោក កាលបានព្រះរាជានុញ្ញាតហើយ ស្ដេច
យាងទៅកុក្កុដារាម ហើយទ្រង់ ព្រះតម្រិះយ៉ាងនេះថា:
«ប្រសិនបើអញ បួសនៅទីនេះ ក៏មិនផុតអំពីការទាក់ទាម
ដោយសេចក្ដីកង្វល់នឹងសួរសព្ទដ៏ច្រើន»។ ខណៈនោះ ស្ដេច
យាងចូលទៅក្នុងទីឯទៀត ទៅនៅក្នុងនគរដ៏ឆ្ងាយ ហើយ
ទើបបួសជាភិក្ខុសិក្សាផ្លូវប្រតិបត្តិតាមធម៌វិន័យ លោកបាន
ប្រព្រឹត្តធ្វើសេចក្ដីព្យាយាមដ៏ហ្មត់ចត់ រហូតដល់បានសម្រេច
ព្រះអរហត្តផល ហើយទ្រង់រំពឹងដូច្នេះថា: «កាលពីមុន
ស្ដេចអសោកបានធ្វើពាក្យប្ដេជ្ញានេះនឹងអាត្មាថា កាលបើឯង

បួសរួចហើយ ត្រូវតែមកសួរយើងផង ឥឡូវនេះ គួរអាត្មាអញទៅសួរស្ដេចក្នុងពេលមុនបច្ចុសសម័យ»។ ព្រះថេរៈតើនឡើងពីព្រលឹម កាន់យកបាត្រ ហើយយាងចំពោះទៅក្រុងបាតលិបុត្រ លោកនិមន្តឈប់ បិណ្ឌបាតជាលំដាប់មករហូតដល់ទ្វារព្រះរាជវាំង ទើបទ្រង់មានព្រះបន្ទូលនឹងនាយទ្វារបាលថា: «ភិក្ខុវីតសោកមានប្រាថ្នាចង់ជួបនឹងស្ដេច»។

គ្រានោះ នាយទ្វារបាល ក៏ម្ទីម្ទាទៅទូលព្រះរាជា ថា: «ឥឡូវនេះ ព្រះថេរវីតសោកមានប្រាថ្នា ចង់ចូលមកគាល់ព្រះរាជា»។

ព្រះរាជាត្រាស់តបថា: «ចូរឯងទៅនិមន្តលោកឲ្យចូលមកឆាប់ៗ»។

ព្រះថេរវីតសោក ស្ដេចយាងមកដល់មាត់ទ្វារព្រះរាជដំណាក់ ព្រះបាទអសោក ទ្រង់ទស្សនាការព្រះអនុជហើយស្ដេចយាងចុះចាករាជបល្ល័ង្ក ក្រាបថ្វាយបង្គំប្រកបដោយអង្គ៥ ផ្ទាល់ចុះលើផែនដី ក្នុងទីចំពោះព្រះភក្ត្រព្រះថេរៈ ហើយព្រះអង្គប្រណម្យអញ្ជលី ទតសម្លឹងមើលព្រះថេរ

វីតសោក ព្រះអង្គទ្រង់ព្រះកន្សែងត្រាស់នូវគាថាតទៅនេះថា: «បាណៈគ្រប់ចំពូក តែបាននៅរួបរួមគ្នា តែងតែសប្បាយរីករាយ ឥឡូវនេះ ខ្ញុំឈ្ងោកសំឡឹងមើលព្រះនេត្រលោក មិនឃើញមានសំដែង អាការវិបល្លាស ដោយការពេញចិត្តនឹងមូលត្រកូលនេះសោះ ខ្ញុំស្មានដោយឥតសង្ស័យថា: «លោកម្ចាស់ច្បាស់ជាបានសម្រេចមគ្គផលហើយ! ទឹកអម្រឹតឆ្អែតពេញក្នុងហឫទ័យលោកម្ចាស់ហើយ!»។

រាធគុប្តៈ ជាសេនាបតីទី១របស់ព្រះបាទអសោក បានឃើញព្រះថេរវីតសោកឃ្លុំដោយចីវរបង្សុកូល កាន់បាត្រដីកាលកំពុងត្រាច់ដើរបិណ្ឌបាត លោកបានទទួលយកអាហារគ្រប់យ៉ាង គឺអាហារដ៏ឧត្តមខ្លះ គ្រោតគ្រាតខ្លះ ក៏រាធគុប្តសេនាបតីនោះ រត់ទៅទូលព្រះរាជា ហើយថ្លែងនូវគាថាតទៅនេះថា: «សូមព្រះអង្គ ទតមើលភិក្ខុវីតសោកចុះ ជនគ្រប់ៗគ្នា គេតែងត្រេកត្រអាលក្នុងការបំពេញទាននឹងលោក តែខ្លួនលោកជាអ្នកមានប្រាថ្នាតិច ហើយចេះពេញចិត្តនឹងរបស់តិច លោកបានសម្រេចកិច្ចដែលលោកត្រូវធ្វើនោះ

ហើយ ព្រោះដូច្នោះ បានជាលោកមានចិត្តក្សេមក្សាន្ត។ លោកបានកាត់ចិត្តចោលរាជសម្បត្តិ ដែលជាមរតកត្រូវបាន ទីក្រុងបាតលិបុត្រ ព្រះរាជទ្រព្យ និងព្រះឃ្លាំងទាំងឡាយ ព្រមទាំងសក្តិយសនិងសេចក្តីសុខ ក៏លោកកាត់ចោលអស់ ឥតស្តាយ។ លោកបានញក់ញីជាតិដ៏ឧត្តមរបស់លោក ដោយព្រះបាទ ដូចជាគេបង្ហូរទឹកភ្នែក ឬខាកកំហាកចោល។ លោកលះវត្ថុទាំងអស់នោះរៀងទៅ រហូតដល់លោកលះ ព្រះរាជវង្ស ដែលធ្វើឲ្យលោក បានចម្រើនសក្តិយសដ៏ខ្ពង់ ខ្ពស់នោះផង»។

កាលព្រះអង្គ ទ្រង់ព្រះសណ្តាប់ វាចានេះហើយ ព្រះបាទអសោក បាននិមន្តឲ្យព្រះថេរវីតសោកគង់ប្រថាប់លើ រាជបល្ល័ង្ក ហើយស្តេចទ្រង់ចាត់ចែងភោជនាហារ ដ៏ថ្លៃថ្នូរ វិសេសវិសាលបំផុតប្រគេនដោយព្រះហស្តព្រះអង្គ។ លុះ គ្រាជាខាងក្រោយភត្តកិច្ច ទ្រង់បានប្រគេនទឹកដ៏បរិសុទ្ធស្រេច ហើយ ទើបទ្រង់កាន់យកនូវទីសេនាសនៈដ៏តូច ទ្រង់ប្រថាប់ នៅក្នុងទីចំពោះព្រះភក្ត្រព្រះថេរៈ ទើបនិមន្តឲ្យព្រះថេរៈ

សំដែងព្រះធម៌ទេសនា។

គ្រានោះ ព្រះថេរវីតសោកត្រាស់សំដែងព្រះគាថាថ្វាយព្រះរាជាតទៅនេះថា:

«រាជសម្បត្តិ ជាធម្មជាតិគួរគេគោរព ហើយថ្លៃថ្លាថ្កើងថ្កានណាស់ ចូរទ្រង់កុំប្រមាទ (ក្នុងរាជកិច្ចរបស់ព្រះអង្គ) ព្រះរតនត្រ័យ ជាធម្មជាតិក្រនឹងបានជួបពេក សូមព្រះអង្គចូរទំនុកបំរុងគ្រឿងសក្ការបូជាដល់កែវទាំង៣ប្រការនោះ»។

កាលព្រះថេរៈសំដែងនូវគាថានេះចប់ហើយ ទើបស្ដេចក្រោកចាករាជបល្ល័ង្ក ព្រះរាជាព្រមទាំងសេវកាមាត្យទាំង ៥០០ និងពួកមហាជនដ៏ច្រើន បានតាមជូនព្រះថេរៈដោយសេចក្ដីគោរព រហូតដល់ទៅទ្វារខាងក្រៅ នេះជាអានិសង្សដ៏រុងរឿងរបស់សមណៈ ដែលឲ្យឃើញជាក់ច្បាស់ បានជាព្រះថេរវីតសោកត្រិះរិះដូច្នេះថា: «ក្នុងកាលមុន ព្រះជេដ្ឋាអាត្មាអញ បានធ្វើឧបាយកលជាច្រើនយ៉ាងដល់អាត្មាអញ ទ្រង់ធ្វើឲ្យអាត្មាអញបានបួស ក្នុងធម៌វិន័យរបស់សម្ពុទ្ធ។ ឥឡូវនេះ គួរអាត្មាអញធ្វើស្ដេច ឲ្យមានសេចក្ដីគោរព និងមាន

ប្រសាទសទ្ធាជ្រះថ្លារឹងរឹតតែខ្លាំងឡើងទៅទៀត»។ ខណៈនោះ ព្រះថេរៈម្ចាស់ស្ដេចហោះឡើងទៅក្នុងអាកាសវេហាស៍ ហើយទ្រង់សំដែងបាដិហារ្យ ឲ្យប្រាកដឡើង ក្នុងកណ្ដាលប្រជុំជន ទើបព្រះបាទអសោក មានពួកសេវកាមាត្យចោមរោមព្រះអង្គជុំវិញ ស្ដេចទ្រង់លើកព្រះហស្តឡើងប្រណម្យ ហើយត្រាស់នូវគាថានេះថា:«ឃ្លាតផុតចាកសាច់សាលោហិតដែលថ្នាក់ថ្នម ជាទីស្រឡាញ់ពេញចិត្ត ទើបលោកហោះអណ្ដែតត្រសែតទៅក្នុងអាកាសវេហាស៍ ដូចជាសកុណជាតិបាន។ ឯខ្លួនខ្ញុំជាប់នៅក្នុងចំណងរួតរឹតដោយរាជសម្បត្តិ ខ្ញុំត្រដាងខ្លួនទៅក្នុងលោកនេះ ដោយការទំនុកបម្រុង និងជាប់ដោយការមូលត្រកូលរបស់ខ្ញុំ។ កាលមិនមានកិច្ចកង្វល់ដោយខ្លួនរបស់លោក កាលខំប្រឹងព្យាយាមដោយកម្លាំងរបស់លោក ហើយលោកអាចក្រេបផឹកនូវរសដ៏ប្រសើរនេះ ព្រោះតែលោកហ្វឹកហ្វឺនចិត្តលោកបាន។ ផលនៃឈាន និងសមាបត្តិ ពួកមនុស្សអប្បឥតប្រាជ្ញា កំបាំងគំនិតងងឹតភ្នែកមើលមិនយល់ទេ។ បាដិហារ្យរបស់លោក ដែលអណ្ដែត

ឡើងទៅនេះ ឈ្មោះថាលោកបានបំបាត់បង់នូវមានៈរបស់ខ្ញុំ ទុកជាកម្លាំងប្រាជ្ញារបស់ខ្ញុំនៅក្បែរខ្សោយ លោកក៏បានធ្វើឲ្យខ្ញុំមានចិត្តសុភាពរៀបរយទៅបាន»។

លុះស្តេចត្រាស់គាថានេះចប់ហើយ ព្រះថេរវីតសោកក៏ហោះរហូតដល់ទៅទីបំផុតនៃដែន លោកចេញទៅនៅខាងក្រៅរាជអាណាចក្រ តមកខាងក្រោយ លោកទ្រង់ប្រឈួនជាទម្ងន់ណាស់ រហូតដល់ ជ្រុះព្រះកេសាចេញអស់រលីង។ ព្រះរាជាទ្រង់ជ្រាបថា ព្រះថេរៈប្រឈួន ស្តេចបានបញ្ជូនពេទ្យ យកឱសថទៅព្យាបាលព្រះថេរៈនៅទីនោះ កាលបើបានជាហើយ ព្រះកេសាក៏ត្រឡប់ដុះដូចពីដើមវិញ លោកក៏បញ្ជូនពេទ្យ ឲ្យត្រឡប់ទៅស្រុកវិញ។ ព្រះថេរវីតសោក បានសោយព្រះក្រយាស្ងោយដែលគេផ្សំដោយទឹកដោះគោ លោកក៏មានកម្លាំងកំហែងរឹងប៉ឹងមាំមួនឡើងដូចដើម លោកនិមន្តទៅមកបានដោយស្រួល ហើយទើបនិមន្តទៅក្នុងព្រៃញាតស្បាត ទៅប្រថាប់ក្បែរទីសំណាក់អាស្រ័យនៃពួកគង្វាលពពែ។

សម័យមួយ ក្នុងប្រទេសបុណ្ឌវធ៌នៈ មានពួកសិស្សគណនិគ្រន្ថបានឃើញព្រះពុទ្ធរូប ហើយក្មេងគូរគូសរំលុបធ្វើជារូបភាពនៃនិគ្រន្ថ ដែលជាទីគោរពរបស់ខ្លួន[១]។ គ្រានោះ ពួកឧបាសកដែលជាពុទ្ធសាសនិកជន ទើបក្រាបទូលរឿងនោះដល់ព្រះបាទអសោកថាៈ ពួកសិស្សគណនិគ្រន្ថបានឃើញព្រះពុទ្ធរូប ហើយក្មេងគូសគូររំលុបរំលោងធ្វើជារូបភាពនៃនិគ្រន្ថដែលជាទីគោរពរបស់ខ្លួនវិញ»។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់ដំណឹងនោះហើយ ស្ដេចទ្រង់ព្រះពិរោធខ្លាំង ត្រាស់ដោយរួសរាន់ ចាត់ឲ្យពួកយក្ខ (ទេវតា) ចាំស្កាត់គ្រប់ច្រក កម្ពស់ចំនួន៤០លី (មួយយោជន៍) ទៅក្នុងអាកាស ហើយពួកនាគ ប្រុងប្រយ័ត្នចុះទៅចំនួនជម្រៅ ៤០លី ទៅក្នុងផែនដី ចាប់សម្លាប់តែក្នុងមួយថ្ងៃនោះអស់ពួកនិគ្រន្ថបុត្រចំនួន ១៨.០០០នាក់ នៅក្នុងក្រុង

[១] ទិវ្យាវទាន និងអាយុវង-កឹង ដែលលោកបួនូហ្វបានប្រែថាៈ «មនុស្សម្នាក់ដែលជ្រះថ្លាក្នុងលទ្ធិព្រាហ្មណ៍ បានរំលើងព្រះពុទ្ធរូបឲ្យរលំទៅ ទៀបនឹងជើងនៃព្រាហ្មណ៍ម្នាក់ ហើយទំលាយចោលព្រះពុទ្ធរូបនោះទៅ»។

បាតលិបុត្រ[១]។

ក្នុងក្រុង បាតលិបុត្រ ក៏មានពួក និគ្រន្ថបុត្រដទៃទៀត បានឃើញព្រះពុទ្ធរូប ហើយក្លែង គូររំលុបរំលោងធ្វើជារូបភាពនៃនិគ្រន្ថ ដែលជាទីគោរព របស់ពួកខ្លួនដូចគ្នាដែរ។ ខណៈនោះពួកឧបាសកដែលជាពុទ្ធសាសនិកជន ទៅក្រាបបង្គំទូលដំណើររឿងនោះ ដល់ព្រះរាជា ស្ដេចទ្រង់ជ្រាបសេចក្ដីនោះហើយ ព្រះអង្គទ្រង់ព្រះពិរោធក្រេវក្រោធខ្លាំង ទ្រង់ឲ្យចាប់ពួកនិគ្រន្ថបុត្រ ព្រមទាំងពូជវង្សត្រកូលផង យកមកគរដុតទាំងអស់ក្នុងគំនរភ្លើងស្លាប់វិនាសអស់ ហើយទ្រង់ឲ្យទូងភេរីប្រកាសជាព្រះរាជានុញ្ញាតថា: «អ្នកណាមួយនឹងអាចកាត់យកក្បាលនិគ្រន្ថបុត្របានមួយឲ្យយើង អ្នកនោះនឹងត្រូវបានដុំមាសឆ្តោរជារង្វាន់»។

ក្នុងវេលានោះ ព្រះថេរវីតសោកបានទៅសូមសំណាក់អាស្រ័យក្នុងផ្ទះនិគ្រន្ថបុត្រម្នាក់ ព្រះអង្គបានប្រឈួនឡើង

(១) តាមច្បាស់នេះខុសទេ ដែលត្រូវនោះ គឺត្រង់ពាក្យថា: «ក្នុងក្រុងបាតលិបុត្រ» ឲ្យថា: «នគរបុណ្ឌវធ៌នៈ» វិញ។ តាមច្បាប់ទិវ្យាវទាន និងអាយុ-វង-កឹងថា: «គេសម្លាប់ពួកនិគ្រន្ថបុត្រ១៨.០០០ក្នុងនគរបុណ្ឌវធ៌នៈ។

ទៀតក្នុងទីនោះ ត្រៃចីវរក៏ដាច់ដាចរយីករយាក ព្រះកេសាក៏វែងហួសសមណៈសមញ្ញ មានឫកពាមើលទៅប្រហែលនឹងនិគ្រន្ថបុត្រ (ថ្ងៃ១) មានអ្នកលេងម្នាក់ កាន់ដាវផ្គាដើរមកឈរចំពោះព្រះភក្ត្រព្រះថេរៈ ទើបព្រះថេរវីតសោក ទ្រង់នឹករំពឹងថាៈ «ព្រោះអាស្រ័យអំពើទុច្ចរិត ក្នុងកាលពីមុនរបស់អាត្មាអញជាប់ជិតតាមមក បានជាអាត្មាអញត្រូវទទួលកម្មចាស់របស់ខ្លួន»។ ខណៈនោះ អ្នកលេងនឹកស្មានថាជានិគ្រន្ថបុត្រ ក៏កាត់ព្រះសិរព្រះអង្គ ក្នុងមួយរំពេចនោះទៅ[១] លុះកាត់បានហើយ នាំយកព្រះសិរនោះមកថ្វាយដល់ព្រះរាជាសូមឲ្យស្តេច ទ្រង់ព្រះរាជទានដុំមាសត្បោរ ព្រះរាជាទ្រង់ទស្សនាការព្រះសិរនោះ ស្គាល់ជាក់ ជាព្រះសិរព្រះអនុជវីតសោក ហើយទ្រង់ជ្រាបតទៅទៀតអំពីសេនាបតីម្នាក់ ក្នុងពួកសេនាបតីរបស់ព្រះអង្គក្រាបទូលថាៈ« ពួកសមណៈ ជាសក្យបុត្រ គេស្មានថាជាពួកនិគ្រន្ថបុត្រ គេសម្លាប់ដោយ

---

[១] ក្នុងទិវ្យាវទាន និងអាយុ-វង-កឹង ព្រះអនុជរបស់ព្រះបាទអសោកមិនមែនទិវង្គតដោយអ្នកលេងសម្លាប់ទេ តែទ្រង់ទិវង្គតដោយអ្នកគង្វាលពពែម្នាក់ ដែលបានថ្វាយទីសំណាក់អាស្រ័យដល់ព្រះអង្គជាអ្នកសម្លាប់។

កាន់ប្រទ្បំ ជាច្រើនរូបណាស់ហើយ ព្រោះពេលនេះ ពួកនិគ្រន្ថមានចំនួនតិចណាស់ហើយ»។

កាលបានទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ព្រះរាជាធិរាជ ស្ដេចទ្រង់ព្រួយព្រះរាជហឫទ័យពន់ពេកណាស់ ទ្រង់មានសេចក្ដីសោកស្ដាយ ទើបដួលចុះទៅលើផែនដី រាជបរិពារទាំងឡាយ បានយកទឹកមកប្រស់ព្រំស្រប់ព្រះភក្ត្រាយូរបន្តិចទៅទើបព្រះអង្គបានស្មារតីឡើងវិញ។ ពួកសេនាបតីបានក្រាបបង្គំទូលព្រះរាជាថា: «ពេលនេះគេសម្លាប់ពួកសមណ:ជាសក្យបុត្តិយ៍ដោយកាន់ប្រទ្បំជាច្រើនណាស់។ ឱព្រះរាជា! សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោស អនុញ្ញាតឲ្យពួកសមណ: ជាសក្យបុត្របានក្សេមក្សាន្តផុតរួចចាកទុក្ខភ័យ»។ ខណ:នោះ ព្រះរាជាបានតែងព្រះរាជឱង្ការហោមប្រាមថា: «ចាប់ដើមតាំងតែពីត្រឹមថ្ងៃនេះទៅ មិនត្រូវអ្នកណាមួយសម្លាប់សមណ:ទេ[១]»។

---

(១) ពុទ្ធឃោស:សំដែងដំណាលរឿងរ៉ាវប្រហែលគ្នាអំពីការដែលឲ្យប្រជុំនិងធ្វើសង្គាយនាដែលនៅក្រោមការបង្គាប់នៃព្រះថេរ:មោគ្គល្លីបុត្រ-តិស្ស។ ក្នុងសេចក្ដីនេះថា ព្រះអនុជរបស់ព្រះបាទអសោកដែលគេសម្លាប់ដោយកាន់ប្រទ្បំនោះ ព្រះនាមតិស្ស។

គ្រានោះ ភិក្ខុទាំងឡាយមានសេចក្ដីសង្ស័យ ទើបចូលទៅក្រាបទូលព្រះមហាថេរឧបគុប្ត:ថា: «ព្រោះហេតុអ្វី បានជាព្រះថេរវីតសោកអង្គនោះ ត្រូវអ្នកលេងពិឃាតជីវិតបង់ដូច្នោះ»។

ព្រះថេរ:តបថា: «ប្រសិនបើអ្នកទាំងឡាយចង់ដឹងរឿងលោកក្នុងជាតិមុន ចូរប្រុងស្ដាប់ចុះ! ក្នុងកាលដែលកន្លងទៅហើយ គ្រាមួយ មានព្រានម្រឹគម្នាក់ បានទៅរាយបន្ទឹងនៅក្បែរមាត់ទឹក មានព្រះបច្ចេកពុទ្ធមួយព្រះអង្គ បានស្ដេចស្វែងរកអាហារបិណ្ឌបាត ហើយទៅគង់នៅក្រោមដើមឈើមួយដើមជិតបន្ទឹងទាំងនោះ កាលព្រានមកដល់មិនឃើញមានម្រឹគជាប់ក្នុងបន្ទឹងនោះសោះ ទើបរំពឹងគិតថា: «ព្រោះហេតុអ្វី ឥឡូវនេះ ម្រឹគមានច្រើនណាស់ ដូចម្ដេចបានជាវាមិនមកជិតបន្ទឹងអញសោះ»។ គ្រានោះ ព្រានខំសង្កេតមើលទីជិតខាងជុំវិញសព្វអន្លើទៅ បានឃើញព្រះបច្ចេកពុទ្ធ គង់នៅក្រោមដើមឈើជិតបន្ទឹងទាំងនោះ ទើបគិតថា ព្រោះតែគាត់នេះឯងបានជាផ្អើលម្រឹគអញរត់បាត់អស់គ្មានសល់»។

ហើយហូតដាវពិឃាតផ្ដិលផ្ដាច់ ព្រះសិរព្រះបច្ចេកពុទ្ធអង្គនោះទៅ។

«ព្រានម្រឹគក្នុងកាលនោះ គឺព្រះថេរៈព្រះនាមវីតសោកក្នុងកាលឥឡូវនេះ ព្រោះតែពីជាតិមុន បានពិឃាតព្រះបច្ចេកពុទ្ធ បានធ្លាក់ទៅទទួលសោយទុក្ខក្នុងនរក ជាវេលាច្រើនកោដិនៃកល្ប បានអន្ទោលជាតិស្លាប់កើតៗ ដោយទុក្ខវេទនាជាមហាវិបាក និងគេសម្លាប់ដោយដាវគ្រប់ៗជាតិ ក្នុងទីបំផុតនេះទុកជាបានលុះព្រះអរហត្តផលហើយ ក៏គង់ត្រូវអ្នកលេងពិឃាតជីវិតដោយដាវទៀត»។

ភិក្ខុទាំងឡាយទូលសួរថា: «ព្រោះព្រះអង្គបានកសាងអ្វីទើបលោកកើតក្នុងត្រកូលខ្ពស់ ហើយបានលុះព្រះអរហត្តផល?»

ព្រះមហាថេរ តបថា: «ក្នុងកាលដ៏កន្លងទៅយូរអង្វែងណាស់ហើយ ក្នុងសាសនកាលនៃព្រះពុទ្ធ ទ្រង់ព្រះនាមកស្សប លោកជាទាយកមានចិត្តជ្រះថ្លា បរិច្ចាគបិណ្ឌបាតទានដល់ព្រះភិក្ខុសង្ឃ ចាត់ចែងធ្វើទឹកបានៈដោយផ្លែឈើ

ផ្សេងៗ ព្រោះវិបាកនៃបុញ្ញកម្មនេះ លោកទើបបានកើតក្នុងត្រកូលខ្ពស់ ម្យ៉ាងទៀតក្នុងគ្រាពុទ្ធកាលទ្រង់ព្រះនាមកស្សបនោះ លោកមានសទ្ធាជ្រះថ្លាណាស់ រហូតដល់បានបួសជាភិក្ខុអស់វេលាមួយសែនឆ្នាំ បានតាំងប្រណិធានប្រព្រឹត្តព្រហ្មចរិយធម៌ដ៏ហ្មត់ចត់ ព្រោះអំណាចផលនៃ បុញ្ញកម្មនោះ លោកទើបបានសម្រេចព្រះអរហត្តផលក្នុងជាតិនេះ»។

ព្រះនាងបទ្មាវតី[១] ជាអគ្គមហេសីនៃព្រះបាទអសោក ព្រះនាងនេះ មានព្រះរាជបុត្រមួយព្រះអង្គ ទ្រង់ព្រះនាមធម៌វិវធ៌ន: (ចំរើនឡើងដ៏វិសេសដោយធម៌)។ មានសេនាបតីម្នាក់ ចូលទៅក្រាបបង្គំទូលព្រះរាជាថា: «ឱព្រះរាជា! សូមព្រះអង្គទ្រង់ព្រះក្សាន្តក្នុងព្រះរាជហឫទ័យ ព្រោះហេតុអ្វី? ព្រោះថា ព្រះរាជបុត្រព្រះអង្គប្រសូតហើយ ព្រះរាជកុមារនោះ មានលក្ខណ:ព្រះភក្ត្រាដ៏សមរម្យល្អវិសេសអស្ចារ្យ មានព្រះនេត្រាដ៏ល្អឥតគូនឹងប្រៀបឲ្យស្មើបាន»។

---

[១] សៀវភៅពុទ្ធសាសនារបស់លោកល្វី-ហ្វីណូត៍ ដែលលោកជុំ-ម៉ៅ ប្រែជាខ្មែរ និងគម្ពីរមហាវង្ស: អសន្ធិមិត្រាជាអគ្គមហេសីបានឱរសមួយអង្គព្រះនាមកុនាល:។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ មានព្រះរាជហឫទ័យត្រេកអរសាទរណាស់ ស្ដេចត្រាស់ថាៈ «រាជត្រកូលរបស់យើង បានថ្កើងរុងរឿងដល់ជាន់ខ្ពស់បំផុត ព្រោះតែយើងគ្រប់គ្រងរាជសម្បត្តិដោយធម៌ដ៏ប្រសើរ ទើបបានឱរស សូមឲ្យវានោះបានទំនុកបំរុងព្រះធម៌ឲ្យចម្រើនក្រៃលែងតទៅទៀត ព្រោះហេតុនោះ ទើបគេហៅព្រះរាជកុមារនោះថា ធម៌វិវឌ្ឍនៈ ដែលប្រែថាៈ «ចម្រើនឡើងដ៏វិសេសដោយធម៌»។ ភីលៀងបាននាំព្រះរាជឱរសមកគាល់ព្រះរាជា លុះទ្រង់ទស្សនាការហើយ ព្រះរាជាស្ដេចពេញទៅដោយសេចក្ដីស្នេហា ទ្រង់បន្លឺនូវឧទានគាថានេះថាៈ «ចក្ខុរបស់ទារកនេះ ល្អលើសលុបឥតអ្វីប្រៀប កូននេះពេញជាមហាកុសលយ៉ាងធំ វាហាក់ដូចជាផ្កាឧត្បល ដែលទើបនឹងរីកស្រស់ថ្មីៗ មុខវាមូល ស្រស់ល្អ ប្រិមប្រិយ ប្រហែលនឹងដួងព្រះចន្ទ្រាដ៏ពេញវង់ អ្នកណាបានឃើញនូវព្រះឱរសនេះ អ្នកនោះនឹងបានសេចក្ដីសប្បាយរីករាយស្រួលចិត្តគ្រប់គ្នា»។

លុះទ្រង់ត្រាស់ព្រះគាថានេះចប់ហើយ ព្រះបរមក្សត្រិយ៍

មានព្រះរាជឱង្ការ នឹងសេនាបតី ថា: «មានគេធ្លាប់បាន ឃើញភ្នែកមនុស្ស បែបដូចជាចក្ខុរបស់ទារកនេះដែរឬ?»។

សេនាបតីក្រាបទូលថា: «បណ្ដាមនុស្សទាំងអស់ ខ្ញុំមិនដែលឃើញមានម្នាក់សោះ ទាំងមិនដែលឮគេនិយាយផងថា អ្នកណាមួយមានចក្ខុបែបយ៉ាងនេះទេ តែខ្ញុំព្រះអង្គបានឮដំណឹងថា ក្នុងហិមវន្តបព៌ត ដែលជាកំពូលនៃភ្នំទាំងឡាយ មានសត្វបក្សា១ឈ្មោះកុនាលៈ ដែលមានភ្នែកល្អជាទីបំផុត វាតែងនៅអាស្រ័យលើភ្នំនោះ»។

គ្រានោះ ព្រះរាជាទ្រង់ប្រទានព្រះរាជអាជ្ញា ឲ្យដល់ពួកយក្សថា: «ចូរអ្នកទាំងឡាយទៅឲ្យឆាប់ ចាប់យកសត្វកុនាលៈ១ អំពីហិមវន្តបព៌តមក យើងប្រាថ្នាចង់មើលសត្វនោះក្នុងកាលឥឡូវនេះ ពេលនោះមានយក្សម្នាក់បានទទួលធ្វើតាមព្រះរាជអាជ្ញា ស្ទុះទៅតែមួយរំពេចនោះ ក៏ចាប់បានសត្វនោះមួយមក ហើយនាំមកថ្វាយដល់ព្រះរាជា កាលទ្រង់ពិចារណាមើលភ្នែករបស់សត្វនោះ ហើយត្រាស់ថា: «ភ្នែកតូចរបស់សត្វនេះល្អពន់ពេក មិនប្លែកគ្នាអំពីនេត្រានៃ

កុមារតូចនេះសោះ ព្រោះដូច្នោះ ទើបទ្រង់ប្រទានព្រះនាម កុមារនោះថាៈ «កុនាលៈ»។ ព្រះនាមនោះ ក៏ផ្សាយទៅដឹង សាយសព្វគ្រប់មនុស្សទាំងអស់ លុះព្រះរាជកុមារព្រះនាម កុនាលៈ មានវ័យវឌ្ឍនាការចម្រើនហើយ គេបានថ្វាយនាង តរុណីម្នាក់ ឈ្មោះកាញ្ចនមាលា (ក្បួងផ្កាមាស) ដើម្បីឲ្យជា ព្រះជាយា។

ថ្ងៃមួយ ព្រះរាជានិងព្រះរាជឱរស ស្ដេចយាងចេញទៅ កាន់វត្តកុក្កុដារាម។ ខណៈនោះ ព្រះយសត្ថេរជាប្រមុខនៃ សង្ឃ បានពិចារណាមើលរូបព្រះកុនាលៈរាជឱរស បាន ជ្រាបថាៈ ក្នុងពេលបន្តិចទៅខាងមុខ ព្រះអង្គខូចព្រះនេត្រ ជាប្រាកដ ទើបថ្វាយព្រះពរព្រះរាជាថាៈ «បពិត្រមហារាជ ព្រោះហេតុអ្វី បានជាទ្រង់ មិនអនុញ្ញាតឲ្យព្រះអង្គម្ចាស់ កុនាលៈ ជារាជឱរសស្ដាប់ព្រះធម៌ឲ្យមានបែបបទឡើង?»។

គ្រានោះ ព្រះបរមក្សត្រិយ៍ទ្រង់ព្រះអនុញ្ញាតឲ្យព្រះរាជ ឱរស ដូច្នេះថាៈ «កុនាលៈ ឥឡូវនេះ ត្រូវឯងប្រព្រឹត្តតាម ពាក្យឱវាទរបស់ព្រះថេរៈដែលលោកប្រៀនប្រដៅ»។

គ្រានោះ ព្រះកុនាលរាជឱរសប្រណម្យអញ្ជលីដោយក្រពុំនៃម្រាមទាំង១០ ហើយចូលទៅទូលសួរជិតព្រះថេរៈថា: «លោកម្ចាស់អនុញ្ញាតឲ្យខ្ញុំធ្វើដូចម្ដេចៗ ក៏ខ្ញុំទទួលរ៉ាប់រងតាមឱវាទនោះទាំងអស់»។

ព្រះថេរៈថ្វាយព្រះឱវាទនេះ ដល់ព្រះរាជឱរសថា: «ចក្ខុនោះៗ មិនមែនជារបស់ខ្លួនឡើយ សូមទ្រង់តាំងប្រណិធាន ព្យាយាមចម្រើននូវសមថនិងវិបស្សនាកម្មដ្ឋាន ឲ្យកើតមានឡើងក្នុងព្រះអង្គជាដរាបទៅ»។

លុះទ្រង់បានស្ដាប់ឱវាទនេះហើយ ព្រះកុនាលរាជឱរសក៏ទទួលសិក្សាតាម ហើយយាងចូលទៅក្នុងទីស្ងាត់មួយ នៅក្នុងព្រះបរមរាជវាំង តាំងផ្ដើមធ្វើសមាធិនោះឡើង ស្ដេចនឹករំពឹងពិចារណាថា: «ចក្ខុជាហេតុនៃសេចក្ដីទុក្ខ ជារបស់ទទេជារបស់មិនទៀងនិងមិនប្រាកដថាជារបស់ខ្លួនឡើយ»។

ថ្ងៃមួយ ព្រះនាងតិស្សរក្សិតា ជាអគ្គមហេសីឯករបស់ព្រះបាទអសោក ព្រះនាងចូលទៅកាន់សំណាក់នៃ ព្រះកុនាលរាជឱរស ឃើញស្ដេចគង់នៅតែមួយព្រះអង្គ ព្រោះ

តែព្រះនាងជាប់ដោយសេចក្ដីស្រឡាញ់ព្រះនេត្រពេក អត់ទ្រាំមិនបាន ក៏ចាប់ឱបរឹតព្រះកុនាលរាជឱរសដោយដៃទាំងពីរ ហើយនិយាយប្រលោមថា: «ភ្លើងដែលកំពុងឆេះឆួលឆាបព្រៃស្បាតនៃភ្នំ មានអណ្ដាតទ្រោលឡើងសន្ធោសន្ធៅច្រាលឆ្អៅក្ដីព្រោងព្រាយ ជាធម្មជាតិក្ដៅរោលរាលយ៉ាងណាមិញ ក៏រាគតណ្ហាដែលកំពុងឆេះពុះក្នុងខ្លួនខ្ញុំ ក៏មានឧបមេយ្យដូច្នោះដែរ ព្រោះដូច្នេះ ពេលនេះ យើងត្រូវរួមសង្វាសជាមួយគ្នាដោយកាមរាគៈក្នុងទីនេះ»។

ព្រះកុនាលរាជឱរស កាលទ្រង់ព្រះសណ្ដាប់ពាក្យនេះហើយ ស្ដេចយកព្រះហស្ដបិទព្រះកាណ៌ទាំងសងខាងរបស់ព្រះអង្គ ហើយត្រាស់គាថាតទៅនេះថា: «ខ្ញុំចុកត្រចៀកខ្ញុំ ព្រោះខ្ញុំមិនចង់ឲ្យឮវាចា ជាសំដីធំលើសហួសវិស័យ ហើយអពមង្គលនេះ ព្រះអង្គគួរជាមាតាមួយរបស់ខ្ញុំ ដូចម្ដេចបានជាក្រឡេកមើលមកឱរសរបស់ព្រះអង្គ ដោយចិត្តប្រកបដោយរាគតណ្ហាទៅវិញ? តណ្ហាជាឧក្រិដ្ឋទោស ដែលមិនត្រូវតាមគន្លងធម៌ដូច្នេះ នឹងនាំព្រះអង្គទៅកាន់ទុគ្គតិនរក»។

ព្រះនាងតិស្សរក្សិតា ឃើញមិនសមតាមប្រាថ្នា ហើយត្រាស់ទាំងខ្ញាល់ថា: «បើឯងមិនទទួលការ:នេះទេ ឲ្យចាំទុកចុះ មិនយូរប៉ុន្មានប្រាកដជាអញនឹងបំផ្លាញជីវិតឯងឲ្យបាន»។

ព្រះកុនាលរាជបុត្រតបដោយសូត្រគាថានេះថា:

«ខ្ញុំពេញចិត្តលះបង់ជីវិត ដើម្បីសុចរិតធម៌ជាជាងការរស់នៅ ដែលពើបពះទៅលើសេចក្ដីអាប់យស ដោយតម្រេកក្នុងកាមតណ្ហា អ្នកដែលបំផ្លាញគតិមនុស្ស និងទេវតា តែងតែបានទទួលពាក្យតិះដៀលអំពីអ្នកប្រាជ្ញទាំងឡាយ»។

ចាប់ដើមអំពីនោះមក ព្រះនាងតិស្សរក្សិតា ខំស្វែងរកហេតុដទៃ ដើម្បីនឹងចាប់ទោសព្រះកុនាលរាជបុត្រ។

ជួនជាពេលមួយ មានដែនមួយឈ្មោះគន្ធារ: តាំងនៅក្នុងភូមិភាគខាងជើង ក្នុងដែននោះ មានក្រុងមួយឈ្មោះតក្សសិលា ពួកអ្នកនគរក្នុងក្រុងនោះ កើតបះបោរជាចលាចល កាលព្រះរាជាទ្រង់ជ្រាបដំណឹងនោះហើយ ទើបតាំងព្រះរាជហឫទ័យថា ស្ដេចនឹងយាងទៅបង្ក្រាបក្រុងនោះដោយព្រះអង្គឯង តែពួកសេនាបតី ទូលទាស់ដូច្នេះថា:

«បពិត្រមហារាជ! ព្រះអង្គមិនសមគួរនឹងយាងទៅក្នុងកិច្ចនោះទេ គ្រាន់តែបញ្ជូនព្រះរាជឱរសមួយអង្គ ក្នុងពួកព្រះរាជបុត្ររបស់ព្រះករុណា ឲ្យស្ដេចយាងទៅបង្ក្រាបក្រុងនោះឲ្យនៅក្រោមព្រះបារមីក៏បានហើយ»។

ខណៈនោះ ស្ដេចត្រាស់សួរទៅព្រះកុនាលៈជាព្រះរាជបុត្រថា: «កូនឯងអាចទៅបង្ក្រាបក្រុងតក្សសិលានោះបានឬទេ?»

ព្រះកុនាលរាជឱរសទូលតបថា: «សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនឹងទៅបង្ក្រាបថ្វាយបាន»។

កាលព្រះបរមក្សត្រិយ៍ ជ្រាបសេចក្ដីប្រាថ្នានៃព្រះរាជឱរសហើយ ព្រះអង្គមានព្រះហឫទ័យត្រេកអរសាទរ ហើយទ្រង់ប្រោសឲ្យចាត់ចែងប្រុងប្រៀបមាគ៌ាក្នុងរាជធានី ឲ្យបានសម្រេចឲ្យឆាប់ ស្ដេចចាត់ព្រះរាជអាជ្ញាបង្គាប់ឲ្យពួកមនុស្សចាស់ជរា មនុស្សឈឺ សាកសព មនុស្សទុព្វលភាព និងពួកស្មូមទាំងអស់ដែលនៅក្នុងទីនោះៗ ឲ្យចេញទៅឆ្ងាយផុតអំពីមាត់មាគ៌ានៃព្រះរាជដំណើរ ទើបព្រះបាទអសោក ព្រមទាំង

ព្រះរាជបុត្រ ស្តេចឡើងគង់លើព្រះរាជរថមួយ មានវិជនីស្វាបសត្វហែហមអមព្រះអង្គ ស្តេចចេញចាកក្រុងបាតលិបុត្រទៅដោយសួស្តី កាលមុនស្តេចនឹងឃ្លាត ចាកព្រះឱរសត្រឡប់ចូលកាន់ព្រះនគរវិញ ព្រះរាជា ទ្រង់កៀកព្រះសូរង់ព្រះរាជបុត្រ ហើយទ្រង់ពិលាបថា: «អ្នកណាសំឡឹងមើលព្រះនេត្រាកូនឯងនេះ អ្នកនោះរមែងបានសុខណាស់ហ្ន៎!»។

តែពេលនេះ មានព្រាហ្មណ៍ម្នាក់ជាហោរាចារ្យ បានពិនិត្យមើលហោរាសាស្ត្រហើយទាយថា: «ព្រះមហាក្សត្រពេញព្រះរាជហឫទ័យ នឹងព្រះនេត្រព្រះរាជបុត្រព្រះអង្គនេះណាស់ តែព្រះនេត្រព្រះរាជបុត្រនោះ មិនយូរប៉ុន្មានទេនឹងអន្តរធានទៅជាប្រាកដក្នុងបច្ចុប្បន្ននេះ មិនមានអ្នកណាមួយមិនចង់ឃើញព្រះនេត្រនៃព្រះកុមារនោះឡើយ ប៉ុន្តែតទៅអនាគតកាល ដែលព្រះនេត្រនោះ អន្តរធានទៅហើយនឹងបានទទួលសេចក្តីទុក្ខទូទៅគ្រប់មនុស្សទាំងអស់»។

ព្រះកុនាលរាជឱរស ស្តេចយាងជាលំដាប់ៗទៅតាមព្រះពន្ធា រហូតដល់ទីក្រុងតក្សសិលា ក៏អ្នកនគរទាំងឡាយ

ក្នុងទីក្រុងនោះ បានដឹងថា ព្រះរាជឱរសស្ដេចមកហើយ ទើបនាំគ្នាតាក់តែង ស្អិតស្អាងផ្លូវ ឲ្យមានរបៀបរៀបចំល្អ ហើយកាន់ក្អមពេញទៅដោយសុគន្ធវារី ជាគ្រឿងសម្គាល់នៃការចុះចូលប្រមូលគ្នា ទៅរង់ចាំថ្វាយគ្រឿងសក្ការបូជាក្នុងទីកន្ទះយោជន៍ កាលបានឃើញព្រះកុនាលៈស្ដេចយាងមកហើយ ក៏ប្រណម្យអញ្ជលីឡើងហើយនិយាយថាៈ «ពួកយើងខ្ញុំសុទ្ធតែជាអ្នកនគរ មិនមែនជាអ្នកក្បត់នឹងស្ដេចទេ ពួកយើងមិនមែនជាអ្នកក្បត់នឹងព្រះឱរសនៃស្ដេចទេ ពួកយើងបះបោរក្បត់ ចំពោះតែសេនាបតីទុច្ចរិត ដែលជាអ្នកតាំងនៅជិតផ្ទាល់នឹងស្ដេច» លុះក្រាបទូលនូវពាក្យនេះហើយ ក៏នាំគ្នាថ្វាយគ្រឿងសក្ការៈ និងសួយសារអាករ ទើបនាំគ្នាហែហមព្រះកុនាលៈដោយសេចក្ដីគោរពយ៉ាងខ្ពស់ នាំចូលឆ្ពោះទៅក្នុងព្រះនគរ។

វេលានោះ ព្រះបាទអសោក ទ្រង់ប្រឈួនខ្លាំងណាស់ អន្ទះអន្ទែងធ្លាក់ឧច្ចារៈមកតាមព្រះឱស្ឋ ហើយចេញឈាមស្អុយឆ្អេះឆ្អាបគ្រប់រន្ធព្រះលោម ព្រះអង្គស្ដេចទ្រង់ជ្រាបថាៈ

មិនអាចនឹងបានជាឡើងវិញ ទើបទ្រង់មានព្រះឱង្ការទៅនឹងពួកសេនាបតីថា «ចូរទៅអញ្ជើញព្រះកុនាលៈមកអភិសេកឲ្យសោយរាជ្យទៅ មិនយូរប៉ុន្មានទេ ខ្ញុំនឹងទិវង្គតហើយ មានប្រយោជន៍អ្វីនឹងជីវិតអាក្រក់លាមកនេះ»។

ព្រះអគ្គមហេសីឯករបស់ព្រះរាជាព្រះនាមតិស្សរក្សិតា លុះព្រះសណ្ដាប់ពាក្យនោះហើយ ព្រះនាងនឹកជញ្ជឹងថា: «បើព្រះកុនាលរាជឱរសបានជាស្ដេចឡើង សមជីវិតរបស់អញនឹងមិនមានឡើយ» ព្រោះដូច្នោះ ទើបព្រះនាងប្រើឧបាយកលក្រាបទូលព្រះរាជាថា: «ឱព្រះរាជា! សូមទ្រង់ហាមពួកពេទ្យ កុំឲ្យចូលមកក្នុងព្រះរាជដំណាក់ ខ្ញុំម្ចាស់នឹងទទួលការរក្សាព្រះអង្គឲ្យបានក្សាន្តព្រះហឫទ័យឡើងវិញ»។

ខណៈនោះ ព្រះបាទអសោក ទ្រង់បញ្ជូនពួកពេទ្យឲ្យចេញទៅក្រៅ ហើយទ្រង់បញ្ញត្តហាមផ្ដាច់មិនឲ្យចូលមកក្នុងព្រះបរមរាជវាំង។

ព្រះនាងតិស្សរក្សិតា បានចេញប្រកាសប្រាប់អ្នកនគរគ្រប់ទីតំបន់ថា: «បើអ្នកណាមួយ ទោះប្រុសក្ដី ស្រីក្ដី ចាប់

ឈឺដូចយ៉ាងអាពាធព្រះរាជា ចូររក្សាទុកកុំព្យាបាលជម្ងឺនោះ ខ្ញុំអនុញ្ញាតឲ្យនាំអ្នកជម្ងឺនោះមកឲ្យខ្ញុំបានគ្រប់ពេល»។ ខណៈនោះ មានមនុស្សម្នាក់ចាប់ឈឺបែបយ៉ាងនោះ ភរិយាក៏ភ័យតក់ស្លុតណាស់ រត់ទៅជំរាបគ្រូពេទ្យម្នាក់ថា: «ស្វាមីខ្ញុំមានជម្ងឺបែបយ៉ាងនោះ»។

គ្រូពេទ្យបង្គាប់ថា: «ចូរនាំយកជម្ងឺនោះឲ្យប្រញាប់មកខ្ញុំនឹងព្យាបាលឲ្យ»។

នាងក៏ម្ទីម្នាទៅនាំយកស្វាមី ដែលមានជម្ងឺនោះមកផ្ទះគ្រូពេទ្យ ឯគ្រូពេទ្យក៏នាំយកជម្ងឺនោះទៅថ្វាយដល់ព្រះនាងតិស្សរក្សិតា។ សម្លាប់ហើយវះពោះពិនិត្យមើល ឃើញមានដង្កូវមួយធំនៅក្នុងពោះនោះ កាលណាដង្កូវស្ទុះឡើងទៅខាងលើ ឧច្ចារៈក៏ប្រាលឡើងតាមខ្លួនវានោះទៅ កាលណាវាស្ទុះចុះទៅក្រោម ឧច្ចារៈក៏ស្រុតចុះទៅខាងក្រោម[១] ពេលនោះព្រះនាងរោយកំទេចម្រេចពីលើដង្កូវ តែដង្កូវនោះមិន

[១] អាយុ-វង់-កឹង បន្ថែមថា «កាលដង្កូវស្ទុះទៅខាងស្តាំឬខាងឆ្វេង ក៏ទឹកសំអុយចេញតាមគ្រប់រន្ធរោមនៃស្បែក។

ស្លាប់ ព្រះនាងធ្វើវិធីសម្លាប់ដង្កូវគ្រប់បែបយ៉ាង ល្បងមើលរសល្វីងចត់ខារ ក៏ដង្កូវនោះនៅតែមិនស្លាប់ រហូតដល់ព្រះនាងដាក់ខ្ទឹមទៅ ដង្កូវក៏ស្លាប់ ហើយធ្លាក់ចេញទៅតាមទ្វារខាងក្រោមមួយរំពេចនោះ ព្រោះដូច្នោះ ព្រះអគ្គមហេសីទៅក្រាបបង្គំទូលព្រះរាជាឲ្យទ្រង់សោយខ្ទឹម។

ព្រះបរមក្សត្រិយ៍ ត្រាស់ថា: «យើងជាជាតិក្សត្រិយ៍ យើងនឹងសោយខ្ទឹមដូចម្ដេចបាន!»។

ព្រះនាងតិស្សរក្សិតា ក្រាបទូលព្រះបរមក្សត្រិយ៍ជាគម្រប់ពីរដងថា: «ត្រូវតែទ្រង់សោយខ្ទឹមនោះទៅ ដើម្បីឲ្យជាព្រះរោគរបស់ព្រះអង្គ»។

លុះទ្រង់ ព្រះសណ្ដាប់ពាក្យនោះហើយ ស្ដេចទ្រង់សោយខ្ទឹមនោះទៅ ដង្កូវនោះក៏ស្លាប់ក្នុងគ្រានោះទៅ ហើយធ្លាក់ចេញទៅតាមទ្វារខាងក្រោម ក្នុងមួយរំពេចនោះ មិនយូរប៉ុន្មានព្រះរាជាក៏បានជាចាករោគាពាធនោះ ព្រះអង្គទ្រង់មានព្រះហឫទ័យត្រេកអរស្រស់ស្រាយ ហើយត្រាស់សួរព្រះនាងតិស្សរក្សិតាថា: «នាងប្រាថ្នាចង់បានអ្វី យើងនឹង

ប្រទានពរដល់ព្រះនាង?»។

ព្រះនាង ទូលតបថា: «ខ្ញុំម្ចាស់ ប្រាថ្នាចង់សោយរាជសម្បត្តិបាន៧ថ្ងៃ»។

គ្រានោះ ព្រះបាទអសោក ទ្រង់ប្រោសប្រទានរាជសម្បត្តិឲ្យព្រះនាងអស់វេលា៧ថ្ងៃ ព្រះនាងតិស្សរក្សិតា លុះបានទទួលពរ គឺរាជសម្បត្តិនោះហើយ ទើបទ្រង់ព្រះចិន្តាថា: «វេលានេះជាពេលគួរធ្វើកិច្ចសងសឹកនឹងកុនាលរាជឱរសហើយ»។

ខណៈនោះ ព្រះនាងទើបក្លែងសរសេរព្រះរាជឱង្ការដោយខ្លួនឯង បង្គាប់ទៅអ្នកនគរតក្កសិលាថា: «ចូរអ្នកទាំងឡាយឆ្កៀលភ្នែកចៅកុនាលៈទាំងពីរចេញ ព្រោះហេតុអ្វី? ព្រោះវាមានទោសខុសជាទម្ងន់ ចូរអ្នកទាំងឡាយឆ្កៀលភ្នែកវាទាំងពីរចេញឲ្យឆាប់ ព្រះបាទអសោក ទ្រង់មានព្រះហឫទ័យទៀងទាត់ណាស់ ចូរអ្នករាល់គ្នាកុំបង្អង់ទុក វានោះជាមនុស្សទទឹងទាស់នឹងអាជ្ញាស្តេច»។

ក្នុងកាលឯណោះ ក្តី កាលព្រះបាទអសោក មាន

ព្រះរាជឱង្ការត្រាស់បង្គាប់ទៅលើអ្វីមួយ តែងតែប្រថាប់ព្រះរាជសារ[១] នឹងព្រះរាជវរលញ្ឆករដោយផ្ដិតព្រះទន្តរបស់ព្រះអង្គ ទើបយកជាការបាន ព្រោះដូច្នោះ ព្រះនាងតិស្សរក្សិតា ទើបរង់ចាំព្រះរាជាទ្រង់ព្រះបន្ទំលក់ស៊ប់ នឹងបានផ្ដិតព្រះរាជឱង្ការនោះ ស្រាប់តែព្រះរាជាស្ដេចស្ទុះតើនដូចជាគេកន្ទ្រាក់ឡើងភ្លាម ភ័យញ័រចំប្រប់សព្វសព៌ាង្គ។

ព្រះនាងតិស្សរក្សិតាក្រាបបង្គំទូលសួរព្រះរាជាថា: «អ្វីធ្វើឲ្យទ្រង់រំខានព្រះរាជហឫទ័យ ស្ទុះតើនឡើងក្រញាំងចាកព្រះបន្ទំក្នុងពេលនេះព្រះអង្គ?»។

ព្រះមហាក្សត្រត្រាស់តបថា: «យើងមានសុបិនអាក្រក់ណាស់ ឃើញថាមានត្មាតពីរ វាចង់ចឹកកែវភ្នែកកុនាលៈកូនយើង»។

លុះទ្រង់ត្រាស់ព្រះឱង្ការនោះហើយ ស្ដេចទ្រង់ផ្ទំតទៅទៀត ក្នុងគ្រាទី២ ព្រះរាជាស្ដេចស្ទុះតើនឡើងដូចជាគេកន្ទ្រាក់ទៀត ហើយត្រាស់ នឹងព្រះអគ្គមហេសីថា: «យើង

[១] ព្រះរាជសារ សំបុត្រស្ដេច។

យល់សុបិនអាក្រក់ទៀតហើយ»។

ព្រះរាជិនី[១] ក្រាបទូលសួរថា: «ព្រះអង្គទ្រង់យល់ព្រះសុបិនដូចម្តេច?»។

ព្រះមហាក្សត្រិយ៍តបថា: «យើងឃើញថាកុនាលៈមានសក់វែងណាស់ ហើយអង្គុយផ្ទាល់លើផែនដី»។

ព្រះរាជិនីក្រាបទូលថា: «សូមទ្រង់ព្រះបន្ទំឲ្យស៊ប់ស្រួលព្រះអង្គទៅ អ្នកណាឡើយនឹងហ៊ានប្រព្រឹត្តទុច្ចរិតនឹងព្រះអង្គម្ចាស់នោះបានហ្ន៎»។

ព្រះរាជាស្តេចទ្រង់ផ្ទំលក់ស្កប់ស្កល់តទៅទៀត ព្រះរាជិនី ទើបលបប្រថាប់ព្រះរាជសារ នឹងព្រះរាជ វរលញ្ចករ ដោយព្រះទន្តព្រះរាជា បានស្រេចហើយ ព្រះនាងបញ្ជូនព្រះរាជបម្រើម្នាក់ ឲ្យនាំយកព្រះរាជឱង្ការនោះ ទៅឲ្យមនុស្សនៅក្នុងក្រុង តក្សសិលា ឲ្យឆ្កៀលព្រះនេត្រាព្រះកុនាលរាជឱរស។

ក្នុងខណៈនោះ ព្រះមហាក្សត្រ ទ្រង់សុបិនទៀតថា:

---

[១] ព្រះរាជិនី ស្តេចស្រី។

«ឃើញព្រះទន្តារបស់ព្រះអង្គ បាក់ធ្លាក់ជ្រុះចាកព្រះឱស្ឋ ទ្រង់តើនឡើងពីព្រលឹម ហើយត្រាស់ហៅហោរាចារ្យមក ដើម្បីនឹងពិចារណាកាត់សុបិននោះ»។

ហោរាពិចារណានូវទំនាយនោះហើយទាយថា: «សុបិនបែបនេះ ប្រាកដជាព្រះរាជបុត្រនឹងវិនាសបង់ចក្ខុ»។

លុះទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ស្ដេចប្រណម្យអញ្ជលីដោយក្រពុំនៃព្រះអង្គុលីទាំង១០ ក្រាបនមស្សការគ្រប់ទិសទាំង៤ ទ្រង់ធ្វើសេចក្ដីបួងសួងទេពារក្សដែលជាអ្នកថែទាំព្រះពុទ្ធសាសនាដោយព្រះវាចាជាសច្ចកថានេះថា:«ឱអស់ទេពារក្សទាំងឡាយ លោកអ្នកដែលមានបសាទសទ្ធាជ្រះថ្លា ក្នុងព្រះធម៌និងព្រះសង្ឃ ខ្ញុំសូមអង្វរឲ្យលោកគ្រប់គ្រងរក្សា បុត្រពន្ធកខ្ញុំផង[១]»។ លុះព្រះរាជសារទៅដល់ក្រុងតក្សសិលាហើយ ពួកអ្នកនគរក្នុងក្រុងនោះ សុទ្ធតែជាអ្នកស្រឡាញ់គោរពរាប់អានព្រះធម៌ និងព្រះសង្ឃក៏មនុស្សទាំង

[១] ក្នុងទិវ្យាវទាន និងអាយុ-វង-គឹង សេចក្ដីបួងសួងរបស់ព្រះរាជានេះរលឹកដល់ឬសីទៀតថា: «សូមឬសីដែលជាប្រធានក្នុងលោក»។

នោះជាអ្នកមានចិត្តអាណិតអាសូរ និងមានសទ្ធាដ៏មាំយ៉ាង នោះ បានជាគ្មានអ្នកណាមួយនឹងនាំព្រះរាជសារនោះ ទៅថ្វាយព្រះកុនាលៈឡើយ។ ពួកអ្នកនគរនោះ ពិគ្រោះគ្នាក្នុងរឿងនោះថាៈ «បើព្រះរាជាមិនទ្រង់ទតមើលព្រះរាជបុត្ររបស់ព្រះអង្គដោយប្រោសប្រណីហើយ ដូចម្ដេច ទ្រង់នឹងបានសព្វព្រះរាជហឫទ័យ ប្រោសប្រាណដល់ពួកយើងដែលជាអ្នកបំបិទបំបាំងព្រះរាជអាជ្ញាព្រះអង្គនោះ? ព្រះកុនាលរាជឱរស ព្រះអង្គមាននិស្ស័យប្រកបដោយមេត្តាឥតស្រាក ចំពោះពួកសត្វគ្រប់ជំពូក ទ្រង់មានប្រាថ្នានឹងជួយការពារឲ្យសត្វទាំងអស់នោះ បានទទួលសេចក្ដីសុខ ទ្រង់មានព្រះហឫទ័យ សន្ដោស និងធូន់ធូរ ទ្រង់មិនមានព្រះហឫទ័យមានះ ប្រកាន់ឫកពា និងក្រេវក្រោធឥតបទសោះឡើយ បើមានបុត្របែបនេះហើយ គង់ព្រះរាជាប្រាថ្នានឹងធ្វើសេចក្ដីវិនាសដល់បុត្រនោះទៅហើយ អម្បាលបើពួកយើងមិនដឹងជាព្រះអង្គនឹងធ្វើដូចម្ដេចទៅទៀត»។

លុះលាក់ព្រះរាជសារនោះ ស្ងាត់ស្ងៀម យូរបន្តិចទៅ

មិនសុខមិនសាប់ ក៏នាំគ្នាយកទៅថ្វាយព្រះកុនាលរាជឱរស ព្រះអង្គបានទទួលព្រះរាជសារនោះហើយ ទ្រង់បន្ថែមសទ្ធា ដែលទ្រង់មានហើយ ឲ្យរឹងរឹតតែចំរើនឡើង ទើបត្រាស់ថាៈ «ចូរធ្វើតាមប្រាថ្នារបស់អ្នកទាំងឡាយចុះ ចូរអ្នកទាំងឡាយ ឆ្កៀលភ្នែកទាំងពីររបស់ខ្ញុំចុះ»។ ប៉ុន្តែពេលនោះ មិនមានអ្នក ណាមួយហ៊ានឆ្កៀលព្រះនេត្រព្រះអង្គ ហើយទ្រង់ត្រាស់ ហៅពួកមនុស្សចណ្ឌាលមក បង្គាប់ឲ្យឆ្កៀលព្រះនេត្រព្រះ អង្គ ពួកមនុស្សចណ្ឌាលនោះទូលប្រកែកថាៈ «ពួកយើងខ្ញុំ បំផ្លាញភ្នែករបស់យើងខ្ញុំប្រសើរជាង ដូចម្ដេចក៏ទៅបំផ្លាញ ភ្នែកមនុស្សបែបនេះវិញ?»។

កាលទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ព្រះអង្គទាញ ប្រអប់[១] ដ៏មានតម្លៃមាសមួយសែនតម្លឹង ប្រទានទៅពួក មនុស្សចណ្ឌាល ជារង្វាន់ដែលឆ្កៀលព្រះនេត្រព្រះអង្គ តែ ពួកចណ្ឌាលប្រកែកទៀតដូចមុន។

---

[១] ទិវ្យាវទាន និងអាយុ-វង-កឹង ព្រះចៅកុនាលៈបានប្រទានគ្រឿងប្រដាប់ព្រះសិររបស់ព្រះ អង្គដល់មនុស្សចណ្ឌាល។

គ្រានោះ កម្មពីអតីតជាតិក៏ជួនជាត្រូវឲ្យផលសម្រេចមួយរំពេចនោះ ក៏ស្រាប់តែមានមនុស្សម្នាក់ មានសណ្ឋានមុខប្រកបដោយវិកលវិការ ១៨អន្លើ ចូលមកសូមធ្មៀលព្រះនេត្រព្រះចៅកុនាលៈ លុះព្រះកុនាលរាជឱរស បានទស្សនាការហើយ ក្នុងខណៈនោះ ស្ដេចទ្រង់រំលឹកដល់ពាក្យព្រះយសត្ថេរ ដែលថាភ្នែកជាធម្មជាតិមិនទៀង ហើយទ្រង់ព្រះតម្រិះនេះថាៈ «លោកបានឃើញច្បាស់ថា អញនឹងត្រូវអន្តរាយភ្នែក ដែលជារង្វាន់នៃផលកម្មរបស់អញ ព្រោះដូច្នោះ លោកទើបបានសំដែងពាក្យនោះ លោកជាកល្យាណមិត្រនឹងអញពិតប្រាកដៗ ព្រោះគុណគឺសេចក្ដីមេត្តាចំពោះមកខ្លួនអញ ទើបលោកបានប្រោសប្រទានឱវាទរបស់លោកដល់អញ លោកប្រាថ្នានឹងឲ្យអញដឹងខ្លួន ក្នុងពេលដែលអញបានទទួលរង្វាន់ នៃផលកម្មរបស់អញនេះ ចិត្តអញមិនបានរំភើបញាប់ញ័រទេៗ ម្យ៉ាងទៀតក្នុងកាលមុននោះ ព្រះថេរៈបានបង្រៀនវិជ្ជានេះដល់អញថា ពួកសត្វ

ទាំង៣ពួក[១] ក៏មិនទៀងទាត់ទេ មិនមែនជារបស់រឹងប៉ឹងទេ តែងតែប្រែប្រួលទៅជាធម្មតា គ្រាន់តែស្រមើស្រមៃបញ្ឆោតចិត្តឥតអំពើ តាំងតែពីយូរយារណាស់មកហើយ អញបានឃើញខ្លួនឯងជាក់ច្បាស់ហើយថា: «នឹងត្រូវខូចខាតចក្ខុប្រសាទជាលក្ខណៈ ចូរខ្លួនឯងខំប្រឹងសម្រឹងខ្លួននៅក្នុងព្រះធម៌ថ្ងៃ»។

គ្រានោះ ព្រះកុនាលរាជឱរស ត្រាស់នឹងមនុស្សរូបវិកលនោះថា: «ចូរឯងឆ្កៀលភ្នែកអញម្ខាង ដាក់មកក្នុងបាតដៃអញសិន»។

ខណៈនោះ មនុស្សរូបវិកលនោះ ស្ទុះស្ទាចូលទៅជិតព្រះកុនាលរាជឱរស ដោយសេចក្ដីប៉ុនប៉ងនឹងឆ្កៀលព្រះនេត្រព្រះអង្គ ហើយឆ្កៀលព្រះនេត្រម្ខាង ដាក់មកក្នុងព្រះហស្តព្រះអង្គ ក៏ពួកអ្នកឈរមើលទាំងអស់ស្រែកគឹកកង ទ្រហឹងអឺងអាប់ ដោយស្ញប់ស្ញែងត្រញែងខ្លួនថា: «ឱចំឡែកអស្ចារ្យណាស់ហ្ន៎!»។

---

[១] ពួកសត្វទាំង៣ពួក: កាមភព រូបភព អរូបភព។

»ឱកម្មអកុសល! លោតែព្រះចន្ទ្រដ៏បរិសុទ្ធមានរស្មីភ្លឺត្រចះធ្លាក់ស្រូតចុះមក ហើយផ្កាឈូកដ៏រីកស្រស់ល្អត្រកាលរោយរុះទៅហើយ ក៏ពួកមនុស្សទាំងសែនកោដិ មិនអាចនឹងទប់ទល់សេចក្ដីសោកស្ដាយបាន ស្រែកយំអឺងកងគ្រប់ៗគ្នា»។

ព្រះកុនាលរាជឱរស បានពិចារណាមើលវង់ចក្ខុដែលនៅក្នុងព្រះហស្តដោយព្រះតម្រិះនេះថា: «ឈិះ! ភ្នែកនេះនៃ! ហេតុអ្វីបានជាឥឡូវនេះ ឯងមើលរូបភាពមិនឃើញសោះ ពីដើមគេថាឯងនេះល្អណាស់ ឥឡូវនេះឯងគ្រាន់តែជាដុំសាច់ជោកទាប ឥតគេរាប់សោះទេតើ ឯងហ្នឹងហើយធ្វើឲ្យវរវីកចិត្ត ពួកមនុស្សល្ងង់ខ្លៅ គេថាព្រោះតែឯងហ្នឹង ទើបបណ្ដាលចិត្តអញ ឲ្យមានសេចក្ដីស្នេហា ឈ្ងក់នៅខុសបែបបទ ឯខ្លួនឯងៗ គ្រាន់តែធ្វើបញ្ឆោរឲ្យស្ទុងចិត្ត ដោយហេតុទាំងពាន់ទាំងម៉ឺន និយាយដោយពិតទៅថា មិនមានភ្នែកក៏មិនជាអ្វីដែរ ភ្នែកឯងដូចពពុះដែលអណ្ដែតនៅលើខ្នងទឹក អ្នកដែលពិចារណាឃើញថា ឯងហ្នឹងជារបស់រឹងប៉ឹងពិតប្រាកដឥតបន្ទូរបន្ថយ អ្នកនោះឈ្មោះថា ជាទាសៈនៃជីវិត ហើយ

នឹងសេចក្តីស្លាប់»។

ពេលដែលព្រះអង្គពិចារណាដូច្នេះ ទ្រង់ក៏បានសម្រេចសោតាបត្តិផល ហើយទ្រង់បានឃើញនូវអរិយសច្ច ដោយជាក់ច្បាស់ក្នុងពេលនោះ។

គ្រាព្រះអង្គបានឃើញអរិយសច្ចហើយ ទើបត្រាស់នឹងមនុស្សរូបវិកលវិការនោះថា: «ចូរឯងឆ្កៀលភ្នែកម្ខាងទៀត»

មនុស្សនោះគោរពតាមពាក្យបង្គាប់ បានឆ្កៀលព្រះនេត្រនោះ ហើយដាក់ទៅក្នុងព្រះហស្ត។

ព្រះចៅកុនាលៈ បានពិចារណាមើលភ្នែកនោះហើយទ្រង់បានសម្រេចដល់សកទាគាមី ព្រោះតែព្រះអង្គវិនាសមំសចក្ខុហើយ ទ្រង់ត្រឡប់បានបញ្ញាចក្ខុដ៏បរិសុទ្ធឡើងវិញ ទើបទ្រង់ត្រាស់ព្រះវាចានេះថា: «មំសចក្ខុទាំងឡាយរបស់អញ គេឆ្កៀលចេញអស់ហើយ តែអញបានហើយនូវចក្ខុគឺប្រាជ្ញា បើព្រះបិតាអញ បោះបង់ចោលបុត្រក្នុងសង្សារវដ្តហើយ អញគប្បីជាឱរសរបស់ព្រះពុទ្ធជាព្រះធម្មរាជាវិញ បើទុកជាអញវិនាសហើយចាករាជសម្បត្តិ អញក៏បានធម្ម

សម្បត្តិក្នុងគ្រានេះដែរ អញបានរួចផុតចេញស្រឡះហើយ ចាកសេចក្តីទោមនស្ស និងសេចក្តីទុក្ខព្រួយ»។

លំដាប់តមក ព្រះកុនាលរាជឱរសទ្រង់ជ្រាបថាៈ «ព្រះរាជសារចុតហ្មាយក្លែងមកអំពីព្រះនាងតិស្សរក្សិតា មិនមែនជាការសម្រេចមកអំពីរាជប្បញ្ញត្តទេ។ ខណៈនោះ ព្រះអង្គតាំងសេចក្តីប្រាថ្នាថាៈ «សូមឲ្យព្រះរាជិនីតិស្សរក្សិតា ទ្រង់សម្រាន្តព្រះជន្មនៅជាសុខឲ្យបានយូរលង់ទៅ ហើយកុំឲ្យវិតក្កអផ្សុកក្នុងព្រះអង្គឡើយ។ ព្រោះហេតុអ្វី? ព្រោះថា ព្រះនាងជាគ្រឿងប្រដាប់ជាហេតុធ្វើឲ្យវិនាសដល់ខ្ញុំ ហើយធ្វើខ្ញុំឲ្យបានសម្រេចគុណធម៌ជាផល»។

គ្រានោះ នាងកាញ្ចនមាលា ជាព្រះជាយាព្រះកុនាលៈបានជ្រាបដំណឹងថាៈ «ព្រះស្វាមីត្រូវគេឆ្កៀលព្រះនេត្រទាំងពីរហើយ នាងក៏ស្ទុះម្នីម្នាទៅជិតព្រះស្វាមី លុះបានឃើញព្រះស្វាមីមានព្រះកាយប្រឡាក់ដោយព្រះលោហិត ដែលហូរស្រោចអំពីព្រះនេត្រាមក នាងស្រែកយំភ័យរន្ធត់តក្កមាពេញដោយសេចក្តីសង្វេគ តក់ស្លុតចិត្ត ហើយដួលដេក

សន្ទប់បាត់ស្មារតីទៅលើផែនដី អ្នកនៅជិតខាងបានយកទឹកប្រស់ព្រំស្រប់ព្រះភក្ត្រា នាងបានដឹងអាត្មាងើបឡើងទាំងទុក្ខ ហើយខ្សឹកខ្សួលទួញថា: «ឱ! ព្រះនេត្រាដ៏បរិសុទ្ធ ហើយល្អបំផុតក្នុងត្រៃកពនោះ ជារបស់វិនាសទៅ ជារបស់ផុតវិស័យនឹងកែឡើងវិញបានហើយ»។

ព្រះកុនាលរាជឱរស មានប្រាថ្នានឹងលួងលោមនាង ទើបត្រាស់នូវគាថានេះថា:

អំពើទុច្ចរិតដែលបងធ្វើហើយ ឥឡូវនេះបងត្រូវទទួលផ្ទុនាអំពីអំពើទុច្ចរិតនោះវិញ សេចក្ដីទុក្ខដ៏ធំបំផុតរបស់សព្វសត្វទាំងឡាយក្នុងលោក គឺការព្រាត់ប្រាសចាកមិត្រស្និទ្ធស្នេហាជាធម្មតា ចូរប្អូនឯងបន្ទោបង់សេចក្ដីទុក្ខសោក ឲ្យផុតឆ្ងាយពីខ្លួនទៅណានាង ប្រយោជន៍អ្វីនឹងការយំសោកនេះ»។

ពួកអ្នកនគរបានឃើញដូច្នោះហើយ ទើបនាំគ្នាបំបរបង់ព្រះកុនាលៈព្រមទាំងព្រះជាយា បង្ខំឲ្យស្ដេចចេញចាកដែនទៅ។

ចាប់ដើមតាំងអំពីកំណើតមក ក៏អ្នកទាំងពីរ ព្រះស្វាមី

និងព្រះជាយា ធ្លាប់បានទ្រង់ព្រះជន្មនៅដោយការសោយសុខសម្រាន្តជាសុខុមាលជាតិ ស្ដេចមិនដែលប្រកបការងារឲ្យនឿយហត់ដល់ព្រះកាយពលទេ មិនដែលសែងលីភារៈដ៏ធ្ងន់ទេ សូម្បីការងារអ្វីតិចតួចក៏មិនដែលធ្វើផង ទ្រង់ក៏ត្រឡប់ទៅជាថោកទាប ស្ដេចយាងសូមទានគេដោយព្រះបាទ។ ទ្រង់ដេញពិណាហើយស្រែកច្រៀងក្ដែងៗ តាមតំបន់ផ្សេងៗ សូមទានអាហារដើម្បីចិញ្ចឹមជីវិតព្រះអង្គ ព្រមទាំងព្រះជាយាផង។ នាងកាញ្ចនមាលា ដឹកព្រះហស្តព្រះស្វាមីស្ដេចទ្រង់ព្រះដំណើរត្រឡប់មក តាមមាគ៌ាដែលចូលទៅកាន់ក្រុងបាតលិបុត្រ កាលដល់ទ្វារព្រះបរមរាជវាំងហើយទ្រង់ប្រាថ្នាចង់ចូលទៅខាងក្នុងព្រះរាជដំណាក់ព្រះបិតា តែនាយទ្វារបាលឃាត់មិនឲ្យស្ដេចចូលទៅ។ វេលានោះ ព្រះកុនាលរាជឱរសទ្រង់ផ្ទំនៅក្នុងរោងដំរី ទៀបទ្វារព្រះរាជវាំងនោះអស់មួយរាត្រី លុះព្រលឹមស្រាងឡើង ទ្រង់ដេញពិណាហើយច្រៀង រៀបរាប់ទៅតាមសំឡេងពិណា អំពីគ្រាជាធំហើយនិងគ្រាអភ័ព្វរបស់ព្រះអង្គ ព្រមទាំងបរិយាយអំពី

ហេតុ ដែលបានសម្រេចមគ្គផល ព្រោះគេធ្មៀលព្រះនេត្រា របស់ព្រះអង្គ។ ពួកអ្នកដែលស្ថិតនៅជិតទ្វារ បានស្ដាប់ទំនុកច្រៀងនោះហើយ ក៏បានពិចារណាដោយខ្លួនឯង អំពីរូបភាពដែលប្រមូលរួមចូលទៅក្នុងខន្ធទាំងឡាយ អ្នកទាំងអស់នោះ ក៏បានរួចចាកជាតិទុក្ខ ដែលប្រព្រឹត្តទៅក្នុងវដ្ដសង្សារបានគ្រប់គ្នា។

ព្រះបាទអសោក កាលទ្រង់ព្រះសណ្ដាប់សំឡេងច្រៀងនិងសំឡេងពិណនោះ ព្រះអង្គនឹកភ្នកដល់ព្រះកុនាលរាជឱរស ហើយទ្រង់ត្រាស់ថា: «សូរសំឡេងពិណនោះដូចជាសូរសំឡេងរបស់កុនាលៈកូនអញ ទំនុកច្រៀងរៀបរាប់អំពីសំណាងវាសនាអាក្រក់និងល្អនោះ ជាទំនុកច្រៀងអ្នកណាមួយក្នុងគ្រាដែលវាបានធ្វើជាធំ។ ព្រះអង្គទើបចាត់រាជបំរើឲ្យទៅពិនិត្យមើល លុះរាជបម្រើបានទៅឃើញ ព្រះកុនាលរាជឱរសប្រាសចាកព្រះនេត្រទាំងសងខាង មានព្រះកាយស្គមកំព្រឹង ហើយកើតចែងថ្ងៃរទុះ ព្រោះហេតុនោះ ទើបចំណាំព្រះអង្គមិនបាន ក៏ត្រឡប់ទៅក្រាបទូលព្រះរាជាថា: «គឺអ្នក

ស្នូមម្នាក់ខ្វាក់ភ្នែកពពើម មានខ្លួនស្គមកំព្រឹង ហើយកើតបែងថ្ងៃរទុះ ប្រពន្ធវាបិតនៅផ្ទាប់ខាងខ្លួនវានោះ»។

ព្រះរាជា កាលទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ទ្រង់មានព្រះតម្រិះថា: «កាលពីមុន អញយល់សុបិនឃើញថា កុនាលៈកូនអញបានអន្តរធានភ្នែកទាំងពីរ ទៅក្រែងវាហ្នឹងហើយដឹង? អញរលឹកដល់កូនអញ គ្មានស្រាកចិត្តមួយស្របក់សោះ នៃអាមាត្យធាប់ឡើង! ឲ្យគេទៅហៅវាមក។ ខណៈនោះ ស្ដេចត្រាស់ប្រើឲ្យរាជបម្រើទៅហៅមនុស្សខ្វាក់នោះពីរោងដំរី លុះដល់ហើយគេសួរមនុស្សខ្វាក់នោះថា: «អ្នកជាអ្វី? អ្នកជាកូនចៅនរណា?»។

មនុស្សខ្វាក់តបថា: «បិតាខ្ញុំជាស្ដេចឈ្មោះអសោកព្រះអង្គជាម្ចាស់នៃជម្ពូទ្វីប ទ្រង់ជាឥស្សរលើមនុស្សទាំងអស់ ខ្ញុំជាឱរសរបស់ព្រះអង្គនោះ ខ្ញុំឈ្មោះកុនាលៈ តែខ្ញុំមានបិតាមួយផ្សេងទៀត ព្រះអង្គជាធម្មិកមហារាជដែលគេធ្លាប់ហៅថាព្រះពុទ្ធនោះ»។

ខណៈនោះ ពួករាជបំរើបាននាំមនុស្សខ្វាក់ ព្រមទាំង

កិរិយាទៅគាល់ព្រះមហាក្សត្រិយ៍។

កាលព្រះមហាក្សត្រិយ៍ ទតឃើញព្រះកុនាលរាជឱរស ប្រាសចាកព្រះនេត្រ មានព្រះកាយស្គមកំព្រឹង លេចឆ្អឹងថ្ងៃរទុះ មានសំលៀកបំពាក់ដ៏គ្រាំគ្រាចាស់រយីករយាកធ្លុះរហុយ ព្រោះហេតុនោះ ទើបទ្រង់ចំណាំព្រះឱរសពុំបាន លុះទ្រង់បានឃើញ មនុស្សកំសត់ទុគ៌ត មានទំនងអាការ រស់នៅដោយលំបាកដូច្នោះ ទើបត្រាស់សួរថា: «ឯងជាចៅកុនាលៈ មែនឬទេ?»។

ព្រះរាជឱរសទូលតបថា:«ទូលព្រះបង្គំហ្នឹងហើយព្រះអង្គ»។

ព្រះរាជាកាលទ្រង់ព្រះសណ្ដាប់ពាក្យនោះ ព្រះវរយោ ក៏កំរើកខ្លាំង សង្រេងសង្រ្រែស្រយុតព្រះហឫទ័យ ដោយសេចក្ដីទុក្ខព្រួយ ស្ដេចដួលទៅលើផែនដី ពួករាជបរិពារបាន យកទឹកប្រស់ព្រំស្រប់ព្រះភក្ត្រា ព្រះអង្គបានដឹងព្រះស្មារតីតើនឡើង ទ្រង់លើកត្រកងបីព្រះកុនាលៈដាក់លើព្រះឱរូ ទ្រង់ក្បែតព្រះនេត្រានឹងព្រះហស្ត ហើយទ្រង់ព្រះកន្សែង ថា: «គ្រាពីមុន នេត្រាឯងដូចជាភ្នែកបក្សីកុនាលៈ ព្រោះ

ដូច្នោះ បានជាគេហៅកូនឯងដោយនាមនេះ ឥឡូវនេះ កូនឯងវិនាសសាបសូន្យចាកនេត្រានោះទៅហើយ តើនឹងហៅកូនឯងដូចម្តេចវិញ? ឱមាសឪពុក ប្រាប់ហ្លួងចូរចុះ អ្នកណាបានធ្មៀលភ្នែកកូនឯង ធ្វើឲ្យដូចជាផ្ទៃមេឃប្រាសចាកដួងព្រះចន្ទ្រនិងតារាដូច្នោះ? មនុស្សមានចិត្តឥតមេត្តាត្រាប្រណី វាបានធ្វើឲ្យសាបសូន្យភ្នែកកូនឯងនោះ តើមនុស្សដូចម្តេច? អ្នកណាបានធ្វើភ្នែកកូនឯង ឲ្យជាប្រធាននៃការឈឺចាប់នៅជាប់រហូតមកដល់ថ្ងៃនេះ? កុនាលៈកូនឪពុកអើយ! អ្នកណាប្រាថ្នាធ្វើភ្នែកកូនឯងឲ្យវិកលវិការបែបនេះ?»។

ចូរប្រាប់ឪពុកមកឲ្យឆាប់ចុះ? ឪពុកឃើញកូនឯងពេលនេះ ឪពុកទន់អស់ទាំងកាយ ឈឺចាប់ជាពន្ទឹក ភ្លើងគឺសេចក្តីសោកស្តាយឆេះសាយសព្វខ្លួន រហូតដល់ដួងហឫទ័យបិតាហើយ ធ្វើឲ្យឪពុកបានសេចក្តីវិនាសសាបសូន្យ ដូចជាគេត្រូវកម្មអសនី។

ព្រះកុនាលរាជឱរស ឱនចុះទៀបព្រះបាទព្រះរាជបិតាហើយក្រាបទូលថា: «ព្រះអង្គកុំសោយសោកជាទុក្ខជាអុកអ៊ី

កុំក្រេវក្រោធដល់ហេតុការណ៍ដែលប្រព្រឹត្តហួសទៅហើយ។ ឱព្រះវរបិតា ព្រះអង្គមិនទ្រង់ជ្រាបទេឬ? សូម្បីព្រះពុទ្ធទាំងឡាយ ក៏គង់ព្រះអង្គត្រូវទទួលរង្វាន់ ជាមត៌កនៃផលកម្មរបស់ព្រះអង្គដែរ។ (ព្រះបច្ចេកពុទ្ធ) ព្រះសាវកពុទ្ធ ព្រមទាំងសាមញ្ញជនទាំងអស់ ក៏ត្រូវតែទទួលរង្វាន់ជាមត៌កនៃផលកម្មរបស់ខ្លួនៗ មិនមានអ្នកឯណាមួយ គេចឲ្យផុតអំពីវិបាកនៃកម្មរបស់ខ្លួននោះឡើយ។ កម្មទាំងឡាយជាកុសលឬអកុសល មិនដែលបាត់ទៅទេ ព្រោះដូច្នោះ មិនគួរនឹងផ្ចាញ់ផ្ចាលដល់អ្នកដទៃ ព្រោះតែអំពើកម្មដែលខ្ញុំព្រះអង្គធ្វើហើយដោយខ្លួនឯងនោះ គឺមិនមែនជាដាវដែលសម្រាប់កាប់ចាក់ មិនមែនរន្ទះ មិនមែនថ្នាំពុល មិនមែនអសិរពិសទេ សេចក្ដីទុក្ខលំបាកកើតមកអំពីហេតុទាំងអស់នោះមកយាយីខ្លួនខ្ញុំព្រះអង្គក៏ទេ គឺជាវិបាកនៃកម្មរបស់ខ្ញុំពីមុនមក ដែលខ្ញុំព្រះអង្គបានទទួលផលក្នុងគ្រានេះ ការធ្វើទោសអ្នកដទៃក្នុងហេតុនេះ នឹងមិនមានយុត្តិធម៌សោះឡើយ សព្វសត្វទាំងអស់ដែលមានអត្តភាពរស់នៅ ដូចជាវង់មូលមួយ ដែលគេ

បាញ់ត្រូវជាប់ព្រួញទាំងពាន់ច្រូងច្រាងយ៉ាងណាមិញ ក៏ខ្លួនខ្ញុំព្រះអង្គនេះ ត្រូវទទួលវិបាក នៃកម្មដ៏អាក្រក់ទាំងពាន់ដែលត្រូវជួបប្រទះក្នុងពេលនេះ ដូច្នោះដែរ។

ព្រះបាទអសោក បើទុកជាបានទ្រង់ព្រះសណ្ដាប់ពាក្យឱរសនោះ ក៏ព្រះអង្គនៅតែមានព្រះហឫទ័យក្ដៅឆេះធ្លូលរងំដោយភ្លើង គឺសេចក្ដីសោកស្ដាយ ទ្រង់ត្រាស់នឹងព្រះរាជឱរសទៀតថា: «ចុះអ្នកណាវាឥតមេត្រីអ្វីម៉្លេះ បានបំផ្លាញភ្នែកកូនប្រុសអញទាំងនេះអេះ?»។

ព្រះកុនាលរាជឱរសតបថា: «បពិត្រព្រះវរបិតា គឺព្រះអង្គឯង បានតែងព្រះរាជឱង្ការទៅឲ្យគេឆ្កៀលភ្នែកទូលព្រះបង្គំជាខ្ញុំ បានជាគេហ៊ានឆ្កៀលបែបនេះព្រះអង្គ»។

ព្រះមហាក្សត្រត្រាស់ថា: «បើជាអញបានបង្គាប់ឲ្យអ្នកណាមួយទៅឆ្កៀលភ្នែកកូនឯងមែន អញនឹងកាត់អណ្ដាតអញចេញដោយខ្លួនឯង»។

ព្រះកុនាលរាជឱរសទូលតបថា: «បពិត្រព្រះវរបិតាព្រះរាជសារ មានទាំងប្រថាប់ព្រះវរលញ្ឆករដោយព្រះទន្ត

ព្រះអង្គផង ហេតុដូចម្ដេចបានជាទ្រង់មិនជ្រាប?»។

ព្រះរាជាត្រាស់ថា: «បើអញបានប្រថាប់ត្រា ព្រះរាជសារដោយឆ្មេញអញមែន អញនឹងគាស់រំលើងឆ្មេញអញដោយខ្លួនឯង បើភ្នែកអញបានឃើញផង អញនឹងឆ្កៀលយកភ្នែកអញចេញដោយខ្លួនឯង»។

គ្រានោះ ព្រះរាជិនីតិស្សរក្សិតា បានត្រាស់ហៅព្រះនាងបទ្មាវតី មកនិយាយថា:[១] «ចូរនាងឯងឆ្កៀលភ្នែកខ្ញុំឥឡូវនេះចុះ ខ្ញុំព្រមទាំងកូនប្រុសនឹងដើរទៅសូមទានគេមកចិញ្ចឹមជីវិត»។

ដំណឹងនោះជាហេតុបណ្ដាលទៅឲ្យជ្រាបដល់ព្រះសោតស្ដេច ទើបទ្រង់ព្រះតម្រិះថា: «ប្រាកដជាតិស្សរក្សិតាហើយឆ្កៀលភ្នែកកូនប្រុសសំឡាញ់របស់អញ» ក្នុងមួយរំពេចនោះព្រះអង្គមានព្រះឱង្ការ ឲ្យហៅព្រះរាជិនី តិស្សរក្សិតាមកហើយត្រាស់ច្រះឆ្អេះថា: «មេស្រីកាចចង្រៃ ព្រោះហេតុអ្វី

[១] សៀវភៅពុទ្ធសាសនារបស់លោកល្វី-ហ្វីណូត៍ ដែលលោកម៉ៅប្រែជាខ្មែរ ព្រះមាតានៃកុនាលឱរសអស់ព្រះជន្មទៅ ទើបព្រះរាជាទ្រង់តាំងព្រះនាងតិស្សរក្សិតាឡើងជាអគ្គមហេសី។

បានជាព្រះធរណីទ្រទ្រង់ហង់ឯង់ទុក មិនស្រូបខ្លួនហង់ឯង់ពន្ទិចឲ្យហើយតែម្តង់ទៅ? ហង់ឯង់ជាស្រីបំផ្លាញអារ្យធម៌ពេលនេះ ពិតជាអញស្អប់ខ្ពើមហង់ឯង់ណាស់ ហង់ឯង់សំដែង់ខ្លួនដោយកលមាយា ធ្វើជាញាតិសាលោហិត ដែលស្រឡាញ់អញស្និទ្ធ តែគំនិតហង់ឯង់លាមកបំផុត!»។

ព្រះមហាក្សត្រ ទ្រង់ក្រេវក្រោធឆេះរោលរាលដោយភ្លើង គឺទោសៈនិង់ព្យាបាទដ៏ខ្លាំង់ក្លា ទ្រង់សំឡឹង់ឆ្ពោះព្រះនាង់តិស្សរក្សិតាមិនដាក់ព្រះនេត្រា ហើយត្រាស់ថាៈ ហង់ឯង់ទំលាយក្អែកកូនអញ អញនឹង់ហែកហួរខ្លួនហង់ឯង់ដោយក្រចកឥឡូវនេះ អញនឹង់ចាក់ហង់ឯង់ទាំង់រស់ដោយឈើអណ្តោត ហើយលើកស្ទួយឡើង់ដាក់ទៅលើចុង់ឈើដ៏ខ្ពស់ អញនឹង់ច្រៀកខ្លួនហង់ឯង់ជាចម្រៀកៗដោយរណារ អញនឹង់កាត់អណ្តាតហង់ដោយកាំបិត អញនឹង់ក្របែលឆ្អឹង់ហង់ដោយពូថៅធំមានមុខទាលគម្រឹល អញនឹង់បោះចោលខ្លួនហង់ទៅក្នុង់គុកភ្លើង់ អញនឹង់បង្អកមាត់ហង់ដោយថ្នាំពិសពុលដ៏ក្លាច្រើនមុខ» ព្រះអង្គ ប៉ុនប៉ង់នឹង់ធ្វើអាឃាត

ព្យាបាទច្រើនបែបដូច្នេះ។

ព្រះកុនាលរាជឱរស ជ្រាបហេតុនោះហើយ ទ្រង់មានព្រះហឫទ័យពេញទៅដោយមេត្តាករុណា ព្រះអង្គក្រាបទូលព្រះវរបិតាថា: «ព្រះនាងតិស្សរក្សិតា បានប្រព្រឹត្តទុច្ចរិតធម៌ហើយ ព្រោះហេតុនោះ បានជានាងធ្វើឫកពាដូច្នេះ ឱព្រះរាជា! ពេលនេះ សូមព្រះអង្គទ្រង់អនុញ្ញាតព្រះអាជ្ញាដោយធម៌ ព្រះអង្គមិនសមគួរនឹងពិឃាតព្រះនាងនេះទេ សូមទ្រង់កុំមានព្រះហឫទ័យក្រោធ នឹងការសំឡឹងឆ្ពោះមកពួកកូន និងពួកសត្វដែលថោកទាបអប្បឥតប្រាជ្ញា[១]»។

តែស្តេចមិនទ្រង់ស្តាប់ពាក្យព្រះរាជបុត្រ ទ្រង់ឲ្យចាត់ចែងកន្លែងសម្រាប់ពិឃាត ហើយឲ្យនាំព្រះរាជិនីទៅដុត

[១] ទិវ្យាវទាន: ព្រះកុនាលរាជឱរសបានក្រាបទូលពាក្យសត្យនេះដល់ព្រះរាជាថា: «សូមតេជ: ខ្ញុំព្រះអង្គមិនបានដឹងថាមានសេចក្តីឈឺចាប់ទេ សូម្បីការទទួលទុក្ខលំបាកអត់ធនដោយភ្លើងគឺទោសៈក៏មិនមានក្នុងខ្លួនខ្ញុំព្រះអង្គដែរ ក្នុងចិត្តរបស់ខ្ញុំព្រះអង្គមិនមានអ្វីក្រៅអំពីកតញ្ញូចំពោះព្រះមាតាដែលលោកបានធ្វើឲ្យខ្វាក់ភ្នែករបស់ខ្ញុំព្រះអង្គ ដើម្បីជាបន្ទាល់សាក្សីឲ្យឃើញជាក់ច្បាស់នូវពាក្យសត្យនេះ សូមឲ្យភ្នែករបស់ខ្ញុំព្រះអង្គចូរត្រឡប់បានជាសុខសប្បាយដូចដើមវិញ។ គ្រាន់តែត្រាស់មិនទាន់ផុតពីព្រះឱស្ឋ ព្រះនេត្រាក៏កើតប្រាកដឡើងវិញព្រមដោយលំអទាំងអស់ដូចពីមុន។

ភ្លើងទាំងរស់ ព្រមទាំងអ្នកនគរតក្កសិលា ដែលជាអ្នកចូលដៃក្នុងការប្រព្រឹត្តបទល្មើសដ៏ឧក្រិដ្ឋនោះ ក៏ស្លាប់វិនាសជាមួយគ្នា ក្នុងគ្រានោះទៅ។

គ្រានោះ ភិក្ខុទាំងឡាយបានឃើញហេតុអស្ចារ្យចម្លែកដូច្នោះ ក៏កើតសេចក្តីសង្ស័យឡើង ទើបនាំគ្នាសួរហេតុនេះចំពោះនឹងព្រះថេរៈឧបគុប្តៈថា: «ព្រោះហេតុអ្វី ក៏ធ្មៀលព្រះនេត្រព្រះកុនាលរាជឱរសក្នុងបច្ចុប្បន្ននេះ?»។

ព្រះថេរៈតបថា: «អ្នកទាំងឡាយចូរតាំងសោតប្រសាទប្រុងស្តាប់ខ្ញុំ ៗ នឹងសម្តែងប្រាប់ដល់ពួកអ្នក ក្នុងអតីតកាលមានព្រានព្រៃម្នាក់ នៅក្នុងក្រុងពារាណសី ព្រាននោះនៅជាមួយនឹងពួកមនុស្សតែក្នុងគិម្ហរដូវ លុះដល់ហេមន្តរដូវ តែងតែទៅបរបាញ់សត្វក្នុងព្រៃភ្នំ ដើររុករានទន្ទ្រានសព្វច្រកល្ហកដងព្រៃ រហូតដល់ ហិមវន្តបព៌ត។ ពេលនោះ ដួនជាមានភ្លៀងរំលាធំអស្ចារ្យ ធ្លាក់ព្រិលសស្វាច ដេរដាសពាសពេញផែនដី ក៏ពួកសត្វម្រឹគទាំង ៥០០ រត់ចូលតាមគ្នាត្រសុកទៅក្នុងរអាងថ្មធំមួយ ព្រានព្រៃឃើញដូច្នោះហើយ ក៏គិតថា:

«បើអញសម្លាប់ម្រឹគទាំងអស់តែម្ដងទៅ សាច់វានឹងស្អុយខូច បើដូច្នេះ អញនឹងឆ្កៀលភ្នែកវាចេញ ហើយអញនឹងស៊ីម្រឹគទាំងនោះម្ដងមួយៗរាល់ថ្ងៃទៅ»។

លុះគិតដូច្នោះ ក៏ចាប់ឆ្កៀលភ្នែកម្រឹគទាំង៥០០ឲ្យខ្វាក់ទាំងអស់គ្មានសល់។ ដល់មកឥឡូវនេះ ព្រោះតែអំពើនោះឯងបានជាត្រូវគេឆ្កៀលភ្នែក។ ព្រានព្រៃក្នុងកាលនោះ គឺព្រះកុនាលរាជឱរសនេះ តាំងតែពីកាលនោះមក រហូតដល់ថ្ងៃនេះព្រះកុនាលៈហ្នឹងឯង មានទោសត្រូវគេឆ្កៀលភ្នែកអស់ ៥០០ជាតិ មកហើយ។

ភិក្ខុទាំងឡាយទូលសួរទៀតថាៈ «ព្រោះហេតុដូចម្ដេចក៏ព្រះកុនាលរាជឱរស បានកើតក្នុងខត្តិយត្រកូល មានរូបឆោមដ៏ល្អ ហើយបានត្រាស់ដឹងនូវអរិយសច្ចនិងមគ្គផល?»។

ព្រះថេរឧបគុប្តៈតបថាៈ «ក្នុងអតីតកាល គ្រានោះ ពួកមនុស្សមានអាយុវែងដល់បួនម៉ឺនឆ្នាំ មានព្រះពុទ្ធមួយព្រះអង្គឧប្បត្តិឡើង ព្រះនាមព្រះកកុសន្ធ កាលព្រះអង្គទ្រង់បំពេញពុទ្ធកិច្ចស្រេចហើយ ស្ដេចចូលកាន់បរិនិព្វានជា

អនុបាទិសេសនិព្វានក្នុងគ្រានោះឯង មានព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាមសោកៈ[១] ទ្រង់គោរពចំពោះព្រះពុទ្ធអង្គនោះ បានប្រោសឲ្យសាងស្តូបមួយ ប្រដាប់ទៅដោយកែវដ៏ប្រសើរទាំង ៧ប្រការ សុទ្ធសឹងតែមានតម្លៃ មានស្ពានផ្ទៃក្រោមបួនជ្រុង ក្នុងមួយជ្រុងទំហំ៤០លី(មួយយោជន៍)។ តែកាលជាខាងក្រោយអំពីព្រះបាទសោកៈនោះទិវង្គតទៅ មានស្តេចមួយព្រះអង្គទៀត ទ្រង់ព្រះនាមអសទ្ធៈ អ្នកមិនជឿសាសនា ស្តេចអង្គនោះបានគាស់កកាយយកកែវដ៏ប្រសើរសុទ្ធសឹងតែមានតម្លៃអំពីព្រះស្តូបនោះអស់រលីងជេង ទុកឲ្យនៅតែដីនិងឈើប៉ុណ្ណោះ។ អ្នកនគរទាំងឡាយបានឃើញដូច្នោះ ក៏ប្រជុំគ្នាជាពួកជាកងនៅទីជិតព្រះស្តូប នាំគ្នាយំសោកស្តាយឆ្អែតចិត្ត នឹកខឹងតែសព្វខ្លួន កាលនោះ មានកុលបុត្រម្នាក់ ឃើញហេតុដូច្នោះទើបសួរថាៈ «ដូចម្តេចបានជាអ្នករាល់គ្នាយំ?» អ្នកនគរទាំងឡាយតបថាៈ

---

[១] ក្នុងទិវ្យាវទាន ទ្រង់ព្រះនាមអសោក តែមិនមែនព្រះបាទអសោកជាព្រះបិតារបស់ព្រះកុនាលរាជឱរសទេ គឺស្តេចអសោកកាលពីព្រេងនាយទៅទៀត។

ព្រះស្តូបនៃព្រះពុទ្ធជាម្ចាស់ ដែលគេសាងដោយកែវដ៏ប្រសើរទាំង ៧ប្រការ សុទ្ធសឹងតែមានតម្លៃដ៏រុងរឿង នេះនៃអ្នកមើលចុះ ត្រូវគេទំលាយបង់ គាស់កកាយយកកែវដ៏ប្រសើរទាំង៧ប្រការសុទ្ធសឹងតែមានតម្លៃអស់រលីងធេង ទុកឲ្យនៅតែដីនិងឈើប៉ុណ្ណោះ ព្រោះដូច្នោះ បានជាយើងយំ»។ វេលានោះ កុលបុត្រនោះ ក៏បានកសាងជួសជុលព្រះស្តូបនោះ ដោយកែវដ៏ប្រសើរទាំង៧ប្រការ សុទ្ធសឹងតែមានតម្លៃ ហើយស្អិតស្អាងដូចដើមឡើងវិញ ព្រមទាំងបានសាងព្រះពុទ្ធបដិមា មានព្រះរូបភាពដូចសុទ្ធសាធទៅនឹងព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះនាមកកុសន្ធអង្គនោះ ហើយបានតាំងសេចក្តីប្រាថ្នាក្នុងពេលនោះដូច្នេះថា: «សូមអំណាចកុសលនេះ តទៅអនាគត ចូរបណ្តាលឲ្យខ្ញុំបានដូចព្រះពុទ្ធជាម្ចាស់អង្គនេះ ខ្ញុំសូមឲ្យបានត្រាស់ដឹងនូវធម៌ដ៏បរិសុទ្ធវិសេស គឺអមតមហានិព្វាន»។ ក៏កុសលដែលព្រះកុនាលរាជឱរសបានកសាងព្រះស្តូប ដោយកែវដ៏ប្រសើរ ក្នុងកាលណោះ ទើបនាំឲ្យបានកើតក្នុងត្រកូលដ៏ខ្ពង់ខ្ពស់ ហើយមានឫទ្ធិ

អំណាចក្នុងកាលបច្ចុប្បន្ននេះ ព្រោះកាលពីអតីតបានកសាងព្រះពុទ្ធបដិមា ទើបមានព្រះរូបឆោមល្អ ក្នុងបច្ចុប្បន្ននេះ សេចក្ដីប្រាថ្នាដែលព្រះកុនាលរាជឱរស បានតម្កល់ទុកហើយកាលពីអតីត ទើបបណ្ដាលឲ្យបានត្រាស់ដឹងនូវផ្លូវនៃអរិយសច្ចក្នុងកាលឥឡូវនេះ។

# អវទានផ្លែកន្ទួតព្រៃមួយចំហៀង

*កាលព្រះបាទអសោក មានប្រសាទសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនាហើយ ស្ដេចទ្រង់ត្រាស់សួរព្រះថេរឧបគុប្តៈក្នុងហេតុនោះថា: «ក្នុងជាន់ពុទ្ធកាល មានអ្នកណាជាពុទ្ធមាមកៈ បានបរិច្ចាគទានច្រើនជាងគេបំផុត?»។*

*ព្រះថេរឧបគុប្តៈថ្វាយព្រះពរតបថា: «បពិត្រមហារាជមានគហបតីម្នាក់ឈ្មោះសុទត្ត[១] បានបរិច្ចាគទានច្រើនជាងគេបំផុត»*

*ព្រះបាទអសោក ត្រាស់សួរថា: «ទានដែលគេបរិច្ចាគនោះជាចំនួនប៉ុន្មាន?»។*

*ព្រះថេរឧបគុប្តៈថ្វាយព្រះពរថា: «ចំនួនមាស១០០កោដិ»*

*ព្រះបាទអសោក ទ្រង់ព្រះតម្រិះថា: «គ្រាន់តែគហបតីគេអាចធ្វើទានអស់ទ្រព្យច្រើនម្ល៉ោះទៅហើយ ចំណង់បើខ្លួន*

---

*[១] ក្នុងអាយុ-វង់-កឹង: គហបតីឈ្មោះអនាថបិណ្ឌិក។ គេដឹងថាសុទត្តក្ដី អនាថបិណ្ឌិកក្ដី ទាំងពីរឈ្មោះនេះជានាមមនុស្សម្នាក់។ ក្នុងភាសាបាលីក៏ប្រាប់ថា «សុទត្ត» ជាឈ្មោះដើម តែតាំងពីដូចជ្រះថ្លាក្នុងព្រះពុទ្ធសាសនាហើយ បានបរិច្ចាគទានលើសលុបណាស់ ទើបបានគុណនេមិត្តកនាមជាថ្មីថា: «អនាថបិណ្ឌិក» ប្រែថាជាអ្នកឲ្យដុំបាយដល់មនុស្សអនាថា ឯពាក្យថា «សុទត្ត» ប្រែថា «ជាអ្នកឲ្យល្អ ឬឲ្យដោយងាយ» ឃើញបានសេចក្ដីថា ចិត្តទូលាយដូចគ្នាដែរ ល្មមជាឈ្មោះហៅជំនួសគ្នាបាន។*

អញឥឡូវបានសោយរាជ្យ ជាឥស្សរលើជម្ពូទ្វីបទាំងមូល ម្ដេចក៏បរិច្ចាគទានមិនបានដល់នឹងគេ»។

ទ្រង់ព្រះរំពឹងដូច្នេះហើយ ព្រះអង្គបានបរិច្ចាគខ្លួនព្រះអង្គ មូលព្រមទាំងព្រះកុនាលរាជឱរស ពួកសេនាបតីរបស់ព្រះអង្គ និងព្រះរាជធានីផង ដល់ព្រះអរិយសង្ឃ ទ្រង់បានឲ្យសាងព្រះស្តូប ៨៤.០០០ សុទ្ធសឹងតែវត្ថុដ៏មានតម្លៃ ព្រមទាំងព្រះស្តូបទាំងឡាយ សម្រាប់ពួកព្រះអរហន្តជាសាវក ទ្រង់បានឲ្យស្រោចដើមពោធិព្រឹក្ស បូករួមចំនួនព្រះរាជទ្រព្យដែលព្រះអង្គបានព្រះរាជទានទាំងអស់ ត្រូវជាមាស ៩៦កោដិតម្លឹង គ្រានោះព្រះបាទអសោក ទ្រង់ប្រឈួនជាទម្ងន់ ព្រះអង្គបានជ្រាបថាៈ «នឹងទ្រង់ទិវង្គតដោយព្រះរោគនោះ ស្ដេចជាទុក្ខព្រួយព្រះរាជហឫទ័យជាខ្លាំង ទើបទ្រង់ព្រះកន្សែងសោកស្ដាយ ក្រែងមិនបានសម្រេចដូចព្រះចិន្តា។

អំពីអតីតកាល គ្រាដែលព្រះបាទអសោក បានធ្វើទានដោយដីមួយក្ដាប់នោះ រាធគុប្តៈដែលជាសំឡាញ់បិតនៅជិតខាងបានជួយអនុមោទនាផង លុះដល់មកជាតិជាបច្ចុប្បន្ន

នេះ បានមកជាសេនាបតីទីមួយរបស់ព្រះបាទអសោកវិញ ក៏រាជគុប្តៈឯកអគ្គមហាសេនា បានឃើញព្រះរាជាទ្រង់ជាទុក្ខព្រួយព្រះរាជហឫទ័យដូច្នោះ ទើបប្រណម្យក្រពុំអញ្ជលី ហើយទូលថាៈ «បពិត្រមហារាជ ឫទ្ធានុភាពនិងអំណាចរបស់ព្រះអង្គ គ្របទៅលើផែនដី ប្រៀបដូចជារស្មីនៃព្រះអាទិត្យ ពួកមនុស្សទាំងអស់ឥតមានអ្នកណាមួយ ហ៊ានក្រឡេកមើលចំព្រះភក្ត្រព្រះអង្គឡើយ»។

ឱព្រះរាជា! មានតែពួកស្ត្រីទាំង ៨៤.០០០ ប៉ុណ្ណោះ ទើបហ៊ានមើលចំព្រះភក្ត្រព្រះអង្គ ការដែលទ្រង់ប្រឈួននេះក៏ហាក់ដូចជាព្រះអាទិត្យទៀបនឹងអស្តង្គតទៅដូច្នោះ លោកទាំង៣តែងតែប្រព្រឹត្តប្រែប្រួលទៅជានិច្ច ពួកសត្វលោកត្រូវតែឈឺចាប់និងស្លាប់ជាធម្មតា សូមទ្រង់ពិចារណានូវអនិច្ចតាធម៌ ប្រយោជន៍អ្វីនឹងទ្រង់ជាទុក្ខព្រួយព្រះរាជហឫទ័យនោះ!។

ព្រះមហាក្សត្រ ត្រាស់តបថាៈ «ខ្ញុំយំសោកពេលនេះ មិនមែនព្រោះខ្លាចវិបត្តិ នៃរាជឥស្សរិយយសទេ ខ្ញុំជាអ្នកមានទុក្ខព្រួយនោះ មិនមែនព្រោះតែត្រូវលះបង់ជីវិតនោះទេ

ខ្ញុំខ្សឹកខ្សួល រំជួលចិត្តនោះ មិនមែនព្រោះខ្លាចឃ្លាតចាក មាតុគ្រាម និងឃ្លាំងព្រះរាជទ្រព្យរបស់ខ្ញុំទេ ដោយសេចក្ដីពិតនោះ ខ្ញុំមានសេចក្ដីទុក្ខព្រួយនេះ ព្រោះនឹងត្រូវឃ្លាតចាកព្រះអរិយសង្ឃទាំងឡាយ ដែលខ្ញុំប្រាថ្នានឹងបរិច្ចាគទានឲ្យគ្រប់ចំនួនមាសមួយរយកោដិ ខ្ញុំបានឲ្យទានទៅហើយតែត្រឹម ៩៦កោដិ នៅខ្វះ៤កោដិទៀត ព្រោះដូច្នោះ បានជាខ្ញុំកើតទុក្ខតានតឹងក្នុងចិត្ត»។

រាធគុប្ត:ឯកអគ្គមហាសេនាបតី ក្រាបទូលថា: «ឃ្លាំងព្រះរាជទ្រព្យទាំងឡាយរបស់ព្រះអង្គនៅមានច្រើន គួរតែព្រះអង្គបំពេញទាននោះ ឲ្យគ្រប់ចំនួនទៅតាមសេចក្ដីប្រាថ្នារបស់ព្រះអង្គ»។

គ្រានោះ ស្ដេចទ្រង់ព្រះរាជទានមាស ប្រាក់និងរបស់មានតម្លៃឯទៀតៗជាច្រើន បញ្ជូនទៅដល់វត្តកុក្កុដារាម។

កាលនោះ ព្រះសម្បទីជាឱរសនៃព្រះកុនាលរាជបុត្របានជារជ្ជទាយាទ (អ្នកទទួលគ្រងមត៌កក្នុងរាជសម្បត្តិ) មានពួកសេនាបតីចិត្តអាក្រក់ជាមិច្ឆាទិដ្ឋិ បានចូលទៅក្រាបទូល

ព្រះអង្គម្ចាស់សម្បទីថាៈ «ព្រះបាទអសោកជិតអស់ព្រះជន្ម ហើយ សូមទ្រង់ទតមើលចុះ នុ៎ះហ្ន៎! ព្រះរាជាទ្រង់បង្ហិនព្រះឃ្លាំង កំពុងតែឲ្យគេកើបខ្ជះខ្ជាយ វិនាសព្រះរាជទ្រព្យអស់ហើយ កាលបើព្រះអង្គនឹងបានជាស្តេច កោដ្ឋាគារទាំងឡាយព្រមទាំងព្រះរាជទ្រព្យដ៏មានតម្លៃនោះឯង នឹងបានលើកតម្កល់តម្កើងព្រះអង្គឲ្យជាស្តេចថ្កើងរុងរឿង ព្រោះដូច្នោះគួរតែទ្រង់បញ្ញត្តកុំឲ្យគេបង្ហិនព្រះរាជទ្រព្យនោះទាំងអស់»។

ព្រះអង្គម្ចាស់សម្បទី លុះទ្រង់ព្រះសណ្តាប់ដូច្នោះហើយ ក៏ទ្រង់យល់ព្រមតាមសេចក្តីពន្យល់របស់ពួកអាមាត្យ ក៏ទ្រង់ដកហូតយកព្រះរាជទ្រព្យទាំងអស់របស់ព្រះរាជា ដែលស្តេចកំពុងតែប្រឈួន ហើយមានព្រះហឫទ័យកំពុងជ្រះថ្លាយ៉ាងនោះទុកឲ្យនៅសល់តែភាជន៍មាសមួយ និងភាជន៍ប្រាក់មួយប៉ុណ្ណោះ ដែលជាវត្ថុសម្រាប់ដាក់ព្រះក្រយាស្ងោយព្រះរាជាកាលទ្រង់ទទួលភាជន៍សោយស្រេចហើយ ក៏ទ្រង់បញ្ជូនភាជន៍ទាំងនោះ ព្រះរាជទានទៅវត្តកុក្កុដារាមទៀត ខណៈនោះ គេដាក់ព្រះក្រយាស្ងោយក្នុងភាជន៍ដីថ្វាយឲ្យ

*ទ្រង់សោយ។ ក្នុងបច្ឆិមវារៈ គេបានថ្វាយផ្លែកន្ទួតព្រៃមួយចំហៀងដល់ព្រះរាជា ព្រះអង្គកាលបានទទួលផ្លែឈើនោះហើយ ស្ដេចឲ្យប្រជុំពួកអាមាត្យហើយត្រាស់នូវព្រះវាចាមុខគួរឲ្យស្ដុតចិត្តថាៈ អ្នកណាជាម្ចាស់នៃជម្ពូទ្វីបនេះ?។*

*ពួកអាមាត្យទូលតបថាៈ «ឱព្រះរាជា! ព្រះអង្គតែមួយទ្រង់ជាម្ចាស់នៃជម្ពូទ្វីបនេះ»។*

*ព្រះរាជាជ្រាបដូច្នោះហើយ ទ្រង់ត្រាស់នឹងពួកអមាត្យដោយព្រះនេត្រពេញទៅដោយអស្សុជលថាៈ «អ្នកទាំងឡាយភាន់ច្រឡំទេ ដែលថាខ្លួនខ្ញុំជាម្ចាស់នោះ ខ្លួនខ្ញុំមិនមែនជាម្ចាស់ទេ ព្រោះហេតុអ្វី? ព្រោះថាខ្ញុំជារាជាធិបតី បានតែត្រឹមលើផ្លែកន្ទួតព្រៃមួយចំហៀងនោះឯង[១]។ ឱអនិច្ចាអើយ! ទ្រព្យសម្បត្តិទាំងឡាយជារបស់ថោកទាប ឥតប្រយោជន៍គ្មានគេរាប់ សូម្បីតែខ្លួនឯងជាឥស្សរៈលើមនុស្សទាំងឡាយគង់ធ្លាក់*

---

*[១] វិសុទ្ធិមគ្គៈ ព្រះបាទអសោកនោះ ទ្រង់សោយឥស្សរភាពលើផែនដីទាំងមូល បានបរិច្ចាគទានទាំងរយកោដិ ព្រះអង្គធ្លាប់បានទទួលសេចក្ដីសុខ លុះដល់ជិតទិវង្គតទ្រង់ជាធំ បានតែត្រឹមផ្លែកន្ទួតព្រៃមួយចំហៀងប៉ុណ្ណោះ កាលបើព្រះអង្គអស់បុណ្យហើយ ក៏ត្រឡប់ជាទៅជាសោយសោក ព្រោះតែចំណង់រួតរឹតរាងកាយគឺរាជសម្បត្តិនោះឯង។*

ខ្លួនទៅជាអ្នកខ្សត់ទុគ៌តផុតចាកអំណាចទៅវិញបាន ពេលនេះ ខ្ញុំនៅមានត្រឹមតែផ្ទៃកន្ទួតព្រៃមួយចំហៀងនេះ ប្រៀបដូចជាទន្លេដែលមានខ្សែទឹកដ៏ខ្លាំងក្លា កំពុងតែហូរធ្លាក់ជ្រុលចុះមកគគុកគគាក់ ហើយត្រឡប់ទៅជាឈប់នៅនឹងថ្កល់ក្នុងកាលដែលផ្ទប់ស្ទះនឹងភ្នំណាមួយដូច្នោះ»។ ខណៈនោះទ្រង់ត្រាស់នូវព្រះគាថាទាំងឡាយតទៅនេះថា: «ព្រះវាចាទាំងឡាយ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ជាពាក្យត្រូវពិតប្រាកដណាស់ ក្នុងព្រះវាចាទាំងឡាយរបស់ព្រះអង្គនោះ មិនមានពាក្យត្រង់ណាមួយដែលមិនពិតទេ» ព្រះអង្គបានត្រាស់ព្រះពុទ្ធដីកាហើយថា: «ពួកអ្នកដែលស្រឡាញ់ទុកចិត្តគ្នាជាហេតុនាំមកនូវសេចក្តីទុក្ខក្នុងគ្រាបែកគ្នាជាទីបំផុត»។

កាលពីដើម តែកាលណាខ្ញុំចេញប្រកាសបញ្ញត្តទៅលើកិច្ចអ្វីនីមួយហើយ ឥតមានអ្នកណាមួយទទឹងទាស់អាជ្ញាទេ ឥឡូវនេះ ខ្លួនខ្ញុំដូចជាខ្សែទឹកដ៏ខ្លាំងក្លា កំពុងតែហូរធ្លាក់ជ្រុលចុះមកគគុកគគាក់ ស្រាប់តែទៅផ្ទប់ស្ទះនឹងភ្នំណាមួយហើយតាំងនៅនឹងថ្កល់យ៉ាងណា ក៏ពាក្យសំដីរបស់ខ្ញុំទាំង

ប៉ុន្មាន ឥឡូវនេះ តាំងនៅនឹងថ្កល់ មិនសម្រេចប្រយោជន៍អ្វី ដូច្នោះដែរ។ កាលពីមុន នៅលើប្រថពីមណ្ឌលនេះ ខ្ញុំជាទីពឹងនិងជាម្ចាស់របស់មនុស្សទាំងអស់ ពួកស្តេចណាជាសត្រូវ មានចិត្តព្រហើនកោងកាចរឹងរឹងរូស ខ្ញុំអាចបង្ក្រាបពួកស្តេចទាំងអស់នោះឲ្យនៅក្រោមអំណាចបាន ពួកមនុស្សណាជាអ្នកខ្សត់ទុគ៌ត និងជាអ្នកទុព្វលភាព ខ្ញុំអាចជួយទំនុកបម្រុងពួកមនុស្សទាំងអស់នោះបាន។ ក្នុងកាលមុន ខ្ញុំជាទីពឹងនៃពួកមនុស្សឯទៀតជាច្រើន ឥឡូវនេះអំណាចរបស់ខ្ញុំ គេផាត់ទាត់ចោលអស់ហើយ ខ្ញុំប្រៀបដូចជារទេះមួយដែលគេរុះរើចេញអស់ ទុកឲ្យនៅសល់តែទ្រុងពង ពុំនោះសោត ដូចជាអសោកព្រឹក្សា កាលបើឫសទាំងឡាយរបស់វាស្ងួតហើយ មែកទាំងឡាយក៏គេកាប់អស់ចេញហើយ ឯផ្កាផ្លែ មែក និងស្លឹកទាំងអស់នោះ គេចទៅណារួច មុខជានឹងស្វិតស្រពោនហួតហែងទៅមិនខាន។ ខ្ញុំខាតចាកបង្គោលដែលជាបង្អែកសម្រាប់ពឹងផ្អែកអស់ហើយ ព្រះរាជសាររបស់ខ្ញុំទាំងប៉ុន្មាន ក៏សុទ្ធតែជាសំបុត្រស្លាប់ឥតប្រយោជន៍ទាំងអស់»។

លុះទ្រង់ត្រាស់គាថានេះចប់ហើយ ព្រះអង្គត្រាស់ហៅរាជបុរសអ្នកគាល់ក្នុងទីជិតព្រះអង្គមក ទ្រង់ប្រទានកន្ទួតព្រៃមួយចំហៀង ហើយថ្លែងព្រះឱង្ការថា: «ចូរឯងយកផ្លែឈើនេះទៅកាន់វត្តកុក្កុដារាម ឯងប្រគេនដល់ព្រះសង្ឃក្នុងវត្តនោះ ហើយឯងទូលព្រះថេរៈថា: ទេយ្យវត្ថុនេះ ជាទានខាងក្រោយបំផុត របស់ស្ដេចអសោក ពេលនេះ ព្រះអង្គនៅមានតែផ្លែកន្ទួតព្រៃមួយចំហៀងប៉ុណ្ណោះ ទ្រង់វិនាសចាកព្រះរាជទ្រព្យដែលមានទាំងប៉ុន្មាននោះអស់ហើយ សូមព្រះសង្ឃទទួលយកដោយមេត្តាចិត្ត ចំពោះបច្ឆិមទានរបស់ស្ដេចកំសត់ទុគ៌តនេះ ដែលជាអ្នកខំខ្នៀតកសាងកុសលយកផលអំពីទាននេះតែប៉ុណ្ណោះ»។

លុះរាជបុរសយកទៅប្រគេនដល់ព្រះសង្ឃ ព្រមទាំងថ្លែងព្រះឱង្ការដោយសព្វគ្រប់ ក៏ព្រះយសត្ថេរ បានប្រកាសប្រាប់ដល់ជំនុំសង្ឃ ថា: «អ្នកទាំងឡាយ បានឃើញ បានស្គាល់ព្រះបាទអសោកច្បាស់លាស់ហើយ ទ្រង់ជួបប្រសព្វតែសេចក្ដីសុខ និងសេចក្ដីសោមនស្សតែម្យ៉ាង ទ្រង់ផ្សាយ

ឥស្សរភាពរបស់ព្រះអង្គទៅលើប្រថពីមណ្ឌល មានសមុទ្រ ជាព្រំប្រទល់ ឥឡូវនេះ ត្រូវរាជបរិពាររបស់ព្រះអង្គរឹបជាន់ យកឫទ្ធិអំណាច ធ្វើឲ្យសាបសូន្យពីព្រះអង្គអស់ទៅ ដកហូត យកព្រះរាជទ្រព្យរបស់ព្រះអង្គអស់គ្មានសល់ ធ្វើឲ្យព្រះអង្គ មានតែខ្លួនទទេ នៅមានត្រឹមតែផ្លែកន្ទួតព្រៃមួយចំហៀង នេះ ដែលទ្រង់បានព្រះរាជទានមក ដោយស្ម័គ្រព្រះរាជ ហឫទ័យចំពោះដល់សង្ឃ ព្រះរាជទានដល់ភិក្ខុសង្ឃ ក្នុង ពេលនេះ ដោយទ្រង់មានព្រះរាជហឫទ័យធ្ងន់ជ្រៅ ដើម្បី នឹងបញ្ឈឺចិត្តដល់ពួករាជបរិពាររបស់ព្រះអង្គ។ ទើបព្រះថេរៈ បានចាត់ឲ្យទាយកម្នាក់ បុកកំទេចផ្លែឈើនោះឲ្យល្អិតជាផង់ ដាក់លាយទៅក្នុងបបរ ដើម្បីឲ្យភិក្ខុទាំងអស់បានចំណែក ទាននោះគ្រប់ៗគ្នា ហើយព្រះថេរៈបានប្រាប់ភិក្ខុទាំងឡាយ ថាៈ «អ្នកទាំងឡាយគួរដឹងខ្លួនថាៈ ហេតុនេះជាកិច្ចសំរាប់វដ្ត សង្សារ ដែលជាធម្មជាតិគួរនឿយណាយ ខ្ពើមរអើមឲ្យណាស់ ទ្រព្យសម្បត្តិនិងកាមគុណទាំងឡាយ រមែងអន្តរធានបាត់ ទៅភ្លាមៗ ឈិះ! សង្សារវដ្តពេញជាគួរឲ្យនឿយណាយចិត្ត

ពេកណាស់ ហើយជាធម្មជាតិនាំមកនូវសេចក្តីទុក្ខព្រួយជាទីបំផុត»។

ប្រពៃណីនេះ ធ្វើឲ្យយើងដឹងបានថា: «បណ្តាស្តេចទាំងឡាយដែលជាតំណតព្រះវង្សមក ពួកស្តេចដែលមានឫទ្ធានុភាពបរិបូណ៌ដោយរាជសម្បត្តិទាំងអស់នោះ ក៏មិនស្មើនឹងព្រះបាទអសោកនេះឡើយ ល្អឹកណា ពួករាជអមាត្យរបស់ព្រះអង្គជួយការពារយ៉ាងណា ក៏គង់តែវិនាសទៅឯង កាលបើយើងនៅមានកម្លាំងកំហែង មិនទាន់ធ្លាក់ទៅក្នុងសេចក្តីទុក្ខនៅឡើយទេ យើងគួរតែខំប្រឹងព្យាយាមឲ្យពេញបន្ទុកដើម្បីឲ្យបានសម្រេចកុសល ជាសុខតទៅ»។

កាលដែលទ្រង់ខ្សោយថយព្រះកាយពល ទៀបរលត់ខន្ធហើយ ព្រះបាទអសោក បានត្រាស់នឹងរាធគុប្តសេនាបតីថា: «ឥឡូវនេះ អ្នកណាជាម្ចាស់ធំជាងគេបណ្តាច់ក្នុងជម្ពូទ្វីបនេះ»។

រាធគុប្តសេនាបតី ក្រាបចុះទៀបព្រះបាទា ហើយទើបទូលតបព្រះមហាក្សត្រិយ៍ថា: «បពិត្រព្រះមហាករុណាជាម្ចាស់ជីវិតលើត្បូង ព្រះអង្គទ្រង់ជាម្ចាស់ធំជាងគេបណ្តាច់»។

លុះទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ស្តេចតើនឡើង ចាកក្រឡាព្រះបន្ទំ ប្រណម្យអញ្ជលី ទ្រង់ទតមើលគ្រប់ទិស ទាំង៤ ហើយថ្លែងឱង្ការនេះថាៈ «វៀរលែងតែឃ្លាំងខ្ញុំចេញ ខ្ញុំសូមថ្វាយប្រថពីមណ្ឌលទាំងមូល ដែលមានមហាសមុទ្រ ទាំង៤ជាព្រំប្រទល់ដល់ព្រះពុទ្ធជាម្ចាស់និងព្រះអរិយសង្ឃ។ ដោយអំណាចបុញ្ញារាសី ជារង្វាន់ដែលខ្ញុំបានបំពេញហើយ នេះ តទៅអនាគត ខ្ញុំមិនប្រាថ្នាចង់បានជាស្តេចចក្រពត្តិទេ ខ្ញុំមិនប្រាថ្នាជាព្រះឥន្ទ្រ ជាព្រះព្រហ្ម ជាលោកាធិបតី ឬជា ទេព្តាទេ តែខ្ញុំសូមតាំងជំកល់សេចក្តីប្រាថ្នាថា តទៅអនាគត ក្នុងពេលដែលខ្ញុំនឹងបានទៅកើតក្នុងជាតិណាៗ ខ្ញុំសូមឲ្យ បានគ្រប់គ្រងខ្លួនដោយអំណាចខ្លួនឯង ហើយខ្ញុំសូមឲ្យបាន សម្រេចព្រះអរហត្តផលឲ្យបានឆាប់រហ័ស»។ ខណៈដែល ទ្រង់ប្រោសប្រទានព្រះបណ្តាំនេះ ព្រះអង្គ ឲ្យប្រថាប់ព្រះរាជ ឱង្ការនោះ ដោយព្រះវរលញ្ចករនឹងព្រះទន្តរបស់ព្រះអង្គ ទ្រង់ប្រគល់ឲ្យទៅរាធគុប្តសេនាបតី កាលព្រះអង្គបរិច្ចាគ ទាននេះដល់ព្រះសង្ឃរួចហើយ ក៏ព្រះវាយោរបស់ព្រះអង្គ

ស្រុតថយចុះទៅជាដរាប ហើយទ្រង់សោយព្រះទិវង្គតក្នុងពេលនោះទៅ។

ពួកសេនាបតី នាំគ្នារៀបចំព្រះបរមសព ទៅតាមរបៀបស្តេចចក្រពត្រាធិរាជ បានចាត់ឲ្យតាក់តែងគ្រឿងសំអាងគ្រប់ប្រដាប់ទៅតាមក្រសួង ដើម្បីជាទីគោរពដល់ព្រះបរមសព ហើយរុំសំពត់ស្នប ដាក់ដំកល់ក្នុងព្រះមឈូស បូជាព្រះបរមសពតាមទំនៀម។

គ្រានោះ ពួកសេនាបតី បានអភិសេកព្រះអង្គម្ចាស់សម្បទីឲ្យឡើងគ្រងសោយរាជ្យជាតំណាងព្រះអង្គមក។

រាធគុប្តសេនាបតី បានប្រាប់ដំណឹងនោះដល់ពួកអមាត្យថា: «ព្រះបាទអសោក បានព្រះរាជទានប្រថពីមណ្ឌលទាំងមូលដល់ព្រះសង្ឃហើយ ព្រោះអ្វី? ព្រោះថា ព្រះអង្គប្រាថ្នានឹងបំពេញការបរិច្ចាគឲ្យគ្រប់ចំនួន មួយរយកោដិ ឲ្យបានដូចជាគហបតីឈ្មោះសុទត្ត តែព្រះអង្គបានបរិច្ចាគហើយកាលដែលទ្រង់ព្រះជន្មនៅឡើយ បានត្រឹមតែ ៩៦កោដិ យើងត្រូវលោះជម្ពូទ្វីបនេះមកវិញ ដោយតម្លៃ ៤កោដិ ដើម្បីនឹង

ធ្វើឲ្យសម្រេចសេចក្ដីប្រាថ្នារបស់ព្រះបរមសពនោះ»។

ពួកអមាត្យទាំងអស់ ជំនុំព្រមព្រៀងគ្នាហើយ ទើបបានលោះជម្ពូទ្វីប ដោយតម្លៃមាស ៤កោដិ ហើយថ្វាយទៅព្រះបាទសម្បទី ជារជ្ជទាយាទ។ ព្រះរាជឱរសរបស់ព្រះបាទសម្បទីដែលបានសោយរាជ្យជាតំណព្រះវង្សតមក ទ្រង់ព្រះនាមគ្ហុបតី (គហបតី) ព្រះរាជឱរសរបស់ព្រះបាទគ្ហុបតី។ល។ ទ្រង់ព្រះនាមបុស្សវរ្ម័ន។ ព្រះរាជឱរស របស់ព្រះបាទបុស្សវរ្ម័ន។ល។ ទ្រង់ព្រះនាមបុស្សមិត្រ[១] ។ ព្រះបាទបុស្សមិត្របានប្រឹក្សាជាមួយនឹងពួកសេនាបតីថា យើងត្រូវធ្វើដូចម្ដេច ដែលអាចល្បីកេរ្តិ៍ឈ្មោះរបស់យើង ឲ្យបានទូទ័រទៅក្នុងលោកនេះបាន?។

គ្រានោះ មានសេនាបតីម្នាក់ ក្រាបទូលថាៈ «ក្នុងកាលមុន មានស្ដេចសោយរាជ្យ ដែលជាព្រះវង្សរបស់ព្រះអង្គដែរ

---

[១] អាយុ-វង-កឹង ព្រះរាជឱរសរបស់ព្រះបាទសម្បទី ទ្រង់ព្រះនាមវ្ហុហស្បតិ ព្រះរាជឱរសរបស់ព្រះបាទវ្ហុហស្បតិ ទ្រង់ព្រះនាមវ្ហុសសេន។ ព្រះរាជឱរសរបស់ព្រះបាទវ្ហុសសេន ទ្រង់ព្រះនាមបុស្សវរ្ម័ន។ ព្រះរាជឱរសរបស់ព្រះបាទបុស្សវរ្ម័ន ទ្រង់ព្រះនាមបុស្សមិត្រ។ ក្នុងទិវ្យាវទានៈ ស្ដេចដែលសោយរាជ្យជាតំណពីព្រះបាទអសោកមកដូចគ្នានឹងអាយុវង-កឹង ប្លែកតែត្រង់ថា ព្រះបាទបុស្សវរ្ម័នទៅជាព្រះបាទបុស្សវរ្ម័នទៅវិញ។ ឯព្រះនាមព្រះបាទវ្ហុសសេន មិនមានក្នុងអាយុ-វង-ជួនទេ។

ទ្រង់សាងព្រះស្តូប៨៤.០០០ ហើយបានបរិច្ចាគទានជាមាស មួយរយកោដិ ព្រះអង្គបានប្រព្រឹត្តប្រតិបត្តិតាមព្រះធម៌របស់ ព្រះពុទ្ធដែលមាននៅក្នុងលោកនេះជាយូរអង្វែងឆ្នាំ ព្រះនាម របស់ព្រះអង្គនោះតាំងនៅឋិតថេររហូតមកដល់សព្វថ្ងៃនេះ»។

បើព្រះអង្គបានកសាងព្រះស្តូប ៨៤.០០០ ដូចយ៉ាង ព្រះបាទអសោកអង្គនោះ ព្រះនាមរបស់ព្រះអង្គក៏គង់នឹង តាំងនៅក្នុងលោកនេះអស់កាលយូរលង់ទៅដូច្នោះដែរ។

ព្រះបាទបុស្សមិត្រត្រាស់តបថា: «ក្នុងកាលមុន ស្តេច សោយរាជ្យដែលជាព្រះវង្សរបស់ខ្ញុំនោះ ព្រះអង្គមានឫទ្ធា- នុភាពគួរនឹងធ្វើវត្ថុទាំងនោះឲ្យសម្រេចបាន ឯខ្លួនខ្ញុំដូចម្តេច នឹងធ្វើការងារធំដល់ម៉្លោះឲ្យសម្រេចបាន ក្រែងអ្នកមានឧបាយ ណាមួយដទៃទៀត ដែលស្មើគ្នានឹងព្រះបាទអសោកនោះ មាន ដែរឬ?»។

ពេលនោះ មានសេនាបតី មានសេចក្តីយល់ឃ្លាងផ្សុយ គ្នានឹងសេចក្តីចម្រើន ក្រាបទូលថា: «ការដែលធ្វើល្អឬធ្វើ អាក្រក់ ក្នុងអំពើទាំងពីរនេះ ក៏បានល្បីទូទាំងកេរ្តិ៍ឈ្មោះស្មើភាគ

គ្នា ព្រោះព្រះរាជាជាន់មុន ទ្រង់បានសាងព្រះស្តូប៨៤.០០០ ហើយកិត្តិយសរបស់ស្តេចបិតនៅអស់កាលយូរអង្វែង ប្រសិនបើព្រះអង្គទម្លាយបង់ព្រះស្តូបទាំងអស់នោះវិញ ក៏គង់ព្រះនាមរបស់មហាបពិត្រ នឹងតាំងនៅជាប់ជាតំណាប្រពៃណីទៅក្នុងអនាគតជាយូរអង្វែងដូចគ្នាដែរ»។

ព្រះបាទបុស្សមិត្រ ទ្រង់យល់ព្រមតាមគំនិតនោះ ទើបត្រាស់ឲ្យប្រជុំពលចតុរង្គសេនា ហើយស្តេចយាងទៅកាន់វត្តកុក្កុដារាម ដោយព្រះបំណងនឹងបុកទម្លាយបំបែកទ្វារវត្តនោះ តែពេលនោះ ស្រាប់តែឮសូរសីហនាទ (សម្រែកសិង្ហ) សន្ធាប់ខ្ទរនៅត្រង់ទ្វារនោះ ព្រះរាជា ទ្រង់រន្ធត់ស្ញប់ស្ញែងព្រះរាជហឫទ័យ មិនអាចហ៊ានយាងចូលទៅក្នុងវត្តនោះ ទ្រង់លើករេហ៍ពលត្រឡប់មកវិញ។ ព្រះអង្គទទូចយាងទៅដល់៣លើក តែមិនអាចនឹងចូលទៅបានដូច្នោះ ដល់គ្រាក្រោយបំផុត ព្រះអង្គបានចាត់ឲ្យនិមន្តភិក្ខុទាំងឡាយមក ហើយត្រាស់ថាៈ «ខ្ញុំបំណងនឹងទម្លាយបំបាត់ព្រះពុទ្ធសាសនាចេញ ឱភិក្ខុទាំងឡាយ ពួកលោកគាប់ចិត្តឲ្យទុកព្រះស្តូប ឬឲ្យទុក្ខសេនា

សនៈរបស់សង្ឃ?»។

ភិក្ខុទាំងឡាយ ថ្វាយព្រះពរ តបថា: «បពិត្រមហារាជ អាត្មាភាពទាំងអស់គ្នា គាប់ចិត្តរក្សាទុកព្រះស្តូប»។

លុះទ្រង់ព្រះសណ្តាប់ដូច្នោះ ព្រះបាទបុស្សមិត្រ ក៏ពិឃាតពួកភិក្ខុទាំងអស់នោះទៅ ទ្រង់ឲ្យទំលាយបង់នូវទីសេនាសនៈរបស់សង្ឃទាំងនោះ ហើយព្រះអង្គខំព្យាយាមក្នុងកិច្ចបំផ្លាញនោះកាន់តែចម្រើនធំឡើង រហូតដល់ទៅដែនសាគលៈ ទ្រង់បានថ្លែងព្រះឱង្ការជាព្រះរាជសារទៅថា: «បើអ្នកណាមួយ យកក្បាលសមណៈបានមួយមកឲ្យយើង អ្នកនោះ នឹងត្រូវបានរង្វាន់ជាមាសមួយដុំ»។

សម័យនោះ ក្នុងប្រទេសនោះ មានព្រះស្តូបមួយធំជាទីនៅអាស្រ័យនៃព្រះអរហន្តមួយអង្គ[១] ព្រះថេរៈអង្គនោះ និម្មិតធ្វើជាក្បាលសមណៈជាច្រើនពាន់ ហើយប្រាប់ឲ្យអ្នកស្រុកនាំយកទៅថ្វាយព្រះរាជា កាលស្តេចទ្រង់ជ្រាបហេតុនោះហើយ ព្រះរាជាទ្រង់ប្រាថ្នាចង់សម្លាប់ព្រះអរហន្តអង្គ

---

[១] ក្នុងអាយុ-វង់-កឹង ព្រះអរហន្តនោះ នៅក្នុងវត្តធម៌រាជា។

នោះទៀត តែព្រះថេរៈលោកចូលកាន់អាកាសកសិននិមន្ត ហួសបាត់ទៅ ព្រះរាជាមិនអាចពិឃាតលោកបាន។

គ្រានោះ ព្រះមហាក្សត្រិយ៍ ស្តេចយាងទៅកាន់រាជធានីឯទៀត ដោយសេចក្តីបំណងនឹងធ្វើព្រះពុទ្ធសាសនាឲ្យវិនាសនៅក្នុងរាជធានីនោះ មានយក្សម្នាក់ជាអ្នកគ្រប់គ្រងរក្សាព្រះពុទ្ធសាសនា យក្សនោះគិតថាៈ «អញទទួលសីលព្រះសម្មាសម្ពុទ្ធម្ចាស់ មិនគួរនឹងធ្វើបាបដល់អ្នកណាឡើយ ប៉ុន្តែអញធ្វើដូចម្តេចនឹងគ្រប់គ្រងព្រះពុទ្ធសាសនាបានហ្ន៎? ក្នុងកាលមុន មានយក្សឈ្មោះក្ឫមិសៈ បានមកសូមធីតាអញ តែអញមិនព្រមឲ្យ ព្រោះវាប្រព្រឹត្តទុច្ចរិត តែឥឡូវនេះគួរអញឲ្យធីតាអញទៅវានោះចុះ ដើម្បីបានវាជួយរក្សាព្រះពុទ្ធសាសនាផង»។ ព្រោះឧបាយនេះ ក្នុងប្រទេសនោះ ទើបពួកយក្សនៅមានអំណាចគ្រប់គ្រងរក្សាព្រះពុទ្ធសាសនា ដោយព្រះបាទបុស្សមិត្រមិនហ៊ានទម្លាយបង់។ ខណៈនោះ ពួកយក្សនិងទេវ្តាដែលរក្សាដើមពោធិព្រឹក្ស នាំគ្នាលួងលួងលោមពួករាជបុរសនាំបណ្តើរព្រមទាំងព្រះរាជាផង យកទៅរហូតដល់មហា

សមុទ្រខាងត្បូង លុះដល់ទីនោះហើយ ក៏យក្សឈ្មោះក្ឫមិសៈលើកថ្មដាមួយដុំធំ មុខគួរស្ញើមអស្ចារ្យ គប់បំបែកព្រះសិរព្រះរាជាអង្គនោះ ស្លាប់ព្រមជាមួយគ្នា និងពួកពលទាំងអស់ក្នុងទីនោះ។

ព្រះរាជវង្សបាក្សត្រិយ៍ក្នុងដែនមគធៈ ក៏ផុតអស់ត្រឹមណោះទៅ(១)។

# ចប់រឿងព្រះចាងអសោកមហារាជតែប៉ុណ្ណោះ។

---

(១) ក្នុងអាយុ-វង-កឹង តពីនោះមក(ព្រះរាជា) ស្តេចយាងចូលទៅទីឯទៀត ដល់មកកោដ្ឋាគារនគរនោះ មានយក្សម្នាក់ជាអ្នកគ្រប់គ្រងរក្សាព្រះចង្កូមនៃព្រះពុទ្ធ យក្សនោះគិតថា «ព្រះពុទ្ធសាសនានឹងអន្តរធានទៅ ព្រោះអញជាអ្នកទទួលភារៈខាងការពារ មិនហ៊ានសម្លាប់សត្វមានជីវិត តែអញមានធីតា ដែលយក្សគិលិសបានសូមដណ្តឹងម្តង ពីកាលមុនអញមិនព្រមឲ្យ ព្រោះវាមិនឈប់ប្រព្រឹត្តអំពើទុច្ចរិត តែឥឡូវនេះគួរអញឲ្យធីតាអញទៅវានោះចុះ ដើម្បីឲ្យវាជួយរក្សាព្រះពុទ្ធសាសនាផង។ មានយក្សម្នាក់ទៀតចិត្តកាចទ្រនង់ជាអ្នករក្សានូវព្រះបាទបុស្សមិត្រជានិច្ច ព្រោះតែដោយកម្លាំងឫទ្ធានុភាពរបស់យក្សនោះទើបមិនមានអ្នកណាមួយហ៊ានប្រទូស្តនឹងស្តេចនោះសោះ។ ទេព្តាជាអ្នករក្សាព្រះចង្កូមរបស់ព្រះពុទ្ធ ទើបល្បួងនាំយក្សដែលជាអ្នកគ្រប់គ្រងរក្សាស្តេចទៅរហូតដល់មហាសមុទ្រខាងត្បូង ក្នុងវេលានោះ យក្សឈ្មោះគិលិស បានលើកភ្នំមួយយ៉ាងធំ គប់បំបែកព្រះបាទបុស្សមិត្រ កំទេចព្រមទាំងចតុរង្គសេនា ស្លាប់ទៅជាមួយគ្នាក្នុងទីនោះ។ ព្រះបាទបុស្សមិត្របានបំផ្លាញបង់នូវរាជត្រកូលដែលជាម៉ៅរ្យវង្សអស់ពីត្រឹមនោះមក។

អប្បមាទោ អមតំ បទំ      បមាទោ មច្ចុនោ បទំ

អប្បមត្តា ន មិយ្យន្តិ      យេ បមត្តា យថា មតាតិ

*សេចក្តីមិនប្រហែស ជាផ្លូវមិនស្លាប់ សេចក្តីប្រហែស ជាផ្លូវស្លាប់ ពួកអ្នកមិនប្រហែសឈ្មោះថាមិនស្លាប់ ពួកអ្នកប្រហែសទុកដូចជាស្លាប់។*




# សម្រាប់ជាជម្ងធាន